ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រធានបទ "តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ"

# THE ROLES OF COMMUNITY IN DEVELOPING STUDENTS' LEARNING OUTCOMES IN UPPER SECONDARY SCHOOLS IN PREAH SIHANOUK VILLE, PREAH SIHANOUK PROVINCE

ឈ្មោះ គាំ រ៉ាវី

KOM RAVY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## ប្រធានបទ "តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ"

## THE ROLES OF COMMUNITY IN DEVELOPING STUDENTS' LEARNING OUTCOMES IN UPPER SECONDARY SCHOOLS IN PREAH SIHANOUK VILLE, PREAH SIHANOUK PROVINCE


គាំ រ៉ាវី

KOM RAVY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំគោល៖ បណ្ឌិត ឡាយ សុវិជ្ជា

គ្រូណែនាំរង៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទ **គាំ វ៉ាទី** ជាបេក្ខជននៃការប្រឡងបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក **គ្រប់គ្រងអប់រំ** ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំនាឆ្នាំសិក្សា **២០២០-២០២២** ។ ខ្ញុំបានជ្រើសរើសសរសេរនិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**តួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**" ដើម្បីបំពេញលក្ខខណ្ឌនៃវគ្គសិក្សានេះ។ ការរៀបរៀងអត្ថបទនេះ ប្រាកដជាមិនមានផ្នែកណាមួយត្រូវបានចម្លង ឬដកស្រង់ខ្លឹមសារដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះក្នុងបញ្ជីឯកសារយោងឡើយ។

ខ្ញុំបាទ សូមធានាអះអាងថា និក្ខេបបទស្រាវជ្រាវនេះ ពិតជាកម្រងស្នាដៃនិពន្ធ សរសេរពិពណ៌នា និងអត្ថាធិប្បាយ សិក្សាស្រាវជ្រាវដោយផ្ទាល់របស់ខ្ញុំទាំងស្រុងមែន។

ថ្ងៃ អាទិត្យ ១៣កើត ខែ កត្តិក ឆ្នាំខាលចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

**ហត្ថលេខាបេក្ខជន**

**គាំ វ៉ាទី**

# លិខិតបញ្ជាក់

បណ្ឌិត **ឡាយ សុវិជ្ជា** ជាគ្រូណែនាំគោល

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **គាំ រ៉ាវី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី ៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា៖ “**តួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**” ប្រាកដមែន។

ថ្ងៃ អាទិត្យ ១៣កើត ខែ កត្តិក ឆ្នាំ ខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

..............................................

**បណ្ឌិត ឡាយ សុវិជ្ជា**

ប្រធានការិយាល័យស្រាវជ្រាវ និងវិភាគ

គោលនយោបាយ

..............................................

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

នាយក

វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាម គណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧០២៤ អយក.ឧទន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វ៉ាំ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វង្ឍា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ **គាំ រ៉ាវី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក **គ្រប់គ្រងអប់រំ** ជំនាន់ទី ៩ នៃវិទ្យាស្ថានជាតិអប់រំ នាឆ្នាំសិក្សា ២០២០-២០២២ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានបញ្ចប់ការសិក្សាស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយលទ្ធផលដ៏ត្រចះត្រចង់នេះ ខ្ញុំបាទក៏មិនភ្លេចផងដែរចំពោះការជួយជ្រោមជ្រែង គាំទ្រ និងយកចិត្តទុកដាក់ពីមជ្ឈដ្ឋានជុំវិញ ព្រមទាំងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

○លោកអ្នកមានគុណទាំងពីរគឺលោកឪពុក **អន កប** និងអ្នកម្ដាយ **ស៊ឹម សារឿន** ដែលបានផ្ដល់កំណើត ផ្ដល់ដំបូន្មានល្អៗ ខិតខំចិញ្ចឹមបីបាច់ថែរក្សា និងតស៊ូផ្គត់ផ្គង់ឱ្យកូនបានសិក្សារហូតបានផ្លែផ្កាដូចសព្វថ្ងៃនេះ ក៏ដូចជាឧត្តមភរិយា **ជ័យ សុខរមនា** និងបុត្រី បុត្រាទាំងពីរដែលបានជួយលើកទឹកចិត្ត បង្កឱកាសងាយស្រួលដល់ដំណើរការសិក្សារហូតដល់សម្រេចបានគោលដៅនេះផងដែរ។

○សាស្ត្រាចារ្យណែនាំគោល បណ្ឌិត **ឡាយ សុវិជ្ជា** ដែលជាគ្រូណែនាំគោលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីជួយណែនាំ ពន្យល់ និងផ្ដល់ជាអនុសាសន៍ល្អៗដល់រូបខ្ញុំគ្រប់ដំណាក់កាល តាំងពីផ្ដើមកិច្ចការស្រាវជ្រាវរហូតដល់សម្រេចជោគជ័យបានជាលទ្ធផលក្នុងកិច្ចការនេះស្រាប់។

○សាស្ត្រាចារ្យណែនាំរង ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ដែលជាគ្រូណែនាំរង បានចូលរួមគ្រប់សកម្មភាពនៃដំណើរការនៃកិច្ចការស្រាវជ្រាវនេះដោយលះបង់កម្លាំងកាយចិត្ត បញ្ញាស្មារតី ពេលវេលាដ៏មានតម្លៃ និងគំនិតល្អៗក្នុងការស្ដាបនា កែតម្រូវដល់ការស្រាវជ្រាវរបស់ខ្ញុំបានលេចចេញជារូបរាងគួរជាទីមោទនក្រៃលែង។

○គណៈកម្មការគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក **គ្រប់គ្រងអប់រំ** នៃវិទ្យាស្ថានអប់រំ ព្រមទាំងលោក លោកស្រី ជាគ្រូឧទ្ទេសទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់ខ្ញុំបាទ ព្រមទាំងនិស្សិតទាំងអស់គ្នាដោយមិនគិតពីការលំបាកនឿយហត់នោះឡើយ។

○មិត្តភក្តិ និងមិត្តរួមថ្នាក់ទាំងអស់ដែលបានចង្អុលបង្ហាញ ណែនាំ ផ្ដល់កម្លាំងចិត្ត និងចែករំលែកចំណេះដឹង ព្រមទាំងឯកសារយោង បទពិសោធន៍ ព័ត៌មានល្អៗនានាដែលពាក់ព័ន្ធផងដែរ។

○គណៈនាយក លោកគ្រូ អ្នកគ្រូនៃវិទ្យាល័យទាំងបីនៃក្រុងព្រះសីហនុ អ្នកអាណាព្យាបាលសិស្សអាជ្ញាធរមូលដ្ឋាន និងសិស្សានុសិស្សក្នុងសាលាគោលដៅទាំងអស់ដែលបានចំណាយពេលវេលាដើម្បីឆ្លើយនូវសំណួរសម្ភាសន៍របស់ខ្ញុំបាទ។

ជាទីបញ្ចប់ ខ្ញុំបាទសូមសម្ដែងនូវក្ដីកតញ្ញូកតវេទីដល់អ្នកមានគុណ ឯកឧត្តម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បងប្អូន និងមិត្តភក្តិទាំងអស់ ព្រមទាំងសូមប្រសិទ្ធិពរជ័យជូនដល់អ្នកទាំងអស់គ្នា ឱ្យជួបនូវសេចក្ដីសុខសួស្តី សិរិមង្គលគ្រប់ប្រការ និងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**

# មាតិកាចំណងជើង


**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ....................................................................................I

**លិខិតបញ្ជាក់**II

**លិខិតឧទ្ទេសនាម គណៈកម្មការការពារនិក្ខេបបទ** ...........................................................III

**សេចក្តីថ្លែងអំណរគុណ** ...................................................................................................... V

**មាតិកាចំណងជើង** ............................................................................................................. VI

**អក្សរកាត់ និងអត្ថន័យជាខេមរភាសា** ........................................................................XVII

**សេចក្តីសង្ខេបមូលន័យ** .......................................................................................................XX

ABSTRACT XXII

**ជំពូកទី ១៖ សេចក្តីផ្តើម** ..........................................................................................................1

I. **វឌ្ឍនភាពនៃការអប់រំនៅកម្ពុជា** ...........................................................................................1

ក. ការវិវត្តលើវិស័យអប់រំ និងគុណវុឌ្ឍិគ្រូបង្រៀន .............................................................1

ខ. ស្ថានភាពទូទៅរបស់បុគ្គលិកអប់រំនៅកម្ពុជា ................................................................ 3

គ. កំណែទម្រង់វិស័យអប់រំនៅកម្ពុជា ..................................................................................... 6

II. **ដំណើរការនៃការសរសេរនិក្ខេបបទ** .................................................................................10

១. ទិដ្ឋភាពទូទៅនៃការស្រាវជ្រាវ ..........................................................................................10

២. បញ្ហានៃការស្រាវជ្រាវ ...........................................................................................................12

៣. ប្រធានបទស្រាវជ្រាវ ...............................................................................................................14

៤. គោលបំណងនៃការស្រាវជ្រាវ ..........................................................................................14

៥. សំណួរនៃការស្រាវជ្រាវ .........................................................................................................15

៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ...................................................................15

៧. សារៈសំខាន់នៃការស្រាវជ្រាវ ..........................................................................................15

៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ................................................................................................16

**ជំពូកទី ២៖ រំឭកទ្រឹស្តី** ...............................................................................................................18

**២.១. ការសិក្សាពាក្យគន្លឹះ** ............ 18
២.១.១. តួនាទី ............ 18
២.១.២. សហគមន៍ ............ 20
២.១.៣. ការអភិវឌ្ឍ ............ 25
២.១.៤. លទ្ធផលសិក្សា ............ 26
**២.២. រំលឹកទ្រឹស្តី** ............ 29
២.២.១. យន្តការផ្សារភ្ជាប់សាលារៀន និងសហគមន៍ ............ 29
២.២.៣. តួនាទីរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ............ 39
**២.៣. តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស** ............ 46
២.៣.១. ការផ្តល់ធាតុចូល ............ 46
ក.ការធ្វើផែនការសាលារៀន ............ 46
ខ. គោលនយោបាយសាលារៀន ............ 47
គ. គ្រោងថវិកាសាលារៀន ............ 47
ឃ. ផែនការសកម្មភាពសាលារៀន ............ 49
ង. ផែនការកសាង ថែរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ............ 49
២.៣.២. គណៈកម្មការថ្នាក់រៀន ............ 50
ក. ការអនុវត្តការងាររបស់គ្រូបង្រៀន ............ 52
ខ. ការអង្កេតការបង្រៀន ............ 52
គ. ពិនិត្យតាមដានលទ្ធផលសិក្សារបស់សិស្ស ............ 52
២.៣.៣. ការលើកទឹកចិត្ត និងកៀរគរធនធាន ............ 53
គ. ការពង្រឹងតម្លាភាព គណនេយ្យភាព និងស្វ័យភាព ............ 57
**២.៤. លទ្ធផលការសិក្សារបស់សិស្ស** ............ 59
២.៤.១. លទ្ធផលប្រឡងបញ្ចប់ ............ 60
ក.បង្ហាញពីអត្រាត្រួតថ្នាក់ថយចុះ: ............ 62

ខ.កាត់បន្ថយការបោះបង់ការសិក្សា.................................................................... 64

គ.ទទួលបានអាហារូបករណ៍/កំណើនសិស្សពូកែ និងឆ្នើម ............................................ 67

ឃ.អាត្រាសិស្សចូលរៀននៅឧត្តមសិក្សាកើនឡើង...................................................... 68

២.៤.២.ផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន .......................................................................68

ក.សិស្សចូលចិត្តសាលារៀន និងស្វ័យសិក្សា ........................................................... 69

គ.មានចរិយាថ្លៃថ្នូរ មនសិការស្នេហាជាតិ ................................................................. 70

២.៤.៣.មានទំនុកចិត្ត និងឧត្តមភាពក្នុងការរស់នៅ ..................................................71

ក.ភាពមានការងារធ្វើ ...........................................................................................71

ខ.ដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងភាពច្នៃប្រឌិត............................. 72

គ.សេដ្ឋកិច្ចគ្រួសារសមរម្យ រស់នៅប្រកបដោយភាតរភាពក្នុងសង្គម.............................. 72

២.៤.៤.ឆ្លើយតបទៅនឹងតម្រូវការសង្គម និងទីផ្សារការងារ ............................................. 73

ក.បំពេញការងារមានប្រសិទ្ធភាព ............................................................................ 74

ខ.មានជំនាញបច្ចេកទេសច្បាស់លាស់......................................................................... 75

គ.ប្រតិបត្តិខ្លួនជាពលរដ្ឋពេញលេញ........................................................................... 76

**២.៥. តួនាទី និងភារកិច្ចរបស់តួអង្គសំខាន់ៗក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស**.....................................................................................................77

២.៥.១.តួនាទីរបស់នាយកសាលា .............................................................................81

២.៥.១.១.ជាអាជ្ញាធរអប់រំ.........................................................................................81

ក.ធ្វើផែនការសកម្មភាពសាលារៀន .................................................................................. 82

ខ.វាយតម្លៃ និងលើកទឹកចិត្តបុគ្គលិក ................................................................................ 83

២.៥.១.២.ជាមន្ត្រីរដ្ឋបាល ......................................................................................... 84

ក.ត្រួតពិនិត្យរបាយការណ៍សាលា( លទ្ធផលសិក្សា ថវិកា គម្រោងអភិវឌ្ឍសាលា ).................84

ខ.បំពេញការងារក្នុងបែបបទរដ្ឋបាល/ ការងារគ្រប់គ្រងលិខិត និងឯកសារនានា ...................84

២.៥.១.៣.ជាទីប្រឹក្សាគរុកោសល្យ ............................................................................... 85

ក.ចែករំលែកបទពិសោធន៍ការងារ ការប្រើប្រាស់សម្ភារឧបទេស ....85
ខ.ធ្វើថ្នាក់និទស្សន៍ ....85
គ.ជំរុញ និងលើកទឹកចិត្តបុគ្គលឱ្យអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈជាប្រចាំ ....86
២.៥.១.៤.ជាអធិការអេចិន្ត្រៃយ៍ ....86
ក.ចុះសង្កេតថ្នាក់រៀន ....87
ខ.ផ្តល់យោបល់កែលម្អការបង្រៀន និងរៀន ....87
២.៥.១.៥.ជាអ្នកចរចារ ....88
ក.ផ្តល់គំនិតយោបល់ដល់បុគ្គលិកដែលមានបញ្ហា ....88
ខ.ជួយចែករំលែក និងដោះស្រាយបញ្ហា ....88
២.៥.១.៦.ជាអ្នកអប់រំ ....89
២.៥.១.៧.ជាអ្នកផ្តល់សេវា និងទំនាក់ទំនងសហគមន៍ ....89
ក.ផ្តល់ព័ត៌មានគ្រឡប់ស្តីពីលទ្ធផលសិក្សា និងអាកប្បកិរិយាដល់អ្នកអាណាព្យាបាលសិស្ស ..89
ខ.បង្កើតកម្មវិធីសំណេះសំណាលដើម្បីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស កត្តាគំរាមកំហែង 90
២.៥.១.៨.ជាអ្នកពិគ្រោះយោបល់ និងចូលរួមធ្វើផែនការសហគមន៍ ....90
ក.ផ្តល់ឱកាសដល់បុគ្គលិកបានបញ្ចេញមតិ ....90
ខ.ពិភាក្សា និងផ្តល់ជម្រើស ....90
២.៥.១.៩.ជាភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍ ....90
ក.លើកកម្ពស់កិច្ចសហការជាមួយភាគីពាក់ព័ន្ធ ....91
ខ.បំផុសគំនិតក្នុងការផ្សារភ្ជាប់លទ្ធផលសិក្សា និងតម្រូវការសង្គម ....91
២.៥.២.តួនាទីរបស់គ្រូបង្រៀន (មុខវិជ្ជា បន្ទុកថ្នាក់)ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស......91
២.៥.២.១.ការស្វែងយល់ពីសហគមន៍ និងការផ្តល់ចំណេះដឹងប្រកបដោយវិជ្ជាជីវៈ....92
ក.បង្រៀនចំមុខវិជ្ជាឯកទេស៖ ....92
ខ.ស្គាល់ពីសិស្ស(សិស្ស គ្រួសារ ចំណេះដឹង) ....92
គ.អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន៖ ....92

ក.រៀបចំកិច្ចតែងការឱ្យមានប្រសិទ្ធភាព.....93
ខ.គ្រប់គ្រងថ្នាក់រៀន បរិស្ថានសិក្សា និងរៀបចំសម្ភារៈឧបទេស.....93
គ.តាមដាន និងចូលរួមពង្រីកចំណេះដឹងសិស្ស.....94
ឃ.សហការជាមួយអ្នកអាណាព្យាបាលសិស្សបានល្អ.....94
ង.ចូលរួមសកម្មភាពអភិវឌ្ឍន៍សាលារៀន.....94
២.៥.២.៣.ការបណ្តុះសីលធម៌ដល់សហគមន៍ដោយប្រកាន់ភ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈ.....95
ក.ប្រកាន់ភ្ជាប់គោលការណ៍គណនេយ្យភាព តម្លាភាព និងយុត្តិធម៌.....95
ខ.ធ្វើជាគំរូដល់សិស្ស និងសហគមន៍របស់ខ្លួន.....95
២.៥.៣. តួនាទីរបស់អ្នកអាណាព្យាបាល/មាតាបិតាក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស.....96
២.៥.៣.១.ការបរិច្ចាគថវិកាសម្រាប់ការសិក្សារបស់សិស្ស.....96
ក.គ្រោងចំណាយលើសម្ភារៈសិក្សា និងមធ្យោបាយធ្វើដំណើរ.....96
ខ.ថ្លៃវគ្គបំប៉នមុខវិជ្ជាបន្ថែម.....96
គ.វិភាគទានផ្សេងៗ.....97
ឃ.ការពិនិត្យតាមដានការសិក្សារបស់កូន.....97
ង.ឆ្លៀតពេលក្នុងការពិភាក្សាពីការសិក្សាជាមួយកូន.....97
២.៥.៣.២.ត្រួតពិនិត្យការសិក្សា និងតាមដានលទ្ធផលសិក្សាជាប្រចាំ.....98
ក.ជួយអង្កេត និងលើកកម្ពស់សកម្មភាពស្វ័យសិក្សានៅផ្ទះ.....98
ខ.ទំនាក់ទំនងជាមួយគ្រូមុខវិជ្ជា គ្រូបន្ទុក និងនាយកបើចាំបាច់.....98
២.៥.៣.៣.ការលើកទឹកចិត្ត.....98
ក.ចូលរួមកម្មវិធីសំណេះសំណាលនៅសាលា.....98
ខ.សម្តែងការកោតសរសើរ និងលើកទឹកចិត្ត.....99
គ.តម្រង់ទិសបំណិនជីវិតរបស់កូន.....99
២.៥.៤. តួនាទីរបស់សិស្សក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់ខ្លួន.....99
២.៥.៤.១.ការចូលរួមការងារសហគមន៍ និងការគោរពវិន័យ.....100

ក.ម៉ោងសិក្សា ............................................................................................................100
ខ.ចូលរួមបោសសម្អាតបរិស្ថានថ្នាក់ សាលារៀន និងការងារសង្គម.....................................100
គ.រក្សាសណ្តាប់ធ្នាប់នៃការសិក្សា ..................................................................................100
២.៥.៤.២.ស្មារតីទទួលខុសត្រូវចំពោះសហគមន៍ និងការសិក្សារបស់ខ្លួន ........................100
ក.ធ្វើស្វ័យសិក្សា ........................................................................................................100
ខ.វិន័យផ្ទាល់ខ្លួន ........................................................................................................100
គ.ផែនការសិក្សា (ត្រៀមប្រឡង និងវាយតម្លៃ)...............................................................101
២.៥.៤.៣.កិច្ចខិតខំសិក្សាអស់ពីលទ្ធភាពរបស់ខ្លួន ....................................................101
ក.បង្កើតក្លឹបសិក្សា ....................................................................................................101
ខ.ចូលរួមដោះស្រាយបញ្ហារបស់មិត្តរួមថ្នាក់.................................................................101
**២.៦. សារៈសំខាន់នៃការចូលរួមរបស់គ្រួសារ និងសហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស**.......................................................................................................101
១. បង្កើនប្រសិទ្ធភាពនៃការប្រតិបត្តិផែនការអភិវឌ្ឍន៍សាលា .............................................102
២. ចូលរួមលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ...........................................................102
៣. អភិវឌ្ឍបរិស្ថានសិក្សាប្រកបដោយចីរភាព ...................................................................103
**២.៧. គោលការគ្រប់គ្រងតាមសាលារៀន**(School-Base Management) **មានប្រសិទ្ធភាព** ......................................................................................................................104
**ជំពូកទី ៣៖ វិធីសាស្ត្រស្រាវជ្រាវ** ....................................................................................107
**៣.១. គម្រោងនៃស្រាវជ្រាវ** ..............................................................................................107
**៣.២. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ** .............................................................................107
៣.២.១. ទីកន្លែងសិក្សាស្រាវជ្រាវ .......................................................................................107
៣.២.២. ការជ្រើសរើសក្រុមគោលដៅសម្ភាសន៍......................................................................109
**៣.៣. ឧបករណ៍ស្រាវជ្រាវ** ................................................................................................111
៣.៣.១. កម្រងសំណួរសម្ភាសន៍សម្រាប់សហគមន៍(អាជ្ញាធរដែនដី) ...................................... 111

៣.៣.២. កម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រងសាលា(នាយក/នាយករង)............... 111
៣.៣.៣. កម្រងសំណួរសម្ភាសន៍សម្រាប់គ្រូបង្រៀន ........................................................ 112
៣.៣.៤. កម្រងសំណួរសម្ភាសន៍សម្រាប់មាតាបិតា/អ្នកអាណាព្យាបាលសិស្ស........................ 112
៣.៣.៥. កម្រងសំណួរសម្ភាសន៍សម្រាប់សិស្ស................................................................ 113
**៣.៤. ដំណើរការនៃការប្រមូលព័ត៌មាន**..............................................................113
**៣.៥. ព័ត៌មានដែលទទួលបាន** ..........................................................................114
ក. របាយការណ៍ស្តីពីលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៃវិទ្យាល័យទាំងបី.... 114
ខ. ក្រុមគោលដៅអ្នកផ្តល់ព័ត៌មានដែលបានផ្តល់ព័ត៌មាន ............................................ 114
**៣.៦. ការវិភាគទិន្នន័យ និងព័ត៌មាន**..............................................................115
៣.៦.១. ការវិភាគទិន្នន័យតាមបរិមាណវិស័យ ................................................................ 115
៣.៦.២. ការវិភាគទិន្នន័យតាមគុណវិស័យ ................................................................... 116
**៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ** ...............................................................118
**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា**..........................................................119
**៤.១. ស្ថានភាពទូទៅនៃសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ**..........119
៤.១.១. កម្រិតគុណវុឌ្ឍិសមាជិកសហគមន៍ ................................................................. 119
៤.១.២. ស្ថានភាពទូទៅនៃសហគមន៍សាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ.............120
៤.២. **ការពិភាក្សាពីតួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សតាមបរិមាណវិស័យ** ....................................................................121
៤.២.១ ការបំពេញតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស .............123
៤.២.២ ការបំពេញតួនាទីរបស់ភាគីពាក់ព័ន្ធចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស............123
៤.៣. **ការពិភាក្សាពីតួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សតាមគុណវិស័យ** ............................................................................125
៤.៣.១ ការចូលរួមរបស់សហគមន៍......................................................................125
៤.៣.២. ការទំនាក់ទំនងរបស់សហគមន៍ ......................................................................126

៤.៣.៣. ការលើកទឹកចិត្តរបស់សហគមន៍ ..... 127
៤.៣.៤. ការផ្សព្វផ្សាយរបស់សហគមន៍ ..... 128
៤.៣.៥. ការកៀរគរធនធានរបស់សហគមន៍ ..... 129
**៤.៤. ការពិភាក្សាពីការគ្រប់គ្រងតាមសាលាមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស** ..... 130
៤.៤.១ គណនេយ្យភាព ..... 130
៤.៤.២. ស្វ័យភាព ..... 131
៤.៤.៣. វង្វាយតម្លៃ ..... 132
៤.៤.៤. ការយកចិត្តទុកដាក់ដល់គ្រូ ..... 133
**៤.៥. អនុសាសន៍ស្តីពីតួនាទីសហគមន៍ និងការគ្រប់គ្រងតាមសាលាក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាឱ្យមានប្រសិទ្ធភាព** ..... 136
៤.៥.១. ដំណើរការនៃការបង្កើតយន្តការគ្រប់គ្រង និងភាពជាដៃគូក្នុងសហគមន៍ ..... 136
៤.៥.២. គណនេយ្យភាពចំពោះតួនាទីរបស់អ្នកពាក់ព័ន្ធ ..... 137
៤.៥.៣. ស្វ័យភាព និងការលើកទឹកចិត្តក្នុងដំណើរការបង្រៀន និងរៀនដែលមានភាពច្នៃប្រឌិត ... 137
៤.៥.៤. ការលើកកម្ពស់បំណិនអាជីពរបស់សិស្ស ..... 137
៤.៥.៥. ធ្វើការតស៊ូមតិនឹងការគិតបែបអវិជ្ជមានរបស់សហគមន៍ ..... 138
៤.៥.៦. បង្កើត និងលើកកម្ពស់ឱកាសសិក្សាប្រកបដោយសមធម៌ និងបរិយាបន្ន ..... 138
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ..... 139
**៥.១. សេចក្តីសន្និដ្ឋាន** ..... 139
**៥.២. សំណូមពរ** ..... 140
៥.២.១. សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ..... 140
៥.២.២. សម្រាប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ..... 140
៥.២.៣. សម្រាប់គណៈគ្រប់គ្រងសាលា ..... 141
៥.២.៤. សម្រាប់សហគមន៍ និងមាតាបិតាសិស្ស ..... 141

៥.២.៥. សម្រាប់គ្រូបង្រៀន ........................................................................ 141

៥.២.៦. សម្រាប់សិស្សានុសិស្ស ........................................................................ 142

៥.២.៧. សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ........................................................................ 142

**៦. ឯកសារយោង** ........................................................................ 143

**៧. ឧបសម្ព័ន្ធ** ........................................................................ 147

**ឧបសម្ព័ន្ធ "ក" កម្រងសំណួរសម្រាប់អាជ្ញាធរ** ........................................................................ 147

**ឧបសម្ព័ន្ធ "ខ" កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា** ........................................................................ 151

**ឧបសម្ព័ន្ធ "គ" កម្រងសំណួរសម្រាប់មាតាបិតា/អ្នកអាណាព្យាបាល** ........................................................................ 155

**ឧបសម្ព័ន្ធ "ឃ" កម្រងសំណួរសម្រាប់គ្រូបង្រៀន** ........................................................................ 159

**ឧបសម្ព័ន្ធ "ង" កម្រងសំណួរសម្រាប់សិស្ស** ........................................................................ 163

**ឧបសម្ព័ន្ធ "ច"គណៈកម្មការវាយតម្លៃ** ........................................................................ 167

**ឧបសម្ព័ន្ធ "ឆ"គណៈកម្មការការពារនិក្ខេបបទ** ........................................................................ 169

**ឧបសម្ព័ន្ធ "ជ"លិខិតបង្គាប់ការគណៈកម្មការការពារនិក្ខេបបទបញ្ចប់** ........................................................................ 171

**ឧបសម្ព័ន្ធ "ឈ" បំណែងចែកក្រុមនិស្សិតការពារនិក្ខេបបទបញ្ចប់** ........................................................................ 174

**ឧបសម្ព័ន្ធ "ញ" សេចក្តីជូនដំណឹងស្តីពី ការចុះប្រមូលទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា** ........................................................................ 178

**ឧបសម្ព័ន្ធ "ដ" លិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា** ........................................................................ 179

**ឧបសម្ព័ន្ធ "ឋ" សេចក្តីជូនដំណឹងស្តីពី ការចុះប្រមូលទិន្នន័យរបស់មន្ទីរអប់រំ យុវជន និងកីឡា** ........................................................................ 183

**ឧបសម្ព័ន្ធ "ឌ" លិខិតស្នើសុំគ្រូណែនាំគោល** ........................................................................ 184

**ឧបសម្ព័ន្ធ "ឍ" លិខិតស្នើសុំគ្រូណែនាំរង** ........................................................................ 185

**ឧបសម្ព័ន្ធ "ណ" លិខិតបង្គាប់ការស្តីពីគណៈគ្រប់គ្រងសាលារៀន** ........................................................................ 186

**ឧបសម្ព័ន្ធ "ត" លិខិតបង្គាប់ការស្តីពីគណៈកម្មការវាយតម្លៃបុគ្គលិក** ........................................................................ 188

**ឧបសម្ព័ន្ធ "ថ" លិខិតបង្គាប់ការស្តីពីគោលការណ៍គ្រប់គ្រងមូលនិធិដំណើរការសាលារៀន** ....................190
**ឧបសម្ព័ន្ធ "ទ" លិខិតបង្គាប់ការស្តីពីគណៈកម្មការគ្រប់គ្រងអាហារូបករណ៍** .......192
**ឧបសម្ព័ន្ធ "ធ" តួនាទី និងភារកិច្ចរបស់កបក/កបក.យ ក្នុងសាលារៀន** ...............194
**ឧបសម្ព័ន្ធ "ន" គម្រូតួនាទី និងភារកិច្ចរបស់មេកងឯកភាពក្នុងសាលារៀន** ........195
**ឧបសម្ព័ន្ធ "ប" គណៈកម្មការប្រតិបត្តិការក្រុមការងារក្នុងសាលារៀន** .................196
**ឧបសម្ព័ន្ធ "ផ" រចនាសម្ព័ន្ធប្រព័ន្ធល្បាត និងកងកាយរឹទ្ធិ** .....................................197

**៨. តារាងសូចនាករ**

១. តារាងទី១៖ ស្តីពីការអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀន ........ 3
២. តារាងទី២៖ ស្តីពីតួនាទីរបស់សហគមន៍សាលារៀន ........ 31
៣. តារាងទី៣៖ ស្តីពីសមត្ថភាពដែលស្តែងចេញពីលទ្ធផលសិក្សាតាមរយៈផលជះនៃការអនុវត្តកម្មវិធីសិក្សា ........ 60
៤. តារាងទី៤៖ ស្តីពីកាលបរិច្ឆេទនៃការសម្ភាសក្រុមគោលដៅផ្តល់ព័ត៌មាន ........ 110
៥. តារាងទី៥៖ស្តីពីរបាយការណ៍លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ........ 114
៦. តារាងទី៦៖ស្តីពីក្រុមគោលដៅអ្នកផ្តល់ព័ត៌មានដែលបានផ្តល់ព័ត៌មាន ........ 114
៧. តារាងទី៧៖ស្តីពីកម្រិតមធ្យមពិន្ទុ និងអត្ថន័យ ........ 115
៨. តារាងទី៨៖ ស្តីពីលទ្ធផលនៃការសម្ភាសពីតួនាទីរបស់សហគមន៍ ........ 116
៩. តារាងទី៩៖ ស្តីពីលទ្ធផលនៃការសម្ភាសពីការគ្រប់គ្រងនៅកម្រិតសាលារៀន ........ 117
១០. តារាងទី១០៖ តារាងទី ១០៖ ការវិភាគ និងការពិភាក្សាលទ្ធផលស្តីពីតួនាទីរបស់សហគមន៍តាមបរិមាណវិស័យ ........ 121
១១. តារាងទី ១១៖ ការវិភាគ និងការពិភាក្សាលទ្ធផលស្តីពីកិច្ចសហការរបស់ភាគីពាក់ព័ន្ធតាមបរិមាណវិស័យ ........ 122

**៩. បញ្ជីរូបភាព**

១. រូបភាពទី១៖ ស្តីពីកម្រិតវប្បធម៌បុគ្គលិកអប់រំ ........ 4
២. រូបភាពទី២៖ ស្តីពីបុគ្គលិកសាលារៀនដែលមានមុខងារដោយឡែក ........ 5
៣. រូបភាពទី៣៖ ស្តីពីកម្រិតវប្បធម៌បុគ្គលិកបង្រៀនតាមភូមិសិក្សា ........ 5

៤. រូបភាពទី៤៖ ស្តីពីផែនការយុទ្ធសាស្ត្រសហគមន៍សាលារៀន 31
៥. រូបភាពទី៥៖ ស្តីពីរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសាលារៀន 32
៦. រូបភាពទី៦៖ ស្តីពីក្របខ័ណ្ឌនៃគំនិតវិមជ្ឈការថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន 34
៧. រូបភាពទី៧៖ ស្តីពីក្រុមប្រឹក្សាភិបាលសាលារៀន 35
៨. រូបភាពទី៨៖ ស្តីពីគណៈកម្មការអភិវឌ្ឍន៍សាលារៀន 36
៩. រូបភាពទី៩៖ ស្តីពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងថវិកាសាលារៀន 37
១០. រូបភាពទី១០៖ ស្តីពីគំរូជំហានសកម្មភាពនៃព្រឹត្តិការណ៍សាមញ្ញ 42
១១. រូបភាពទី១១៖ ស្តីពីតួនាទីរបស់សហគមន៍ 45
១២. រូបភាពទី១២៖ ស្តីពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងថវិកាសាលារៀន 48
១៣. រូបភាពទី១៣៖ ស្តីពីរចនាសម្ព័ន្ធគណៈកម្មការអភិវឌ្ឍន៍សាលារៀន 51
១៤. រូបភាពទី១៤៖ ក្រុមការងារទាំង១១របស់គណៈកម្មការអភិវឌ្ឍន៍សាលារៀន 51
១៥. រូបភាពទី១៥៖ ស្តីពីប្រព័ន្ធវដ្តបិទជិត ៣A 58
១៦. រូបភាពទី១៦៖ ស្តីពីអត្រាលំហូរសិស្សតាមកម្រិតសិក្សា និងសិស្សប្រឡងជាប់ឆ្នាំ ២០២១ 62
១៧. រូបភាពទី១៧៖ ស្តីពីអត្រាត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សា 63
១៨. រូបភាពទី១៨៖ ស្តីពីអត្រាសិស្សបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សា 65
១៩. រូបភាពទី១៩៖ ស្តីពីអត្រាសិស្សឡើងថ្នាក់នៅកម្រិតមធ្យមសិក្សា 66
២០. រូបភាពទី២០៖ ស្តីពីអត្រាគង់វង្ស និងអត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សា 67
២១. រូបភាពទី២១៖ ស្តីពីអត្រាការចូលរៀនរបស់សិស្សនៅប្រទេសមួយចំនួនក្នុងតំបន់ 68
២២. រូបភាពទី២២៖ ស្តីពីកម្រិតជំនាញរបស់ពលករ 74
២៣. រូបភាពទី២៣៖ ស្តីពីសហគមន៍សាលារៀន 78
២៤. រូបភាពទី២៤៖ ស្តីពីផែនទីសិក្សានៃខេត្តព្រះសីហនុ 108
២៥. រូបភាពទី២៥៖ ស្តីពីផែនទីសិក្សានៃវិទ្យាល័យហ៊ុន សែនមិត្តភាព 108
២៦. រូបភាពទី២៦៖ ស្តីពីផែនទីសិក្សានៃវិទ្យាល័យក្រុងព្រះសីហនុ 109
២៧. រូបភាពទី២៧៖ ស្តីពីផែនទីសិក្សានៃវិទ្យាល័យហ៊ុន សែនឃ្លាំងលើ 109

# អក្សរកាត់ និងអត្ថន័យជាខេមរភាសា

| អក្សរកាត់ | ពាក្យពេញ | អត្ថន័យជាខេមរភាសា |
|---|---|---|
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **AOP** | Annual Operational Plan | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| **ASEAN** | Association of South East Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CAR** | Council for Administrative Reform | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| **CDPF** | Cambodia Development Partnership Fund | មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព |
| **CDRI** | Cambodia Development Resource Institute | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា |
| **CLC** | Community Learning Centre | មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| **CRDB** | Cambodian Rehabilitation and Development Board | គណៈកម្មាធិការស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| **CSO** | Civil Society Organization | អង្គការសង្គមស៊ីវិល |
| **D&D** | Decentralization and Deconcentration | វិមជ្ឈការ និងវិសហមជ្ឈការ |
| **DGAF** | Directorate General of Administration and Finance | អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| **DOE** | District Office Education | ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ |
| **DTMT** | District Training and Monitoring Team | ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ |
| **ECE** | Early Childhood Education | ការអប់រំកុមារតូច |
| **ECED** | Early Childhood Education Department | នាយកដ្ឋានអប់រំកុមារតូច |
| **EEQP** | Education Equity and Quality Programme | កម្មវិធីសមធម៌ និងគុណភាពនៃការអប់រំ |
| **EFA** | Education For All | ការអប់រំសម្រាប់ទាំងអស់គ្នា |
| **EMIS** | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| **ESP** | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| **ESI** | Education Statistics and Indicators | ស្ថិតិ និងសូចនាករអប់រំ |
| **EU** | European Union | សហភាពអឺរ៉ុប |

| | | |
|---|---|---|
| **FTI-EFA** | Education Fast Track Initiative for Education for All (now GPE) | គំនិតផ្តួចផ្តើមពន្លឿនការអប់រំសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា(ឥឡូវនេះហៅថា GPE) |
| **GIZ** | German International Cooperation | សហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| **GPE** | Global Partnership for Education | ភាពជាដៃគូសកលសម្រាប់ការអប់រំ |
| **GSED** | General Secondary Education Department | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| **GEIP** | General Education Improvement Project | គម្រោងកែលម្អការអប់រំចំណេះទូទៅ |
| **HE** | Higher Education | ការអប់រំឧត្តមសិក្សា |
| **HRD** | Human Resource Development | ការអភិវឌ្ឍធនធានមនុស្ស |
| **HRMIS** | Human Resource Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស |
| **IBEC** | Improving Basic Education in Cambodia | គម្រោងលើកកម្ពស់ការអប់រំជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា |
| **ICT** | Information and Communications Technology | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| **IIEP** | International Institute for Educational Planning | វិទ្យាស្ថានអន្តរជាតិសម្រាប់ការរៀបចំផែនការអប់រំ |
| **IP3** | Implementation Plan (3 years) | ផែនការអនុវត្ត(រយៈពេល៣ឆ្នាំ) |
| **JICA** | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន |
| **MDGs** | Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| **MoEYS** | Ministry of Education Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| **M&E** | Monitoring and Evaluation | ការពិនិត្យតាមដាន និងការវាយតម្លៃ |
| **MPCD** | Master Plan for Capacity Development | ផែនការគោលស្តីពី ការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យអប់រំ |
| **MEF** | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| **NEFAC** | National EFA Committee | គណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នា |
| **NEA** | National Employment Agency | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| **NGO** | Non-Government Organization | អង្គការមិនមែនរដ្ឋាភិបាល |
| **NFE** | Non-Formal Education | ការអប់រំក្រៅប្រព័ន្ធ |
| **NIE** | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| **NSDP** | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| **NPSDD** | National Program for Sub-national Democratic Developments | កម្មវិធីជាតិសម្រាប់អភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន |
| **PAR** | Public Administrative Reform | កំណែទម្រង់រដ្ឋបាលសាធារណៈ |
| **PFMR** | Public Financial Management Reform | កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| **POE** | Provincial Office of Education | មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **RUPP** | Royal University of Phnom Penh | សកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| **Sida** | Swedish International Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត |
| **SNA** | Sub-National Administration | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **SNDD** | Sub-National Democratic Development | ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **SSC** | School Support Committee | គណៈកម្មការទ្រទ្រង់សាលារៀន |
| **SSC** | Strategic School Community | យុទ្ធសាស្ត្រសហគមន៍សាលារៀន |
| **TTC** | Teacher Training College | សាលាគរុកោសល្យ |
| **TVET** | Technical and Vocational Education and Training | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| **UNESCO** | United Nations Educational, Scientific and Cultural Organization | ទីភ្នាក់ងារអប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |
| **UNICEF** | United Nations Children’s Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |

# សេចក្ដីសង្ខេបមូលន័យ

ជាទូទៅ គុណតម្លៃនៃការអប់រំត្រូវបានគេយកចិត្តទុកដាក់អភិវឌ្ឍជាសកល និងជាលក្ខណៈតំបន់ផងដែរ តួយ៉ាងក្នុងសតវត្សទី ២១នេះ ប្រទេស ១៦០ បានចូលរួមកំណត់គោលនយោបាយអប់រំស្ដីពីការអប់រំប្រកបដោយចីរភាព និងធានាការអប់រំមានគុណភាព សមធម៌ បរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសនៃការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាហើយវាក៏ស្របទៅនឹងបរិបទសមាហរណកម្មអាស៊ាន និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយជ្រើសយកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ព្រមទាំងជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ផងដែរក្នុងគោលបំណងដើម្បីផ្លាស់ប្ដូរប្រទេសទៅជាប្រទេសឧស្សាហកម្មនាឆ្នាំ ២០២៥ និងមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយបន្តទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០។

កាលានុវត្តភាពនៃកំណែទម្រង់វិស័យអប់រំ បានទទួលសមិទ្ធិផលជាច្រើន រួមទាំងរបកគំហើញលើបញ្ហាប្រតិបត្តិតួនាទីរបស់សហគមន៍ ចំពោះការអភិវឌ្ឍសាលារៀន ដែលជាកត្តារាំងស្ទះសម្រាប់ការអនុវត្តការងារដឹកនាំ គ្រប់គ្រងអប់រំនៅកម្រិតមូលដ្ឋានពោលគឺ៖ អត្រាសិស្សចូលរៀននៅមធ្យមសិក្សាមានចំនួនតិច សមត្ថភាពជំនាញបច្ចេកទេសវិជ្ជាជីវៈរបស់សិស្សនៅមានកម្រិតទាប អត្រាសិស្សបោះបង់ការសិក្សា និងអត្រាសិស្សរៀនត្រួតថ្នាក់មានចំនួនច្រើន។ ដូចនេះ ដើម្បីសិក្សាស្វែងយល់ពីតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស និងស្វែងរកដំណោះស្រាយនានា ចំពោះការពង្រឹងការចូលរួមរបស់សហគមន៍ជាមួយនឹងការគ្រប់គ្រងនៅកម្រិតសាលារៀនឱ្យកាន់តែមានប្រសិទ្ធភាព ប្រធានបទស្ដីពី "**តួនាទីរបស់សហគមន៍ចំពោះ ការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**" ត្រូវបានលើកយកមកធ្វើការសិក្សាតាមរយៈសំណួរស្រាវជ្រាវពីរគឺ៖១. តើសហគមន៍មានតួនាទីធ្វើអ្វីខ្លះ ដើម្បីអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ? ២.តើសហគមន៍ និងសាលារៀនត្រូវចូលរួមដោះស្រាយយ៉ាងដូចម្ដេចខ្លះ ដើម្បីឱ្យការគ្រប់គ្រងនៅកម្រិតសាលារៀនមានប្រសិទ្ធភាព? ការសិក្សាស្រាវជ្រាវបានជ្រើសយកគម្រោងវិភាគទិន្នន័យ និងព័ត៌មានតាមបែបចម្រុះគឺប្រើទាំងបរិមាណវិស័យ និងគុណវិស័យហើយជ្រើសរើសយកវិទ្យាល័យទាំងអស់(បី)ក្នុងក្រុងព្រះសីហនុមកធ្វើការសិក្សាស្រាវជ្រាវដោយមានអ្នកផ្ដល់ព័ត៌មានចំនួន ៦៣នាក់ចេញពី៖ សហគមន៍(អាជ្ញាធរដែនដី មេឃុំ មេភូមិ) ៣នាក់ គណៈគ្រប់គ្រងសាលា ៦នាក់ គ្រូបង្រៀន ១៨នាក់ មាតាបិតា/អ្នកអាណាព្យាបាល ១៨នាក់ និងសិស្សានុសិស្ស ១៨នាក់។ ឧបករណ៍នៃការស្រាវជ្រាវត្រូវបានបង្កើតជាកម្រងសំណួរដែលមានលក្ខណៈជាទម្រង់សំណួរបើក និងសំណួរបិទដើម្បីបំពេញ ព្រមទាំងសម្ភាសន៍យកព័ត៌មានផងដែរ។

ជាលទ្ធផលនៃការស្រាវជ្រាវ វិទ្យាល័យពីរមានការរីកចម្រើនទាំងលទ្ធផលសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដោយមានសហគមន៍ចូលរួមរៀបចំផែនការសាលារៀន ពិនិត្យតាមដានការអនុវត្តផែនការជួយឧបត្ថម្ភគាំទ្រ ជាពិសេសដោយសារសមាជិកសហគមន៍ទាំងនោះជាអតីតសិស្សដែលមានធនធានកិត្តិយស និងសិទ្ធិអំណាចក្នុងសង្គម។ ប៉ុន្តែ វិទ្យាល័យមួយទៀត វឌ្ឍនភាពការសិក្សា និងបរិស្ថានសិក្សានៅមានភាពរីកចម្រើនយឺតដោយសារតែ បញ្ហាប្រឈមមួយចំនួនរបស់សហគមន៍ដូចជា៖ ភាពមិន

ច្បាស់លាស់ពីតួនាទីរបស់ខ្លួន ជីវភាពខ្វះខាត កម្រិតវប្បធម៌ត្រឹមបឋមសិក្សា(ខ្លះមិនចេះអក្សរ) បម្លាស់ទីលំនៅញឹកញាប់ ភាពមមាញឹកនឹងអាជីពបុគ្គលជាដើម។ តាមការសិក្សាស្រាវជ្រាវនេះ ដំណោះស្រាយនៃកម្រោយការចូលរួមពីសហគមន៍ត្រូវបានលើកឡើងដូចជា៖ ភាគីពាក់ព័ន្ធត្រូវបង្កើតយន្តការគ្រប់គ្រង និងរក្សាភាពជាដៃគូក្នុងសហគមន៍ ដោយជ្រើសរើសគណៈកម្មការសាលារៀនឱ្យបានហ្មត់ចត់តាមនីតិវិធី ហើយសមាជិក ព្រមទាំងអ្នកពាក់ព័ន្ធត្រូវចូលរួមកៀរគរធនធាន ទាក់ទងស្វែងរកសប្បុរសជន ពង្រឹងការប្រាស្រ័យទាក់ទងគ្នាជាមួយសហគមន៍ជាតិ និងអន្តរជាតិ ស្វែងយល់ពីគ្នាដោយភាតរភាព និងភាពស្មោះត្រង់ ជាពិសេសត្រូវមានក្រុមដើម្បីចែករំលែកព័ត៌មានបានសព្វគ្រប់ជ្រុងជ្រោយតាមគោលការណ៍ប្រាំគឺ៖ ១. គណនេយ្យភាព ២. ស្វ័យភាព ៣. វង្វាយតម្លៃ ៤. ការយកចិត្តទុកដាក់ដល់គ្រូ និង ៥. ការសហការ។

សេចក្តីសន្និដ្ឋាន ការគ្រប់គ្រងនៅកម្រិតសាលារៀន ពិតជាធ្វើឱ្យការសិក្សារបស់សិស្សមានវឌ្ឍនភាព និងប្រសិទ្ធផលតាមរយៈការចូលរួមប្រតិបត្តិតួនាទីប្រកបដោយទំនួលខុសត្រូវពីសហគមន៍ និងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ។ ទន្ទឹមនឹងឥរិយាបថគ្រប់គ្រងអប់រំជាវិជ្ជមាននេះ បញ្ហាប្រឈមមួយចំនួនក៏ត្រូវរៀបចំយន្តការដោះស្រាយឱ្យទាន់ពេលវេលាផងដែរ តាមសំណើយោបល់ដែលបានលើកឡើងដូចតទៅ៖ សូមស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានជួយផ្តល់ថវិកា ជាតុចូលដល់សាលារៀនដើម្បីរៀបចំផែនការសាលា បណ្តុះបណ្តាលគ្រូ និងបំប៉នសមត្ថភាពអាជីពយ៉ាងទាបត្រឹមកម្រិតបរិញ្ញាបត្រអប់រំ ចុះទៅផ្សព្វផ្សាយដល់សហគមន៍ពីតួនាទីភារកិច្ចក្នុងការចូលរួមអភិវឌ្ឍសាលារៀន និងការសិក្សារបស់សិស្ស ព្រមទាំងចងក្រងបញ្ជីទំនាក់ទំនងអ្នកពាក់ព័ន្ធផងដែរ។ សូមអ្នកសិក្សាជំនាន់ក្រោយៗ លើកយកប្រធានបទនេះ ទៅសិក្សាស្រាវជ្រាវបន្តនៅមូលដ្ឋានរបស់ខ្លួនដើម្បីជាយន្តការចែករំលែកបទពិសោធន៍ដំណោះស្រាយ និងពង្រីកឧត្តមានុវត្តន៍លើការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព។

# ABSTRACT

Generally educational value is drawn the most attention to develop globally and regionally for example, in this 21st century, 160 countries have cooperatively identified the educational policy on sustainable education by ensuring quality education with equity, inclusion and strengthening the long-life learning opportunity for all as well as the visions of ASEAN integration and Cambodian government. Human resource development has been chosen as the first priority in 4th pace of the Square-Strategic Plan and the 4th of Sustainable Development Goals with the aims to alter Cambodia to become an industrial country in 2025, a high-medium income state in 2030 and continue to be a developing one in 2050.

The opportunity of educational reformation has resulted in remarkable accomplishment with the prompt issues on community's role performances in developing schools. Some educational affects at the school-based levels have been arisen due to these barren key factors in schooling management such as: the low enrollment rate at upper-secondary school, low-vocational and technical competencies, high-rate of drop-out and repeated class. In order to know about the roles of community in developing student-learning outcomes and to figure out its solutions in strengthening the community involvement in school-based management more effectively, this topic "**The roles of community in developing students' learning outcomes in Upper Secondary School in Preah Sihanouk Ville, Preah Sihanouk Province**" must be conducted through the two research questions: 1/. What are the roles of community in developing student-learning outcomes in upper-secondary school in Preah Sihanouk Ville, Preah Sihanouk Province? 2/. What do the community and school have to cooperatively solve to promote the school-based management more effective? This research is proceeded with mixed-method data analysis (Quantity and Quality Research) and conducted the interview 63 key informants from the 3 target-high schools: 3 communities (Authority, Chef of commune or village), 6 school principals, 18 guardians and 18 students. The information protocol is applied in closed-ended question and opened question forms in order to gather the information with ticking the answers as well as interviewing questions.

As the result, the two above-mentioned high schools have improved both student-learning outcomes and main infrastructures with the community involvement in managing school plans, assessing school plan application, supporting schools especially their community's members are the former students who have well-living conditions, good reputation and power in the society. However, the improvement of student-learning outcomes and learning environment in another high school remains slow progress due to some challenges in the community such as: unspecific individuals' duty, shortage of living condition, primary-educational background (illiteracy), high frequency of movement and business of personal profession. Some solutions on the weak community involvement are stated in this paper like: the involved parties have to set up the managing mechanism and maintain the partnership in the community by promoting a school committee in the strictly legal procedure as well as the members and involved individuals have to help fund raising, contacting charity, strengthening the national and international partnership, having a friendly and honest relationship especially establishing an information group with the five guidelines of school-based management such as: Accountability, Autonomy, Assessment, Pay Attention to teachers and Participation.

In conclusion, School-Based Management (SBM) absolutely improves the student-learning outcomes through the community involvement with the responsible roles performances and other involved parties with the prior three guidelines: 1. Strengthening the capacity of educational system to apply School-Based Management, 2. Strengthening the teacher's efficiency by teacher's working performances and 3. Promoting community's involvement in school autonomy and accountability. Despite the positive school management manners, some challenges must be established timely measurement for urging the involved constitutions and partners to offer schools the budget and inputs, train the teachers on professional development at least bachelor degree in education, raise awareness on the community roles of taking part in developing school and student-learning outcomes, and make the involved person's contact list. Hopefully, the topic will be considered to conduct by the next generation researchers in order to share experiences, solutions and generate the best practice on the effective School-Based Management.

# ជំពូកទី ១

# សេចក្តីផ្តើម

# ជំពូកទី ១៖ សេចក្តីផ្តើម

## I. វឌ្ឍនភាពនៃការអប់រំនៅកម្ពុជា

### ក. ការវិវត្តលើវិស័យអប់រំ និងគុណវុឌ្ឍិគ្រូបង្រៀន

ប្រទេសកម្ពុជាមានវប្បធម៌ អរិយធម៌របស់ខ្លួនតាំងពីបុរាណកាលមកម្លេះ ហើយការអប់រំនៅក្នុងសង្គមខ្មែរមានការរីកចម្រើនខ្លាំងនៅសម័យកាលអាណាចក្រខ្មែរ(ជួន, ២០១៦)[(1)] ។ ព្រះពុទ្ធសាសនា វត្តអារាម មានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យមកបម្រើក្នុងរាជការ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិនាសម័យនោះ។ ក្នុងការសិក្សាឯកសារច្រើនមានជាភាសាបាលី ប៉ុន្តែក្នុងការទំនាក់ទំនងជីវភាពប្រចាំថ្ងៃ ប្រជាជនប្រើប្រាស់ភាសាខ្មែរ។ ប្រព័ន្ធអប់រំកម្ពុជានាអំឡុងពេលមុនសតវត្សទី ២០ ជាប្រព័ន្ធមួយដែលឈរលើមូលដ្ឋាននៃរចនាសម្ព័ន្ធសង្គមដែលមិនមែនស្ថាប័នទេតែគឺបុគ្គលដែលដើរតួនាទីឈានមុនគេនៅក្នុងរដ្ឋបាល។ ប្រព័ន្ធអប់រំប្រពៃណីនេះព្រះសង្ឃរាជ បុព្វជិត ព្រាហ្មណ៍ អ្នកប្រាជ្ញកវីនិពន្ធ គឺជាសសរស្តម្ភនៃប្រព័ន្ធអប់រំបែបប្រពៃណី។ ប្រព័ន្ធអប់រំបែបប្រពៃណីនេះបានដួលរលំនៅពេលបាត់បង់ធនធានមនុស្សទាំងអស់នៅក្នុងសង្គ្រាម(ឧស្សាហ៍, ២០១៨)[(2)]។

ប្រព័ន្ធអប់រំនៃព្រះរាជាណាចក្រកម្ពុជា មានការវិវត្តចុះឡើង រីកចម្រើន ថប់ថយតាមដំណាក់កាលនៃការដឹកនាំ និងគ្រប់គ្រងប្រទេសតួយ៉ាង ក្នុងរជ្ជកាលព្រះបាទអង្គឌួង ព្រះអង្គបានចាត់ទុកវិស័យព្រះពុទ្ធសាសនាជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យមានសន្តិភាព និងការរស់ឡើងវិញនៃកម្ពុជា។ ព្រះអង្គបានបង្កើតបណ្ណាល័យ ប្រមូលគម្ពីរព្រះពុទ្ធសាសនាដែលបាត់បង់មកចងក្រងសម្រាប់ធ្វើជាឯកសាររៀនសូត្រ និងបានអំពាវនាវផ្សព្វផ្សាយប្រមូលកុមារឱ្យចូលរៀននៅតាមសាលាវត្តដោយមានទំនាក់ទំនងជាមួយភាគីបរទេសដូចជា៖ ប្រទេសបារាំង និងវៀតណាម។ ម្យ៉ាងវិញទៀត នៅក្នុងឆ្នាំ ១៩១១ ព្រះបាទស៊ីសុវត្ថិ បានបង្កើតឱ្យមានការអប់រំ ជាកាតព្វកិច្ច(Compulsory)នៅក្នុងប្រទេសកម្ពុជា ហើយនៅទសវត្សឆ្នាំ ១៩៥០ និង១៩៦០ បានពង្រីកការអប់រំកម្រិតបឋមសិក្សា និងការបង្កើតគ្រឹះស្ថានឧត្តមសិក្សាជាដើម។ គ្រូបង្រៀនទទួលបានការគាំទ្រពេញលេញពីរាជរដ្ឋាភិបាល និងមានគន្លងអាជីពខ្ពង់ខ្ពស់អាចក្លាយជាឧត្តមមន្ត្រី ឬជាអ្នកនយោបាយ។ ជាមួយគ្នានេះ គេក៏បានមើលឃើញពីលទ្ធផលសិក្សារបស់សិស្ស និស្សិតប្រកបដោយគុណភាពផងដែរ។ ជាទូទៅគេអាចវាយតម្លៃថាសិស្ស និស្សិតបញ្ចប់ការសិក្សានៅមធ្យមសិក្សា ឬឧត្តមសិក្សា និងគ្រូបង្រៀនសុទ្ធតែមានសមត្ថភាពខ្ពស់ជាធនធានដ៏មានសក្តានុពលពិតប្រាកដក្នុងការអភិវឌ្ឍប្រទេសជាតិ។ សោធនាដកម្មដ៏ធំធេងក្នុងវិស័យអប់រំក្នុងទសវត្សឆ្នាំ ១៩៧០ ដល់ ១៩៧៩ បានបំផ្លិចបំផ្លាញស្ទើរទាំងស្រុងដោយរបបខ្មៅងងឹតខ្មែរក្រហមបានកាប់សម្លាប់គ្រូបង្រៀន បំផ្លាញអគារសិក្សា រចនាសម្ព័ន្ធអប់រំ បណ្ណាល័យ សៀវភៅសិក្សា និងសម្ភារៈសិក្សាដទៃទៀត។ល។ គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាចំនួន ៧៥ភាគរយ សាស្ត្រាចារ្យនៅសាកលវិទ្យាល័យចំនួន ៩១ភាគរយ ព្រម

[1] កំណែទម្រង់វិស័យអប់រំនៅកម្ពុជា ទំព័រ A

[2] ស្ថានភាពដំណើរវិវត្ត និងកំណែទម្រង់អប់រំតាមដំណាក់នីមួយៗ ទំព័រ ៤

ទាំងសិស្សានុសិស្សនៅបឋមសិក្សា និងមធ្យមសិក្សា ៦៧ភាគរយ និងនិស្សិតសាកលវិទ្យាល័យចំនួន ៩៦ ភាគរយត្រូវបានសម្លាប់ ឬស្លាប់ដោយអត់អាហារ( នូវ, ២០២១ )[3]។

ក្រោយថ្ងៃដួលរំលំរបបឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុល ពត នៅថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ ដោយរណសិស្សសង្គ្រោះជាតិកម្ពុជា រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការស្តារឡើងវិញនូវវិស័យអប់រំដោយដំណើរការទៅតាមបីដំណាក់កាលដូចខាងក្រោម៖

| ដំណាក់កាល | ចន្លោះឆ្នាំ | ប្រព័ន្ធអប់រំ | ចំនួនឆ្នាំសិក្សា | កំណត់សម្គាល់ |
|---|---|---|---|---|
| ទីមួយ | ១៩៧៩-១៩៨៥ | ៤-៣-៣ | ១០ឆ្នាំ | ▪បឋមសិក្សា<br>▪មធ្យមសិក្សាបឋមភូមិ<br>▪មធ្យមសិក្សាទុតិយភូមិ |
| ទីពីរ | ១៩៨៦-១៩៩៥ | ៥-៣-៣ | ១១ឆ្នាំ | |
| ទី បី | ១៩៩៦ ដល់បច្ចុប្បន្ន | ៦-៣-៣ | ១២ឆ្នាំ | |

នៅដំណាក់កាលទី១នេះ ក្រសួងអប់រំទទួលយកអ្នកណាក៏ដោយឱ្យតែស្ម័គ្រចិត្តមកបង្រៀន ទោះបីជាពួកគេគ្មានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីក្លាយជាគ្រូបង្រៀនក៏ដោយ។ អ្នកដែលស្ម័គ្រចិត្តភាគច្រើនមានកម្រិតសិក្សាមិនលើសពីបឋមសិក្សាឡើយ ហើយដើម្បីក្លាយជាគ្រូបង្រៀនពួកគាត់ទទួលបានការបណ្តុះបណ្តាលខ្លីពីមួយសប្តាហ៍ទៅបួនខែប៉ុណ្ណោះ។ នៅឆ្នាំ ១៩៨៣ ស្តង់ដាគ្រូបង្រៀនមត្តេយ្យ និងបឋមសិក្សាត្រូវបានបង្កើតឡើងដោយអនុវត្តទៅតាមរូបមន្ត ៧បូក១ សម្រាប់ខេត្តតំបន់វាលរាប ប៉ុន្តែសម្រាប់ខេត្តជួបការលំបាក និងតំបន់ដាច់ស្រយាលអនុវត្តតាមបទដ្ឋាន ៣បូក១។ នៅឆ្នាំ ១៩៨៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគត្រូវបានបង្កើតឡើង ដើម្បីបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិ ដោយប្រើរូបមន្ត ៧បូក៣ ហើយដើម្បីក្លាយជាគ្រូបង្រៀននៅវិទ្យាល័យ គ្រូមធ្យមសិក្សាបឋមភូមិ ត្រូវរៀនក្នុងវគ្គបណ្តុះបណ្តាលរយៈពេល១ខែកន្លះរយៈពេល២ឆ្នាំជាប់គ្នាផងដែរ។ សម្រាប់ដំណាក់កាលទី ២ រូបមន្តគុណវុឌ្ឍិគ្រូបង្រៀនត្រូវបានអនុវត្តសម្រាប់មត្តេយ្យ និងបឋមសិក្សានៅតំបន់វាលរាប គ្រូបង្រៀនត្រូវបានជ្រើសរើសពីក្នុងចំណោម អ្នកដែលប្រឡងធ្លាក់ថ្នាក់ទី ១១ ហើយត្រូវសិក្សារយៈពេល២ឆ្នាំ ចំណែកឯខេត្តជួបការលំបាក ឬដាច់ស្រយាលអនុវត្តតាមរូបមន្ត ៩បូក២។ សម្រាប់គ្រូមធ្យមសិក្សាបឋមភូមិគឺថ្នាក់ទី១១បូក២ ចំណែកគ្រូមធ្យមសិក្សាទុតិយភូមិថ្នាក់ទី ១១បូក៣។ ដំណាក់កាលទី ៣ ចាប់តាំងពីឆ្នាំ ១៩៩៦ ប្រព័ន្ធអប់រំ ១២ឆ្នាំ ត្រូវបានអនុវត្តដើម្បីគោរពតាមស្តង់ដាអន្តរជាតិ។ គុណវុឌ្ឍិរបស់គ្រូបង្រៀនគឺ គ្រូបឋមសិក្សាត្រូវធ្វើតាមរូបមន្ត ១២បូក២ និង ៩បូក ២ សម្រាប់ខេត្តជួបការលំបាក និងខេត្តដាច់ស្រយាល។ ចំណែកគ្រូមធ្យមសិក្សាបឋមសិក្សាត្រូវជ្រើសរើសពីក្នុងចំណោមសិស្សបញ្ចប់ការសិក្សាថ្នាក់ទី ១២ បន្ទាប់មកទទួលការបណ្តុះ បណ្តាលរយៈពេល២ឆ្នាំ។ គ្រូមធ្យមសិក្សាទុតិយភូមិត្រូវអនុវត្តរូបមន្ត ១២បូក៤ ឬបរិញ្ញាបត្រ បូក១ដែលត្រូវបណ្តុះបណ្តាលនៅមហាវិទ្យាល័យគរុកោសល្យ និងក្រោយមកមានឈ្មោះជាវិទ្យាស្ថានជាតិអប់រំ (NIE) (ថៅ, ២០១៨)[4]។

---

[3] បទបង្ហាញរបស់សាស្ត្រាចារ្យ បណ្ឌិតនូវ វីរ៉ា ឆមាសទី១ ឆ្នាំទី១ នៃមុខវិជ្ជាក្រមសីលធម៌វិជ្ជាជីវៈអ្នកដឹកនាំការងារអប់រំ

[4] ស្ថានភាពដំណើរវិវត្ត និងកំណែទម្រង់អប់រំតាមដំណាក់នីមួយៗ ទំព័រ ៦

**តារាងទី ១៖ គុណវុឌ្ឍិគ្រូបង្រៀន**

| ដំណាក់កាល | ចន្លោះឆ្នាំ | គ្រូបង្រៀន | គុណវុឌ្ឍិគ្រូ | |
|---|---|---|---|---|
| | | | ខេត្តវាលរាប | ខេត្តជួបការលំបាក/ដាច់ស្រយាល |
| ទីមួយ | ១៩៧៩ ដល់ ១៩៨៥ | បឋមសិក្សា | រើសអ្នកស្ម័គ្រចិត្ត ៧+១ | រើសអ្នកស្ម័គ្រចិត្ត(១៩៧៩) ៣+១ (១៩៨៣) |
| | | មធ្យមសិក្សាបឋមភូមិ | ៧+៣ | ៧+៣(១៩៨៤) |
| | | មធ្យមសិក្សាទុតិយភូមិ | គ្រូមធ្យមសិក្សាបឋមភូមិត្រូវបណ្តុះបណ្តាលរយៈពេល១ខែកន្លះរយៈពេល២ឆ្នាំជាប់គ្នា | |
| ទីពីរ | ១៩៨៦ ដល់ ១៩៩៥ | បឋមសិក្សា | ប្រឡងធ្លាក់ថ្នាក់ទី ១១+២ | ៩+២ |
| | | មធ្យមសិក្សាបឋមភូមិ | ១១+២ | ១១+២ |
| | | មធ្យមសិក្សាទុតិយភូមិ | ១១+៣ | ១១+៣ |
| ទី បី | ១៩៩៦ រហូតដល់បច្ចុប្បន្ន | បឋមសិក្សា | ជាប់ ឬធ្លាក់ថ្នាក់ទី ១២+២ | ៩+២ |
| | | មធ្យមសិក្សាបឋមភូមិ | ជាប់ថ្នាក់ទី ១២+២ | ជាប់ថ្នាក់ទី ១២+២ |
| | | មធ្យមសិក្សាទុតិយភូមិ | ជាប់១២ +៤ ឬបរិញ្ញា+១ | ជាប់១២ +៤ ឬបរិញ្ញា+១ |

## ខ. ស្ថានភាពទូទៅរបស់បុគ្គលិកអប់រំនៅកម្ពុជា

ប្រព័ន្ធអប់រំកម្ពុជាត្រូវបានបំផ្លាញទាំងស្រុងនៅចុងទសវត្ស១៩៧០។ គ្រូបង្រៀនជាច្រើននាក់ត្រូវបានសម្លាប់ និងភៀសខ្លួនពីសង្គ្រាម ចំណែកឯហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាសាលារៀនត្រូវបានកម្ទេចគ្មានសល់ដោយសារភ្លើងសង្គ្រាម។ លុះដល់ថ្ងៃរំដោះ ៧ មករា ១៩៧៩ ដែលជាថ្ងៃកំណើតទីពីររបស់ប្រជាជនកម្ពុជាបានរួចជីវិតពីសេចក្តីមរណៈ ក្រោយមកតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍និងសហគមន៍ជាតិ និងអន្តរជាតិបានធ្វើឱ្យវិស័យអប់រំនៅកម្ពុជាប្រែមុខមាត់ថ្មីជាបណ្តើរ តាំងពីបាតដៃទទេរហូតដល់មានការរីកចម្រើនដូចសព្វថ្ងៃនេះ (ជួន, ២០១៦)[5]។ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំនៅកម្ពុជាដ៏មានប្រសិទ្ធភាពស្របតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយស្តីពី

[5] កំណែទម្រង់វិស័យអប់រំនៅកម្ពុជា ទំព័រ B

ធនធានមនុស្សក្នុងវិស័យអប់រំ គោលនយោបាយស្តីពីគ្រូបង្រៀន ស្តង់ដានាយកសាលា គោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនជាអាទិ៍គឺ មានគោលបំណងប្រែក្លាយធនធានមនុស្សឱ្យកាន់តែមានសមត្ថភាពការងារ មានប្រសិទ្ធភាព មានភាពស័ក្តិសិទ្ធិ និងមានការជឿទុកចិត្តក្នុងការផ្តល់ និងគាំទ្រសេវាអប់រំសំដៅរួមចំណែកអភិវឌ្ឍសមត្ថភាពបុគ្គល និងស្ថាប័នប្រកបដោយឧត្តមភាព។ ក្នុងន័យនេះ ភាពរីកចម្រើនរបស់ប្រទេសជាតិត្រូវពឹងផ្អែកលើការអប់រំប្រកបដោយគុណភាពដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ និងការប្រកួតប្រជែងស្វែងរកឧត្តមភាពនៅលើពិភពលោកក្នុងបរិបទសាកលភាវូបនីយកម្ម ដោយត្រូវទាមទារឱ្យប្រទេសនីមួយៗ ខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឱ្យបានជាអតិបរិមា។ ការប្រើប្រាស់ធនធានមនុស្សឱ្យអស់លទ្ធភាពមានសារៈសំខាន់ណាស់ដែលជាកម្លាំងចលករមិនអាចខ្វះបានក្នុងការធ្វើឱ្យសម្រេចបំណងប្រាថ្នាខាងលើ និងអាចធ្វើឱ្យអាជីពជីវិតបុគ្គល អង្គភាព សង្គម និងប្រទេសជាតិមានការផ្លាស់ប្តូរ និងរីកចម្រើនប្រកបដោយចីរភាព និងនិរន្តរភាព។ ជាក់ស្តែង ដូចការបង្ហាញពីការប្រើប្រាស់គ្រូ និងការអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀននៅផ្នែកខាងលើ។ បច្ចុប្បន្នតាមការបង្ហាញរបស់ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០២១-២០២២បានបង្ហាញដូចខាងក្រោម៖

| រាជធានី ខេត្ត | កម្រិតវប្បធម៌បុគ្គលិកបង្រៀន | | | | | | កម្រិតវប្បធម៌បុគ្គលិកមិនបង្រៀន | | | | | | បុគ្គលិកបង្រៀនដែលមិនបានទទួលការបណ្តុះបណ្តាលគរុកោសល្យ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បឋមសិក្សា | ម.បឋមភូមិ | ម.ទុតិយភូមិ | បរិញ្ញាបត្រ | អនុបណ្ឌិត | បណ្ឌិត | បឋមសិក្សា | ម.បឋមភូមិ | ម.ទុតិយភូមិ | បរិញ្ញាបត្រ | អនុបណ្ឌិត | បណ្ឌិត | បឋមសិក្សា | ម.បឋមភូមិ | ម.ទុតិយភូមិ | បរិញ្ញាបត្រ | អនុបណ្ឌិត | បណ្ឌិត |
| បន្ទាយមានជ័យ | 106 | 797 | 2 217 | 1 553 | 93 | 0 | 39 | 180 | 357 | 310 | 52 | 0 | 3 | 9 | 32 | 43 | 1 | 0 |
| បាត់ដំបង | 249 | 913 | 2 704 | 2 942 | 271 | 20 | 56 | 242 | 573 | 726 | 152 | 9 | 18 | 26 | 31 | 22 | 3 | 0 |
| កំពង់ចាម | 175 | 1 385 | 2 441 | 1 728 | 107 | 4 | 81 | 506 | 701 | 423 | 67 | 1 | 4 | 23 | 15 | 25 | 9 | 0 |
| កំពង់ឆ្នាំង | 54 | 467 | 1 581 | 1 419 | 64 | 1 | 10 | 125 | 274 | 287 | 44 | 0 | 0 | 1 | 27 | 32 | 0 | 0 |
| កំពង់ស្ពឺ | 100 | 846 | 1 772 | 1 494 | 95 | 1 | 32 | 181 | 287 | 311 | 60 | 0 | 0 | 12 | 18 | 54 | 5 | 3 |
| កំពង់ធំ | 129 | 670 | 1 996 | 1 546 | 122 | 0 | 29 | 136 | 285 | 335 | 43 | 0 | 0 | 2 | 13 | 29 | 3 | 0 |
| កំពត | 83 | 799 | 2 303 | 1 482 | 73 | 0 | 30 | 161 | 448 | 309 | 50 | 0 | 1 | 3 | 17 | 20 | 3 | 0 |
| កណ្តាល | 274 | 1 343 | 2 870 | 2 611 | 201 | 0 | 52 | 318 | 488 | 548 | 107 | 3 | 1 | 5 | 10 | 22 | 2 | 0 |
| កែប | 0 | 23 | 266 | 177 | 10 | 0 | 1 | 5 | 43 | 45 | 3 | 0 | 0 | 0 | 1 | 0 | 0 | 0 |
| កោះកុង | 13 | 186 | 783 | 215 | 2 | 0 | 0 | 41 | 96 | 42 | 7 | 0 | 0 | 3 | 17 | 10 | 0 | 0 |
| ក្រចេះ | 36 | 625 | 1 635 | 376 | 24 | 0 | 9 | 119 | 203 | 60 | 13 | 0 | 2 | 1 | 38 | 24 | 3 | 0 |
| មណ្ឌលគិរី | 59 | 210 | 577 | 87 | 4 | 0 | 11 | 9 | 27 | 16 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ឧត្តរមានជ័យ | 111 | 340 | 903 | 276 | 11 | 0 | 30 | 73 | 187 | 53 | 6 | 0 | 5 | 7 | 7 | 7 | 4 | 0 |
| ប៉ៃលិន | 12 | 75 | 366 | 210 | 6 | 0 | 1 | 7 | 44 | 39 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ភ្នំពេញ | 345 | 1 254 | 3 330 | 3 742 | 563 | 8 | 53 | 173 | 349 | 433 | 159 | 3 | 11 | 7 | 18 | 13 | 1 | 0 |
| ព្រះសីហនុ | 44 | 179 | 948 | 449 | 38 | 0 | 4 | 21 | 147 | 89 | 11 | 0 | 0 | 1 | 0 | 3 | 0 | 0 |
| ព្រះវិហារ | 96 | 312 | 1 353 | 384 | 33 | 0 | 41 | 88 | 136 | 73 | 11 | 1 | 0 | 1 | 3 | 2 | 0 | 0 |
| ព្រៃវែង | 252 | 1 338 | 2 028 | 2 138 | 96 | 1 | 91 | 513 | 597 | 649 | 75 | 2 | 1 | 6 | 24 | 24 | 2 | 0 |
| ពោធិ៍សាត់ | 62 | 632 | 1 608 | 782 | 55 | 1 | 15 | 206 | 323 | 150 | 41 | 0 | 0 | 3 | 4 | 2 | 0 | 0 |
| រតនគិរី | 69 | 320 | 774 | 259 | 8 | 0 | 16 | 32 | 51 | 38 | 5 | 0 | 1 | 2 | 16 | 6 | 0 | 0 |
| សៀមរាប | 180 | 737 | 3 136 | 1 736 | 153 | 1 | 69 | 255 | 904 | 445 | 84 | 1 | 2 | 9 | 24 | 62 | 14 | 0 |
| ស្ទឹងត្រែង | 62 | 276 | 901 | 173 | 4 | 0 | 11 | 47 | 96 | 35 | 5 | 0 | 0 | 10 | 34 | 5 | 0 | 0 |
| ស្វាយរៀង | 54 | 479 | 1 865 | 1 290 | 59 | 0 | 28 | 157 | 484 | 283 | 19 | 0 | 3 | 4 | 22 | 30 | 0 | 0 |
| តាកែវ | 122 | 802 | 3 039 | 2 392 | 130 | 1 | 32 | 270 | 863 | 555 | 51 | 0 | 3 | 2 | 27 | 21 | 6 | 0 |
| ត្បូងឃ្មុំ | 109 | 586 | 2 039 | 1 107 | 64 | 0 | 42 | 181 | 417 | 231 | 43 | 0 | 2 | 37 | 56 | 48 | 0 | 0 |
| ទូទាំងប្រទេស | 2 796 | 15 594 | 43 435 | 30 568 | 2 286 | 38 | 783 | 4 046 | 8 380 | 6 485 | 1 117 | 20 | 57 | 174 | 454 | 504 | 56 | 3 |
| - តំបន់ទីប្រជុំជន | 631 | 3 098 | 9 077 | 8 698 | 1 108 | 15 | 145 | 598 | 1 362 | 1 301 | 362 | 9 | 16 | 19 | 44 | 27 | 5 | 0 |
| - តំបន់ជនបទ | 2 165 | 12 496 | 34 358 | 21 870 | 1 178 | 23 | 638 | 3 448 | 7 018 | 5 184 | 755 | 11 | 41 | 155 | 410 | 477 | 51 | 3 |

(រូបភាពទី១៖ កម្រិតវប្បធម៌បុគ្គលិកអប់រំ អយក, ២០២២)

| រាជធានី ខេត្ត | ចំនួនសាលារៀនដែលមាន | | | | | | | | | | គ្រូមកពី | គ្រូជាប់កិច្ច |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លេខាធិការ | បណ្ណារក្ស | គេហ-បច្ចេក | សិល្បៈ | កសិកម្ម | កីឡា | បច្ចេកវិទ្យា ICT | គណនេយ្យ | បន្ទប់ពិសោធន៍ | យុវជន | សាលាផ្សេង | សន្យា |
| បន្ទាយមានជ័យ | 165 | 224 | 98 | 43 | 113 | 20 | 38 | 48 | 28 | 855 | 17 | 0 |
| បាត់ដំបង | 415 | 352 | 145 | 65 | 331 | 28 | 91 | 157 | 95 | 1 854 | 33 | 0 |
| កំពង់ចាម | 333 | 376 | 119 | 53 | 175 | 55 | 69 | 73 | 57 | 1 378 | 9 | 0 |
| កំពង់ឆ្នាំង | 110 | 146 | 86 | 51 | 127 | 13 | 96 | 87 | 62 | 796 | 11 | 0 |
| កំពង់ស្ពឺ | 183 | 245 | 205 | 79 | 343 | 12 | 190 | 88 | 147 | 1 594 | 0 | 0 |
| កំពង់ធំ | 124 | 226 | 93 | 27 | 122 | 20 | 44 | 39 | 37 | 826 | 2 | 0 |
| កំពត | 235 | 211 | 189 | 36 | 157 | 12 | 79 | 141 | 121 | 1 215 | 9 | 0 |
| កណ្តាល | 293 | 379 | 169 | 71 | 134 | 67 | 100 | 96 | 15 | 1 387 | 41 | 0 |
| កែប | 25 | 22 | 15 | 7 | 17 | 6 | 4 | 10 | 7 | 113 | 0 | 0 |
| កោះកុង | 66 | 55 | 28 | 24 | 53 | 5 | 24 | 20 | 29 | 314 | 3 | 0 |
| ក្រចេះ | 86 | 94 | 63 | 56 | 115 | 19 | 51 | 33 | 35 | 616 | 0 | 0 |
| មណ្ឌលគិរី | 15 | 14 | 19 | 10 | 29 | 4 | 11 | 14 | 36 | 181 | 1 | 0 |
| ឧត្តរមានជ័យ | 124 | 57 | 43 | 23 | 74 | 6 | 25 | 14 | 50 | 456 | 3 | 0 |
| ប៉ៃលិន | 17 | 20 | 17 | 7 | 16 | 8 | 9 | 5 | 6 | 113 | 0 | 0 |
| ភ្នំពេញ | 167 | 202 | 219 | 85 | 150 | 62 | 117 | 241 | 70 | 1 324 | 8 | 3 |
| ព្រះសីហនុ | 71 | 61 | 29 | 51 | 40 | 8 | 35 | 11 | 30 | 335 | 3 | 1 |
| ព្រះវិហារ | 122 | 65 | 68 | 39 | 171 | 13 | 25 | 42 | 46 | 646 | 17 | 0 |
| ព្រៃវែង | 497 | 362 | 198 | 96 | 295 | 43 | 130 | 133 | 167 | 2 035 | 18 | 0 |
| ពោធិ៍សាត់ | 106 | 117 | 97 | 37 | 194 | 6 | 79 | 58 | 73 | 806 | 17 | 0 |
| រតនគិរី | 34 | 40 | 26 | 14 | 33 | 11 | 18 | 16 | 13 | 269 | 34 | 0 |
| សៀមរាប | 307 | 392 | 131 | 59 | 193 | 16 | 75 | 119 | 88 | 1 552 | 66 | 1 |
| ស្ទឹងត្រែង | 87 | 33 | 45 | 19 | 78 | 10 | 22 | 34 | 50 | 381 | 2 | 0 |
| ស្វាយរៀង | 178 | 182 | 89 | 63 | 161 | 27 | 67 | 86 | 55 | 1 002 | 15 | 0 |
| តាកែវ | 332 | 322 | 232 | 53 | 212 | 63 | 98 | 103 | 121 | 1 675 | 2 | 0 |
| ត្បូងឃ្មុំ | 206 | 201 | 92 | 44 | 189 | 25 | 61 | 60 | 82 | 1 016 | 2 | 1 |
| ទូទាំងប្រទេស | 4 298 | 4 398 | 2 515 | 1 112 | 3 522 | 559 | 1 558 | 1 728 | 1 520 | 22 739 | 313 | 6 |
| - តំបន់ទីប្រជុំជន | 637 | 756 | 550 | 268 | 522 | 210 | 380 | 486 | 289 | 4 498 | 35 | 3 |
| - តំបន់ជនបទ | 3 661 | 3 642 | 1 965 | 844 | 3 000 | 349 | 1 178 | 1 242 | 1 231 | 18 241 | 278 | 3 |

(រូបភាពទី២៖ បុគ្គលិកក្នុងសាលារៀនដែលមានមុខងារដោយឡែក អយក, ២០២២)

| រាជធានី ខេត្ត | កម្រិតវប្បធម៌សម្រាប់មត្តេយ្យសិក្សា | | | | | | កម្រិតវប្បធម៌សម្រាប់បឋមសិក្សា | | | | | | កម្រិតវប្បធម៌សម្រាប់មធ្យមសិក្សា | | | | | | គ្មាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បឋមសិក្សា | ម.បឋមភូមិ | ម.ទុតិយភូមិ | បរិញ្ញាបត្រ | អនុបណ្ឌិត | បណ្ឌិត | បឋមសិក្សា | ម.បឋមភូមិ | ម.ទុតិយភូមិ | បរិញ្ញាបត្រ | អនុបណ្ឌិត | បណ្ឌិត | បឋមសិក្សា | ម.បឋមភូមិ | ម.ទុតិយភូមិ | បរិញ្ញាបត្រ | អនុបណ្ឌិត | បណ្ឌិត | គរុកោសល្យ |
| បន្ទាយមានជ័យ | 0 | 22 | 54 | 15 | 0 | 0 | 63 | 639 | 1 531 | 558 | 24 | 0 | 43 | 136 | 632 | 980 | 69 | 0 | 87 |
| បាត់ដំបង | 17 | 108 | 276 | 190 | 13 | 2 | 109 | 591 | 1 635 | 1 290 | 94 | 4 | 123 | 214 | 793 | 1 462 | 164 | 14 | 97 |
| កំពង់ចាម | 20 | 90 | 163 | 60 | 2 | 0 | 92 | 768 | 1 189 | 480 | 12 | 4 | 63 | 527 | 1 089 | 1 188 | 93 | 0 | 67 |
| កំពង់ឆ្នាំង | 4 | 59 | 89 | 22 | 1 | 0 | 49 | 255 | 999 | 461 | 12 | 0 | 1 | 153 | 493 | 936 | 51 | 1 | 60 |
| កំពង់ស្ពឺ | 9 | 73 | 122 | 30 | 1 | 0 | 52 | 515 | 1 121 | 416 | 20 | 0 | 39 | 258 | 529 | 1 048 | 74 | 1 | 87 |
| កំពង់ធំ | 13 | 49 | 178 | 34 | 0 | 0 | 94 | 434 | 1 261 | 614 | 22 | 0 | 22 | 187 | 557 | 898 | 100 | 0 | 44 |
| កំពត | 12 | 57 | 175 | 22 | 0 | 0 | 39 | 400 | 1 275 | 510 | 8 | 0 | 32 | 342 | 853 | 950 | 65 | 0 | 41 |
| កណ្តាល | 26 | 186 | 231 | 63 | 1 | 0 | 69 | 702 | 1 246 | 387 | 21 | 0 | 179 | 455 | 1 393 | 2 161 | 179 | 0 | 38 |
| កែប | 0 | 7 | 28 | 3 | 0 | 0 | 0 | 10 | 130 | 58 | 1 | 0 | 0 | 6 | 108 | 116 | 9 | 0 | 1 |
| កោះកុង | 4 | 11 | 49 | 3 | 0 | 0 | 9 | 101 | 519 | 38 | 0 | 0 | 0 | 74 | 215 | 174 | 2 | 0 | 30 |
| ក្រចេះ | 6 | 52 | 92 | 3 | 0 | 0 | 29 | 404 | 1 042 | 67 | 3 | 0 | 1 | 169 | 501 | 306 | 21 | 0 | 65 |
| មណ្ឌលគិរី | 3 | 4 | 35 | 0 | 0 | 0 | 56 | 187 | 381 | 6 | 1 | 0 | 0 | 19 | 161 | 81 | 3 | 0 | 0 |
| ឧត្តរមានជ័យ | 13 | 13 | 81 | 1 | 0 | 0 | 90 | 247 | 592 | 55 | 3 | 0 | 8 | 80 | 230 | 220 | 8 | 0 | 26 |
| ប៉ៃលិន | 1 | 4 | 28 | 3 | 0 | 0 | 11 | 70 | 153 | 60 | 5 | 0 | 0 | 1 | 185 | 147 | 1 | 0 | 0 |
| ភ្នំពេញ | 22 | 114 | 114 | 35 | 6 | 1 | 153 | 649 | 1 669 | 666 | 70 | 0 | 170 | 491 | 1 547 | 3 041 | 487 | 7 | 49 |
| ព្រះសីហនុ | 5 | 28 | 49 | 7 | 0 | 0 | 25 | 143 | 511 | 142 | 7 | 0 | 14 | 8 | 388 | 300 | 31 | 0 | 4 |
| ព្រះវិហារ | 12 | 29 | 55 | 4 | 0 | 0 | 79 | 230 | 881 | 77 | 2 | 0 | 5 | 53 | 417 | 303 | 31 | 0 | 6 |
| ព្រៃវែង | 35 | 133 | 188 | 113 | 2 | 0 | 144 | 794 | 1 020 | 797 | 12 | 0 | 73 | 411 | 820 | 1 228 | 82 | 1 | 55 |
| ពោធិ៍សាត់ | 10 | 54 | 124 | 10 | 1 | 0 | 48 | 341 | 896 | 192 | 5 | 1 | 4 | 237 | 588 | 580 | 49 | 0 | 9 |
| រតនគិរី | 6 | 29 | 46 | 3 | 0 | 0 | 62 | 259 | 500 | 36 | 1 | 0 | 1 | 32 | 228 | 220 | 7 | 0 | 25 |
| សៀមរាប | 12 | 81 | 354 | 38 | 0 | 0 | 134 | 438 | 2 007 | 392 | 28 | 0 | 34 | 218 | 775 | 1 306 | 125 | 1 | 97 |
| ស្ទឹងត្រែង | 10 | 9 | 38 | 1 | 0 | 0 | 50 | 199 | 551 | 34 | 1 | 0 | 2 | 68 | 312 | 138 | 3 | 0 | 49 |
| ស្វាយរៀង | 16 | 68 | 119 | 38 | 0 | 0 | 12 | 227 | 1 065 | 314 | 1 | 0 | 26 | 184 | 681 | 938 | 58 | 0 | 59 |
| តាកែវ | 20 | 106 | 239 | 60 | 0 | 0 | 62 | 454 | 1 556 | 696 | 9 | 0 | 40 | 242 | 1 244 | 1 636 | 121 | 1 | 53 |
| ត្បូងឃ្មុំ | 8 | 56 | 147 | 37 | 1 | 0 | 82 | 360 | 1 198 | 454 | 12 | 0 | 19 | 170 | 694 | 616 | 51 | 0 | 143 |
| ទូទាំងប្រទេស | 284 | 1 442 | 3 074 | 795 | 28 | 3 | 1 613 | 9 417 | 24 928 | 8 800 | 374 | 9 | 899 | 4 735 | 15 433 | 20 973 | 1 884 | 26 | 1 192 |
| - តំបន់ទីប្រជុំជន | 44 | 286 | 535 | 147 | 10 | 1 | 345 | 1 663 | 4 710 | 1 971 | 159 | 2 | 242 | 1 149 | 3 832 | 6 580 | 939 | 12 | 106 |
| - តំបន់ជនបទ | 240 | 1 156 | 2 539 | 648 | 18 | 2 | 1 268 | 7 754 | 20 218 | 6 829 | 215 | 7 | 657 | 3 586 | 11 601 | 14 393 | 945 | 14 | 1 086 |

(រូបភាពទី៣៖ កម្រិតវប្បធម៌បុគ្គលិកបង្រៀនតាមភូមិសិក្សា អយក, ២០២២)

ការពង្រឹងគុណវុឌ្ឍិគ្រូបង្រៀន មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់គឺជាការឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយប្រទេសកម្ពុជា ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការធានាសម្រេចចក្ខុវិស័យនេះ ទាមទារឱ្យមានកម្លាំងពលកម្មប្រកបដោយគុណសម្បទាកម្រិតខ្ពស់រួមមាន៖ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលបំពេញនូវតម្រូវការទីផ្សារការងារក្នុងសតវត្សទី ២១នេះ(អយក,២០១៩)[6]។ គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ជាតួអង្គដ៏មានសក្តានុពល និងអានុភាពក្នុងការបណ្តុះបណ្តាលធនធានមនុស្សដែលជាកម្លាំងពលកម្មសកម្ម និងមានផលិតភាពសេដ្ឋកិច្ចខ្ពស់សម្រាប់ធានាកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ ជាក់ស្តែង គោលនយោបាយដែលបានរៀបរាប់ខាងលើ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍគ្រូបង្រៀន លើកកម្ពស់គុណភាពអប់រំ និងគុណតម្លៃគ្រូបង្រៀននឹងអាចអនុវត្តនូវកម្មវិធីពន្លឿនឆ្ពោះទៅបរិញ្ញាបត្រដល់គ្រូបង្រៀន(១២បូក២) និងប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ និងខេត្តបាត់ដំបងឱ្យទៅជាវិទ្យាស្ថានគរុកោសល្យ សម្រាប់ផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រស្របតាមស្តង់ដាអន្តរជាតិ។ ដូចនេះ ជោគជ័យ នៃការធានាឱ្យមានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាពត្រូវផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍវិជ្ជាជីវៈ អាជីព និងការលើកទឹកចិត្តដល់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំមានការសប្បាយចិត្តជាមួយនឹងអាជីព និងក្តីសង្ឃឹមក្នុងការបម្រើការងារក្នុងវិស័យអប់រំ ព្រោះដើមចមនៃគុណភាពអប់រំត្រូវតែផ្តើមចេញពីគ្រូបង្រៀនល្អ នាយកល្អ អ្នកឯកទេសអប់រំពូកែៗ និងសហគមន៍ល្អ។

## គ. កំណែទម្រង់វិស័យអប់រំនៅកម្ពុជា

វិស័យអប់រំនៅប្រទេសកម្ពុជាមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ដែលឆ្លុះបញ្ចាំងពីការប្រឹងប្រែងកសាងប្រព័ន្ធអប់រំមួយឡើងវិញ បន្ទាប់ពីត្រូវបំផ្លាញខ្ទេចខ្ទីក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីការចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ ប្រទេសកម្ពុជាឈានទៅរកការបោះឆ្នោត និងដំណើរការកសាងសន្តិភាព។ តាមរយៈកិច្ចព្រមព្រៀងនេះផ្តល់ឱកាសដល់ប្រទេសកម្ពុជាទទួលបានការជួយជ្រោមជ្រែងពីសំណាក់ភ្នាក់ងារអភិវឌ្ឍអន្តរជាតិជាច្រើនដូចជា៖ ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក អង្គការអន្តរជាតិ កម្មវិធីសហប្រតិបត្តិការទ្វេភាគីរួមទាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត។ នៅឆ្នាំ ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តដាក់បញ្ចូលមាត្រាមួយចំនួនទាក់ទងនឹងការអប់រំ។ មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញចែងថា"រដ្ឋផ្តល់ការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ"។ មិនតែប៉ុណ្ណោះ កម្ពុជាក៏ជាប្រទេសហត្ថលេខីលើលិខិតូបករណ៍អន្តរជាតិដែលទទួលស្គាល់សិទ្ធិស្តីពីការអប់រំផងដែរដូចជា៖ ១. សេចក្តីប្រកាសជាសកលឆ្នាំ ១៩៤៨ស្តីពីសិទ្ធិមនុស្ស ២. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ៣. អនុសញ្ញាស្តីពីសិទ្ធិកុមារ ៤. អនុសញ្ញាស្តី

[6] គោលនយោបាយជាតិ ស្តីពីការអប់រំពេញមួយជីវិត ទំព័រ ១

ពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំង នឹងនារីភេទ(CEDAW)។ នៅឆ្នាំ ១៩៩៦ ក្រសួងអប់រំ យុវជន និងកីឡាបានចេញនូវគោលនយោបាយដោយផ្តោតលើ៖ ១. ធ្វើសាកលកម្មនូវការអប់រំមូលដ្ឋាន ចំនួនប្រាំបួនឆ្នាំ និងបង្កើតឱកាសសម្រាប់មុខងារអក្ខរកម្ម(Functional Literacy) ២. ធ្វើទំនើបកម្ម និង កែលម្អគុណភាពអប់រំតាមរយៈកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព ៣. ផ្សារភ្ជាប់ការអប់រំ/ការ បណ្តុះប ណ្តាលជាមួយទីផ្សារការងារ និងសង្គម និង៤. ស្តារ និងអភិវឌ្ឍវិស័យយុវជន និងកីឡា។ អ្វីដែលជាការ ផ្លាស់ប្តូរចម្បងចាប់តាំងពីឆ្នាំ ១៩៩៦ មកគឺ ប្រព័ន្ធអប់រំ ១២ឆ្នាំ (៦ ៣ ៣) ត្រូវបានដាក់ឱ្យអនុវត្តនៅ ប្រទេសកម្ពុជាដើម្បីគោរពតាមស្តង់ដាអន្តរជាតិ។

- **គោលនយោបាយអប់រំ ការអប់រំសម្រាប់ទាំងអស់គ្នា (២០០៣-២០១៥)**

ដោយសារការអនុវត្តដោយជោគជ័យនូវនយោបាយ "**ឈ្នះ-ឈ្នះ**" របស់រាជរដ្ឋាភិបាលកម្ពុជា អង្គ ការចាត់តាំងខ្មែរក្រហមត្រូវបានរំលាយទាំងស្រុងនៅឆ្នាំ ១៩៩៨ ដោយនាំមកនូវសុខសន្តិភាពពេញផ្ទៃ ប្រទេស និងការផ្លាស់ប្តូរទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច។ នៅឆ្នាំ ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួម ក្នុងសេចក្តីថ្លែងការទីក្រុងដាកកាដោយគាំទ្រដល់ការអនុវត្តគោលដៅនៃការអប់រំទាំងអស់គ្នា(Education For All-EFA)។ ការអប់រំសម្រាប់ទាំងអស់គ្នា គឺជាត្រីវិស័យមួយសម្រាប់តម្រង់ទិសគោលនយោបាយ និង ជាវេទិកាមួយសម្រាប់ប្រមូលផ្តុំរាល់សកម្មភាពអប់រំទាំងអស់ឱ្យស្ថិតនៅក្រោមដំបូលតែមួយ។ ក្នុងឆ្នាំ ២០០០ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តបង្កើនការវិនិយោគលើវិស័យអប់រំឱ្យស្របនឹងចរន្តពិភពលោកស្តីពី ការអប់រំសម្រាប់ទាំងអស់គ្នា និងឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ខ្លួន។ គោលនយោបាយនេះបានដាក់ ចេញនូវផែនការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០០៣-២០១៥ ផ្តល់នូវក្របខណ្ឌការងារយ៉ាងទូលំទូលាយ ដើម្បីសម្រេចឱ្យបាននូវគោលដៅអប់រំដោយធានាថាកុមារ និងយុវវ័យកម្ពុជាទាំងអស់មានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំត្រឹមឆ្នាំ ២០១៥។ ផែនការអប់រំសម្រាប់ទាំងអស់គ្នានេះរួមបញ្ចូលទាំងផែនការ បច្ចេកទេស និងហិរញ្ញវត្ថុយ៉ាងទូលំទូលាយដោយផ្តោតលើ៖ ១.យុទ្ធសាស្ត្រឆ្លើយតបយេនឌ័រ ២. ការថែទាំ និងការអភិវឌ្ឍកុមារតូចៗ ៣. ការអប់រំមូលដ្ឋានជាផ្លូវការ ៤. ការអប់រំក្រៅប្រព័ន្ធ និងអក្ខរកម្មមនុស្សពេញ វ័យ។ ផែនការនេះសង្កត់ធ្ងន់លើការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពសេវាអប់រំ និងការ ពង្រីកលទ្ធភាពទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ពិសេសប្រជាពលរដ្ឋដែលងាយរងគ្រោះ ក្រុម ទទួលបានផលប្រយោជន៍សង្គមតិចតួច(Disadvantaged Group)និង នៅតំបន់ជនបទដាច់ស្រយាល។ អាទិភាពដែលបានកំណត់ក្នុងវិស័យអប់រំបានអនុវត្តជាបណ្តើរៗ ដោយការព្យាយាមលុបបំបាត់វិសមភាព យេនឌ័ររវាងតំបន់ជនបទ និងតំបន់ទីក្រុងនៅក្នុងការអប់រំមូលដ្ឋាន និងកម្រិតមធ្យមសិក្សាទុតិយភូមិ (អយក, ២០១៥) [7]។

- **គោលនយោបាយអប់រំស្តីពី ការសិក្សាពេញមួយជីវិត(២០១៩)**

[7] គោលនយោបាយ ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា

បន្ទាប់ពីបានអនុវត្តគោលនយោបាយ **ការអប់រំសម្រាប់ទាំងអស់គ្នា** ការសិក្សានៅក្នុងសាលារៀនមានកំណើនសិស្សចូលរៀនច្រើន នៅក្នុងកម្រិតបឋមសិក្សាដោយគោលនយោបាយនេះបានអនុវត្តទៅតាមច្បាប់រដ្ឋធម្មនុញ្ញ សិទ្ធិទទួលបានការអប់រំសម្រាប់ពលរដ្ឋគ្រប់រូបដោយមិនមានការបង់ថ្លៃ។ ប៉ុន្តែ គុណភាពអប់រំមិនទាន់ឆ្លើយតបនឹងការវិវត្តរបស់ពិភពលោកឡើយ ហើយគោលនយោបាយនេះត្រូវបានពិនិត្យឡើងវិញនៅឆ្នាំ ២០០០ នៅទីក្រុងដាកា ប្រទេសសេណេហ្គាល់ ស្របពេលដែលប្រទេសជឿនលឿន បានផ្តោតលើការអប់រំជនពេញវ័យអំពីជំនាញវិជ្ជាជីវៈដើម្បីលើកកម្ពស់ជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង(អយក, ២០១៩)[8]។ ការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំសកលលោក ហើយត្រូវបានក្លាយជាសមាសភាគសំខាន់ក្នុងគោលដៅទី៤ នៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ នៅអ៊ីនឈាន់ សាធារណរដ្ឋកូរេពោលគឺ "**ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**"។ វាជាកាលានុវត្តភាពដ៏ប្រសើរនៃការអនុវត្តគោលនយោបាយនេះ តាមរយៈខ្លឹមសារនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា ៦៥ ដែលបានចែងថាៈ " រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប" និងមាត្រា ៦៦ "រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត"។

អាស្រ័យហេតុនេះ ដើម្បីឆ្លើយតបទៅនឹង គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិរបស់រាជរដ្ឋាភិបាលមានតែការបណ្តុះបណ្តាលធនធានមនុស្សដ៏មានសក្តានុពលសម្រាប់ទីផ្សារការងារទេ ទើបជាកត្តាចម្បង ហើយទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងដៃគូអភិវឌ្ឍន៍វិស័យអប់រំជាតិ និងអន្តរជាតិតាមរយៈការជួយឧបត្ថម្ភគាំទ្រថវិកា បច្ចេកទេស សម្ភារៈដើម្បីគោលនយោបាយនេះដំណើរការបានតាំងពីថ្នាក់កណ្តាលដល់ថ្នាក់មូលដ្ឋាន។ ការអប់រំសម្រាប់ទាំងអស់គ្នា នឹងនាំមកនូវសង្គមមួយពោរពេញដោយអ្នកចេះដឹង មានពលរដ្ឋប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណតម្លៃពេញបរិបូរណ៍ដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ច និងអភិវឌ្ឍភាពសុខដុមជីវិតបុគ្គល និងសង្គមតាមរយៈការផ្តល់ឱកាសសិក្សាពេញមួយជីវិត គ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយ។

- **គោលនយោបាយអប់រំ (២០១៨-២០២៣)**

បន្ទាប់ពីបានអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៤-២០១៨ លើគោលនយោបាយអប់រំទាំងបីគឺៈ ១. ធានាលទ្ធភាពទទួលបានសេវាកម្មអប់រំប្រកបដោយសមធម៌ ២. លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ ៣. អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ អស់រយៈពេល ៥ឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍បានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់

[8] គោលនយោបាយស្តីពីការអប់រំពេញមួយជីវិត ២០១៩

តាមរយៈការអនុវត្តវិធានការកំណែទម្រង់ ៨ចំណុចនៅឆ្នាំ ២០១៤ និងវឌ្ឍនភាពនៃកំណែទម្រង់ ១៥ ចំណុច ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ សម្រេចបាននូវលទ្ធផលគួរជាទីគាប់ចិត្តដោយ សិស្សបានខិតខំរៀនសូត្រជាងមុន និងគ្រូបង្រៀនខិតខំបំពេញការងារល្អប្រសើរជាងមុនផងដែរ(អយក, ២០១៨)[9]។ គោលដៅអប់រំជាតិគឺកសាងមនុស្សពេញលេញ ដែលមានការរីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នាប្រកបដោយតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបកាយពោលគឺៈ ពលរដ្ឋដែលមានលក្ខណៈថ្លៃថ្នូរ មនសិការស្នេហាជាតិ ស្រឡាញ់យុត្តិធម៌ គោរពច្បាប់ និងសិទ្ធិមនុស្ស ចេះថែរក្សាការពារបរិស្ថាន ចេះផ្សព្វផ្សាយ និងលើកកម្ពស់តម្លៃវប្បធម៌ អរិយធម៌ជាតិ មានភាពម្ចាស់ការ មានទំនុកចិត្តលើខ្លួនឯង ចេះដោះស្រាយបញ្ហាក្នុងជីវភាព ចេះច្នៃប្រឌិត ចេះធ្វើពលិកម្ម មានស្មារតីទទួលខុសត្រូវខ្ពស់ មានសមត្ថភាពកសាងសុខុមាលភាពគ្រួសារ ហើយអាចចូលរួមយ៉ាងសកម្មក្នុងការបង្រួបបង្រួមជាតិ ស្តារ និងអភិវឌ្ឍជាតិមាតុភូមិជាទីស្នេហាដោយផ្អែកលើស្មារតីប្រជាធិបតេយ្យសេរី ពហុបក្ស។ ដូច្នេះ ដើម្បីសម្រេចបាននូវសមិទ្ធិផលនេះ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍប្រកបដោយចីរភាពស្តីពីការអប់រំឆ្នាំ ២០៣០ ដោយដាក់ចេញនូវគោលនយោបាយពីរជាចម្បងគឺៈ ១). ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង ២). ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវយុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំដូចខាងក្រោមៈ

១. កំណែទម្រង់ការគ្រប់គ្រងការសិក្សាផ្តោតលើវង្វាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ ការកែលម្អវិធីសាស្រ្តបង្រៀន និងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល

២. កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល ផ្តោតលើការធានាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងការអនុវត្តគោលនយោបាយអប់រំ ព្រមទាំងផែនការយុទ្ធសាស្រ្តវិស័យអប់រំផងដែរ

៣. កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ផ្តោតលើការបង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ការធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ និងការបង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ

៤. កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ផ្តោតលើការបណ្តុះបណ្តាលជាសំខាន់លើវិធីសាស្រ្តបង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង ការបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។

---

[9] ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ ២០១៨-២០២៣

ជាសេចក្តីសន្និដ្ឋានសម្រាប់គំនិតផ្តួចផ្តើមចំពោះការសិក្សាពីប្រធានបទៈ "តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ" ពិតជាសំខាន់ព្រោះប្រធានបទនេះ នឹងត្រូវសិក្សាស្វែងយល់ពីការបំពេញតួនាទីរបស់សហគមន៍ និងកាតព្វកិច្ចរបស់គណៈនាយក គ្រូបង្រៀន សិស្ស មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស។ កិច្ចការស្រាវជ្រាវនេះក៏នឹងបង្ហាញឱ្យឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងឱកាសនៃការចូលរួមរបស់អ្នកពាក់ព័ន្ធចំពោះការលើកកម្ពស់គុណភាពសិក្សា។ ទន្ទឹមនឹងនេះ ការគ្រប់គ្រងនៅកម្រិតសាលាឱ្យមានប្រសិទ្ធភាព និងសំណូមពរក៏នឹងត្រូវលើកយកមកតាមរយៈសម្រង់ទិន្នន័យរបស់អ្នកផ្តល់ព័ត៌មាននៅតាមសាលារៀន និងសហគមន៍ដើម្បីជាអនុសាសន៍សម្រាប់អភិវឌ្ឍប្រសិទ្ធភាពការងារបង្រៀន និងរៀននាឆ្នាំសិក្សាជាបន្តបន្ទាប់។

## II. ដំណើរការនៃការសរសេរនិក្ខេបបទ

### ១. ទិដ្ឋភាពទូទៅនៃការស្រាវជ្រាវ

ជាទូទៅ គុណតម្លៃនៃការអប់រំត្រូវបានគេយកចិត្តទុកដាក់អភិវឌ្ឍជាសកល និងជាលក្ខណៈតំបន់ផងដែរ គឺដោយសារតែការអប់រំជាអាវុធដ៏មានអានុភាពដើម្បីផ្លាស់ប្តូរពិភពលោក(Nelson, 1918) ក្នុងសតវត្សទី ២១នេះ ប្រទេស ១៦០ បានចូលរួមកំណត់គោលនយោបាយអប់រំស្តីពីការអប់រំប្រកបដោយចីរភាព និងធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសនៃការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (SK/Incheon, 2015)។ ក្នុងបរិបទសមាហរណកម្មអាស៊ានវិស័យអប់រំផ្តោតលើការអភិវឌ្ឍធនធានមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធផ្តល់ការសិក្សាពេញមួយជីវិត វិទ្យាសាស្ត្រ និងបច្ចេកទេសឆ្លើយតបទៅនឹងការប្រកួតប្រជែងទីផ្សារការងារដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រទេសក្នុងសមាគមអាស៊ាន(អ៊ុង, ២០១៧)។ ដោយយល់ឃើញថា ការអប់រំគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ហើយក៏ស្របនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ក្នុងគោលបំណងផ្លាស់ប្តូរប្រទេសទៅជាប្រទេសឧស្សាហកម្មនាឆ្នាំ ២០២៥ និងមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយបន្តទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០(អយក/ផយអ, ២០១៩)។ កាលានុវត្តភាពនៃភាពរីកចម្រើនទាំងនេះ ក៏ព្រោះតែវិស័យអប់រំមានគុណភាព និងឆន្ទៈស្នេហាជាតិរបស់ថ្នាក់ដឹកនាំប្រទេសជាតិ ព្រមទាំងប្រជាពលរដ្ឋផងដែរ។ តាមរយៈការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស ត្រូវពឹងផ្អែកលើការអនុវត្តតួនាទីដោយការទទួលខុសត្រូវរបស់មន្ត្រីអប់រំនៅមូលដ្ឋាន សហគមន៍ មាតាបិតា/អ្នកអាណាព្យាបាលសិស្ស និងអ្នកសិក្សាផ្ទាល់(អយក,២០២២ & ហង់,២០២១ &ផាន់, ២០២១)។ រាជរដ្ឋាភិបាលបានប្រគល់មុខងារ និងធនធានពីក្រសួងទៅឱ្យអាជ្ញាធរមូលដ្ឋានតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (អ

យក, ២០១៦)[10]។ ជាការឆ្លើយតបដ៏ឈ្លាសវៃរបស់ថ្នាក់ដឹកនាំ ក្នុងវិស័យអប់រំទៅលើគោលនយោបាយ ជាសាកលស្តីពីការអប់រំប្រកបដោយចីរភាព និងធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសនៃការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ព្រមទាំងការលើកកម្ពស់ភាពជាអ្នក ដឹកនាំរបស់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NPSDD) ត្រូវបានយកមកធ្វើការគ្រប់គ្រងអប់រំតាមបែបវិមជ្ឈការក្នុងរយៈពេល១០ឆ្នាំ ទាក់ទងនឹងយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តតាមរយៈការផ្ទេរមុខងារ និងធនធានទៅឱ្យថ្នាក់មូលដ្ឋាន (អយក, ២០១៦)[11]។ ការពង្រឹងការចូលរួម ការទទួលខុសត្រូវ ធានាតម្លាភាព និងប្រសិទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈគឺជាគោលបំណងចម្បងក្នុងការបង្កិតសេវាអប់រំជូនដល់ប្រជាជន(អយក, ២០១៦)[12] ។ ជាទស្សនៈនៃសង្គមវិទ្យា បុគ្គលគ្រប់រូបគឺជាកោសិកាក្នុងការបង្កើតសង្គមមួយដែលប្រកបដោយទិសដៅជាក់លាក់ និងស្ថិរភាព។ រីឯ សហគមន៍ ត្រូវតែមានមនោសញ្ចេតនា អចិន្ត្រៃយ៍ភាព ឯករាជ្យភាព ភាពដូចគ្នា និងផលប្រយោជន៍រួម(អេង, ២០០៧)[13]។ អ្នកពាក់ព័ន្ធដែលជាកម្លាំងចលករក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស ១. នាយកល្អ ២. គ្រូល្អ ៣. សិស្សល្អ ៤. មាតាបិតា និងសហគមន៍ល្អ (ហង់, ២០២០)[14]។ ហេតុនេះ ដើម្បីឆ្លើយតបនឹងគោលនយោបាយអប់រំជាតិកម្ពុជាទាំងពីរ តួនាទីភារកិច្ច គណនេយ្យភាព និងស្វ័យភាពរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដី និងមាតាបិតាសិស្សពិតជាមានសក្តានុពលណាស់ ក្នុងការជួយនូវសុខដុមនីយកម្មនៃវិស័យអប់រំនៅកម្ពុជា ។ ក្នុងន័យនេះ ខ្លឹមសារនៃកិច្ចការស្រាវជ្រាវនេះ នឹងបង្ហាញឱ្យឃើញពីសូចនាករនៃកង្វះខាតនៃគុណភាពអប់រំមកពិភាក្សា ស្រាវជ្រាវ និងប្រមូលនូវទ្រឹស្តីនានាដើម្បីដោះស្រាយ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវចំណុចខ្វះខាតនៃលទ្ធផលសិក្សារបស់សិស្ស។

អាស្រ័យហេតុនេះ ការបង្កើតមូលដ្ឋានរឹងមាំសម្រាប់ប្រតិបត្តិកិច្ចការអប់រំត្រូវតែមានការចូលរួមពីសហគមន៍ ហើយសមាជិកនីមួយៗ ក្នុងសហគមន៍ត្រូវតែស្គាល់ពីតួនាទីភារកិច្ចដែលខ្លួនត្រូវបំពេញឱ្យឆ្លើយតបនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំដ៏ច្បាស់លាស់ ប្រសិទ្ធភាពនៃអន្តរកម្មរបស់មន្ត្រីអប់រំ និងភាគីពាក់ព័ន្ធនានានៅតាមមូលដ្ឋានជាពិសេសគឺ សហគមន៍ និងអ្នកអាណាព្យាបាលសិស្សពោល **"ទាំងអស់គ្នាដើម្បីការអប់រំ ការអប់រំដើម្បីទាំងអស់គ្នា"** ដោយមានចែងជាគោលការណ៍គតិយុត្តិ និងសេចក្តីណែនាំដូចជា៖ គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហាវិមជ្ឈការក្នុងវិស័យអប់រំឆ្នាំ ២០១៦ ឯកសារប្រតិបត្តិការរៀបចំផែនការអភិវឌ្ឍសាលារៀន ឆ្នាំ២០១៧ ឯកសារប្រតិបត្តិគណៈកម្មការអភិវឌ្ឍន៍សាលារៀន ឆ្នាំ២០១៧ ឯកសារប្រតិបត្តិការគ្រប់គ្រងថវិកាសាលារៀន ឆ្នាំ២០១៧

[10] គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ, បុព្វកថា

[11] គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ, បុព្វកថា

[12] គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ, បុព្វកថា

[13] សង្គមវិជ្ជា សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ទំព័រ ២២

[14] សន្ទរកថាឯកឧត្តមបណ្ឌិតសភាចារ្យហង់ជួនណារ៉ុន ក្នុងពិធីបើកសន្និបាតបូកសរុបការងារអប់រំ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២២

សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន ឆ្នាំ ២០១៨ សេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន ឆ្នាំ ២០២១ ជាដើម។

### ២. បញ្ហានៃការស្រាវជ្រាវ

ក្នុងទិដ្ឋភាពទូទៅ ដោយសារតែគុណភាពអប់រំនៅកម្ពុជានៅមានកម្រិត ទើបការធ្វើកំណែទម្រង់របស់ក្រសួងអប់រំត្រូវបានរៀបចំឡើង គឺដើម្បីទាមទារឱ្យមានគុណភាពអប់រំប្រកបដោយគុណធម៌ បរិយាបន្ន និងបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយបំណិនសម្បទា វិជ្ជាសម្បទា ចរិយាសម្បទា និងជំនាញបច្ចេកទេសឆ្លើយតបទៅនឹងទីផ្សារការងារនាពេលបច្ចុប្បន្ន។ ក្នុងបរិបទជាសកល ការអនុវត្តវិមជ្ឈការអប់រំ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជាបានយល់ឃើញថា ការរក្សាប្រព័ន្ធគណនេយ្យភាពដោយរក្សាអំណាចសម្រេចចិត្តនៅថ្នាក់កណ្តាលគឺ មិនអាចឆ្លើយតបទៅនឹងតម្រូវសេវាសាធារណៈទាន់ពេលវេលានោះឡើយ។ ដូច្នេះ នៅឆ្នាំ ២០១៧ ក្រសួងបានសម្រេចចិត្តថាត្រូវផ្តល់អំណាចសម្រេចចិត្តទៅសាលារៀន និងសហគមន៍សម្រាប់ដោះស្រាយអាទិភាពដែលជាតម្រូវការនៃការសិក្សារៀនសូត្ររបស់សិស្ស។ ពិសោធន៍ពីអតីតកាលទាក់ទងដល់ការអនុវត្តការសម្រេចចិត្តរបស់សាលារៀន និងសហគមន៍ដើម្បីជួយការសិក្សារបស់សិស្សបានបង្ហាញថាអត្តចរិត និងចរិយាកន្លងមក មិនអាចជួយសាលារៀន និងសហគមន៍បានទេ។ តាមការសង្កេតជារួមបង្ហាញថា អត្រាសិស្សចូលរៀននៅមធ្យមសិក្សាមានចំនួនតិច សមត្ថភាពសិស្សនៅទាប ទាំងការអាន និងគិតលេខ ការបោះបង់ការសិក្សាខ្ពស់ សមត្ថភាពចិញ្ចឹមខ្លួន និងគ្រួសារមិនបានសមរម្យ គ្រូបង្រៀនមួយចំនួនអវត្តមាន ឬមានវត្តមាននៅសាលារៀនតែមិនបានបង្រៀនឱ្យបានពេញលេញ ឬបន្តបង្រៀនតាមវិធីដែលពុំអាចជួយសិស្សឱ្យរៀនចេះ ហើយសិស្សដែលរៀនមិនចេះក៏ឱ្យឡើងថ្នាក់ដែរ(អយក, ២០២១)[15]។ ។ យោងតាមទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោក "ការអប់រំមនុស្សជំនាន់ក្រោយ" បង្ហាញនូវការបែងចែង និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានមានដូចជា៖ ការបែងចែកគ្រូបង្រៀនមិនស្របតាមតម្រូវការជាក់ស្តែងគឺ ផលធៀបគ្រូ/សិស្សនៅមធ្យមសិក្សាក្នុងរាជធានីភ្នំពេញ១/១៤.៨ រីឯនៅខេត្តព្រៃវែងមាន ១/២៩.៩។ ការបំពេញការងាររបស់គ្រូបង្រៀនវិញជាមធ្យម ៤៧.៦% នៃសំណាកគំរូមានកិច្ចតែងការបង្រៀនក្នុងនោះ ៦៦.២% គឺគ្រូបង្រៀននៅតំបន់ប្រជុំជន និងមានតែ៣៤.៧% ប៉ុណ្ណោះសម្រាប់គ្រូបង្រៀននៅតំបន់ជនបទ និងដាច់ស្រយាល។ គ្រូបង្រៀនដែលអវត្តមានញឹកញាប់មានចំនួន ៦% ក្នុងនោះ ៣.៦% នៅតំបន់ប្រជុំជន ៧.៦%នៅតំបន់ជនបទ និង ១០.២% នៅតំបន់ដាច់ស្រយាល ជារួម ទង្វើទាំងនេះបណ្តាលមកពីគណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងគណៈកម្មការអភិវឌ្ឍសាលារៀនមិនយល់ច្បាស់

[15] សេចក្តីណែនាំស្តីពី យុទ្ធសាស្ត្រសហគមន៍សាលារៀន ឆ្នាំ ២០២១, ទំព័រ ២

ពីតួនាទីរបស់ខ្លួន(អយក, ២០១៨)[16]។ យ៉ាងណាមិញ ធនធានមនុស្សខ្វះជំនាញបច្ចេកទេសនាំឱ្យបាត់បង់ឱកាសការងារតំណែងខ្ពស់ មិនអាចប្រកួតប្រជែងជាមួយនឹងធនធានមនុស្សនៅបណ្តាប្រទេសអាស៊ានផ្សេងទៀតបាន (អ៊ុង, ២០១៧)[17] ហើយនៅកម្ពុជាមានការអប់រំមិនទាន់ឆ្លើយតបទៅនឹងតម្រូវការសង្គមនៅឡើយ ព្រោះធនធានមុស្សនៅខ្វះជំនាញបច្ចេកទេស និងសមត្ថភាពវិជ្ជាជីវៈ(ទជមក, ២០១៨)[18]។ លើសពីនេះទៅទៀត អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ នៅទូទាំងប្រទេសមាន ១៦.៩% នៅឆ្នាំ២០១៩ និង ១៨.៥% នៅឆ្នាំ២០២១ ហើយអត្រាសិស្សរៀនត្រួតថ្នាក់មាន ១.៦%នៅឆ្នាំ ២០១៩ និង ១.១% នៅឆ្នាំ ២០២១។ ចំពោះខេត្តព្រះសីហនុវិញ អត្រាសិស្សបោះបង់នៅមធ្យមសិក្សាទុតិយភូមិ ១៥.២% នៅឆ្នាំ ២០១៩ និង ១៣.៤% នៅឆ្នាំ ២០២១ ហើយសាលារៀនដែលគ្មានទឹកស្អាតប្រើប្រាស់មាន ៨១សាលា និងគ្មានបង្គន់មានចំនួន ៥៤សាលារៀន។ តាមរយៈ តិកតាងអត្រាត្រួតថ្នាក់ និងកង្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធជារូបវន្តរបស់សាលារៀននេះអាចឆ្លុះបញ្ចាំងបានថា ការចូលរួមរបស់សហគមន៍នៅមានកម្រិតនៅឡើយ (អយក/សស, ២០១៨-២០២១)។ នៅតារាងទី២៥ នៃស្ថិតិ និងសូចនាករអប់រំឆ្នាំ ២០២១-២០២២ បានបង្ហាញថា នៅខេត្តព្រះសីហនុ គណៈកម្មការទ្រទ្រង់សាលារៀនមាន១៨៤ បានប្រជុំចំនួន ១៣០ដង សមាជិក ៧នាក់ ស្រី ៣នាក់ គ្រូដែលទទួលបានការឧបត្ថម្ភពីសហគមន៍មានពីរនាក់ សាលារៀនដែលមានប្រាក់ចំណូលមាន១៦សាលា សាលាដែលទទួលបានការឧបត្ថម្ភមូលនិធិពីសហ គមន៍មាន៣សាលា និងសាលារៀនដែលមានអង្គការក្រៅរដ្ឋាភិបាល/អង្គការអន្តរជាតិជួយមាន ១សាលា(អយក, ២០២២)[19]។ ទន្ន័ករណ៍ទាំងនេះ ក៏បង្ហាញបានថាភាគីពាក់ព័ន្ធនឹងវិស័យអប់រំបានយកចិត្តទុកដាក់ដល់ការសិក្សារបស់សិស្សផងដែរ ប៉ុន្តែកិច្ចសហការនេះមិនទាន់ឆ្លើយតបបានល្អនៅឡើយនោះទេ ពីព្រោះកំណើននៃការរៀនត្រួតថ្នាក់ និងបរិស្ថានអនាម័យសិក្សានៅមានចំណុចខ្វះខាតជាច្រើនទៀត។ បច្ចុប្បន្ន ភាពក្រីក្រគឺជាធាតុបង្ករឱ្យមានការបោះបង់ការសិក្សា ការរៀនត្រួតថ្នាក់ និងសិស្សរៀនយឺតផងដែរ(UNICEF, 2018)។ យ៉ាងណាមិញ តាមការស្រាវជ្រាវពីការចូលរួមរបស់គណៈកម្មការគ្រប់គ្រងសាលារៀននៅស្រុកព្រៃនប់ ខេត្តព្រះសីហនុបានបង្ហាញថា គណៈកម្មការគ្រប់គ្រងសាលារៀនមិនទាន់យល់ច្បាស់ពីតួនាទីរបស់ខ្លួន ការចូលរួមដោះស្រាយបញ្ហារបស់សាលារៀនមិនទាន់បានល្អ ហើយកត្តាទាំងអស់នេះគឺ បណ្តាលមកពីសហគមន៍មិនសូវចាប់អារម្មណ៍ពីការពង្រឹងគុណភាពអប់រំក៏ដូចជាលទ្ធផលសិក្សារបស់សិស្សផងដែរ(ឡាយ&ម៉ី&លឿង&អ៊ុំ&សេង&ផល, ២០២១)[20]។

[16] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន ទំព័រ ៧

[17] បទបង្ហាញរបស់លោក អ៊ុង សុវណ្ណា ស្តីពីការអប់រំនៅអាស៊ាន ឆ្នាំ ២០១៧

[18] របាយការណ៍របស់ទីភ្នាក់ងារជាតិស្តីពីមុខរបរ និងការងារ ២០១៨

[19] ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំ ២០២១-២០២២

[20] ការសិក្សាលើការចូលរួមរបស់គណៈកម្មការគ្រប់គ្រងសាលានៅបឋមសិក្សា

## ៣. ប្រធានបទស្រាវជ្រាវ

ដោយពឹងផ្អែកលើបញ្ហា និង ទឡ្ហីករណ៍ខាងលើ និក្ខេបបទដែលមានចំណងជើងថា ៖ “**តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស នៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**” នឹងត្រូវលើកយកមកធ្វើការសិក្សាស្រាវជ្រាវដើម្បីបំពេញលក្ខខណ្ឌ ក្នុងការប្រឡងបញ្ចប់វគ្គបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី ៩ នៃវិទ្យាស្ថានជាតិអប់រំ នៅកម្ពុជា។

ឈរលើមូលដ្ឋាននៃការជ្រើសរើសប្រធានបទស្រាវជ្រាវនេះ ការអនុវត្តការងារដឹកនាំ គ្រប់គ្រងសាលារៀនដែលផ្ដោតលើលទ្ធផលសិក្សារបស់សិស្ស នៅកម្រិតមធ្យមសិក្សាត្រូវតែធ្វើឡើងដោយបង្កើនគណនេយ្យភាព និងស្វ័យភាពនៅកម្រិតសាលារៀនក្រោមការចូលរួមសហការពីអ្នកពាក់ព័ន្ធជាពិសេសគឺសហគមន៍នេះឯង។ ការអភិវឌ្ឍសាលារៀនមួយ ប្រកបដោយនិរន្តរភាពទៅបានតម្រូវឱ្យមាន គណៈគ្រប់គ្រងសាលាមានសមត្ថភាពក្នុងការស្វែងរកជំនួយ និងការកៀរគរធនធានផ្សេងៗពីគ្រប់មជ្ឈដ្ឋានក្នុងវិស័យអប់រំ ដោយពង្រឹងលើសិល្បៈនៃទំនាក់ទំនងរបស់ខ្លួនជាមួយនឹងសិស្សានុសិស្ស បុគ្គលិកអប់រំ មាតាបិតា/អ្នកអាណាព្យាបាលសិស្ស គណៈកម្មការទ្រទ្រង់សាលារៀន អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍន៍នានានៅក្នុងមូលដ្ឋានរបស់ខ្លួន។ ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនត្រូវតែអនុវត្តដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ត្រូវធ្វើស្វ័យវាយតម្លៃសាលារៀន ដើម្បីរកឱ្យឃើញពីចំណុចល្អ ចំណុចខ្វះខាត បញ្ហាប្រឈម និងឱកាសក្នុងគោលបំណងលើកកម្ពស់កិច្ចសហការរវាងសហគមន៍ និងមន្ត្រីអប់រំដែលទទួលបន្ទុកក្នុងការបណ្ដុះបណ្ដាលយុវសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ។ ខ្លឹមសារនិក្ខេបបទនេះនឹងឆ្លុះបញ្ចាំងឱ្យឃើញនូវតួនាទីភារកិច្ចរបស់សហគមន៍ ក៏ដូចជាសមាសភាពពាក់ព័ន្ធក្នុងវិស័យអប់រំចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស។ កិច្ចការស្រាវជ្រាវនេះ ក៏ត្រូវលើកយកមកពិភាក្សាវែកញែកស្វែងរកដំណោះស្រាយចម្បងៗលើបញ្ហាប្រឈម ដែលបានរកឃើញដើម្បីរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យក្លាយជាពលរដ្ឋពេញលេញ មានជំនាញបច្ចេកទេសច្បាស់លាស់មានសមត្ថភាពបង្កើនសេដ្ឋកិច្ចគ្រួសារ ហើយឈានទៅជួយលើកកម្ពស់ចំណូលសេដ្ឋកិច្ចប្រទេសជាតិដល់កម្រិតមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រែក្លាយជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ ព្រមទាំងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្នែកសង្គមឌីជីថលផងដែរ។

## ៤. គោលបំណងនៃការស្រាវជ្រាវ

ជាការពិតណាស់ ការអភិវឌ្ឍសាលារៀនគឺជាផ្នែកមួយនៃការពង្រឹងគុណភាពអប់រំ ដូចនេះ ការបង្កើតឱ្យមានគណៈកម្មការគ្រប់គ្រង អភិវឌ្ឍ និងទ្រទ្រង់សាលារៀនគឺជាមូលដ្ឋានគ្រឹះដ៏មានសក្ដានុពលដល់ការប្រមូលផ្ដុំកម្លាំង និងធនធានក្នុងសហគមន៍ដែលមានភូមិ ឃុំជាសេនាធិការសម្រាប់ធ្វើឱ្យសាលារៀនមានភាពរីកចម្រើនទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសមិទ្ធផលសិក្សារបស់សិស្ស។ ជាការឆ្លើយតបទៅនឹងគោលនយោបាយអប់រំទាំងពីររបស់ក្រសួងអប់រំ យុវជន និងកីឡា គណៈគ្រប់គ្រងនៅកម្រិតសាលារៀនមានភារកិច្ចក្នុងការធ្វើទំនាក់ទំនង និងបង្កើតឱ្យមានភាពជិតស្និទ្ធ និងសហការជាមួយក្រុមប្រឹក្សាឃុំកុមារ យុវជន និងស្ថាប័នផ្សេងៗក្នុងមូលដ្ឋានដើម្បីជួយអភិវឌ្ឍសាលារៀន ហើយគណៈកម្មការសាលារៀន មានតួនាទីក្នុងការធ្វើផែនការអភិវឌ្ឍន៍សាលារៀនផ្ដោតលើការជួយប្រមូលកុមារក្រៅសាលារៀន និង

ជួយបង្កើនលទ្ធផលសិក្សារបស់សិស្សផងដែរ។ អាស្រ័យហេតុនេះ ប្រធានបទនៃនិក្ខេបបទស្រាវជ្រាវស្ដីពី **"តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ"** ត្រូវបានលើកឡើងដោយមានគោលបំណងដូចតទៅ៖

- ស្វែងយល់ពីតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ
- រកដំណោះស្រាយនានាចំពោះការពង្រឹងការចូលរួមរបស់សហគមន៍ជាមួយនឹង ការគ្រប់គ្រងនៅកម្រិតសាលារៀនឱ្យកាន់តែមានប្រសិទ្ធភាព

## ៥. សំណួរនៃការស្រាវជ្រាវ

ឈរលើមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រធានបទខាងលើ និក្ខេបបទនេះត្រូវបានរៀបរៀងសរសេររៀបរាប់នូវខ្លឹមសារជាច្រើនដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដូចខាងក្រោម៖

ក/. តើសហគមន៍មានតួនាទីធ្វើអ្វីខ្លះដើម្បីអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស?

ខ/. តើសហគមន៍ និងសាលារៀនត្រូវចូលរួមដោះស្រាយយ៉ាងដូចម្ដេចខ្លះ ដើម្បីឱ្យការគ្រប់គ្រងនៅកម្រិតសាលារៀនមានប្រសិទ្ធភាព?

## ៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដំណើរការនៃការសរសេរនិក្ខេបបទនេះទៅរលូន និងសម្រេចបាននូវគោលដៅតាមផែនការដែលបានគ្រោងទុកត្រូវពឹងផ្អែកលើកត្តាពេលវេលា ធនធានសម្ភារៈ និងថវិការបស់អ្នកសិក្សាស្រាវជ្រាវជាចម្បង។ ខ្លឹមសារសំខាន់នៃនិក្ខេបបទនេះ គឺផ្ដោតទៅលើឥរិយាបថរបស់សហគមន៍ក្នុងកិច្ចសហការជាមួយសាលារៀនមានដូចជា៖ ១. ការផ្ដល់ជាតុចូល ២. គណៈកម្មការថ្នាក់រៀន ៣. ការលើកទឹកចិត្ត និងកៀរគរធនធាន។ សហគមន៍ក្នុងសំណេរនិក្ខេបបទនេះមានវិសាលភាពលើអាជ្ញាធរដែនដី(មេភូមិ មេឃុំ ក្រុមប្រឹក្សាឃុំសង្កាត់) គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកអាណាព្យាបាល/មាតាបិតាសិស្ស និងសិស្សានុសិស្សតាមសាលាគោលដៅនៅក្នុងក្រុងព្រះសីហនុ។ នាពេលបច្ចុប្បន្ន ដោយសារកត្តាពេលវេលា និង ថវិការបស់អ្នកសិក្សាស្រាវជ្រាវផ្ទាល់ដែលកំពុងតែបង្រៀនសិស្ស នៅវិទ្យាល័យមួយនាឆ្នាំសិក្សា ២០២១-២០២២ ការចុះប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ នឹងត្រូវកំណត់ការជ្រើសយកវិទ្យាល័យចំនួនបីដែលចំណុះឱ្យភូមិសិក្សាសង្កាត់លេខ១ លេខ២ លេខ៣ លេខ៤ និងសង្កាត់កោះរុង នៃក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ដើម្បីគោរពតាមគោលការណ៍នៃការសរសេរកិច្ចការស្រាវជ្រាវ ករណីសិក្សានេះ នឹងត្រូវកំណត់យកក្រុមគោលដៅសម្រាប់សម្ភាសន៍ប្រមូលទិន្នន័យពី អាជ្ញាធរចំនួន៣នាក់ គណៈគ្រប់គ្រងសាលា៦នាក់ មាតាបិតា/អ្នកអាណាព្យាបាលសិស្ស ១៨នាក់ គ្រូបង្រៀន ១៨នាក់ និងសិស្សានុសិស្សដែលកំពុងរៀននៅថ្នាក់ទី ១០ ទី១១ និងទី១២ ចំនួន១៨នាក់ ក្នុងឆ្នាំសិក្សា ២០២១- ២០២២។

### ៧. សារៈសំខាន់នៃការស្រាវជ្រាវ

និក្ខេបបទដែលត្រូវលើកមកស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ណាស់ព្រោះ វាបានរកឱ្យឃើញនូវការអនុវត្តតួនាទីរបស់សហគមន៍នាពេលកន្លងមក និងបានដឹងពីប្រសិទ្ធភាពនៃការគ្រប់គ្រងនៅកម្រិត

សាលារៀន(School-Based Management) តាមរយៈការបំពេញតួនាទីរបស់សហគមន៍ និងអ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ កិច្ចការស្រាវជ្រាវនេះនឹងផ្តល់ជាអនុសាសន៍ដ៏មានគុណតម្លៃក្នុងការដោះស្រាយបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធ នឹងភាពខ្វះចន្លោះនៃការបំពេញភារកិច្ចរបស់សហគមន៍ សាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាកុមារក្នុងការអនុវត្តកាលពីពេលមុនៗ តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ នឹងជួយដល់សមាជិកនៃសហគមន៍សិក្សា អាជ្ញាធរដែនដី មាតាបិតាសិស្ស គណៈគ្រប់គ្រងសាលា និងក្រសួងអប់រំយុវជន និងកីឡាដឹងពីដើមចមដែលនាំឱ្យសិស្សានុសិស្សទទួលបានលទ្ធផលសិក្សាល្អប្រសើរ។ ឯកសារនេះក៏ជួយដល់ការប្រតិបត្តិតួនាទីភារកិច្ចរបស់ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាក្នុងកិច្ចដំណើរការអភិវឌ្ឍសាលារៀន ការគ្រប់គ្រងថវិកា ការរៀបចំផែនការសកម្មភាពរបស់សាលារៀនជាមួយនឹងសហគមន៍ដែលចំណុះឱ្យសាលានេះតែម្តង។ ជាពិសេសអ្នកសិក្សាស្រាវជ្រាវក្រោយៗ ក៏អាចស្វែងរកខ្លឹមសារដែលពាក់ព័ន្ធនឹងកិច្ចដំណើររបស់សហគមន៍ និងសាលារៀនក្នុងអត្ថបទស្រាវជ្រាវនេះមកធ្វើការសិក្សាស្វែងយល់ និងឆ្លុះបញ្ចាំងពីតថភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រសហគមន៍សាលារៀន ព្រមទាំងការបំពេញតួនាទីរបស់សមាជិកសំខាន់ៗ របស់សហគមន៍សម្រាប់សរសេរកិច្ចការស្រាវជ្រាវរបស់ខ្លួនផងដែរ។

## ៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទស្តីពី **"តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ"** នឹងត្រូវពិពណ៌នាសរសេរជាប្រាំជំពូកដូចខាងក្រោម៖

**ជំពូកទី ១៖ សេចក្តីផ្តើម** នឹងត្រូវចែកចេញជា៖ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ព្រមទាំងរចនាសម្ព័ន្ធនៃការស្រាវជ្រាវផងដែរ។

**ជំពូកទី ២៖ រំលឹកទ្រឹស្តី** ជាផ្នែកមួយដែលត្រូវលើកឡើងពីពាក្យគន្លឹះ តួនាទី សហគមន៍ ការអភិវឌ្ឍលទ្ធផលសិក្សា។ ជាមួយគ្នានេះផងដែរ ជំពូកនេះនឹងនិយាយអំពី៖ ការចូលរួមរបស់សហគមន៍ តួនាទីរបស់សហគមន៍(អាជ្ញាធរដែនដី មេភូមិ មេឃុំ ក្រុមប្រឹក្សា) តួនាទីរបស់គណគ្រប់គ្រងសាលា គ្រូបង្រៀន តួនាទីរបស់អ្នកអាណាព្យាបាល/មាតាបិតា និងតួនាទីរបស់សិស្សានុសិស្សផងដែរ។ សារៈសំខាន់នៃគ្រួសារ និងសហគមន៍ ទំនាក់ទំនងសាលារៀន និងសហគមន៍ ឥទ្ធិពលវិជ្ជមានរបស់អ្នកអាណាព្យាបាលលើការចូលរួមក្នុងការអប់រំកូន បញ្ហាប្រឈមនៃការប្រតិបត្តិតួនាទីភារកិច្ចរបស់សហគមន៍ និងសាលារៀន ព្រមទាំងយុទ្ធវិធីនានា ដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍន៍សាលារៀនដែលផ្តោតលើការបង្កើនលទ្ធផលសិក្សារបស់សិស្ស។

**ជំពូកទី ៣៖ វិធីសាស្ត្រស្រាវជ្រាវ** ជាផ្នែកមួយដែលមានសូចនាករឆ្លុះបញ្ចាំងពីកិច្ចការស្រាវជ្រាវប្រធានបទខាងលើ ហើយចែកចេញជា៖ វិធីសាស្ត្រស្រាវជ្រាវ ការជ្រើសរើសភាគសំណាក ការប្រើប្រាស់

ឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ កម្រិតចង្អុលបង្ហាញ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

**ជំពូកទី ៤៖ លទ្ធផល និងការពិភាក្សា** ក្នុងផ្នែកនេះអ្នកស្រាវជ្រាវបានលើកឡើងពីលក្ខណៈជាក់ស្តែងដែលបានធ្វើការសិក្សាស្រាវជ្រាវ គឺត្រូវឆ្លើយតបទៅនឹងចំណុចដែលបានចោទសួរនៅក្នុងចំណោទបញ្ហា។ ចំពោះលទ្ធផលដែលទទួលបានពីការសម្ភាសនឹងត្រូវបានបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវដោយយោងទៅលើលទ្ធផលនៃការស្រាវជ្រាវទ្រឹស្តី ឬខ្លឹមសារដែលមានក្នុងកម្រងសំណួរ(ឧបសម្ព័ន្ធ)។

**ជំពូកទី ៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីអ្វីដែលបានរកឃើញទាក់ទងនឹងកម្រិតនៃការចូលរួម បញ្ហាប្រឈមនានា ទស្សនទានរបស់ភាគីពាក់ព័ន្ធចំពោះការចូលរួមក្នុងវិស័យអប់រំ និងសំណូមពរមួយចំនួនដើម្បីធ្វើឱ្យការចូលរួម និងការរៀបចំគោលនយោបាយអប់រំឆ្លើយតបទៅនឹងតម្រូវការសង្គម។ អ្នកស្រាវជ្រាវត្រូវធ្វើការសង្ខេបកិច្ចការ រួចទាញជាសេចក្តីសន្និដ្ឋានលើចំណុចដែលបានវិភាគ និងផ្តល់យោបល់ ឬសំណូមពរទៅលើចំណុចដែលត្រូវដោះស្រាយ និងកែលម្អ។

# ជំពូកទី ២

# រំលឹកទ្រឹស្តី

# ជំពូកទី ២៖ រំឭកទ្រឹស្តី

## ២.១. ការសិក្សាពាក្យគន្លឹះ

### ២.១.១. តួនាទី

តួនាទី ជាពាក្យដែលត្រូវបានគេប្រើប្រាស់ដើម្បីធ្វើបទបរិយាយការងារក្នុងមុខដំណែង ឬឋានៈណាមួយជាក់លាក់ក្នុងជីវភាពរស់នៅ។ ជាក់ស្តែង តួនាទីរបស់សហគមន៍ក្នុងការអប់រំ តួនាទីរបស់មាតាបិតាចំពោះកូន តួនាទីរបស់កូនចំពោះឪពុកម្តាយ តួនាទីរបស់ប្រជាពលរដ្ឋចំពោះប្រទេសជាតិជាដើម ។ ក្នុងសំណោរនៃការស្រាវជ្រាវ យើងឃើញថា ស្ទើរច្រើនសរសេរថា តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស។ តើពាក្យ តួនាទីជាបញ្ញត្តិមួយមានន័យយ៉ាងដូចម្តេច?

ផ្អែកតាមវចនានុក្រមខ្មែរដែលនិពន្ធដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យ "តួនាទី" បានមកពីពាក្យ (តួ+ នាទី)។ តួ (នាមសព្ទ) រូបរាង សព៌ាង្គកាយ ខ្លួន តួអក្សរ តួលេខ តួល្ខោន។ រីឯពាក្យ នាទី (នាមសព្ទ)មុខក្រសួង មុខងារ មុខការ ធ្វើការតាមនាទីរបស់ខ្លួន ធ្វើតាមនាទីដែលគេដាក់ឱ្យ(ជួន, ១៩៦៧)([21])។ ផ្អែកតាមអត្ថន័យនេះ តួនាទីមានន័យថាជាមុខងារ មុខការរបស់បុគ្គលណាមួយដែលក្រសួង ស្ថាប័នឬអង្គភាពសាមីបានដាក់ឱ្យធ្វើ។ ជាក់ស្តែងពាក្យ តួនាទី ត្រូវបានប្រជាពលរដ្ឋខ្មែរ មន្ត្រីរាជការសាធារណៈ និងឯកជនប្រើដើម្បីណែនាំ សម្រាប់ជាបទពិពណ៌នាការងារសំដៅដល់ទំនួលខុសត្រូវការងារ និងភារកិច្ចរបស់បុគ្គលិក និយោជិក ឬនិយោជកក្នុងមុខតំណែងដែលខ្លួនកាន់ការ។ ឧទាហរណ៍៖ តួនាទីរបស់នាយកសាលា តួនាទីរបស់គ្រូបង្រៀន តួនាទីរបស់បណ្ណារក្ស តួនាទីរបស់បេឡា តួនាទីរបស់ប្រធានមណ្ឌលប្រឡង តួនាទីរបស់អប្បមាទ និងអនុរក្ស ជាអាទិ៍។ ទន្ទឹមនឹងនេះ តាមរយៈការចាក់ផ្សាយរបស់សារព័ត៌មានថ្មី ថ្មីតាមបណ្តាញយូធូប កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២០ ថា "តួជាទីជាកាតព្វកិច្ច" (ThmeyThmey Media, 2020)([22]) រីឯវចនានុក្រមខ្មែរ ពាក្យកាតព្វកិច្ចត្រូវមើលពាក្យករណីយកិច្ចវិញ ហើយត្រូវបានពន្យល់ន័យថា ជាកិច្ចដែលគួរធ្វើ ការងារដែលត្រូវតែធ្វើ ដូចជា៖ មុខការនេះជាករណីយកិច្ចរបស់អ្នកហើយ(ជួន, ១៩៦៧)([23])។ ផ្អែកតាមការពន្យល់ន័យនៃវចនានុក្រម Cambridge ជំនាន់ទី ៣ ពាក្យថា តួនាទី (Role=Duty) មានវេវចនាស័ព្ទនឹងពាក្យ កាតព្វកិច្ច ដែលមាននិយមន័យថា ជាមុខងារ ឬបំណងដែលបុគ្គលម្នាក់ ឬអ្វីមួយមានចំពោះសភាពការណ៍មួយ អង្គភាពមួយ សង្គមមួយ ឬសម្ព័ន្ធភាពមួយ តួយ៉ាង៖ សាលារៀនមានតួនាទីយ៉ាងសំខាន់ចំពោះសង្គម(Cambridge,

---

[21] វចនានុក្រមខ្មែរភាគទ១, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី ៥, ១៩៦៧, ទំព័រ ៣៥០, ៥០២

[22] https://www.youtube.com/watch?v=R0nn5agffdI

[23] វចនានុក្រមខ្មែរភាគទ១, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី ៥, ១៩៦៧, ទំព័រ ២៨, ៣២

2008)។ ស្របគ្នានេះដែរ តាមគេហទំព័រ Google Search និង merriam-webster[24] និយមន័យនៃពាក្យ តួនាទី (Definition of role) ជាអាកប្បកិរិយាគម្រូដែលគេបានសន្មត់ថា ត្រូវធ្វើនៅក្នុងសង្គមតាមឋានៈរបស់បុគ្គលណាម្នាក់ និងក្នុងដំណើរការប្រតិបត្តិការអ្វីមួយ។

ក្នុងការឆ្លើយតបនឹងនិយមន័យនេះ យើងអាចពិនិត្យមូលន័យនៃពាក្យតួនាទីតាមរយៈឧទាហរណ៍ទាំងនេះដូចខាងក្រោម៖

- តួនាទី និងភារកិច្ចគណៈកម្មការអភិវឌ្ឍន៍សាលារៀនមានជាអាទិ៍៖ ការងារត្រៀមឆ្លើយតបគ្រោះមហន្តរាយ ការងារគណនេយ្យភាពសង្គម ការងារឃោសនាអប់រំ និងបណ្តុះបណ្តាលដល់សហគមន៍ពីការងារអប់រំសម្រាប់ទាំងអស់គ្នាពិសេសការងារអប់រំកុមារតូច ការងារជួយដល់កុមារងាយរងគ្រោះ មានកុមារពិការ ជនជាតិភាគតិច និងកុមារក្នុងគ្រួសារជួបការលំបាកពិសេសកុមារី ការងារលុបបំបាត់អំពើហិង្សាលើផ្លូវកាយ ផ្លូវចិត្ត និងកេងប្រវ័ញ្ចគ្រប់រូបភាពដល់កុមារ ការងារលើកទឹកចិត្តដល់គ្រូបង្រៀន ក្នុងការអនុវត្តតួនាទី និងភារកិច្ច(ម៉ោងសិក្សា) ការងារគ្រប់គ្រងស្ថិតិទិន្នន័យអប់រំ សុខភាព សេដ្ឋកិច្ច សង្គម ការងាររៀបចំមណ្ឌលអានសម្រាប់កុមារនៅតាម ក្លឹបសិក្សា ការងារផ្តល់សេវាសុខភាពសុវត្ថិភាព និងការងារសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធ(អយក, ២០១៧)[25]។
- តួនាទីរបស់នាយកសាលា៖ ជាអាជ្ញាធរអប់រំ ជាមន្ត្រីរដ្ឋបាល ជាទីប្រឹក្សាគរុកោសល្យ ជាអធិការអចិន្ត្រៃយ៍ ជាអ្នកផ្តល់សេវាអប់រំ ជាអ្នកពិគ្រោះយោបល់ និងជាភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍ផងដែរ(នូវ&នី, ២០២១)[26]។
- មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែក កសាងប្រទេសជាតិ និងការពារមាតុភូមិ (រដ្ឋធម្មនុញ្ញ, ២០០៨)[27]។

---

[24] https://www.google.com/search?q=defenition+of+role+merriam+webster&rlz=1C1CHBD_enKH1006KH1006&oq=defenition+of+role+merriam&aqs=chrome.1.69i57j33i10i160l2j33i22i29i30.20029j1j7&sourceid=chrome&ie=UTF-8

[25] គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, ទំព័រ ៩

[26] បទបង្ហាញរបស់សាស្ត្រាចារ្យ នូវ វីរ៉ា មុខវិជ្ជា ក្រមសីលធម៌អ្នកដឹកនាំគ្រប់គ្រងអប់រំ និងសាស្ត្រាចារ្យ នី រដ្ឋា មុខវិជ្ជា ការបំពេញការងារក្នុងសាលារៀន, ២០២១

[27] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២០០៨ ជំពូក ៣, ទំព័រ ១១

- តួនាទីគ្រូប្រឹក្សាគរុកោសល្យឆ្លើយតបសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន៖ ជួយប្រឹក្សាចំណេះដឹង និងជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀន ជួយការអនុវត្តការងាររបស់គ្រូបង្រៀនថ្មីថ្មោងជួយអភិវឌ្ឍគ្រូថ្មី (ឈាង, ២០២១)[28]

លើសពីនេះទៅទៀត តាមរយៈការស្រាវជ្រាវស្តីពីនិយមន័យថ្មីលើបញ្ញត្តិនៃពាក្យ "តួនាទី" ហើយនិងភាពសមហេតុផលនៃការប្រើពាក្យនេះ បានលើកឡើងថា៖ *"Role is an abstraction of the behaviour of an object that consists of a subset of the interactions of that object together with a set of constraints on when they may occur. A role always belongs to a specific larger behaviour that involves other roles, called a collaborative behaviour."* ដែលអាចមានន័យជាខេមរភាសាថា៖"តួនាទី ជាសកម្មភាពនៃអង្គប្រតិបត្តិមួយដែលត្រូវអនុវត្តជាមួយនឹងសមាជិកដទៃទៀតក្នុងទំនាក់ទំនងអន្តរកម្មជាមួយគ្នា ដោយមានគោលការណ៍កំណត់។ នៅពេល តួនាទីនេះ ពាក់ព័ន្ធនឹងតួនាទីជាក់លាក់សំខាន់ៗដទៃទៀត គេហៅថាសកម្មភាពសហការ (*Guy Genelloud& Alain Wegmann, 2000*)។

## ២.១.២. សហគមន៍

សហគមន៍ជាបញ្ញត្តិមួយដ៏ពេញនិយមសម្រាប់ទស្សនវិទូ អ្នកសង្គមវិទ្យា មនោគមវិទ្យា និងចិត្តវិទូប្រើប្រាស់ដើម្បីទាញយកទ្រឹស្តីគោលការណ៍សម្រាប់គ្រប់គ្រង និងដឹកនាំ(អេង, ២០០៧)[29]។

តើពាក្យ"សហគមន៍" មានអត្ថន័យយ៉ាងដូចម្តេច? តើតួអង្គសំខាន់ៗណាខ្លះដែលជាសមាសភាពនៃសហគមន៍?

សហគមន៍គឺជាបញ្ញត្តិមួយ ដែលត្រូវបានគេនិយមប្រើក្នុងស្ថានការណ៍មួយដែលពាក់ព័ន្ធដល់ការរួមគ្នាធ្វើកិច្ចការមួយជាក់លាក់។ យោងតាមសំណេរក្នុងវចនានុក្រមខ្មែរ សហគមន៍ត្រូវបានកកើតឡើងដោយពាក្យ សហ + គមន៍។ សហ(សៈហៈ)ជាពាក្យបាលីសំស្ក្រឹតដែលមានន័យថាព្រមព្រៀងជាមួយគ្នា ព្រមរួមជាមួយគ្នា ហើយវាត្រូវបានគេប្រើរៀងភ្ជាប់ពីខាងដើមសព្ទដទៃតាមគួរដល់ការប្រកប៖ សហកម្ម ការងារដែលរួមគ្នាធ្វើដំណើររួមគំនិតគ្នាធ្វើការ។ សហករណ៍ មានអត្ថន័យដូចគ្នានឹង សហកម្មដែរ ប៉ុន្តែសព្វថ្ងៃប្រើសំដៅយកក្រុមហ៊ុន ឬអង្គការដែលប្រមូលផ្តុំជនអ្នកបង្កើតផលផ្សេងៗ ឬអ្នកទទួលទិញដើម្បីយកកម្រៃមកចែកគ្នាតាមសមគួរដល់ប្រាក់ដើមដែលបានចូលហ៊ុន ឬតម្លៃដែលសមាជិកម្នាក់ៗបានទិញ(ពុំមែនជាជំនួញទេ)បង្កើតសហករណ៍ ទិញអីវ៉ាន់នៅសហករណ៍។ សហការី អ្នកធ្វើការជាមួយគ្នា អ្នកព្រួតគ្នា

---

[28] បទបង្ហាញរបស់សាស្ត្រាចារ្យ ឈាង សង្វាត ក្នុងសន្និសិទលើកទី១ ស្តីពី សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន, ២០២១

[29] សង្គមវិទ្យាសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន, អេង ឡុង, ឆ្នាំ ២០០៧, ទំព័រ ២០

ជួយធ្វើកិច្ចការណាមួយ ភ្នាក់ងារក្នុងមុខដំណែងរាជការជាដើម(ជួន, ១៩៦៧)[30]។ រីឯពាក្យសហគមន៍ (សៈហៈគំ) ការទៅជាមួយ ដំណើរជាមួយគ្នា ហើយក៏ប្រជុំភូមិ ឬតំបន់អ្នកស្រុកប្រកបមុខរបរចូលគ្នាបង្កើតឱ្យមានជាសហគមន៍ សហករណ៍ សហការី រឺសហជីព(ជួន, ១៩៦៧)[31]។

យ៉ាងណាមិញ និយមន័យសហគមន៍ត្រូវបានអ្នកសិក្សាស្រាវជ្រាវកំណត់ថា ជាពាក្យសំដៅដល់មនុស្សគ្រប់ស្រទាប់វណ្ណៈ ដែលរស់នៅក្នុងតំបន់មួយដោយធ្វើការទំនាក់ទំនងជាមួយគ្នាទាំងផ្នែកសម្ភារៈ និងស្មារតី(ផាន់, ២០២១)[32]។ អ្នកស្រាវជ្រាវរូបនេះក៏បានគូសបញ្ជាក់ពីគំនិតរបស់លោក *Dr. Pramote Benchakarn* នាយកវិទ្យាស្ថានរាជភ័ត្តបុរីរាម "**សហគមន៍បានសំដៅដល់តំបន់មួយដែលមានព្រំប្រទល់ដែនទឹកដីច្បាស់លាស់មានប្រជាជនរស់នៅទាក់ទងគ្នាប្រកបដោយវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងច្បាប់**"។ ដោយឡែក តាមការរៀបរៀងរបស់សាស្ត្រាចារ្យ អេង ឡុងបានសរសេរថា "***សហគមន៍ជាក្រុមមនុស្សដែលរស់នៅក្នុងទីតាំងភូមិសាស្ត្រតែមួយ ហើយប្រកាន់យកនូវជីវភាពរួមមួយ ក្នុងការប្រាស្រ័យទាក់ទងគ្នា(Lundburg)។ វាក៏ជាសមាជិកនៃសមូហភាពមួយដែលមានដែនដីរួមគ្នា ដំណើរជីវភាពដូចគ្នា គោលបំណង និងទិសដៅរួមគ្នា (Ogbum, Nem Koff, Sot therland, Tolcott Parsons)***" (អេង, ២០០៧)[33]។ លើសពីនេះទៅទៀត ផ្អែកតាមសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀននៃគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា បានលើកឡើងថា"សហគមន៍សំដៅលើមាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងសហគមន៍ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន (អយក, ២០១៨)[34]។ បើផ្អែកតាមការស្រាវជ្រាវពាក្យ "សហគមន៍" នៃវចនានុក្រម អង់គ្លេស-ខ្មែរ (*The Best Mekong Queen's Office Oxford Advanced Learner's Dictionary*) គឺជាបញ្ញត្តិនៃការរស់នៅរបស់ប្រជាជននៅទីតាំងមួយ ឬស្រុកមួយ ឬក៏ប្រទេសមួយហើយត្រូវបានគេចាត់ទុកជាក្រុមមួយដែលមានមនុស្សរស់នៅរួមគ្នា មានផលកម្រៃរួមគ្នា ការងាររួមគ្នា និងសាសនាដូចគ្នាជាដើម(គីម ហាក់, ២០០៤-២០០៥)។ យ៉ាងណាមិញ ទាក់ទងនឹង បរិបទនៃការយកចិត្តទុកដាក់លើវិស័យអប់រំជាវិស័យស្នូលនៃការអភិវឌ្ឍខឿនសេដ្ឋកិច្ចរបស់ប្រទេសជាតិបញ្ញត្តិនេះត្រូវបានគេនិយមប្រើជាពីរសណ្ឋានគឺ៖ សហគមន៍ជាតិ និងសហគមន៍អន្តរជាតិ(ផាន់, ២០២១)[35] ក្នុងគោលបំណងសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិ

---

30 វចនានុក្រមខ្មែរភាគ១, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី ៥, ១៩៦៧, ទំព័រ ២៨, ៣២

31 វចនានុក្រមខ្មែរភាគ១, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី ៥, ១៩៦៧, ទំព័រ ២៨, ៣២

32 និក្ខេបបទផាន់ សំអាតស្តីពីការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង, ២០២១, ទំព័រ ១២

33 សង្គមវិទ្យាសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន, អេង ឡុង, ឆ្នាំ ២០០៧, ទំព័រ ២១

34 សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨, ទំព័រ ៦

35 និក្ខេបបទផាន់ សំអាតស្តីពីការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង, ២០២១, ទំព័រ ១៣

ការរួមគ្នាក្នុងការលើកកម្ពស់គុណភាពអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន ព្រមទាំងពង្រឹងភាពជាអ្នកដឹកនាំដល់មន្ត្រីគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ដោយបង្កឱកាសសិក្សាពេញមួយជីវិត។ ចំពោះ ការស្រាវជ្រាវរបស់លោក *Suzanne Gatte* ដែលស្តីអំពី តួនាទីរបស់សហគមន៍ក្នុងការលើកកម្ពស់ការសិក្សានៃសកលវិទ្យាល័យ *Malta* បានពណ៌នាពី សហគមន៍សំដៅការប្រជុំភូមិ ក្រុមមនុស្ស សាលារៀន និងអ្នកផ្សេងៗដែលមានទំនាក់ទំនងគ្នាជារួម ហើយត្រូវអ្នកសង្គមវិទ្យា និងទស្សនវិទូ លោក *Ferdinand Tonnies* កំណត់ចែកជាពីរទម្រង់សហគមន៍ *Gesellschaft* ជាសមាគមមួយរវាងមនុស្សដែលមានគោលបំណងរបស់សមាជិកជាកម្រៃរួមគ្នា។ ឯ *Gemeinschaft* ជាសមាគមមួយដែលមានគោលបំណងរួមគ្នា ចំណង់ចំណូលចិត្ត និងសុចរិតភាពបុគ្គលដូចគ្នា( *Watkins, 2007)* ។ ថ្វីត្បិត ថាពាក្យ "សហគមន៍" ត្រូវចែកជាពីរទម្រង់ក៏ពិតមែន ក៏សហគមន៍ជាក់ស្តែងអាចត្រូវកកើតឡើងបាន ទោះបីជាមានធនធានខុសគ្នា ផ្នត់គំនិត និងទស្សនៈផ្សេងៗក៏ដោយ ព្រោះថា ក្នុងសង្គមប្រជាធិបតេយ្យដ៏រឹងមាំ សហគមន៍គឺជា ការរួមបញ្ចូលនូវទស្សនវិស័យរួមគ្នាដូចជា៖ ការជ្រើសយកមតិភាគច្រើន ការអប់រំ សុខភាព និងសុខមាលភាពសមភាពសេដ្ឋកិច្ច កាលានុវត្តភាព ចីរភាព ព័ត៌មាន ការទំនាក់ទំនង សេចក្តីចម្រើន ព្រមទាំងវប្បធម៌ផងដែរ *(Schuler, 1996)*។ យ៉ាងណាមិញ តាមច្បាប់អប់រំនៃព្រះរាជាណាចក្រកម្ពុជា ពាក្យសហគមន៍ត្រូវបានពិព័ណ៌នាជាពីរផ្នែកគឺ សហគមន៍ជាតិ និងសហគមន៍អន្តរជាតិ ហើយវានឹងត្រូវបានបង្ហាញដូចតទៅនេះ៖

**ក. សហគមន៍អន្តរជាតិ៖**

រដ្ឋត្រូវបើកទូលាយឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់មានជាអាទិ៍ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នៅក្នុងដំណើរការនៃការអភិវឌ្ឍការតាក់តែង ការតាមដានវាយតម្លៃលើការអនុវត្ត លើការលើកសំណើឱ្យពិនិត្យឡើងវិញ និងសំណើកែលម្អគោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រវិស័យអប់រំ។ រដ្ឋលើកទឹកចិត្ត និងគាំទ្រដល់ស្ថាប័នឯកជនដើម្បីបង្កើតភាពជាដៃគូក្នុងការផ្តល់សេវាអប់រំគ្រប់ប្រភេទ និងគ្រប់កម្រិត ( ច្បាប់អប់រំ, ២០០៧ ) ។ ក្នុងន័យនេះ ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងគោលនយោបាយអប់រំជាតិ ក្រសួងអប់រំយុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍វិស័យអប់រំជាច្រើន ក្នុងការឧបត្ថម្ភគាំទ្រដល់ធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈ បច្ចេកទេស និងអាហារូបករណ៍ក្នុង/ក្រៅប្រទេសដោយចងភ្ជាប់នូវតួនាទី និងទំនួលខុសត្រូវតាមនីតិវិធីជាកាតិកាសញ្ញា សន្ធិសញ្ញា និងជាកិច្ចព្រមព្រៀងអនុស្សរណយោគយល់គ្នាជាដើម។ តាមកាលានុវត្តភាពនៃសមាជិកភាពក្នុងអង្គការសហប្រជាជាតិ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាលបានទាញយកទំនុកចិត្ត ចំណាប់អារម្មណ៍របស់ដៃគូអភិវឌ្ឍក្នុងឆាកអន្តរជាតិ និងតំបន់មានដូចជា៖

អង្គការ (UNICEF) អង្គការ (UNDP) អង្គការ (UNFPA) អង្គការ (UNESCO) អង្គការ (USIAD) អង្គការ (AUSAID) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អង្គការចាយកា(JICA) អង្គការខយកា(KOICA) អង្គការ(GTZ) និងអង្គការស៊ីដា(SIDA) ជាដើម។

**ខ. សហគមន៍ជាតិ៖**

ផ្អែកតាមនិយមន័យនៃពាក្យសហគមន៍ខាងលើ ដើម្បីវឌ្ឍនភាពគ្រប់វិស័យនៅក្នុងតំបន់មួយ និងបុគ្គលមួយ ប្រជាជននៅមូលដ្ឋាននេះអាចមានលទ្ធភាពចូលរួមសាមគ្គីគ្នា ទំនាក់ទំនងគ្នាជាសហគមន៍ដោយមានគោលបំណងរួម និងទិសដៅរួម ព្រមទាំងទទួលបានផលប្រយោជន៍រួមគ្នាផងដែរ។ ថ្វីបើប្រជាជននៅតំបន់នោះ មានសិទ្ធិអាចបង្កើតសហគមន៍មួយបានមែន ប៉ុន្តែពួកគេត្រូវតែគោរពតាមនីតិវិធី និងច្បាប់ជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងជំពូក ៣ មាត្រា ៣៦ គន្លីទី ៧ និង៨បានចែងថា៖ **"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព(សហគមន៍) និងចូលជាសមាជិកសហជីពនេះ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់"** (រដ្ឋធម្មនុញ្ញ, ២០០៨)។

តាមរយៈគេហទំព័រ វីគីភីឌៀខ្មែរ បានលើកឡើងថា "ពាក្យសហគមន៍នេះ ត្រូវបានគេប្រទះឃើញ និងប្រើប្រាស់ជាញឹកញាប់នៅក្នុងជីវភាពរស់នៅធម្មតា និងមុខវិជ្ជាផ្សេងៗទៀតរួមមាន៖ បរិស្ថាន វិទ្យា ភូមិវិទ្យា ផែនទីវិទ្យា សង្គមវិទ្យា ចិត្តវិទ្យា និងសេដ្ឋកិច្ចវិទ្យាជាដើម។ នៅក្នុងអក្សរសាស្ត្រខ្មែរ ចំពោះអត្ថន័យនៃពាក្យ សហគមន៍នេះ មានន័យថា ការទៅជាមួយគ្នា ដំណើរជាមួយ ប្រជុំគ្នា ឬអ្នកស្រុកប្រកបមុខរបរចូលគ្នា....។ តាមរយៈបទពិសោធន៍ និងការអង្កេតជារួមនៅក្នុងចក្ខុវិស័យទេសចរណ៍ (Schmink 1999) ពាក្យសហគមន៍គឺ សំដៅទៅលើមនុស្សផ្សេងៗគ្នាដែលមានលំនៅដ្ឋានស្ថិតនៅតំបន់ភូមិសាស្ត្រដូចគ្នា និងអាស្រ័យផលធនធានធម្មជាតិក្នុងមូលដ្ឋាន។" ឧទាហរណ៍៖ ទេសចរណ៍សហគមន៍ព្រែកត្នោត សហគមន៍នេសាទ សហគមន៍អភិរក្សសត្វព្រៃ សហគមន៍សាលារៀនជាដើម។ អាស្រ័យហេតុនេះ សហគមន៍ គឺជាក្រុមមនុស្សដែលរស់នៅក្នុងតំបន់មួយ ហើយបានចូលរួមសកម្មភាពនានាដែលបម្រើឱ្យគោលគំនិតរួមមួយ ទស្សនៈរួម ផលប្រយោជន៍រួមគ្នា។ មិនត្រឹមតែប៉ុណ្ណោះ ពាក្យ សហគមន៍ ត្រូវបានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC Cambodia)ឱ្យន័យថា៖ សហគមន៍ គឺជាអង្គការវិជ្ជាជីវៈរបស់កសិករប្រជាពលរដ្ឋថ្នាក់មូលដ្ឋាន ដែលបានសហការគ្នាបង្កើតឡើងក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់កសិករ និងពលរដ្ឋដែលមានលក្ខណៈជាអចិន្ត្រៃយ៍ ហើយគេសន្មត់ឱ្យនិយមន័យសហគមន៍ថា ៖ គឺជាដំណើរការរួមគ្នា ឬការរស់នៅផ្តុំគ្នា ការប្រជុំភូមិតំបន់ អ្នកស្រុកដែលរស់នៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា និងធ្វើការងារអ្វីមួយរួមគ្នាជាប្រយោជន៍រួម ហើយបង្កើតឱ្យមានសហគមន៍(CCFC Cambodia, 2016)។ ជាពិស្តារនៃអត្ថបទស្រាវជ្រាវនេះ សហគមន៍គឺផ្តោតសំខាន់ទៅលើបុគ្គលគ្រប់រូបដែលពាក់ព័ន្ធនឹងសាលារៀន ការសិក្សា និងការអប់រំនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

តើតួអង្គសំខាន់ៗណាខ្លះដែលជាសមាសភាពនៃសហគមន៍?

វិស័យអប់រំជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយប្រជាពលរដ្ឋគ្រប់រូបត្រូវតែចូលរួមដើម្បីពង្រឹងគុណភាពអប់រំ និងផលិតនូវមូលធនមនុស្សដ៏មានសក្តានុពលឱ្យឆ្លើយតបទៅនឹង

ជំនាញបច្ចេកទេស ព្រមទាំងតម្រូវការទីផ្សារការងារផងដែរ។ គុណភាពអប់រំអាស្រ័យលើគុណភាពរបស់នាយកសាលារៀន និងគុណភាពរបស់គ្រូបង្រៀន ព្រមទាំងត្រូវបញ្ចូលសមាសភាពមកពីក្រុមប្រឹក្សាឃុំសង្កាត់ គណៈកម្មការអភិវឌ្ឍន៍ភូមិ មណ្ឌលសុខភាព នគរបាលប៉ុស្តិ៍រដ្ឋបាល វត្តអារាម និងមាតាបិតា អ្នកអាណាព្យាបាលសិស្សផងដែរ(អយក, ២០១៧)[36]។ ក្នុងន័យនេះ តួអង្គសំខាន់ៗនៃសហគមន៍គឺៈ សមាសភាពពីសាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ(អ្នកអាណាព្យាបាល មាតាបិតាសិស្ស និងសប្បុរសជន)ដែលមានទំនាក់ទំនងទៅនឹងការងាររបស់សាលារៀន។ យ៉ាងណាមិញ នៅក្នុងឯកសារប្រតិបត្តិស្តីពីគណៈកម្មការអភិវឌ្ឍន៍សាលារៀនគឺមានសមាសភាពមកពី ១. សាលារៀនៈ គណកម្មការទ្រទ្រង់សាលារៀន គណៈគ្រប់គ្រងសាលារៀន ក្រុមបច្ចេកទេស គ្រូបង្រៀន ក្រុមប្រឹក្សា កុមារ(សិស្ស) ២. អាជ្ញាធរដែនដីៈ មេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់ គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារស្មៀនឃុំ មេភូមិ នារីភូមិ មណ្ឌលសុខភាពឃុំ នគរបាលប៉ុស្តិ៍រដ្ឋបាល ចៅអធិការវត្ត អាចារ្យ ចាស់ព្រឹទ្ធាចារ្យ ព្រមទាំងសប្បុរសជននានា(អយក, ២០១៧)[37]។ លើសពីនេះទៅទៀត សមាសភាពនៃគណៈកម្មការគ្រប់គ្រងសាលារៀន នាយកសាលាត្រូវផ្តួចផ្តើមគំនិតអញ្ជើញភាគីពាក់ព័ន្ធក្រុមគ្រូបង្គោល គ្រូបង្រៀន និងបុគ្គលិកសាលារៀន តំណាងមាតាបិតា(អ្នកអាណាព្យាបាលសិស្ស) សហគមន៍(ប្រធានភូមិ អ្នកមានប្រជាប្រិយភាព និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់)ដើម្បីចូលរួមប្រជុំបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន (អយក, ២០១៨)[38]។ ម្យ៉ាងវិញទៀត ជាការឆ្លើយតបទៅនឹងគោលនយោបាយអប់រំជាសកល និងក្នុងតំបន់ដែលផ្តោតលើការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត ការអប់រំសម្រាប់ទាំងអស់គ្នា ក្នុងរបាយការណ៍របស់អង្គការសហប្រជាជាតិបានគូសបញ្ជាក់ពីសមាសភាពអ្នកពាក់ព័ន្ធនឹង ផែនទីបង្ហាញផ្លូវការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពត្រង់សកម្មភាពជាអាទិភាព ទី ២ ស្តីពី ការផ្លាស់ប្តូរជាវិជ្ជមាននៃបរិយាកាសរៀនសូត្រ សកម្មភាពអាទិភាពទី៣ ស្តីពី ការកសាងសមត្ថភាពអ្នកអប់រំ សកម្មភាពអាទិភាពទី៤ ស្តីពី ផ្តល់ភាពអង់អាច និងកៀរគរចលនាយុវជន និងទី៥ ពន្លឿនសកម្មភាពនៅមូលដ្ឋាន។ សកម្មភាពអាទិភាពទាំងនេះ បានរៀបរាប់ពីតួអង្គសំខាន់ៗមានដូចជាៈ ថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា នាយកសាលា សាកលវិទ្យាធិការ ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អាជ្ញាធរសាធារណៈក្នុងមូលដ្ឋាន ក្រុមហ៊ុនឯកជន អ្នកអប់រំ អ្នកសិក្សាក៏ដូចជាបុគ្គលិករដ្ឋបាលនៅតាមគ្រឹះស្ថានសិក្សានានា អ្នកដឹកនាំសហគមន៍មូលដ្ឋាន គ្រួសារនៅតាមសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋទាំងអស់នៅក្នុងសហគមន៍មូលដ្ឋាន យុវជន និងដៃគូរបស់ខ្លួន (ESD,UNESCO, ២០១៤-២០២១)។ អាស្រ័យហេតុនេះ ពាក់ព័ន្ធនឹងខ្លឹមសាររួមនៃនិក្ខេបបទខាងលើ ពាក្យ "**សហគមន៍**" ផ្តោតលើបុគ្គលទាំងឡាយណាដែលពាក់ព័ន្ធនឹងកិច្ចដំណើរការអប់រំ ការសិក្សា ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន ហើយតួអង្គទាំងនោះសុទ្ធតែមានឆន្ទៈរួមគ្នា ទិសដៅរួមគ្នា និងទទួលបានផលប្រយោជន៍ក្នុងសហគមន៍សិក្សាដូចគ្នា ពោលសមាសភាពនេះមានដូចជាៈ អាជ្ញាធរ

---

[36] គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, ទំព័រ ៦

[37] គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, ទំព័រ ៦

[38] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨, ទំព័រ ១៧

ដែនដី(ចៅសង្កាត់ មេឃុំ មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់) អ្នកអាណាព្យាបាល/មាតាបិតាសិស្ស គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្សានុសិស្ស។

**២.១.៣. ការអភិវឌ្ឍ**

អភិវឌ្ឍ(អៈភិវ៉ែ)ចម្រើនក្រៃលែង លូតលាស់ចម្រើន។ សេចក្ដីចម្រើនក្រៃលែង(ជួន, ១៩៦៧)[39]។ សណ្ឋាននៃពាក្យនេះអាចត្រូវបានគេប្រើដូចជា៖ អភិវឌ្ឍនភាព អភិវឌ្ឍនាការ ដែលត្រូវសំដៅដល់ភាពនៃសេចក្ដីរីកចម្រើន និងអាការនៃការអភិវឌ្ឍ។ យ៉ាងណាមិញ តាមការពន្យល់ក្នុងគេហទំព័រ ពុទ្ធសាសនាដើម្បីការអប់រំនៃកម្ពុជា (BEC) ពាក្យ អភិវឌ្ឍ(កិ) រីកចម្រើនក្រៃលែង រីឯអភិវឌ្ឍន៍(ន) ការរីកចម្រើន (ហាក់, ២០២០)។ បើយោងតាមគេហទំព័រ etymonlinedictionary បានពន្យល់ថា ***"development(develop+ment) a gradual unfolding, a full working out or disclosure of the details of something"1756 and in 1976 development means "the internal process of expanding and growing" and by the time 1836 it means "advancement through progressive stages".*** អត្ថន័យនេះអាចមានន័យជាភាសាខ្មែរថា៖ "កាលពីឆ្នាំ ១៧៥៦ ពាក្យ អភិវឌ្ឍ ជាការបង្ហាញនូវសេចក្ដីលម្អិតលើលទ្ធផលរីកចម្រើននៃការងារអ្វីមួយជាបណ្ដើរៗ ។ លុះមកដល់ឆ្នាំ ១៧៩៦ ពាក្យ អភិវឌ្ឍ មានន័យថាជាដំណើរការខាងក្នុងនៃការរីកចម្រើន ល្អប្រសើរឡើង។ ហើយនៅឆ្នាំ ១៨៣៦ ពាក្យនេះមានន័យថាជា សេចក្ដីចម្រុងចម្រើន ល្អប្រសើរតាមដំណើរការវិវត្តន៍"។ បើពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ក្នុងឆ្នាំ ១៨៨៥ ពាក្យ អភិវឌ្ឍ គឺជាផលរីកចម្រើនផ្នែកការប្រើប្រាស់ និងផលចំណេញ (Pickering's glossary of Americanisms, 1816, has betterments)។ រហូតមកដល់ឆ្នាំ ១៩០២ ពាក្យ អភិវឌ្ឍ ជា សភាពនៃការរីកចម្រើនផ្នែកសេដ្ឋកិច្ច (etymonlinedictionary.com)។ លើសពីនេះទៅទៀត ពាក្យអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅឆ្នាំ ២០០៥ ដល់ឆ្នាំ២០០៩ នៃគោលនយោបាយ៥ឆ្នាំបន្ទាប់២០១០ ដល់ឆ្នាំ ២០១៤ ក្នុងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ សរសរស្តម្ភទី ២ គឺ សំដៅដល់ការកែប្រែ ធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សាគោលរបស់រដ្ឋដើម្បីឆ្លើយតបទៅនឹង តម្រូវការនានាក្នុងបរិបទសកលនីយកម្ម តំបន់នីយកម្ម និងតម្រូវការបុគ្គលប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។ ផ្អែកតាមអ្នកទស្សនវិទូ ពាក្យថា "ការអភិវឌ្ឍ" ក្នុងមុខវិជ្ជាជីវវិទ្យាគឺសំដៅដល់ដំណើរការនៃការរីកលូតលាស់ និងបំលែងចរិកលក្ខណៈរបស់សព៌ាង្គរាងកាយមានជីវិត ដែលវាបន្តផ្លាស់ប្តូរជាវដ្តនៃជីវិតកោសិកា ចាប់តាំងពីដំណាក់កាលដំបូងរហូតដល់ពេលងាប់។ ពាក្យ "អភិវឌ្ឍ"ក៏និយាយអំពីដំណើរការនៃវឌ្ឍនភាព និងការបំលែងខ្លួននៃសរីរាង្គតាមដំណាក់កាលនីមួយៗ។ ទន្ទឹមនឹងអត្ថន័យខាងលើ ពាក្យ"អភិវឌ្ឍ" ដែលទាក់ទងនឹងដំណើរការសេដ្ឋកិច្ច និងចិត្តសាស្ត្រក្នុងក្រុមវាក្យសព្ទរបស់អាល្លឺម៉ង់ Entwicklung បានធ្វើការគូសបញ្ជាក់ទៅជាពីរប្រភេទគឺ

[39] វចនានុក្រមខ្មែរភាគទី១, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី ៥, ១៩៦៧, ទំព័រ ២៨

ការអភិវឌ្ឍជាលក្ខណៈបុគ្គល(Ontogeny) និងការអភិវឌ្ឍជាបដិវត្ត(evolutionary development) ហើយអត្ថន័យរបស់វាបានពង្រីកទៅជាយន្តការសិល្បៈ និងអក្សរសិល្ប៍ (Entwicklungsroman)។ ចាប់តាំងពីទសវត្ស ១៩៧០ ពាក្យ "អភិវឌ្ឍ" ក៏បានប្រើក្នុងបរិបទស្តារឡើងវិញ ផ្នែកសុខភាពបន្តពូជដោយពាក់ព័ន្ធនឹងប្រព័ន្ធសារជាតុគីមី និងរូបសាស្ត្រ។ លុះមកដល់សតវត្សទី ២១នេះ អត្ថន័យនៃពាក្យ "អភិវឌ្ឍ" គឺសំដៅដល់ការបន្សាំខ្លួនទៅនឹងបរិស្ថានជុំវិញនានាដូចជា៖ កោសិកា សារពាង្គកាយ រូបរាង និងវប្បធម៌។ ពាក្យនេះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងកិច្ចការពិភាក្សាក្នុងវិស័យវិទ្យាសាស្ត្រ និងទស្សនវិទ្យាអស់រយៈកាល២៥០០ឆ្នាំមុន(science.jrank.org)។ ទោះបីជាមានការពន្យល់បកស្រាយផ្សេងៗគ្នាក៏ដោយក៏អត្ថន័យនៃពាក្យ អភិវឌ្ឍ នៅតែសង្កត់ធ្ងន់លើការប្រែប្រួលជាវិជ្ជមានដែរ ហើយរួមជាមួយគ្នានេះ អ្នកស្រាវជ្រាវម្នាក់ផ្សេងទៀត ក៏ឱ្យនិយមន័យពាក្យ "អភិវឌ្ឍ"(Development)ថាជាពាក្យត្រូវបានគេប្រើជាក្រុមសំណាកមួយដើម្បីកត់ចំណាំពីការសង្ខេបការផ្លាស់ប្តូរ និងដំណើរការបន្តនៅក្នុងកិច្ចពិភាក្សាផ្នែកទស្សនវិទ្យាអំពីប្រធានបទណាមួយក្នុងអំឡុងពេលដែលបានរៀបចំទុក (KANT-STUDIEN, Ursula Renz, 2016)។

សេចក្តីសន្និដ្ឋាន ពាក្យ "អភិវឌ្ឍ" គឺផ្តោតទៅលើដំណើរការវិវត្តទៅរកភាពល្អប្រសើរក្រៃលែងក្នុងថេរវេលាមួយដ៏ជាក់លាក់។ ជាទឡ្ហីករណ៍ យើងអាចលើកជាសំអាងនឹងការប្រើប្រាស់ពាក្យនេះដូចតទៅ៖ សហគមន៍សាលារៀនមានតួនាទីអភិវឌ្ឍគុណភាពអប់រំនៅក្នុងតំបន់ព្រៃលិចទឹក។ ការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារជាកត្តាជំរុញដល់ការរីកចម្រើនសេដ្ឋកិច្ចប្រទេសជាតិ។ គ្រូបង្រៀនត្រូវតែអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំជាដើម។

### ២.១.៤. លទ្ធផលសិក្សា

តាមវចនានុក្រមខ្មែរនិពន្ធដោយសម្តេចសង្ឃរាជ ជួន ណាតពាក្យ លទ្ធ(ល័តធៈ,បា., សំ.) ដែលបានហើយ។ លទ្ធផល ផលដែលបានហើយ ផលនៃការងារដែលបានសម្រេចហើយ កម្រៃដែលបានសម្រេចមកពីការប្រកបកិច្ចការផ្សេងៗ សេចក្តីសម្រេចនៃការគិតលេខ បានទទួលលទ្ធផល គ្មានលទ្ធផល ។ រីឯ ពាក្យ "សិក្សា" ជាសិក្ខា គឺការរៀន ការរៀនទន្ទេញ ការសូត្ររៀន ការហ្វឹកហាត់ ការប្រុងប្រយ័ត្នរក្សាមារយាទ ឧទាហរណ៍៖ មាតាបិតាទំនុកបម្រុងបុត្រឱ្យសិក្សា(ជួន, ១៩៦៧)[40]។ តាមការពន្យល់នៃសៀវភៅសិក្សាគោលភាសាខ្មែរថ្នាក់ទី ៩ ពាក្យ លទ្ធផល (ន) ផលនៃការងារដែលបានសម្រេច ផលដែលបានសម្រេចហើយ (អយក, ២០១៧)[41]។ ទាក់ទងនឹងបញ្ញត្តិ លទ្ធផលសិក្សានេះ អ្នកស្រាវជ្រាវម្នាក់ឈ្មោះ(Stanford)បានឱ្យនិយមន័យថា វាជាសេចក្តីថ្លែងការមួយស្តីពីចំណេះដឹង ជំនាញ និងសមត្ថភាព

[40] វចនានុក្រមខ្មែរភាគទ១, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី ៥, ១៩៦៧, ទំព័រ ១០៩២

[41] ពន្យល់ពាក្យ ភាសាខ្មែរថ្នាក់ទី ៩, ទំព័រ ១៦៩

របស់និស្សិតផ្ទាល់ដែលគេគួរតែទទួលបាន និងអាចបង្ហាញពីលទ្ធផលបញ្ចប់បទពិសោធន៍រៀនសូត្រតាមដំណាក់កាលនីមួយៗ។ លទ្ធផលសិក្សានេះ គួរតែអនុលោមតាមគោលការណ៍ណែនាំដូចខាងក្រោម៖

- លទ្ធផលសិក្សាគួរតែមានភាពច្បាស់លាស់
- លទ្ធផលសិក្សាគួរតែមានសុក្រឹតភាព
- លទ្ធផលសិក្សាគួរតែពឹងផ្អែកដោយពាក្យបរិយាយជាកិរិយាសព្ទបង្ហាញពីអនាគតបានដូចជា៖ បន្ទាប់ពីបញ្ចប់វគ្គនេះ អ្នកសិក្សានឹងអាចពន្យល់ .....អាចនឹងបង្កើត......អាចនឹងបរិយាយ........ អាចនឹងពណ៌នា....ជាដើម។
- លទ្ធផលសិក្សាគួរតែឆ្លើយតបនឹងវត្ថុបំណងរបស់វគ្គសិក្សា
- លទ្ធផលសិក្សាគួរតែអាចគណនា និងវាយតម្លៃបាន
- លទ្ធផលសិក្សាគួរតែពាក់ព័ន្ធនឹងកម្មវិធីសិក្សា
- លទ្ធផលសិក្សាគួរតែមានភាពសមញ្ញមិនពិបាកយល់
- លទ្ធផលសិក្សាគួរតែផ្តោតលើផលិតផលនៃការសិក្សាមិនមែនដំណើរការបង្រៀននោះទេ




លើសពីនេះ តាមទ្រឹស្តីរបស់លោក ប្លូម (Bloom's Taxonomy) ១៩៥៦ លទ្ធផលសិក្សារបស់សិស្សគឺជារចនាសម្ព័ន្ធនៃកម្រិតឥរិយាបថផ្នែកបញ្ញាស្មារតីរបស់សិស្ស(Cognitive Domain) រួមមានកម្រិតចងចាំ កម្រិតយល់ដឹង កម្រិតអនុវត្ត កម្រិតវិភាគ កម្រិតសន្និដ្ឋាន និងវាយតម្លៃ(Adapted from California State University, Bakersfield, PACT Outcomes Assessment Handbook, 1999)។ យ៉ាងណាមិញ ដើម្បីលើកកម្ពស់គុណភាពលទ្ធផលសិក្សារបស់សិស្ស ត្រូវអភិវឌ្ឍន៍ការបង្រៀន និងរៀន ក៏ដូចជាគុណភាពរបស់ប្រព័ន្ធសាលារៀនឱ្យកាន់តែទូលំទូលាយជាងមុន ដើម្បីជួយសិស្សានុសិស្ស ឪពុកម្តាយ សហគមន៍ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនសម្រេចបាននូវស្តង់ដាថ្នាក់ជាតិពោលគឺ ត្រូវធ្វើយ៉ាងណាឱ្យប្រាកដថាអ្នកពាក់ព័ន្ធ និងបុគ្គលិកអប់រំកំពុងផ្តល់ការអប់រំប្រកបដោយគុណភាព ធនធានមនុស្សកំពុងត្រូវបានកែលម្អ ហើយប្រទេសកម្ពុជាកំពុងស្ថិតនៅលើផ្លូវដែលត្រឹមត្រូវឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងនិរន្តភាព(www.moeys.gov.kh)([42])។ ទាក់ទងនឹងនិយមន័យនៃពាក្យលទ្ធផលសិក្សា(Learning Outcomes) របស់គេហទំព័រ blog.citl.mun.ca/ instructional

[42] http://www.moeys.gov.kh/index.php/kh/about-us.html#.YwHlRHZBzIU

resources/learning-outcomes/ បានគូសបញ្ជាក់ថា៖ "លទ្ធផលសិក្សាជាការបង្ហាញនូវអ្វីដែលអ្នកសិក្សាគួរតែចេះ អាចធ្វើការបាន និងគុណតម្លៃក៏ដូចជាលទ្ធផលនៃការរួមបញ្ចូលគ្នានូវចំណេះដឹង ជំនាញ និងឥរិយាបថរៀនសូត្រ នៅក្នុងវគ្គសិក្សា ហើយលទ្ធផលសិក្សានេះ ជាលិខិតមួយអាចវាស់វែង ព្រមទាំងប៉ាន់ប្រមាណនូវសមិទ្ធិផលបានផងដែរ"។ គេហទំព័រមួយនេះ ក៏បានបង្ហាញពីពាក្យពាក់ព័ន្ធនឹងដំណើរការលទ្ធផលសិក្សា(Learning Outcomes)នេះផងដែរ ដូចជា៖ គោលបំណងនៃវគ្គសិក្សា(Goal/Learning Goals) គឺជាផលទូទៅមួយដែលវគ្គសិក្សាចង់សម្រេចបាន ហើយគោលបំណងនេះត្រូវឆ្លុះបញ្ចាំងពីបំណងរបស់វគ្គសិក្សា និងអាចសម្រេចផលបានពីកម្មវិធីសិក្សា។ គោលបំណងនៃវគ្គសិក្សាគឺជាអ្វីដែលអ្នកអប់រំចង់ឱ្យសិស្សស្វែងយល់ដឹងពីវគ្គសិក្សាតែម្តង(Fink, 2013)។ រីឯពាក្យ វត្ថុបំណងនៃការសិក្សា (Learning Objectives) ត្រូវបានបកស្រាយថាជាផលនៃបទពិសោធន៍រៀនសូត្ររបស់អ្នកសិក្សាចង់សម្រេចបានដោយត្រូវបានគេរៀបរាប់ពីផលដែលអាចវាស់វែងបាន។ វត្ថុបំណងនៃការសិក្សា(Learning Objectives) ត្រូវកំណត់ជាទិដ្ឋភាពដោយឡែកពីគ្នានៃលទ្ធផលសិក្សា និងគោលបំណងនៃការសិក្សា។ ជារួម វត្ថុបំណងនៃការសិក្សាត្រូវតែបញ្ចូលគ្នានូវលទ្ធផលសិក្សា និងគោលបំណងវគ្គសិក្សា។ ដើម្បីឱ្យលទ្ធផលសិក្សាមួយមានប្រសិទ្ធភាព(Effective Learning Outcomes)គឺត្រូវ៖

- មានសេចក្តីអត្ថាធិប្បាយច្បាស់លាស់ មានកិរិយាសព្ទដែលបញ្ជាក់ពីវត្ថុបំណងដែលចង់ឱ្យសិស្សចេះ និងធ្វើអ្វីមួយ
- មានការហ្វឹកហ្វឺនសកម្មភាព
- ប្រើគោលវិធីសិស្សមជ្ឈមណ្ឌល
- លទ្ធផលសិក្សាឆ្លើយតបទៅនឹងគោលបំណងនៃវគ្គសិក្សា
- ផលដែលសម្រេចបានត្រូវផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែង
- ហើយក៏អាចឆ្លើយតបទៅនឹងកម្រិតយល់ដឹងរបស់សិស្សបានសមស្របតាមទ្រឹស្តី ប្លូមតាក់ហ្សូណូមី(Bloom Taxonomy)ផងដែរ។

ចំណែកឯ សារប្រយោជន៍នៃលិខិតលទ្ធផលសិក្សា(Learning Outcome Statements)គឺបញ្ជាក់ពីអ្វីដែលសិស្សរំពឹងថានឹងចេះដឹង ចេះធ្វើ និងជាគុណតម្លៃច្បាស់លាស់មួយដែលត្រូវសម្រេចបានពីការសិក្សា ហើយលិខិតនេះនឹងជួយតម្រង់ពីជម្រើសនៃវិធីសាស្ត្របង្រៀន សម្ភារឧបទេស សកម្មភាពបង្រៀន និងការវាយតម្លៃ ព្រមទាំងវាអាចជួយដឹកនាំសិស្សឱ្យកំណត់ពីអ្វីដែលត្រូវរៀន វិធីរៀននៅក្នុងវគ្គសិក្សា(Gronlund & Brookhart, 2009; Krathwohl, 2002)។

ក្នុងការបកស្រាយ និងការស្រាវជ្រាវប្រធានបទនៃនិក្ខេបបទស្តីពី "**តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្ត**

**ព្រះសីហនុ**" នឹងផ្តោតទៅលើការចូលរួមរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅវិទ្យាល័យដោយមានសមាសភាពចូលរួមរបស់អាជ្ញាធរដែនដី មេឃុំ ចៅសង្កាត់ សប្បុរសជន គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកអាណាព្យាបាល មាតាបិតាសិស្ស និងសិស្សានុសិស្សផ្ទាល់។ ដើម្បីឆ្លើយតបទៅនឹងប្រធានបទនេះឱ្យកាន់តែស៊ីជម្រៅ តួនាទីរបស់អ្នកពាក់ព័ន្ធទាំងនេះ ពាក្យការចូលរួមរបស់សហគមន៍ចំពោះលទ្ធផលសិក្សានេះ នឹងត្រូវបកស្រាយពន្យល់ដូចតទៅៈ

ការចងក្រងសហគមន៍ជាផ្នែកមួយនៃដំណើរការអភិវឌ្ឍសង្គមក្នុងគោលបំណង ធ្វើការផ្លាស់ប្តូរឥរិយាបថស្ពឹកស្រពន់ អាត្មានិយម និងប្រជាពលរដ្ឋដែលគ្មានសំឡេងគ្មានអំណាចឱ្យមានភាពស្វាហាប់មានការចូលរួម និងជាសហគមន៍មួយប្រកបដោយការទទួលខុសត្រូវដែលសំដៅលើការប្រមូលផ្តុំកម្លាំងពិតដែលនៅជុំវិញ ដើម្បីឆ្លើយតបនឹងការកកើតមាននូវវិវាទ បង្ខំឱ្យមានទំនាក់ទំនង និងភាពច្របូកច្របល់។ ផ្ទុយទៅវិញ សហគមន៍គឺត្រូវបានគេប្រើដើម្បីចងក្រងប្រជាពលរដ្ឋឱ្យមានសាមគ្គីភាពរឹងមាំ ហើយមានឥទ្ធិពលទៅលើដំណើរការនៃការសម្រេចចិត្ត។ ដូច្នេះ វាមានន័យថា ប្រជាពលរដ្ឋត្រូវបញ្ចេញមតិ ទទួលបានព័ត៌មាន និងសកម្មភាពទាំងឡាយព្រមទាំងការអនុវត្តទៅលើការសម្រេចចិត្តរួមគ្នា។ ការចងក្រងសហគមន៍គឺជាសិល្បៈ ឬជំនាញ ឬក៏ជាវិធីសាស្ត្រក្នុងការកៀងគរមនុស្ស ដើម្បីជួយឱ្យពួកគេចេះគិតបានគ្រប់ជ្រុងជ្រោយ។ ជាទូទៅ គេចងក្រងសមាជិកក្រុមមួយឱ្យទៅជានីតិបុគ្គលដូចជាៈ សហគមន៍ និងសមាគមជាដើម (CCFC Cambodia, 2016)។ យ៉ាងណាមិញ សហគមន៍នៅក្នុងកិច្ចការស្រាវជ្រាវនិក្ខេបបទនេះ គឺសំដៅដល់សហគមន៍សាលារៀនដែលត្រូវបានចងក្រងឡើងដោយសមាសភាពពីអាជ្ញាធរដែនដី ភាគីសាលារៀន អ្នកអាណាព្យាបាលសិស្ស សប្បុរសជន និងភាគីពាក់ព័ន្ធនានា ពោលអ្នកដែលស្ថិតក្នុងភូមិសិក្សា ហើយមានឆន្ទៈចូលរួម សហការគ្នាជួយដល់ការអភិវឌ្ឍគុណភាពអប់រំសម្រាប់ទាំងអស់គ្នា។

ជាសេចក្តីសន្និដ្ឋាន និក្ខេបបទស្តីពី "**តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**" នឹងចង្អុលបង្ហាញឱ្យឃើញនូវសារៈប្រយោជន៍នៃការចូលរួមនានាតាមតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងសហគមន៍ក្នុងការជួយលើកកម្ពស់គុណភាពអប់រំរបស់សិស្សនៅកម្រិតវិទ្យាល័យ។

## ២.២. រំលឹកទ្រឹស្តី

### ២.២.១. យន្តការផ្សារភ្ជាប់សាលារៀន និងសហគមន៍

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលមានព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិសេរីភាពស្មើគ្នាក្នុងការចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ មានសិទ្ធិបង្កើតសហជីព

និងចូលជាសមាជិកដោយស្របតាមច្បាប់កំណត់។ រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេស នារីនៅជនបទដែលគ្មានទីពឹងឱ្យទទួលបានការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។ ប្រជាពលរដ្ឋត្រូវបានទទួលបានការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ និងការសិក្សានៅសាលារៀនចំណោះទូទៅសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតគិតថ្លៃ(រដ្ឋធម្មនុញ្ញ, ២០០៨)[43]។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាផ្នែកមួយនៃកំណែទម្រង់សាធារណៈដើម្បីប្រគល់មុខងារ និងធនធានពីក្រសួងទៅឱ្យអាជ្ញាធរមូលដ្ឋានធ្វើការពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់ការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រ។ គោលដៅរួមរបស់កម្មវិធីនេះគឺដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ពន្លឿនកំណើនសេដ្ឋកិច្ច និងផ្តល់ឱកាសប្រកបដោយសមធម៌ដល់ប្រជាពលរដ្ឋគ្រប់រូប។ គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំមានគោលបំណងពង្រឹងការចូលរួម ការទទួលខុសត្រូវ ជានាតម្លាភាព និងប្រសិទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការពង្រឹងយន្តការស្វ័យភាពគ្រឹះស្ថានសិក្សាសាធារណៈ និងរៀបចំធ្វើការផ្ទេរមុខងារ និងធនធានវិស័យអប់រំ យុវជន និងកីឡាឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កិតសេវាអប់រំជូនប្រជាជនស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ(អយក, ២០១៦)[44] ។ ក្នុងការឆ្លើយតបទៅនឹងគោលបំណង និងការប្តេជ្ញាចិត្តខាងលើនេះក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតយន្តការណែនាំ និងក្របខណ្ឌគតិយុត្តិមួយចំនួនដូចខាងក្រោម៖។

**ក. សេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន (២០២១)**

"**ការបង្កើនល្បឿនអភិបាលកិច្ចតាមរយៈការធ្វើវិមជ្ឈការអំណាចទៅមូលដ្ឋាន ក្នុងគោលបំណងធ្វើឱ្យសេវាសាធារណៈអាចបម្រើផលប្រយោជន៍ប្រសើរបំផុតសម្រាប់ប្រជាជន និងការកសាងជាតិ**" គឺជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ហើយក្រសួងអប់រំ យុវជន និងកីឡាក៏បានអនុវត្តខ្លឹមសារគោលនេះដោយដាក់ចេញនូវគោលនយោបាយ ការកែលម្អគុណភាពអប់រំ ការកសាងសមត្ថភាពដឹកនាំ និងការគ្រប់គ្រងអប់រំមកធ្វើជាក្របខណ្ឌប្រតិបត្តិស្តីពី "**យុទ្ធសាស្ត្រសហគមន៍សាលារៀន**" ជាលទ្ធផល បីឆ្នាំនៃការអនុវត្តការងារក្នុងក្របខណ្ឌយុទ្ធសាស្ត្រស្នូលនេះគឺ៖ ដើម្បីពន្លឿនអភិបាលកិច្ចតាមរយៈវិមជ្ឈការអំណាចពីថ្នាក់កណ្តាលទៅសាលារៀន និងសហគមន៍ ជាពិសេសគឺដើម្បីបម្រើផលប្រយោជន៍ប្រសើរបំផុតដល់សិស្ស និងសហគមន៍(អយក, ២០២១)[45]។ ភាពពិតនៃសមធម៌អប់រំគឺមានការកើនឡើងទាំងបរិមាណ និងគុណភាពរៀនសូត្រដោយសារតែមានកិច្ចសហការល្អពីថ្នាក់ដឹកនាំគោលនយោបាយ មន្ត្រីអប់រំថ្នាក់ជាតិ និងក្រោមជាតិ នាយកសាលា និងគ្រូបង្រៀនបានបណ្តុះនូវសុជីវធម៌បុគ្គល ធ្វើតែអំពើល្អដើម្បីផលប្រយោជន៍សិស្ស និងសហគមន៍។ យ៉ាងណាមិញ គុណតម្លៃនៃទំនួលខុសត្រូវតាមតួនាទី

---

[43] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២០០៨ ជំពូក ៣, ទំព័រ ១១

[44] គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ, ២០១៦, បុព្វកថា

[45] ផែនការយុទ្ធសាស្ត្រសហគមន៍សាលារៀន, ២០២១, ទំព័រ ៨

ពីគ្រប់ភាគីពាក់ព័ន្ធបានសម្រេចចិត្ត និងបានអនុវត្តនូវអ្វីដែលថ្មី អ្វីដែលមានប្រយោជន៍ដល់សិស្ស សហគមន៍ និងសង្គមដូចជា៖ នាយកសាលា គ្រូបង្រៀន សិស្ស និងសហគមន៍សហការធ្វើការជាមួយគ្នា គ្រូខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន សហគមន៍ចូលរួមជួយឧបត្ថម្ភដល់គ្រូ អាជ្ញាធរមូលដ្ឋានឧបត្ថម្ភគាំទ្រសាលា សហគមន៍សប្បាយចិត្តដោយឃើញកូនចៅខិតខំរៀនសូត្រ។ ការអនុវត្តការគ្រប់គ្រងតាមសាលារៀនដែលមានប្រសិទ្ធភាពនាពេលកន្លងមកនេះ មន្ត្រីអប់រំបានផ្លាស់ប្តូរឥរិយាបថការងារ គ្រូបង្រៀនសហការគ្នា និងចេះចែករំលែកចំណេះដឹង និងបទពិសោធន៍ការងារ ជាពិសេសលទ្ធផលសិក្សារបស់សិស្សមានការប្រែប្រួលជាវិជ្ជមានគួរឱ្យកត់សម្គាល់ ដោយអនុលោមតាមយុទ្ធសាស្ត្រសហគមន៍សាលារៀន(អយក, ២០២១)[46]។




(រូបភាពទី ៤៖ យុទ្ធសាស្ត្រសហគមន៍សាលារៀន, អយក, ២០១៨)

**តារាងទី ២៖ តួនាទីរបស់សហគមន៍សាលារៀន**

| តួនាទី | យុទ្ធសាស្ត្រ(៦អា) |
|---|---|
| នាយកសាលា | ១. ការធ្វើតេស្តស្តង់ដា |
| គណៈកម្មការគ្រប់គ្រងសាលារៀន | ២.ការប្រើអំណាចសម្រេចចិត្ត |
| នាយកសាលា | ៣. ការបង្ហាញគណនេយ្យភាព |
| គណៈកម្មការគ្រប់គ្រងសាលារៀន | ៤. ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន |
| នាយកសាលា | ៥. ការយកចិត្តទុកដាក់ដល់វប្បធម៌ និងគុណតម្លៃ |
| គណៈកម្មការគ្រប់គ្រងសាលារៀន | ៦. ការយកចិត្តទុកដាក់ដល់សិស្ស(កុមារតូច) |

ដើម្បីឱ្យដំណើរការអនុវត្តសកម្មភាពទៅបានរលូន សហគមន៍សាលារៀនត្រូវមានការព្រមព្រៀងនូវគុណតម្លៃសហគមន៍សាលារៀនមួយចំនួនដូចជា៖ ១. បម្រើផលប្រយោជន៍រួម និងប្រសើរបំផុតសម្រាប់

[46] ផែនការយុទ្ធសាស្ត្រសហគមន៍សាលារៀន, ២០២១, ទំព័រ ១

ប្រជាជន និងសិស្ស ២. គោរព និងថែទាំគ្នាទៅវិញទៅមក ៣. រៀនសូត្រ និងធ្វើការជាក្រុមជាប់ជាប្រចាំ ៤. ផ្តួចផ្តើមគំនិតថ្មីសម្រាប់អភិវឌ្ឍសាលារៀន និងសហគមន៍ ៥. ធ្វើឱ្យមាននិរន្តរភាពដំណើរការសាលារៀន និងរៀបចំសិស្សរបស់យើងសម្រាប់រស់ជាមួយជីវិត និងការងារដែលប្រសើរ ដោយផ្អែកលើប្រព័ន្ធផ្តល់លទ្ធភាពអនុវត្តតាមរចនាសម្ព័ន្ធច្បាស់លាស់នៃយុទ្ធសាស្ត្រសហគមន៍សាលារៀនជាគណៈកម្មការគ្រប់គ្រងសាលារៀន(គគស) និងជាក្រុមប្រឹក្សាសាលារៀន(កបស)។ គណៈកម្មការនេះមានរចនាសម្ព័ន្ធផ្លូវការ មានតួនាទីទទួលខុសត្រូវ និងគ្រប់គ្រងការអនុវត្តការគ្រប់គ្រងសាលារៀនប្រចាំថ្ងៃ និងអភិវឌ្ឍសាលារៀនដែលមានសមាជិកយ៉ាងតិចប្រាំមួយនាក់ ហើយត្រូវបានជ្រើសរើសពីសហគមន៍ គ្រួសារក្រីក្រ ឬអ្នកមាន ឬជីវភាពមធ្យម ប្រធានភូមិ ប្រជាជនដែលមានការគោរពពីសហគមន៍ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ រដ្ឋអំណាចក្រុងស្រុកខណ្ឌ មន្ត្រីឃុំ មន្ត្រីមន្ទីរពេទ្យ ឬសុខាភិបាល មន្ត្រីរាជការ សហគមន៍មានបំណិនវិជ្ជាជីវៈ និងសិស្ស ឬសមាជិកក្រុមប្រឹក្សាយុវជនជាដើម ជាបន្តក្នុងការអនុវត្តការងារបានល្អ អាចប្រែក្លាយជាក្រុមប្រឹក្សាសាលារៀននៅឆ្នាំបន្ទាប់ដោយមានការអនុម័តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌតាម រយៈការិយាល័យអប់រំ យុវជន និងកីឡា(អយក, ២០២១)[(47)]។




(រូបភាពទី ៥៖ រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសាលារៀន, អយក, ២០១៨)

## ខ. សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន (២០១៨)

ដើម្បីប្រតិបត្តិកំណែទម្រង់យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា រួមនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយល់ឃើញថា សាលារៀននឹងត្រូវក្លាយជាកន្លែងផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាបន្ន ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀនត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍បីធំៗ

[47] ផែនការយុទ្ធសាស្ត្រសហគមន៍សាលារៀន, ២០២១, ទំព័រ ១២

គឺ៖ ១. ការពង្រឹងសមត្ថភាពប្រព័ន្ធអប់រំដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន ២. ការពង្រឹងប្រសិទ្ធភាពគ្រូបង្រៀនតាមរយៈការអនុវត្តការគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន និង ៣. ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងស្វ័យភាព និងគណនេយ្យភាពសាលារៀន(អយក, ២០១៨)[48]។ ដើមចមផ្តើមចេញពីការអនុវត្តគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ និង ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលដើម្បីកែលម្អគុណភាពអប់រំការគ្រប់គ្រងតាមសាលារៀន ត្រូវតែប្រតិបត្តិទៅដោយមានប្រសិទ្ធភាព និងប្រសិទ្ធផលដោយអនុលោមទៅតាមសកម្មភាពចំនួនបីដូចជា៖ ១. ពង្រឹងការគ្រប់គ្រងតាមសាលារៀន ២. បំប៉នបន្ថែម និងផ្តល់ការគាំទ្រផ្ទាល់ដល់គ្រូបង្រៀន និង ៣. សាងសង់ និងកែលម្អអគារសិក្សា និងបរិស្ថានសិក្សា។ យ៉ាងណាមិញ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ មានកម្មវិធីកំណែទម្រង់ចំនួន ៣ ដែលទាក់ទងនឹងវិស័យអប់រំដែរគឺ៖ កម្មវិធីកំណែទម្រង់ទី ១ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់ទី ៣ ផ្តោតលើការលើកកម្ពស់ការផ្សារភ្ជាប់គ្នារវាងថវិកាគោលនយោបាយ និងក្រុមគោលដៅសេវា និងដំណាក់កាលទី ៤ ផ្តោតលើការធានានូវគណនេយ្យភាពក្នុងការចំណាយទាំងលើកម្មវិធីរបស់វិស័យអប់រំ និងហិរញ្ញវត្ថុ។ កម្មវិធីកំណែទម្រង់ទី២ រដ្ឋបាលសាធារណៈ ផ្តោតលើការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ ការអភិវឌ្ឍសមត្ថភាព និងកែទម្រង់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភ។ កម្មវិធីកំណែទម្រង់ទី ៣ ប្រជាធិបតេយ្យ និងការអភិវឌ្ឍថ្នាក់ក្រោមជាតិ ផ្តោតលើការអនុវត្តច្បាប់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័នរដ្ឋ និងពង្រីកប្រសិទ្ធផលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ(អយក, ២០១៨)[49]។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់ត្រូវពង្រឹងគណនេយ្យភាពក្នុងប្រព័ន្ធអប់រំ ដើម្បីធានាថាសាលារៀនទទួលបានធនធាន (គ្រូបង្រៀន និងសម្ភាររូបវន្ត)ដែលមានគុណភាព ស្របតាមនិយាមស្តង់ដាកំណត់ ហើយសាលារៀនត្រូវប្រើប្រាស់ធនធានទាំងនោះឱ្យអស់ពីលទ្ធភាព។ ចំពោះស្ថាប័នថ្នាក់ក្រោមជាតិ (សាលារៀន)ត្រូវខិតខំពង្រឹងខ្លួនឱ្យក្លាយជាសាលារៀនមានឧត្តមានុវត្ត និងបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាពដោយមានការអន្តរាគមន៍ និងផ្តល់ការគាំទ្រពីក្រសួង និងមន្ទីរសាមី។ ការចូលរួម និងការប្តេជ្ញាចិត្តរបស់មន្ត្រីអប់រំនៅគ្រប់កម្រិត របស់សិស្សានុសិស្ស របស់សហគមន៍ និងមាតាបិតា/អ្នកអាណាព្យាបាល ជាតួអង្គសំខាន់ខ្វះមិនបានក្នុងការអនុវត្តអភិក្រម **ការគ្រប់គ្រងតាមសាលារៀន** នេះ(អយក, ២០១៨)[50]។

[48] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨, ទំព័រ ៥

[49] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨, ទំព័រ ៦

[50] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨, ទំព័រ ៦

**ក្របខ័ណ្ឌនៃគំនិតវិមជ្ឈការ ៖ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានឆ្ពោះទៅរកគណនេយ្យភាព**




(រូបភាពទី ៦៖ លំនាំនៃការគ្រប់គ្រងតាមសាលារៀន, អយក, ២០១៨)

### គ. គណៈកម្មការអភិវឌ្ឍន៍សាលារៀន (២០១៧)

ជាការឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍខឿនសេដ្ឋកិច្ចជាតិ ការអប់រំនៅកម្ពុជាត្រូវតែមានគុណភាព និងប្រសិទ្ធភាព។ ការអប់រំអាចទទួលបានគុណភាពតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសនាយកសាលារៀន និងគ្រូបង្រៀនត្រូវតែប្រកបដោយគុណវុឌ្ឍិច្បាស់លាស់។ ស្របគ្នានេះដែរ ការអភិវឌ្ឍសាលារៀនត្រូវតែមានការបង្កើតគណៈកម្មការអភិវឌ្ឍន៍សាលារៀនដោយចងក្រងជារចនាសម្ព័ន្ធគ្រប់គ្រងមួយច្បាស់លាស់ ប្រកបដោយការទំនួលខុសត្រូវ មានគណនេយ្យភាព មានតម្លាភាពអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អជាពិសេសការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការពោលគឺ៖ ការគ្រប់គ្រងដឹកនាំសាលារៀនត្រូវតែមានការយកចិត្តទុកដាក់ពីថ្នាក់មូលដ្ឋាន សហគមន៍ និងគ្រប់ភាគីពាក់ព័ន្ធទើបអាចទទួលបានគុណផលលើប្រសិទ្ធភាពនៃការផ្ដល់សេវាអប់រំ។ អាស្រ័យហេតុនេះ ទើបក្រសួងអប់រំយុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជារៀបចំចងក្រងឯកសារណែនាំទាំងនេះឡើងដើម្បីបង្ហាញពី៖ ១. យន្តការនៃការរៀបចំបង្កើតគណៈកម្មការអភិវឌ្ឍសាលារៀនរួមមានរចនាសម្ព័ន្ធតួនាទី ភារកិច្ច និងដំណើរការបង្កើតគណៈកម្មការអភិវឌ្ឍន៍សាលារៀន ២. សកម្មភាពរបស់ក្រុមការងារគណៈកម្មការអភិវឌ្ឍន៍សាលារៀនមានដូចជា៖ ការរៀបចំផែនការ ការអនុវត្តផែនការ ការតាមដាន និងការវាយតម្លៃផែនការសកម្មភាពរបស់គណៈកម្មការអភិវឌ្ឍន៍សាលារៀន(អយក, ២០១៧)([51])។ ក្នុងការអនុវត្តជាក់ស្ដែងនៅថ្នាក់មូលដ្ឋាន គណៈកម្មការនេះត្រូវបានបង្កើតឡើងដើម្បីប្រមូលផ្ដុំ និងចងក្រងបានជាគណកម្មការអភិវឌ្ឍន៍សាលារៀន ដែលមានសមាសភាពចូលរួមដូចជា៖ គណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការថ្នាក់រៀន ក្រុម

[51] គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, អារម្ភកថា

បច្ចេកទេស គ្រូបង្រៀន ក្រុមប្រឹក្សាយុវជន/កុមារ និងអ្នកពាក់ព័ន្ធទាំងឡាយដូចជា៖ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធផ្សេងៗ នៅក្នុងសហគមន៍។ គណៈកម្មការអភិវឌ្ឍន៍សាលារៀនត្រូវទទួលខុសត្រូវលើកិច្ចការមួយចំនួនរួមមាន៖ ការងារត្រៀមឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ការងារគណនេយ្យភាពសង្គម ការងារឃោសនាអប់រំ និងបណ្តុះបណ្តាលការងារជួយដល់កុមារងាយរងគ្រោះ(ពិការ ជនជាតិភាគតិច និងជនក្រីក្រ) ការងារលុបបំបាត់អំពើហិង្សាលើផ្លូវកាយ ផ្លូវចិត្ត និងកេងប្រវ័ញ្ចគ្រប់រូបភាពដល់កុមារ ការងារលើកទឹកចិត្តដល់គ្រូបង្រៀនក្នុងការអនុវត្តតួនាទី និងភារកិច្ចបង្រៀន ការងារគ្រប់គ្រងស្ថិតិទិន្នន័យអប់រំ សុខភាព សេដ្ឋកិច្ច សង្គមកិច្ច ការងាររៀបចំមណ្ឌលអានសម្រាប់កុមារនៅតាមក្លឹបសិក្សា ការងារផ្តល់សេវាសុខភាពសុវត្ថិភាព និងការកសាងហេដ្ឋារចនាសម្ព័ន្ធជាដើម(អយក, ២០១៧)[52]។




(រូបភាពទី ៧៖ រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលសាលារៀន, អយក, ២០១៧)

គណៈកម្មការអភិវឌ្ឍន៍សាលារៀនគឺមានសមាសភាពមកពី៖ ១.សាលារៀនរួមមាន៖ គណៈកម្មការទ្រទ្រង់សាលារៀន គណៈគ្រប់គ្រងសាលារៀន ក្រុមបច្ចេកទេស គ្រូបង្រៀន ក្រុមប្រឹក្សាយុវជន/កុមារ ២. អាជ្ញាធរដែនដី៖ មេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ ស្មៀនឃុំ មេភូមិ នារីភូមិ មណ្ឌលសុខភាពឃុំ នគរបាលប៉ុស្តិ៍រដ្ឋបាល ចៅអធិការវត្ត អាចារ្យ ចាស់ព្រឹទ្ធាចារ្យ ព្រមទាំងសប្បុរសជន....។ សមាសភាពទាំងឡាយដែលបានរៀបរាប់ខាងលើត្រូវបានរៀបចំទៅជាក្រុមការងារតូចៗស្របទៅតាមជំនាញ និងបទពិសោធន៍ការងារជាក់ស្តែងនៅមូលដ្ឋានដែលមានឈ្មោះថា ក្រុមការងាររបស់គណៈកម្មការអភិវឌ្ឍសាលារៀន ដើម្បីមានភាពងាយស្រួលក្នុងការជួយដោះស្រាយ

[52] គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, ទំព័រ ៥

នូវបញ្ហាប្រឈមចំពោះមុខបានឆាប់រហ័ស ទាន់ពេលវេលា ព្រមទាំងមានការទទួលខុសត្រូវខ្ពស់(អយក, ២០១៧)[53] ។




(រូបភាពទី ៨៖ គណៈកម្មការអភិវឌ្ឍសាលារៀន, អយក, ២០១៧)

## ឃ. ការគ្រប់គ្រងថវិកាសាលារៀន (២០១៧)

ក្នុងបរិបទនៃការគ្រប់គ្រងសាលារៀនឱ្យមានប្រសិទ្ធភាព ទាមទារការយកចិត្តទុកដាក់លើសមាសធាតុសំខាន់ៗ នៃការគ្រប់គ្រងអប់រំរួមមាន៖ ១. ការគ្រប់គ្រងរដ្ឋបាល ២. ការគ្រប់គ្រងការបង្រៀន និងរៀន ៣. ការគ្រប់គ្រងបុគ្គលិក និង ៤. ការគ្រប់គ្រងហិរញ្ញវត្ថុ(ម៉ម, ២០២១)[54]។ ដូចនេះ ការគ្រប់គ្រងថវិកាជាផ្នែកមួយយ៉ាងសំខាន់ សម្រាប់កិច្ចសហការដ៏ជិតស្និទ្ធជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស សប្បុរសជន និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ក្នុងការប្រើប្រាស់ថវិកាឱ្យមានតម្លាភាព សុច្ចរិតភាព និងចំទិសដៅតាមដែលនាយកសាលាបានគ្រោងទុកដើម្បីជួយអភិវឌ្ឍកែលម្អសោភ័ណភាពសាលា ការបង្រៀនរបស់គ្រូ ការសិក្សារបស់សិស្សឱ្យបានលទ្ធផលល្អប្រសើរជាទីគាប់ចិត្ត និងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស មាតាបិតាសិស្ស សហគមន៍ផងដែរ។ លើសពីនេះទៅទៀត ការគ្រប់គ្រងថវិកាសាលារៀនមានដំណើរការប្រកបដោយតម្លាភាព និងប្រសិទ្ធភាពត្រូវអនុវត្តតាមការបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវក្នុងការទទួល ទុកដាក់ ចំណាយ និងផ្សព្វផ្សាយពីថវិកាសាលារៀនជាមួយការចូលរួមសម្រេចចិត្ត និងត្រួតពិនិត្យប្រកបដោយគុណភាពពីអ្នកពាក់ព័ន្ធតាមរយៈការរៀបចំ ដឹកនាំ ចងក្រង និងផ្សព្វផ្សាយគោល

---

[53] គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, ទំព័រ ៦

[54] បទបង្ហាញមុខវិជ្ជា ការគ្រប់គ្រងផែនការ និងរដ្ឋបាលអប់រំ, បណ្ឌិតម៉ម ចាន់សៀន, ២០២១

ការណ៍ និងសេចក្ដីណែនាំស្ដីពីការគ្រប់គ្រងថវិកាសាលារៀនពីនាយកសាលា។ ការរៀបចំការគ្រប់គ្រងថវិការបស់សាលារៀនគឺមានគោលបំណងសំខាន់ៗដូចតទៅៈ

១. ដើម្បីធានាអំពីតម្លាភាព និងគណនេយ្យភាពនៃការប្រើប្រាស់ថវិកានៅសាលារៀន ស្របតាមគោលការណ៍ និងសេចក្ដីណែនាំស្ដីពីការគ្រប់គ្រងថវិកាសាលារៀន។

២. ដើម្បីកៀរគរធនធានពីសហគមន៍ និងពីប្រភពផ្សេងៗយកមកអភិវឌ្ឍសាលា

គោលការណ៍នៃការគ្រប់គ្រងថវិការបស់សាលារៀន នឹងបង្កឱ្យមានឱកាសចូលរួមទទួលខុសត្រូវកសាងទំនុកចិត្ត និងសម្រេចផែនការអភិវឌ្ឍន៍សាលារៀនប្រកបដោយតម្លាភាព ហើយវាក៏ជាមូលដ្ឋានដ៏សំខាន់ក្នុងការទាក់ទាញកិច្ចគាំទ្រ និងទំនុកចិត្តពីឪពុកម្ដាយសិស្ស អាជ្ញាធរដែនដី និងភាគីទាំងឡាយណាដែលធ្វើការជាមួយសាលារៀនតាមរយៈការជួយកៀរគរថវិកា ព្រមទាំងជួយផ្សព្វផ្សាយបន្តពីការងារអប់រំក្នុងផែនការវិនិយោគឃុំផងដែរ(អយក, ២០១៧)[55]។




(រូបភាពទី ៩ៈ រចនាសម្ព័ន្ធការគ្រប់គ្រងថវិកាសាលារៀន, អយក, ២០១៧)

### ២.២.២. ការចូលរួមរបស់សហគមន៍

ទាក់ទងនឹងការពង្រឹងគុណភាពអប់រំ សាលារៀនជាតួអង្គដ៏សំខាន់ក្នុងការប្រតិបត្តិកិច្ចការផ្ដល់ចំណេះដឹង បំណិនសម្បទា បច្ចេកទេស និងជំនាញដោយមានការចូលរួមពីមជ្ឈដ្ឋានគ្រួសារ និងសហគមន៍។ តើការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំមានអត្ថន័យយ៉ាងដូចម្ដេច?

តាមការសិក្សាស្រាវជ្រាវ ការចូលរួមរបស់សហគមន៍(Community Involvement in School) សំដៅដល់ទំនាក់ទំនងរវាងសាលារៀន និងរូបវន្តបុគ្គល ពាណិជ្ជករ និងអង្គភាពផ្លូវការ និងមិនផ្លូវការ ព្រម

[55] ឯកសារប្រតិបត្តិស្ដីពី ការគ្រប់គ្រងថវិកាសាលារៀន, ២០១៧, ទំព័រ ៤, ៥

ទាំងស្ថាប័នដទៃទៀត ដែលមាននៅក្នុងសហគមន៍នោះ(Mavis G. Sanders, 2003) ។ម្យ៉ាងទៀត ការចូលរួមក្នុងរូបភាពនេះ ក៏ជាការចូលរួមរបស់គ្រួសារផងដែរ (Family Involvement &Participation) គឺដោយសារតែការចូលរួមរបស់សហគមន៍ត្រូវបានគិតគូរដល់ការពាក់ព័ន្ធនឹងមាតាបិតា អ្នកអាណាព្យាបាលសិស្ស។ ភាពជាដៃគូរបស់សាលារៀន គ្រួសារ និងសហគមន៍(អាជ្ញាធរដែនដី)គឺជាមធ្យោបាយដ៏ល្អប្រសើរក្នុងការកំណត់សកម្មភាពរបស់សាលារៀនទាំងមូលរួមទាំងសហគមន៍ ដែលអ្នកពាក់ព័ន្ធទាំងអស់ត្រូវចែករំលែកការទទួលខុសត្រូវរួមគ្នាចំពោះការសិក្សា និងការអភិវឌ្ឍរបស់សិស្ស(Epstein &Sheldon, 2006) ។ ការចូលរួមរបស់សហគមន៍គឺជា បញ្ញត្តិដ៏ស្មុគ្រស្មាញ និងមានច្រើនវិស័យខុសៗគ្នាទៅតាមការអនុវត្តនៅតាមកម្រិតមិនដូចគ្នា ក្នុងវិធីសាស្ត្រមិនដូចគ្នា ព្រមទាំងតម្រូវឱ្យមានភាពជាអ្នកដឹកនាំផងដែរ (Sanchez, 1999; Esptien, 2001, Delga Do-Gaitan, 2001; Garcia, 2002)។ នៅកម្ពុជា ដើម្បីធានាថាសាលារៀនទទួលបានធនធាន(គ្រូបង្រៀន និងសម្ភាររូបវន្ត) ដែលមានគុណភាពស្របតាមនិយាម/ស្តង់ដាកំណត់ ហើយសាលាត្រូវប្រើប្រាស់ធនធានទាំងនោះឱ្យអស់ពីលទ្ធភាពត្រូវតែមានការចូលរួម និងផ្តល់ការគាំទ្រពីមន្ត្រីអប់រំនៅគ្រប់កម្រិត សិស្សានុសិស្ស អាជ្ញាធរ មាតាបិតា អ្នកអាណាព្យាបាលជាកត្តាចាំបាច់ដែលមិនអាចខ្វះបានឡើយ(អយក, ២០១៨)[56]។ បើផ្អែកតាមផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន ២០១៩-២០២៣ បានលើកឡើងថា៖ ការចូលរួមនៅក្នុងសាលារៀនជាការចូលរួមរបស់កុមារនៅក្នុងសេចក្តីសម្រេចវិធានរបស់សាលារៀន សកម្មភាពសាលារៀន ព្រឹត្តិការណ៍របស់សាលារៀន និងការយល់ឃើញវិជ្ជមានអំពីការចូលរួមនៅក្នុងសាលារៀន(អយក, ២០១៨)។ ម្យ៉ាងវិញទៀត ជាសាក្ខីកម្មចំពោះដើមចមក្នុងការស្រាវជ្រាវនេះ មាននិក្ខេបបទរបស់រៀមច្បងមួយចំនួនបានសិក្សាស្វែងយល់ពីការសហការរបស់សាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងសហគមន៍លើការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួននៅក្នុងសហគមន៍សាលារៀនចំនួន៤ក្នុងខេត្តព្រះសីហនុ។ ជាលទ្ធផល សាលារៀនដែលមានការគាំទ្រពីគណៈកម្មការគ្រប់គ្រងសាលារៀនមានការរីកចម្រើន និងលទ្ធផលសិក្សារបស់សិស្សល្អជាងសាលានានាដែលមិនមានការចូលរួម។ តែផ្ទុយទៅវិញ ការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនឹងមិនអាចសម្រេចបានតាមផែនការនោះទេ បើមិនមានការចូលរួមពីសហគមន៍ និងភាគីពាក់ព័ន្ធនានា។ ជាទឡ្ហីករណ៍ ការសិក្សាមួយចំនួនក៏បានលើកឡើងហើយដែរថា៖ ការបំពេញតួនាទីរបស់គណៈកម្មការគ្រប់គ្រងសាលារៀននៅមានកម្រិត ព្រោះបណ្តាលមកពីបញ្ហាប្រឈមបួនធំៗគឺ៖ កង្វះសិល្បៈនៃការធ្វើទំនាក់ទំនងរវាងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលា ទីពីរ គឺភាពធកល្វែងរបស់សាលារៀនក្នុងការអនុវត្តនីតិវិធីលើការបង្កើតគណៈកម្មការ ទីបី ភាពមិនច្បាស់លាស់អំពីតួនាទីក្នុងការចូលរួមរបស់គណៈគ្រប់គ្រងសាលា និងទីបួនគឺការយកចិត្តទុកដាក់ និងលទ្ធភាពកៀរគរ

[56] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, ២០១៨, ទំព័រ ៧

ជំនួយនៅមានកម្រិតរបស់គណៈកម្មការគ្រងគ្រងសាលារៀន។(ម៉ី &លឿង &អ៊ុំ &សេង &ផល &ឡាយ, 2021)[57]។ លើសពីនេះទៀត មានការសិក្សាពីការចូលរួមរបស់សហគមន៍ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅវិទ្យាល័យ១០ ក្នុងខេត្តស្វាយរៀង ក៏បានបង្ហាញឱ្យឃើញថា ការចូលរួមរបស់សហគមន៍មិនសូវបានល្អដោយបញ្ហាប្រឈមមួយចំនួនដូចជា៖ ទីមួយ គ្រួសារមានជីវភាពខ្វះខាត ទីពីរ រវល់ធ្វើការ និងរកចំណូលចិញ្ចឹមគ្រួសារ ទី៣ មាតាបិតាសិស្សខ្លះគិតថាឱ្យកូនទៅរៀននៅសាលាគឺគ្រប់គ្រាន់ហើយ ទីបួន គ្មានជំនាញច្បាស់លាស់ និងទីប្រាំ មាតាបិតាសិស្សខ្លះមានកម្រិតវប្បធម៌ទាប(ផាន់, ២០២១)[58]។ កត្តាទាំងអស់នេះហើយ ដែលនាំឱ្យលទ្ធផលសិក្សារបស់សិស្សមិនសូវមានគុណភាព ហើយក៏មិនបានឆ្លើយតបទៅនឹងតម្រូវការសង្គមផងដែរ។

### ២.២.៣. តួនាទីរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន

ការអភិវឌ្ឍសង្គមអាចប្រព្រឹត្តទៅបានល្អ និងមានស្ថិរភាពយូរអង្វែង លុះត្រាតែ ក្នុងការអភិវឌ្ឍនេះមានការចូលរួមយ៉ាងសកម្មពីសំណាក់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដែលក្នុងនោះមានផ្នែកឯកជន អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ប្រជាពលរដ្ឋទាំងបុរស និងនារី (អយក, ២០១៤)[59]។ ជារួម សិស្សានុសិស្សក៏នៅជាកុមារដែលត្រូវទទួលបានការគាំពារ និងការយកចិត្តទុកដាក់ពីមនុស្សពេញវ័យយោងតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ដែលមានសិទ្ធិធំៗចំនួនបួនគឺ៖ សិទ្ធិរស់រានមានជីវិត សិទ្ធិក្នុងការអភិវឌ្ឍ សិទ្ធិទទួលការការពារ និងសិទ្ធិចូលរួម។ ដូចនេះ ក្នុងនាមជាឪពុកម្ដាយ អ្នកអាណាព្យាបាល គ្រូបង្រៀន និងសមត្ថកិច្ចសាធារណៈត្រូវទទួលខុសត្រូវ និងត្រូវគិតគូរដល់ផលប្រយោជន៍របស់សិស្សជាចម្បង។ អាស្រ័យហេតុនេះ ប្រសិទ្ធភាពនៃការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស សហគមន៍ និងសាលារៀនត្រូវតែមានទំនាក់ទំនងគ្នាយ៉ាងពេញទំហឹងដោយត្រូវប្រកាន់ភ្ជាប់នូវតួនាទី និងភារកិច្ចដូចចែងក្នុងសៀវភៅណែនាំប្រតិបត្តិស្ដីពីការគ្រប់គ្រងសាលារៀននៃគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ ២០១៨។ ខាងក្រោមនេះ គឺជាតួនាទីភារកិច្ចរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀនដែលផ្ដោតលើការចូលរួមរបស់មាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងសហគមន៍ក្នុងនាមជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀនដូចជា៖

**១. ការចូលរួមក្នុងការគ្រប់គ្រង ការអនុវត្តការងាររបស់មន្ត្រី និងការពិនិត្យតាមដានសាលារៀន**

[57] ការសិក្សាលើការចូលរួមរបស់គណៈកម្មការគ្រប់គ្រងសាលានៅបឋមសិក្សា, មី សេងលាក, លឿង ពេជ្រ, អ៊ុំ ស៊ីថេត, សេង វណ្ណដា, ផល ដៀប, និង ឡាយ សុវិជ្ជា, ២០២១

[58] និក្ខេបបទផាន់ សំអាតស្តីពីការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង, ២០២១, ទំព័រ ១៣

[59] សីលធម៌ពលរដ្ឋវិជ្ជា ថ្នាក់ទី ១២, ២០១៤, ទំព័រ ១៣៩

ការចូលរួមនេះមានប្រយោជន៍ ធ្វើឱ្យមានការធានានូវគុណភាពរបស់សាលារៀន និងគ្រូបង្រៀន។ សហគមន៍អាចពិនិត្យតាមដានម៉ោងបង្រៀនដូចជា៖ អវត្តមានគ្រូបង្រៀន សិស្សអវត្តមាន ថ្នាក់រៀនបើកយឺត បិទមុខម៉ោងជាដើម ព្រមទាំងដំណើរការសាលារៀនបើក បិទខុសប្រតិទិនសិក្សាជាដើម។ ដើម្បីឱ្យការចូលរួមសកម្មភាពទាំងនេះបានល្អ សហគមន៍ ក៏ដូចជាតំណាងសហគមន៍ត្រូវតែបានចូលរួមក្នុងវគ្គបំពាក់បំប៉នក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់។

**២. ការធ្វើផែនការ ការគ្រោងថវិកា និងការពិនិត្យថវិកាសាលារៀន**

សារៈប្រយោជន៍នៃការចូលរួមរបស់សហគមន៍គឺបង្កើនការទុកចិត្តគ្នារវាងសហគមន៍ គ្រូបង្រៀន និងសាលារៀន។ ការទុកចិត្តនេះអាចធ្វើឱ្យមានការចូលរួម និងការបរិច្ចាគរបស់សហគមន៍ជួយដល់សាលារៀន ហើយសាលារៀន និងគ្រូបង្រៀនត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ និងមាតាបិតាតាមគោលការណ៍គណនេយ្យភាព។ មានន័យថាគ្រប់ធនធានដែលសាលារៀនបានទទួលពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន និងសហគមន៍ត្រូវបានប្រើប្រាស់ក្នុងការអនុវត្តសកម្មភាពអាទិភាពដែលបានរកឃើញពេលធ្វើផែនការ និងគ្រោងថវិកា។ នាយកសាលាអញ្ជើញសហគមន៍ និងមាតាបិតាចូលរួមក្នុងការធ្វើផែនការ និងគ្រោងថវិកាសាលារៀនតាមការណែនាំនៅក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល និងសេចក្ដីណែនាំពីការគ្រប់គ្រងតាមសាលារៀន។

**៣. ការចូលរួមក្នុងសកម្មភាពសាលារៀន**

សហគមន៍អាចអនុវត្តសកម្មភាព ដែលមានការឯកភាពនៅក្នុងផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ឬដោយមានការប្ដេជ្ញាចិត្តពីសហគមន៍នៅក្នុងឆ្នាំសិក្សា។ សកម្មភាពមានដូចជា៖ ជួយសិស្សមករៀនទៀងទាត់ គ្រប់គ្រងការសាងសង់សាលារៀន ជាសមាជិកគណៈកម្មការថ្នាក់រៀន ចូលរួមក្នុងការរៀបចំព្រឹត្តិការណ៍ ឬពិធីផ្សេងៗនៅសាលារៀន ជាអ្នកជំនាញបង្ហាញប្រធានបទអ្វីមួយដល់សិស្ស ជួយរកមូលនិធិសាលារៀន សង្កេតសកម្មភាពបង្រៀនក្នុងថ្នាក់ ធានាថាសិស្ស(ជាកូនរបស់ខ្លួន)ធ្វើកិច្ចការផ្ទះជាលំហាត់ ឬជាគម្រោងដែលគ្រូដាក់ឱ្យជួយសិស្សឱ្យអាន និងសិក្សានៅផ្ទះទៀងទាត់ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធសាលារៀន។ល។

**៤. គ្រប់គ្រងការសាងសង់សាលារៀន**

ការសាងសង់ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនដោយសហគមន៍គឺជាផ្នែកមួយដែលតម្រូវឱ្យមានការចូលរួមបរិច្ចាគថវិកា កម្លាំងកាយចិត្ត បញ្ញាស្មារតីតាមលទ្ធភាពរបស់ខ្លួនពីដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ព្រមទាំងសប្បុរសជននានាផងដែរ។ គណៈកម្មការអភិវឌ្ឍន៍សាលារៀនត្រូវពង្រឹងគណនេយ្យភាពដោយការកត់ត្រាចំណូល ចំណាយទៅតាមមុខចំណាយដែលបានព្រមព្រៀងគ្នានៅពេលប្រជុំរៀបចំផែនការសាងសង់ពោល រាល់ការសម្រេចចិត្តត្រូវតែមានការឯកភាពគ្នានៅក្នុងអង្គប្រជុំ

និងមានរបាយការណ៍ច្បាស់លាស់ ជាពិសេសនៅពេលចាប់ផ្តើមដំណើរការ អំឡុងពេលដំណើរការ និងក្រោយការបញ្ចប់ការសាងសង់ត្រូវតែមានការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

### ៥. ជាសមាជិកគណៈកម្មការថ្នាក់រៀន

ដើម្បីឱ្យដំណើរការនៃគណៈកម្មការថ្នាក់រៀនប្រព្រឹត្តិទៅបានយ៉ាងរលូន ការអប់រំមាតាបិតាពីការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀន នឹងត្រូវរៀបរៀងជាគោលការណ៍ណែនាំមួយដោយឡែក។ នាយកសាលាត្រូវកោះអញ្ជើញសហគមន៍ មាតាបិតា/អ្នកអាណាព្យាបាលសិស្សមកចូលរួមស្តាប់ការណែនាំ និងនីតិវិធីនៃការត្រួតពិនិត្យតាមដានការសិក្សារបស់កូនៗ ដោយផ្តល់ជាអនុសាសន៍ដល់ពួកគាត់ឱ្យជួយផ្សព្វផ្សាយដល់សមាជិកភូមិ ក្នុងភូមិសិក្សារបស់ខ្លួនពីសកម្មភាពរៀន និងបង្រៀននៅសាលាមានជាព្រឹត្តិប័ត្រពិន្ទុ សៀវភៅតាមដានការសិក្សា និងសិក្ខាគារិកជាដើម។ សាមគ្គីភាពគ្នាក្នុងការពង្រឹងកិច្ចការបង្រៀន និងរៀនគឺជាយន្តការមួយអាចជួយតម្រែតម្រង់ឥរិយាបថសិក្សារបស់សិស្សបានទាន់ពេលវេលា។ ហេតុនេះ សហគមន៍ ឪពុកម្តាយ/អ្នកអាណាព្យាបាលត្រូវតែចូលរួមធ្វើជាសមាជិកគណៈកម្មការថ្នាក់រៀនដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សគ្រប់រូប។

### ៦. ចូលរួមក្នុងការរៀបចំព្រឹត្តការណ៍ ឬពិធីផ្សេងៗនៅសាលារៀន

ក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន នៅពេលមានព្រឹត្តិការណ៍ ឬពិធីផ្សេងៗ ជាទូទៅ ជំហាននៃការអនុវត្តសកម្មភាពនេះមានរៀបរាប់ដូចខាងក្រោម៖

១. គណៈកម្មការគ្រប់គ្រងសាលារៀន និងនាយកសាលាពិភាក្សាពីការអនុវត្តព្រឹត្តិការណ៍ ឬពិធីនេះ។ ព្រឹត្តិការណ៍ ឬពិធីគប្បីមានបញ្ចូលទៅក្នុងផែនការលម្អសាលារៀន។

២. ជំហាននៃការប្រជុំមាន៖

- ពិភាក្សា និងឯកភាពលើវត្ថុបំណងនៃព្រឹត្តិការណ៍ ឬពិធី
- ពិភាក្សា និងឯកភាពថា ត្រូវធ្វើសកម្មភាពអ្វីនៅមុនពេល ក្នុងពេល និងក្រោយពេលមានព្រឹត្តិការណ៍ ឬពិធី
- ពិភាក្សា និងឯកភាពថា អ្នកណាជាអ្នកអនុវត្តសកម្មភាពអ្វី និងនៅពេលណា

៣. ពិនិត្យឡើងវិញនូវការសម្រេចបានពីព្រឹត្តិការណ៍ ឬពិធីក្រោយពីបានរៀបចំហើយ។ សំណួរត្រូវសួរ សម្រាប់ការពិនិត្យឡើងវិញមាន៖

- តើវត្ថុបំណងបានសម្រេចឬទេ ហើយតើសំអាងលើភស្តុតាងអ្វី?
- តើអ្នកចូលរួមបានអនុវត្តសកម្មភាពដែលបានឯកភាពដោយមានគុណភាពតាមការគ្រោងទុក និងទាន់ពេលឬទេ?

- ប្រសិនបើវត្ថុបំណង ឬសកម្មភាពមិនបានធ្វើឱ្យសម្រេច ឬមិនបានអនុវត្តទេ តើមកពីអ្វី និង តើត្រូវដោះស្រាយតាមវិធីណា?

គំរូពីផែនការសកម្មភាពព្រឹត្តិការណ៍ឬពិធីសាមញ្ញមួយ

| វត្ថុបំណង | សកម្មភាព | អ្នកទទួលអនុវត្ត | ថ្ងៃទីខែឆ្នាំ |
|---|---|---|---|
| អាចមាន៖ កសាងទំនុកចិត្ត ឬ រកមូលនិធិ ឬ ផ្តល់រង្វាន់ដល់សិស្ស ឬ គ្រូពូកែ | មុនពេលព្រឹត្តិការណ៍ | | |
| | ក. រៀបចំផែនការសកម្មភាព | | |
| | ខ. ផលិតសម្ភារៈសម្រាប់ប្រើក្នុងព្រឹត្តិការណ៍ | | |
| | គ. ជូនព័ត៌មានមាតាបិតានិងសហគមន៍ចូលរួមកម្មវិធី | | |
| | ក្នុងពេលមានព្រឹត្តិការណ៍ | | |
| | ក. ប្រជុំជូនព័ត៌មានពីកម្មវិធី | | |
| | ខ. រៀបចំការធ្វើទស្សនៈកិច្ចអគារសិក្សា ឬផលិតផលស្នាដៃសិស្ស ឬសកម្មភាពក្នុងថ្នាក់រៀន | | |
| | គ. ប្រជុំបិទកម្មវិធី និងជូនព័ត៌មានពីការសម្រេចបាននូវ វត្ថុបំណងរបស់ព្រឹត្តិការណ៍ | | |
| | ក្រោយពេលព្រឹត្តិការណ៍ | | |
| | ក. ប្រជុំពិនិត្យឡើងវិញ | | |
| | ខ. ជូនសំបុត្រសាលារៀនជាព័ត៌មានអំពីព្រឹត្តិការណ៍ចំណូល ឬការបរិច្ចាគដែលសាលារៀនបានទទួល ព្រមទាំងថ្លែងអំណរគុណមាតាបិតានិងសហគមន៍ | | |

(រូបភាពទី ១០៖ គំរូផែនការសកម្មភាព, អយក, ២០១៨)

## ៧. ជាអ្នកជំនាញបង្ហាញប្រធានបទអ្វីមួយដល់សិស្ស

ប្រធានបទអាចមានដូចជា៖ បំណិនរកចំណូល ច្បាប់ទាក់ទងនឹងបញ្ហាដែលកើតមាននៅក្នុងសាលារៀន(ដូចជា៖អំពើហិង្សា បញ្ហាគ្រឿងញៀន ច្បាប់ចរាចរណ៍) ការថែទាំកូន ការរកមូលនិធិ ឬចំណូលសាលារៀន ការជួយសិស្សធ្វើលំហាត់ ឬគម្រោងនៅផ្ទះដែលគ្រូដាក់ឱ្យ ការជួយមាតាបិតាសិស្សដើម្បីជួយកូនខ្លួនឯង និងសិស្សជួយសិស្សជាបណ្តាញ ឬដៃគូ មិត្តអប់រំមិត្តជាដើម។

## ៨. ជួយរកមូលនិធិសាលារៀន

ការចូលរួមជួយរៀបចំព្រឹត្តិការណ៍ ឬពិធីនៅសាលារៀនគឺអាចលើកកម្ពស់ដល់យន្តការកៀរគរសប្បុរសជន និងធនធានពីដៃគូអភិវឌ្ឍន៍ឱ្យជួយឧបត្ថម្ភគាំទ្រសកម្មភាពនានា និងផែនការរបស់សាលារៀនទាំងថវិកាកសាងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការងារបង្រៀន និងរៀនផងដែរ។

## ៩. សង្កេតសកម្មភាពបង្រៀនក្នុងថ្នាក់

ការចូលរួមយ៉ាងសកម្មពីឪពុកម្តាយ គ្រួសារ និងសហគមន៍ពិតជាបានលើកកម្ពស់សមិទ្ធិផលសិក្សារបស់សិស្ស ព្រោះពួកគាត់បានជួបផ្ទាល់ជាមួយគ្រូបង្រៀនផ្ទាល់ ការអង្កេតមើលការសិក្សារបស់កូនក្នុងថ្នាក់ ការជូនកូនមកសាលារៀន ការគ្រោងចំណាយលើសម្ភារៈសិក្សា ការសាកសួរព័ត៌មាន ឬប្រឹក្សាយោបល់ជាមួយពួកគាត់ ការតាមដានការសិក្សារបស់កូន ការណែនាំកូនឱ្យធ្វើកិច្ចការផ្ទះ(ផាន់, ២០២១)[60]។

## ១០. ជួយសិស្សឱ្យអាន និងសិក្សានៅផ្ទះទៀងទាត់

អំណានគឺជាដើមចមដែលនាំឱ្យសិស្សអាចសិក្សាស្វែងយល់មុខវិជ្ជាដទៃទៀតបាន ព្រោះការចេះអក្សរអាចជួយសិស្សធ្វើស្វ័យសិក្សា ស្រាវជ្រាវ ពង្រីកសមត្ថភាពយល់ដឹងទាំងវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម ដោយប្រើព័ត៌មានវិទ្យាសាស្ត្រស្រាវជ្រាវពីឯកសារយោងក្នុងប្រព័ន្ធអ៊ីនធើណិត ឬសៀវភៅដែលខ្ចីពីបណ្ណាល័យសាលារៀន។ វាជាការសំខាន់ដែលអ្នកអាណាព្យាបាលត្រូវតែចំណាយពេលតាមដែលអាចធ្វើទៅបានជួយកូនឱ្យអានអក្សរ ឬស្តាប់ការអានលឺៗរបស់គេ ក្នុងន័យនេះ វាជាការលើកទឹកចិត្តដល់សិស្ស ឱ្យមានវប្បធម៌អាន និងសិក្សានៅផ្ទះបានយ៉ាងទៀងទាត់។

## ១១. ថែរក្សាហេដ្ឋារចនាសម្ព័ន្ធសាលារៀន

ដើម្បីថែរក្សាបរិស្ថាន និងសំណង់អគារសិក្សាសម្រាប់ការសិក្សារៀនសូត្ររបស់សិស្សទៅតាមអាយុកាលរួមមានៈ ថ្នាក់រៀន បន្ទប់ពិសោធន៍ រោងជាង សំណង់អនាម័យទឹកស្អាត ការិយាល័យ និងឧបករណ៍ប្រើប្រាស់ដែលមាននៅក្នុងបរិវេណសាលារៀន សហគមន៍អាចៈ

- សង្កេតមើលការប្រើប្រាស់ និងដំណើរការនៃហេដ្ឋារចនាសម្ព័ន្ធខាងលើដោយមានការឯកភាពជាមួយនាយកសាលារៀបចំកាលវិភាគទទួលខុសត្រូវតាមថ្ងៃនិមួយៗ
- ផ្តល់ព័ត៌មានដល់នាយកសាលាគ្រប់ពេល នៅពេលណាឃើញថា អគារណាមួយត្រូវការជួសជុលតូច
- ពិភាក្សាពីការសម្រេចចិត្តប្រើថវិកាសាលារៀនដើម្បីជួសជុល និងត្រូវអនុវត្តតាមការណែនាំសម្រាប់ការជួសជុល និងការសាងសង់។

## ១២. ការជួយផ្តល់ធាតុចូលដល់សាលារៀន

សហគមន៍អាចចូលរួមចំណែកជាប្រាក់ដល់សាលារៀន សម្ភារៈសិក្សាដល់សិស្ស ឬកុមារ ផ្តល់វត្ថុធាតុដើមសម្រាប់ធ្វើគ្រឿងសង្ហារឹម តុ កៅអី ទូរសៀវភៅ ទ្វារ បង្អួចក្នុងថ្នាក់រៀនជាដើម។

## ១៣. ការពង្រឹងតម្លាភាពក្នុងការចូលរួមរបស់សហគមន៍

[60] និក្ខេបបទផាន់ សំអាតស្តីពីការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង, ២០២១, ទំព័រ ១៥

នៅក្នុងវិស័យអប់រំ ជំនឿចិត្តរបស់សហគមន៍គឺជាមូលដ្ឋានគ្រឹះក្នុងការកសាងគុណភាពអប់រំប្រកបដោយសមធម៌ និងសាមគ្គីភាព( ពិន, ២០២២ )[61]។ តម្លាភាពនេះមានន័យថា៖ ១. តម្លាភាពក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ២. តម្លាភាពក្នុងការធ្វើផែនការសាលារៀន និងការគ្រោងថវិកា ៣. តម្លាភាពក្នុងការចំណាយ ការរកមូលនិធិ និងការផ្សព្វផ្សាយទិន្នន័យហិរញ្ញវត្ថុ ៤. តម្លាភាពពីការអនុវត្ត និងប្រតិបត្តិការសាលារៀន ៥. តម្លាភាពពីលទ្ធផលសិក្សារបស់សិស្ស ៦. តម្លាភាពក្នុងការបង្កើតគណៈកម្មការសាងសង់ និងជួសជុលសាលារៀន និង ៧. តម្លាភាពពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិពីការផ្តល់ជាតុចូលដល់សាលារៀន និងការកសាងសមត្ថភាពសាលារៀន។

[61] បទបង្ហាញរបស់លោកពិន គឹមធេន ទីប្រឹក្សាក្រសួងអប់រំ ស្តីពី ឧត្តមានុភាពនៃភាពជាអ្នកដឹកនាំ, ២០២២

## តួនាទីរបស់សហគមន៍

១. ការផ្តល់ធាតុចូល

១.១.ការធ្វើផែនការសាលារៀន

១.២.គោលនយោបាយសាលារៀន

១.៣.គ្រោងថវិកាសាលារៀន

១.៤.ផែនការសកម្មភាពសាលារៀន

១.៥.ផែនការកសាង ថែរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

២. គណៈកម្មការថ្នាក់រៀន

២.១.ការអនុវត្តការងាររបស់គ្រូបង្រៀន

២.២.ការអង្កេតថ្នាក់រៀន

២.៣.ពិនិត្យតាមដានលទ្ធផលសិក្សារបស់សិស្ស

៣. ការលើកទឹកចិត្ត និងកៀរគរធនធាន

៣.១.ទំនាក់ទំនងអ្នកជំនាញ ឥស្សរជន សប្បុរសជន(ចែករំលែកបទពិសោធន៍ បរិច្ចាគថវិកា ការគាំទ្រ និងចូលរួមកម្មវិធីសាលា)

៣.២.លើកកម្ពស់ការទទួលខុសត្រូវរបស់អាណាព្យាបាល

៣.៣.ការពង្រឹងតម្លាភាពគណនេយ្យភាព និងស្វ័យភាព

**អភិវឌ្ឍ**

## លទ្ធផលសិក្សារបស់សិស្ស

I. ប្រឡងជាប់បាននិទ្ទេសល្អ

១.អត្រាត្រួតថ្នាក់ថយចុះ

២.កាត់បន្ថយការបោះបង់ការសិក្សា

៣.ទទួលបានអាហារូបករណ៍

II. ផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន

១.សិស្សចូលចិត្តសាលារៀន និងស្វ័យសិក្សា

២.មានជំនាញក្នុងការអាន សរសេរ ទំនាក់ទំនង និងលេខនព្វន្ត

៣.មានចរិយាថ្លៃថ្នូរ

III.មានទំនុកចិត្ត និងឧត្តមភាពក្នុងការរស់នៅក្នុងសង្គម

១.ភាពមានការងារធ្វើ

២.ដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ឯករាជ្យភាព និងច្នៃប្រឌិត

៣.សេដ្ឋកិច្ចគ្រួសារសមរម្យ រស់នៅប្រកបដោយភាតរភាពក្នុងសង្គម

IV. ឆ្លើយតបទៅនឹងតម្រូវការសង្គម និងទីផ្សារការងារ

១.បំពេញការងារមានប្រសិទ្ធភាព

២.មានជំនាញបច្ចេកទេស ច្បាស់លាស់ សមត្ថភាពភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មានវិទ្យា

៣.ប្រតិបត្តិខ្លួនជាពលរដ្ឋពេញលេញ

(រូបភាពទី ១១៖ តួនាទីសហគមន៍, ២០២២)

## ២.៣. តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

### ២.៣.១. ការផ្តល់ជាតុចូល

ការបណ្តុះបណ្តាលធនធានមនុស្សត្រូវពឹងផ្អែកលើវិស័យអប់រំជាស្នូល ព្រោះដើម្បីអភិវឌ្ឍជំនាញបច្ចេកទេស បំណិនអាជីព ក្រមសីលធម៌ជាពលរដ្ឋពេញលេញត្រូវតែឆ្លើយតបទៅនឹងគោលនយោបាយជាតិ និងតម្រូវការរបស់សង្គមជាតិ ព្រមទាំងទីផ្សារការងារទាំងក្នុងតំបន់ និងអន្តរជាតិផងដែរ។ ដូចនេះការអភិវឌ្ឍកម្មវិធីសិក្សាគឺជាគន្លឹះនៃការបង្កើនគុណភាព និងប្រសិទ្ធភាពអប់រំដោយមានការចូលរួមមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ទើបគោលនយោបាយអប់រំនោះមានជាតុចូលគ្រប់ជ្រុងជ្រោយ ហើយបានឆ្លើយតបនឹងតម្រូវការនានាក្នុងបរិបទសកលនីយកម្ម តំបន់នីយកម្ម បុគ្គល និងមានសមធម៌ក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិតមូលដ្ឋានទាំងបីក្នុងភាពជាដៃគូរវាងរដ្ឋ សហគមន៍ និងឯកជនព្រោះ កម្មវិធីសិក្សាជាឯកសារគោលដ៏មានសារៈសំខាន់សម្រាប់គ្រូបង្រៀន នាយកគ្រឹះស្ថានសិក្សា មន្ត្រីអប់រំ មាតាបិតាសិស្ស អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវអប់រំផងដែរ(អយក, ២០០៤)[(62)]។

### ក.ការធ្វើផែនការសាលារៀន

ផ្អែកតាមការចង្អុលបង្ហាញរបស់ក្រសួងអប់រំ យុវជន និងកីឡា យន្តការសម្រាប់អភិវឌ្ឍផែនការសាលារៀន គឺត្រូវដឹកនាំដោយនាយកសាលារៀន គណៈកម្មការអភិវឌ្ឍន៍សាលារៀន និងគណៈកម្មការប្រតិបត្តិសាលារៀន។ អ្នកចូលរួមមាន៖ គណៈគ្រប់គ្រងសាលា អាជ្ញាធរដែនដី ប្រធានក្រុម ប្រធានភូមិ ក្រុមប្រឹក្សាឃុំ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្រុមប្រឹក្សាកុមារ សិស្ស និងមាតាបិតាសិស្ស។ ការកសាងផែនការអភិវឌ្ឍន៍សាលារៀននឹងត្រូវប្រព្រឹត្តទៅក្នុងរយៈពេលមួយឆ្នាំម្តងគឺ ចាប់ផ្តើមអនុវត្តនៅដើមឆ្នាំសិក្សានីមួយៗដែលមានសមាសភាពចូលរួមពីគណៈគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន ក្រុមប្រឹក្សាកុមារ គ្រូបង្រៀន តំណាងសិស្ស ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល និងមណ្ឌលសុខភាពរួមជាមួយអ្នកពាក់ព័ន្ធមួយចំនួនទៀត។ នៅរៀងរាល់ដើមឆ្នាំសិក្សានីមួយៗ សាលារៀនចាំបាច់ត្រូវរៀបចំធ្វើផែនការអភិវឌ្ឍសាលារៀនក្រោមការចាត់ចែងសម្របសម្រួលពី គណៈគ្រប់គ្រងសាលារៀនដើម្បីប្រជុំពិភាក្សាពីបញ្ហាដែលតែងតែកើតមានឡើង ក្នុងសាលារៀនដោយផ្អែកលើលទ្ធផលស្វ័យវាយតម្លៃសាលារៀន។ បន្ទាប់មក គណៈគ្រប់គ្រងយកផែនការអភិវឌ្ឍន៍សាលារៀនទៅដាក់បញ្ចូលនៅក្នុងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ និងសម្រាប់ប្រើប្រាស់ដើម្បីស្វែងរកថវិកាពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នផ្សេងៗផងដែរ(អយក, ២០១៧)[(63)]។

---

62 គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណោះទូទៅ ២០០៥-២០០៩, នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ, ២០០៤, អារម្ភកថា

63 ឯកសារប្រតិបត្តិការរៀបចំផែនការអភិវឌ្ឍសាលារៀន, ២០១៧, ទំព័រ ៤

### ខ. គោលនយោបាយសាលារៀន

ជាងពីរទសវត្សកន្លងទៅនេះ សាកលភាវូបនីយកម្មលើគ្រប់វិស័យជាពិសេស វិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្របច្ចេកទេស និងនយោបាយបានធ្វើឱ្យពិភពលោកកាន់តែមានការប្រកួតប្រជែងគ្នាផង និងសហការគ្នាផងដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហវត្ស និងការអភិវឌ្ឍប្រកបដោយចីរភាព ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាជាកត្តាកំណត់ជោគជ័យនៃការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យទាំងអស់(អយក, ២០១៥)[64]។ ជាមួយគ្នានេះផងដែរ ដើម្បីជួយដល់ការរៀបចំគោលនយោបាយសាលារៀន និងការរៀបចំផែនការយុទ្ធសាស្ត្រសាលារៀន គណៈគ្រប់គ្រង គណៈកម្មការទ្រទ្រង់សាលា និងគណៈកម្មការអភិវឌ្ឍន៍សាលារៀនត្រូវគិតគូរពិចារណាដល់ការកំណត់បញ្ហាចម្បងៗទាក់ទងទៅនឹងការចូលរៀន គុណភាពសិក្សា ការដឹកនាំគ្រប់គ្រង និងការកសាងរៀបចំ បរិស្ថានសិក្សា (សម្ភារៈឧបទេស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត) ជាដើម។ ក្នុងការរៀបចំឱ្យសាលារៀនមួយមានគោលនយោបាយរបស់ខ្លួនបានច្បាស់លាស់ចាំបាច់ត្រូវឆ្លើយតប និងរួមបញ្ចូលនូវធាតុសំខាន់ៗនៃចក្ខុវិស័យ បេសកកម្ម និងគោលបំណង(អយក, ២០១៧)[65]។

### គ. គ្រោងថវិកាសាលារៀន

ការរៀបចំគ្រប់គ្រងថវិការបស់សាលារៀន គឺជាការគូសបង្ហាញនូវការប្រើប្រាស់ថវិកាឱ្យមានតម្លាភាព សុច្ចរិតភាព និងចំទិសដៅតាមផែនការដែលនាយកសាលារៀនបានគ្រោងទុកដើម្បីជួយអភិវឌ្ឍ កែលម្អសោភ័ណភាពសាលា ការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលល្អប្រសើរជាទីបំផុត និងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស មាតាបិតាសិស្ស សហគមន៍ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការគ្រប់គ្រងថវិកាជាផ្នែកមួយដ៏សំខាន់ ក្នុងការជួយគាំទ្រឱ្យសាលារៀនសម្រេចបាននូវផែនការអភិវឌ្ឍន៍ និងធានាឱ្យបាននូវការចូលរៀនរបស់សិស្សមានការកើនឡើង ជាពិសេសគឺការសិក្សាប្រកបដោយគុណភាព សមធម៌ និងបរិយាបន្នដែលអាចឆ្លើយតបទៅនឹងតម្រូវសេដ្ឋកិច្ចសង្គម និងការរីកចម្រើនយ៉ាងរហ័សនៃសង្គមឌីជីថល(អយក, ២០១៧)[66]។ ដើម្បីធានាឱ្យមានដំណើរការនៃការគ្រប់គ្រងថវិកាសាលារៀនប្រកបដោយតម្លាភាព និងប្រសិទ្ធភាព សាលារៀនត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងថវិកាដោយមានបែងចែកពីតួនាទី និងភារកិច្ចទទួលខុសត្រូវក្នុងការប្រើបាស់ ទទួល ទុកដាក់ ចំណូល ចំណាយ និងផ្សព្វផ្សាយពីថវិការបស់សាលារៀនជាមួយនឹងការចូលរួម

---

[64] ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស, នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១៥, បុព្វកថា

[65] ឯកសារប្រតិបត្តិការរៀបចំផែនការអភិវឌ្ឍសាលារៀន, បោះពុម្ពដោយក្រសួងអប់រំ, ២០១៧, ទំព័រ ៤

[66] ឯកសារប្រតិបត្តិការគ្រប់គ្រងថវិកាសាលារៀន, បោះពុម្ពដោយក្រសួងអប់រំ, ២០១៧, ទំព័រ អារម្ភកថា

សម្រេចចិត្ត និងមានការត្រួតពិនិត្យប្រកបដោយគុណភាពពីអ្នកពាក់ព័ន្ធ(អយក, ២០១៧)[67]។ ការរៀបចំឱ្យមានយន្តការក្នុងការគ្រប់គ្រងថវិការបស់សាលារៀនគឺជា ការបង្ហាញឱ្យភាគីពាក់ព័ន្ធនានាបានចូលរួមក្នុងការទទួលខុសត្រូវតាមតួនាទី និងភារកិច្ចរៀងៗខ្លួន។ សាលារៀនគឺជាស្ថាប័នរដ្ឋដែលមានតួនាទីនិងភារកិច្ចក្នុងការផ្តល់សេវាអប់រំទៅដល់កុមារដោយត្រូវរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំដើម្បីដំណើរការសាលារៀនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។ គណៈកម្មការគ្រប់គ្រងថវិកាសាលារៀន ត្រូវបានជ្រើសរើសឡើងពីអ្នកពាក់ព័ន្ធរួមមាន៖គណៈគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលា គ្រូបង្រៀន និងភាគីពាក់ព័ន្ធដទៃទៀតដោយមានការចូលរួមចំណែកក្នុងការដឹងឮពីចំណូល ចំណាយ និងបោះឆ្នោតជ្រើសតាំងមួយឆ្នាំម្តងៗ ហើយមានសមាសភាគដូចខាងក្រោម(អយក, ២០១៧)[68]៖

- នាយកសាលា ជាប្រធាន
- ប្រធានគណៈកម្មការទ្រទ្រង់សាលា ជាអនុប្រធាន
- តំណាងគ្រូបង្រៀនក្នុងសាលា ជាហិរញ្ញិក និងបេឡាករ
- គ្រូបង្រៀន និងសមាជិកគណៈកម្មការទ្រទ្រង់សាលា ជាសមាជិក
- គណៈកម្មការថ្នាក់រៀន ជាសមាជិក
- ក្រុមប្រឹក្សាកុមារ ជាសមាជិក
- អ្នកពាក់ព័ន្ធផ្សេងទៀត ជាសមាជិក




(រូបភាពទី ១២៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រងថវិកាសាលារៀន, អយក, ២០២២)

[67] ឯកសារប្រតិបត្តិការគ្រប់គ្រងថវិកាសាលារៀន, បោះពុម្ពដោយក្រសួងអប់រំ, ២០១៧, ទំព័រ អារម្ភកថា
[68] ឯកសារប្រតិបត្តិការគ្រប់គ្រងថវិកាសាលារៀន, បោះពុម្ពដោយក្រសួងអប់រំ, ២០១៧, ទំព័រ ៦

## ឃ. ផែនការសកម្មភាពសាលារៀន

ផែនការបង្រៀនគឺជាបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំខែតាមមុខវិជ្ជា និងតាមថ្នាក់នីមួយៗដែលត្រូវបានគ្រោងទុកធ្វើជាយុទ្ធវិធី ផែនទីការងារសម្រាប់ការរៀបចំដំណើរការរៀន និងបង្រៀនឱ្យកាន់តែសុក្រឹត។ ផែនការបង្រៀនត្រូវមានសកម្មភាពរស់រវើក មានប្រសិទ្ធភាព និងស្របតាមបរិបទសាលារៀនទាមទារឱ្យគណៈគ្រប់គ្រងយល់ដឹង ពីការប្រើប្រាស់កម្មវិធីសិក្សាលម្អិត និងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេស ព្រមទាំងសៀវភៅសិក្សាគោលឱ្យបានច្បាស់លាស់។ សហគមន៍ មាតាបិតាសិស្ស និងភាគីពាក់ព័ន្ធត្រូវតែចូលរួមផ្តល់ធាតុចូលដើម្បីឱ្យផែនការបង្រៀនមានការឯកភាពគ្នា ហើយអនុវត្តទទួលបានលទ្ធផលឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។ ហេតុនេះហើយ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តផែនការបង្រៀនប្រចាំឆ្នាំដោយត្រូវអញ្ជើញគ្រប់សមាសភាពពាក់ព័ន្ធចូលរួមប្រជុំឱ្យបានទៀងទាត់(សៀង, ២០២១)[69]។

## ង. ផែនការកសាង ថែរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

គម្រោងកែលម្អបរិស្ថានសាលារៀន(SEIP) ត្រូវបានស្នើឡើងនឹងបានទទួលហិរញ្ញវត្ថុតាមរយៈ IDA ដែលជាភ្នាក់ងារកណ្តាលសម្រាប់ធនាគារហើយគម្រោងតាមការដ្ឋានជាក់លាក់នៃផែនការសាងសង់។ ការអនុវត្តគម្រោងនឹងត្រូវធ្វើឡើងនៅទូទាំងប្រទេស ហើយទីតាំងជាក់លាក់សម្រាប់ការសាងសង់សាលា បន្ទប់រៀនបន្ថែម អន្តេវាសិកដ្ឋាន និងបរិក្ខារជាកន្លែងស្នាក់នៅរបស់គ្រូ សិស្ស នឹងត្រូវទាញចេញពីលំហាត់ធ្វើផែនទីសាលារៀន ដោយផ្អែកលើភាពតំណាងនៃចរិតលក្ខណៈពិសេសជាច់ដោយឡែកនៃជនជាតិភាគតិច បរិយាកាសផ្នែកនយោបាយ សង្គម វប្បធម៌ សាសនា និងបរិស្ថានរបស់តំបន់អនុគម្រោងដែលត្រូវស្នើឡើងរួមនឹងក្តីរំពឹងទុកថា ៩០ភាគរយនៃទីតាំងគម្រោង និងស្ថិតនៅក្នុងបរិវេណសាលារៀនដែលមានស្រាប់។ ក្នុងករណីត្រូវការដីថ្មីសម្រាប់ការសាងសង់សាលារៀន អាជ្ញាធរមូលដ្ឋាន(ជាពិសេសគឺអាជ្ញាធរឃុំ សង្កាត់) ឬគណៈកម្មាធិការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មរាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡាតាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តនឹងផ្តល់ចំណារអនុម័ត។ ដំណើរការនេះអាចមានដូចខាងតទៅ៖

- ពេលកំណត់ទីតាំងថ្មីបានហើយ នាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងអាជ្ញាធរឃុំ សង្កាត់នឹងរួមគ្នាធ្វើការពិនិត្យជ្រើសរើសទូលំទូលាយមួយដើម្បីបញ្ជាក់អះអាងថា ទីតាំងដែលបានកំណត់មានសុវត្ថិភាពផ្នែកបរិស្ថាន និងសង្គម និងមានលក្ខណៈសម្បត្តិអាចធ្វើការសាងសង់បាន។

[69] បទបង្ហាញដោយឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ស្តីពី ផែនការបង្រៀន, ២០២១

- ករណីមិនមានប័ណ្ណកម្មសិទ្ធិលើដីសម្រាប់សាងសង់អនុគម្រោងដែលបានស្នើឡើងទេ អាជ្ញាធរឃុំ សង្កាត់(ឬថ្នាក់ក្រុង ស្រុក ខណ្ឌ)នឹងត្រូវផ្តល់ចំណារយល់ព្រមលើលទ្ធផលនៃការពិនិត្យជ្រើសរើស និងចេញលិខិតផ្លូវការដើម្បីបញ្ជាក់ការប្រើប្រាស់ដី។ EMP នឹងត្រូវដាក់បញ្ចូលនៅក្នុងឯកសារដេញថ្លៃដើម្បីជម្រាបប្រាប់ដល់អ្នកម៉ៅការ/សហគមន៍ អំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេក្នុងការអនុវត្តតាមឧបករណ៍ការពារ និងសុវត្ថិភាព(អយក, ២០១៨)[70]។

ការកសាងផែនការសហប្រតិបត្តិការត្រូវធ្វើជាកិច្ចការលាយបញ្ចូលគ្នា នៅក្នុងការកសាងផែនការកែលម្អសាលារៀនជាប្រចាំដោយសហគមន៍ និងសាលារៀនត្រូវពិភាក្សាគ្នាបង្កើតថ្នាក់រៀនដើម្បីបំពេញតាមនិយាមសិស្សតាមរយៈកិច្ចសហការ ការឧបត្ថម្ភគាំទ្រពីក្រសួងសាមី ជួយផ្តល់គ្រូបង្រៀនបានគ្រប់គ្រាន់ និងទាន់ពេលវេលា។ អាស្រ័យហេតុនេះ សហគមន៍ត្រូវតែបំពេញភារកិច្ចជាកម្លាំងចលករមួយក្នុងការកៀរគរធនធាន និងប្រមូលថវិកាសហគមន៍ ឬប្រើថវិកាដែលបានពីកម្មវិធីបំណិនរកចំណូលរបស់សាលាមធ្យមសិក្សាសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានសិក្សាទៅតាមភាពជាក់ស្តែងនៃតម្រូវការ(អយក, ២០២១)[71]។ ទាក់ទងនឹងការស្ថាបនា ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនគឺផ្តោតទៅលើកង្វះបន្ទប់រៀនថយចុះរហូតមានចំនួនសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន បន្ទប់ស្នាក់នៅរបស់គ្រូបានសាងសង់តាមតម្រូវការ បន្ទប់រដ្ឋបាលសាលារៀន និងសង្ហារឹមបានផ្តល់តាមតម្រូវការ បន្ទប់ទឹកបានសាងសង់តាមស្តង់ដា និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្សទាំងប្រុស ទាំងស្រីជាដើម(អយក, ២០១៨)[72]។

### ២.៣.២. គណៈកម្មការថ្នាក់រៀន

គណៈកម្មការថ្នាក់រៀនក៏ជាធាតុសំខាន់ ក្នុងរចនាសម្ព័ន្ធរបស់គណៈកម្មការអភិវឌ្ឍន៍សាលារៀន ព្រោះថាការងារទាំងនេះពាក់ព័ន្ធទៅនឹងផែនការអភិវឌ្ឍន៍សាលារៀន ផ្តោតលើការជួយកុមារក្រៅសាលាឱ្យមកចូលក្នុងថ្នាក់ដើម្បីទទួលបានការអប់រំរៀនសូត្រ ការបណ្តុះបណ្តាល និងជួយបង្កើនលទ្ធផលសិក្សារបស់សិស្សឆ្លើយតបទៅនឹងកម្មវិធីសិក្សា និងផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលបានគ្រោងទុក ជាពិសេស គណៈកម្មការនេះមានគោលបំណងពង្រឹងចំណងសាមគ្គីភាព កិច្ចសហការរវាងភាគីសាលារៀន និងសហគមន៍ ពិនិត្យតាមដានសកម្មភាពបង្រៀន រៀនដើម្បីឆ្លុះបញ្ចាំងពីចំណុចខ្វះខាត និងបញ្ហាប្រឈមនានាមកពិភាក្សាដោះស្រាយឱ្យបានទាន់ពេលវេលា(អយក, ២០១៧)[73]។

---

[70] សៀវភៅណែនាំប្រតិបត្តិស្តីពី ការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨, ទំព័រ ១១៩

[71] សេចក្តីណែនាំប្រតិបត្តិ យុទ្ធសាស្ត្រសហគមន៍សាលារៀន, ២០២១, ទំព័រ ១៣០

[72] សៀវភៅណែនាំប្រតិបត្តិស្តីពី ការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨, ទំព័រ ១១៩

[73] ឯកសារប្រតិបត្តិ គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, សេចក្តីផ្តើម




(រូបភាពទី ១៣៖ រចនាសម្ព័ន្ធគណៈកម្មការអភិវឌ្ឍន៍សាលារៀន អយក, ២១៧)




(រូបភាពទី ១៤៖ ក្រុមការងារទាំង១១ របស់គណៈកម្មការអភិវឌ្ឍន៍សាលារៀន អយក, ២០១៧)

### ក. ការអនុវត្តការងាររបស់គ្រូបង្រៀន

ប្រសិទ្ធផលនៃការងារអប់រំក្នុងបរិបទបច្ចុប្បន្ន សំដៅលើគុណភាពអប់រំប្រកបដោយសមធម៌ គុណធម៌ និងបរិយាបន្ន ព្រមទាំងយន្តការការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា(អយក, ២០១៨)(74)។ តាមផែនការបង្រៀនជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ គណៈនាយកបានអង្កេតពិនិត្យដោយផ្ទាល់ក្នុងកិច្ចដំណើរការបង្រៀន និងរៀន រីឯសហគមន៍ មាតាបិតាសិស្ស អាចស្វែងយល់បន្ថែមតាមរយៈការបិទផ្សាយ ការប្រកាសលទ្ធផល ព្រមទាំងចូលរួមប្រជុំយ៉ាងទៀងទាត់តាមការអញ្ជើញពីសាលារៀនស្តីពីវឌ្ឍនភាពស្តីពីកម្មវិធីសិក្សារបស់គ្រូបង្រៀនជាពិសេសការចូលរួមធ្វើថ្នាក់និទស្សន៍ និងការធ្វើតេស្តប្រចាំខែរបស់គ្រូតាមមុខវិជ្ជាជាដើម។

### ខ. ការអង្កេតការបង្រៀន

ការអង្កេតថ្នាក់រៀន អាចឆ្លើយតបទៅនឹងការអនុវត្តការងាររបស់គ្រូបង្រៀននៅកម្រិតថ្នាក់រៀនដែលអាចផ្តល់ជាសារៈប្រយោជន៍ដល់ការដោះស្រាយបញ្ហាប្រឈមមុខទាក់ទងទៅនឹង ការងារបង្រៀន និងរៀនរបស់គ្រូ សិស្សដូចជា៖ សៀវភៅសិក្សាគោល សម្ភារៈឧបទេស កម្មវិធីសិក្សា រដ្ឋបាលថ្នាក់រៀន និងបរិស្ថានសិក្សាបានទាន់ពេលវេលា ព្រោះថាការងាររបស់សាលារៀនមានប្រសិទ្ធភាពតែងតែមានការចូលរួមដោះស្រាយរួមគ្នាពីសំណាក់ខាងសាលារៀន សហគមន៍ មាតាបិតា សិស្សក្នុងការធ្វើការសម្រេចចិត្តថាត្រូវធ្វើសកម្មភាពអ្វី អ្វីជាតម្រូវការចាំបាច់ និងជាអាទិភាពសម្រាប់សាលារៀន និងថ្នាក់រៀននីមួយៗរបស់ខ្លួន(អយក, ២០១៨)(75)។

### គ. ពិនិត្យតាមដានលទ្ធផលសិក្សារបស់សិស្ស

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស គឺជាធាតុផ្សំមួយក្នុងដំណើរការត្រួតពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាពការងារបង្រៀន និងរៀនរបស់គ្រូ និងសិស្ស។ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់គណៈកម្មការគ្រប់គ្រងសាលារៀន ក៏ដូចជាសហគមន៍នឹងត្រូវ៖

- ធានានិរន្តរភាពនៃការពិនិត្យតាមដាន និងវាយតម្លៃជាផ្លូវការតាមរយៈការរៀបចំសិក្ខាសាលារបាយការណ៍ និងការប្រជុំដើម្បីឆ្លុះបញ្ចាំងពីខ្លឹមសារមេរៀន ព្រមទាំងបទពិសោធន៍ការងារអប់រំនាពេលកន្លងមក
- ធ្វើអធិការកិច្ចរួមគ្នារវាងថ្នាក់ខេត្ត រាជធានី និងក្រុង ស្រុក ខណ្ឌ ដោយកសាងក្រុមការងារជាក់លាក់ និងចែករំលែកបទពិសោធន៍ដែលទទួលបានពីការធ្វើអធិការកិច្ច
- រៀបចំកាតរបាយការណ៍សាលារៀនដែលបង្ហាញនូវភាពជោគជ័យ និងប្រសិទ្ធភាពនៃការពិនិត្យតាមដាន និងអាចប្រើជាឧបករណ៍ជួយដល់ការរៀនសូត្រ និងកសាងសមត្ថភាព

---

74 ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩ ២០២៣, គោលនយោបាយអប់រំទី ១, ទំព័រ អារម្ភកថា, ២០១៩

75 សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨, ទំព័រ ២០

- ពិនិត្យតាមដាន និងវាយតម្លៃលើការប្រែប្រួលជាវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្សតាមយន្តការច្បាស់លាស់ ជាពិសេស តេស្តស្តង់ដា(នៅដើមឆ្នាំ) ពិន្ទុតេស្តតាមខែនីមួយៗ ប្រចាំឆមាស និងប្រចាំឆ្នាំជាដើម។ (អយក, ២០១៨)[76]

ក្នុងតួនាទី និងភារកិច្ចជាគណៈកម្មការថ្នាក់រៀន សហគមន៍ មាតាបិតា អ្នកអាណាព្យាបាលសិស្សត្រូវមានភារកិច្ចៈ

- គាំទ្រក្នុងការដោះស្រាយបញ្ហាដែលលើកឡើងដោយមាតាបិតា និងសិស្សពីការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀន
- ជានាតម្លាភាពក្នុងការចូលរួមរបស់សហគមន៍
- អនុម័តលទ្ធផលវាយតម្លៃការអនុវត្តរបស់សាលារៀន
- ទទួលស្គាល់របាយការណ៍រីកចម្រើនប្រចាំត្រីមាសពី ការអនុវត្តផែនការកែលម្អសាលារៀន
- ទទួលស្គាល់របាយការណ៍រីកចម្រើនប្រចាំឆ្នាំពីការសម្រេចសូចនាករ និងក្រុមគោលដៅផលសម្រេច(អយក, ២០១៨)[77]

### ២.៣.៣. ការលើកទឹកចិត្ត និងកៀគរធនធាន

អ្នកចិត្តសាស្ត្របានកំណត់ថា ការលើកទឹកចិត្ត (Motivation) ជាដំណើរការផ្នែកខាងក្នុងដែលបង្កឱ្យកើតមាន តម្រែតម្រង់ និងបន្តអនុវត្តនូវអាកប្បកិរិយាជាបន្តបន្ទាប់ទៀត **(as an internal process that activates, guides, and maintains behavior over time)** (Marphy & Alexander, 2000; Pintrich, 2003; Schunk, 2000; Stipex, 2002). ក្នុងន័យទូទៅ ការលើកទឹកចិត្ត គឺជាអ្វីដែលជំរុញឱ្យនរណាម្នាក់បន្តការងារ និងកំណត់ពីទិសដៅដែលត្រូវប្រឹងប្រែងឆ្ពោះទៅកាន់។ ការលើកទឹកចិត្តនេះ (Motivation)អាចខុសគ្នាត្រង់ប្រពលភាព និងការលើកទឹកចិត្តដោយផ្ទាល់ **Motivation can vary in both intensity and direction** (Ryan & Deci, 2000)។ ការលើកទឹកចិត្តក៏ជា (Motivation) ឥទ្ធិពលនៃតម្រូវការ និងចំណង់ដែលកើតមានចំពោះប្រពលភាពនិងការលើកទឹកចិត្តដោយផ្ទាល់នៃអាកប្បកិរិយា **is the influence of needs and desires on the intensity and direction of behavior**(Robert, 2006)[78]ការលើកទឹកចិត្តត្រូវបានគេនិយមប្រើក្នុងការត្រួសត្រាយផ្លូវសម្រាប់បុគ្គលម្នាក់ៗឱ្យខិតខំធ្វើការងារ សកម្មភាពផ្តួចផ្តើមច្នៃប្រឌិតដើម្បីសម្រេចបាននូវប្រសិទ្ធផលការងារដែលគេកំពុងបំពេញតាមតួនាទី និងទំនួលខុសត្រូវ(Robbins&Coulter, 2002)។ តាមរយៈការសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៃសាកលវិទ្យាល័យបៀលប្រាយបានគូសបញ្ជាក់ថា វឌ្ឍន

---

[76] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨, ទំព័រ ១៥

[77] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨, ទំព័រ ៩

[78] Educational Psychology, Theory and Practice Eight Edition, Robert E. Slavin, Johns Hopkins University, 2006 Page 318

ភាពនៃសហគមន៍មួយ អង្គភាពមួយ ស្ថាប័នមួយ តែងតែត្រូវបានថ្នាក់ដឹកនាំ គ្រប់គ្រងរៀបចំនូវគោលនយោបាយលើកទឹកចិត្តដោយផ្តល់ជាប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗជាច្រើន ព្រោះថាវាជាយុទ្ធសាស្ត្រមួយដើម្បីលើកតម្កើនលទ្ធភាពការងារ គុណផល និងប្រសិទ្ធផលឆ្លើយតបទៅនឹងទិសដៅស្ថាប័ន និងបុគ្គលផ្ទាល់។ ម្យ៉ាងទៀត អ្នកគ្រប់គ្រងដែលទទួលបានជោគជ័យសុទ្ធតែប្រកាន់ភ្ជាប់នូវគោលការណ៍លើកទឹកចិត្ត និងមានការគោរពស្រឡាញ់ពីបុគ្គលិកក្រោមបង្គាប់ និងនាំឱ្យមានការប្រតិបត្តិការងារមានកំនើនផងដែរ( សំ, ២០០៨)(79)។

### *ក. ទំនាក់ទំនងអ្នកជំនាញ ឥស្សរជន សប្បុរសជន( ចែករំលែកបទពិសោធន៍ បរិច្ចាគថវិកា ការគាំទ្រ និងចូលរួមកម្មវិធីសាលា)*

ដើម្បីអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស ចាំបាច់ត្រូវការគ្រូឧទ្ទេស គ្រូបង្រៀន អ្នកបំប៉នសមត្ថភាពគ្រូបង្រៀន គណៈគ្រប់គ្រងសាលាគរុកោសល្យ និងគណៈគ្រប់គ្រងសាលារៀនដែលមានសមត្ថភាពដោយក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គោលនយោបាយស្តីពីគ្រូបង្រៀន ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ក្របខណ្ឌស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន និងសេចក្តីណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀនក្នុងគោលដៅអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន និងនាយកសាលាក្នុងការបណ្តុះវប្បធម៌រៀនពេញមួយជីវិត។ ក្នុងបរិការណ៍នេះ ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅក្នុងប្រព័ន្ធអប់រំកម្ពុជា ជាការឆ្លើយតបមួយដ៏ចាំបាច់ដើម្បីបង្កើនសមត្ថភាពបង្រៀនរបស់គ្រូ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ សហគមន៍នេះ បានបង្កើនចំណេះវិជ្ជា ជំនាញបច្ចេកទេសជាប្រចាំក្នុងក្របខណ្ឌនៃការសិក្សាពេញមួយជីវិតតាមរយៈការសហការ ការចែករំលែក ការវិភាគ ការស្រាវជ្រាវប្រតិបត្តិ និងការឆ្លុះបញ្ចាំងលើការបង្រៀន និងរៀន។ សកម្មភាពទាំងនេះបានទទួលការចាប់អារម្មណ៍ពីបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកដូចជាប្រទេសកូរ៉េខាងត្បូង សិង្ហបុរី ថៃ និងម៉ាឡេស៊ីជាដើម។ បន្ថែមពីនេះ ក្រុមការងារចម្រុះដើម្បីគ្រូបង្រៀននៅក្នុងពិភពលោក (International Task Force on Teachers)ដែលដឹកនាំ និងសម្របសម្រួលដោយអង្គការយូណេស្កូ តម្រូវឱ្យប្រទេសដែលជាសមាជិកប្រែក្លាយការងារបង្រៀនមិនមែនត្រឹមតែជាមុខរបរប៉ុណ្ណោះទេ តែជាអាជីពដើម្បីឱ្យគ្រូបង្រៀនមានសមត្ថភាពវិជ្ជាជីវៈខ្ពស់ និងទទួលបានការគាំទ្រពីសង្គម( អយក, ២០២១ )(80)។ នៅក្នុងឆ្នាំ ២០២០ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំចងក្រងសៀវភៅប្រវត្តិរូប និងស្នាដៃនាយក

---

79 គម្រោងស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មរៀបរៀងដោយ សំ ប៊ុនលៀង, ប្រធានបទ ការបណ្តុះបណ្តាល និងការលើកទឹកចិត្តបុគ្គលិកក្នុងមន្ទីរអប់រំយុវជន និងកីឡាខេត្តព្រះសីហនុ, ទំព័រ ៧

80 សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ បោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា, ២០២១, ទំព័រ បុព្វកថា

ល្អ គ្រូបង្រៀនល្អ គ្រូបង្រៀនល្អថ្នាក់លេខ ១ លេខ២ លេខ៣ ពានរង្វាន់ សម្តេចតេជោសែន ក្នុងគោលបំណងផ្សព្វផ្សាយបទពិសោធន៍ការងារ និងជាការរួមចំណែកលើកទឹកចិត្ត ជំរុញឱ្យនាយកសាលា គ្រូបង្រៀនទាំងអស់ ខិតខំប្រឹងប្រែងបន្តនៅក្នុងអាជីពរបស់ខ្លួនដើម្បីជាកម្លាំងស្នូលក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាធនធានមនុស្សនៅកម្ពុជាទាំងមូលតាមរយៈស្នាដៃរបស់ពួកគាត់ទាំង ៤៧រូប ចាប់ពីឆ្នាំសិក្សា ២០១៣-២០១៤ ដល់ឆ្នាំសិក្សា ២០១៦-២០១៧ ដល់គណៈគ្រប់គ្រងសាលា បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធដទៃទៀតបានសិក្សាស្វែងយល់ពីប្រវត្តិរូបបុគ្គល ប្រវត្តិសិក្សា ប្រវត្តិការងារ ស្នាដៃដែលទទួលបាន បទពិសោធន៍ការងារ និងទិសដៅអនាគតរបស់ពួកគាត់ ជាក់ស្តែងដូចជាជ័យលោភីពានរង្វាន់សម្តេចតេជារបស់លោកនាយកសាលាបឋមសិក្សាវត្តពោធិ៍ ពឹង គឹមឆេន លោកនាយកសាលាវិទ្យាល័យហ៊ុន សែនប្រាសាទបាគង ស៊ិន សំណាង និងលោកអាន លឹមខេង នាយកវិទ្យាល័យពួកជាដើម (អយក, ២០២០)[81]។

*តាមការអង្កេតរបស់ខ្ញុំក្នុងបទពិសោធន៍ជាគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស នៅវិទ្យាល័យហ៊ុនសែនមិត្តភាព " គណៈគ្រប់គ្រងមន្ទីរ ការិយាល័យក្រុង គណៈនាយក គ្រូបង្រៀន និងសហគមន៍បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសាលារៀនមាន៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធ និង ការលើកកម្ពស់គុណភាពអប់រំ តាមរយៈ ការចែករំលែកបទពិសោធន៍ បរិច្ចាគថវិកា ការគាំទ្រ និងចូលរួមកម្មវិធីសាលារួមមានសកម្មភាព វិភាគទានកសាងទីធ្លា សួនច្បារ សួនជីវចម្រុះ សួនអំណាន ឧបត្ថម្ភគ្រូសិស្សជួបការលំបាក កម្មវិធីសំណេះសំណាលសិស្សនិទ្ទេស A កសាងបណ្ណាល័យ ប្រកួតប្រជែងវេទិកាសាធារណៈ ការលើកទឹកចិត្តចែករង្វាន់គ្រូសិស្សឆ្នើមពូកែ ជួយឧបត្ថម្ភប្រាក់ម៉ោងដល់គ្រូសម្រាប់ការបំប៉នសិស្សថ្នាក់ទី ១២ ពិធីគោរពគុណគ្រូ និងការជួបជុំសំណេះសំណាល អាហារសាមគ្គីជាដើម"*

តាមរយៈសកម្មភាពទាំងនេះ សហគមន៍ សប្បុរសជន អ្នកជំនាញ និងវាគ្មិនល្បីៗពិតជាបានបំពេញតួនាទីយ៉ាងខ្ជាប់ខ្ជួនទាំងកំលាំងកាយចិត្ត និងការឧបត្ថម្ភគាំទ្រធនធានសម្ភារៈ ថវិកា បទពិសោធន៍ការងារ បំណិនជីវិតដល់សមាជិក សមាជិកានៃសហគមន៍សាលារៀន គណៈកម្មការគ្រប់គ្រងសាលា អាជ្ញាធរដែនដី អ្នកអាណាព្យាបាលសិស្ស ក្រុមប្រឹក្សាយុវជន និងសិស្សានុសិស្សផងដែរ។ ក្នុងន័យនេះ អ្វីៗដែលអ្នកទាំងអស់គ្នាបានធ្វើគឺដើម្បីគុណភាពអប់រំ និងវឌ្ឍនភាពលទ្ធផលសិក្សារបស់សិស្សតែប៉ុណ្ណោះពោលគឺ "**ដាំនៅសាលា ផ្លែផ្កាក្នុងសង្គម**"។

*ខ. លើកកម្ពស់ការទទួលខុសត្រូវរបស់អ្នកអាណាព្យាបាលសិស្សចំពោះការសិក្សារបស់កូន (ការជួយសិស្សឱ្យអាន និងរៀននៅផ្ទះ)*

---

[81] សៀវភៅពានរង្វាន់សម្តេចតេជា សែន នាយកសាលាល្អ និងគ្រូបង្រៀនល្អ, បោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា, ២០២០

អ្នកសិក្សារៀនសូត្រអាចសម្រេចជោគជ័យគឺត្រូវពឹងផ្អែកលើការបង្កើត និងការលើកកម្ពស់ទំនាក់ទំនងរវាងសាលារៀន និងគ្រួសារ ព្រមទាំងសហគមន៍ ហើយសិស្សពិតជាមានឆន្ទៈក្នុងការធ្វើឱ្យសម្រេចបាននូវសមិទ្ធិផលសិក្សា ប្រសិនបរិស្ថានសិក្សានៅផ្ទះរបស់ពួកគេ មានការលើកទឹកចិត្ត និងជួយគាំទ្រពីគ្រូបង្រៀន ឪពុកម្តាយ និងសហគមន៍(Epstein, 2001,2009&Sanders and Sheldon, 2009)[82]។ Richard W. Riley បានលើកឡើងថា៖ "***ប្រសិនគ្រួសារបង្រៀនកូននូវសេចក្តីស្រឡាញ់ វាអាចធ្វើពិភពលោកមានការផ្លាស់ប្តូរចំពោះកូនៗរបស់ពួកគេ If families teach the love of learning, it can make all the difference in the world to their children*** "(Richard, 2004)[83]។ ឪពុកម្តាយគឺជាគ្រូដើមអ្នកអប់រំដំបូងបំផុតក្នុងការបណ្តុះបណ្តាលចំណេះដឹង បំណិន ចរិយា សុជីវធម៌ និងគុណធម៌សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់កូនៗ។ នៅក្នុងរចនាសម្ព័ន្ធនៃគណៈកម្មការអភិវឌ្ឍន៍សាលារៀន មានក្រុមការងារចំនួន១១ ហើយនៅក្នុងនេះក្រុមការងាររៀបចំមណ្ឌលអានសម្រាប់កុមារនៅតាមក្លឹបសិក្សាដែលមានសមាសភាពក្រុមការងារដូចតទៅ៖ ១. ប្រធានភូមិ ឬអ្នកដែលមានទេពកោសល្យក្នុងផ្នែកនេះជា ប្រធាន ២. នាយកសាលា ជាអនុប្រធាន ៣. គ្រូបន្ទុកថ្នាក់ ជាសមាជិក ៤. ប្រធានក្រុមប្រឹក្សាយុវជន និងកុមារ ជាសមាជិក ៥. មាតាបិតាបង្គោល ឬប្រធានក្រុមបណ្តាញជា សមាជិក ដោយសមាជិក សមាជិកដែលបានរៀបរាប់ខាងលើនេះត្រូវអនុវត្តភារកិច្ចរបស់ខ្លួនដូចជា៖

- រៀបចំទីកន្លែងរបស់ក្លឹបសិក្សានៅតាមផ្ទះ តាមក្រុមខ្នងផ្ទះ និងនៅកន្លែងប្រមូលផ្តុំក្នុងភូមិ ដោយបន្ថែមឱ្យមានកន្លែងអាន និងមានការដាក់សៀវភៅសម្រាប់សិស្សជួបជុំគ្នាអាន និងធ្វើសកម្មភាពរៀនផ្សេងៗ
- រៀបចំបណ្តាញ និងក្រុមការងារជួយសិស្សអានតាមផ្ទះ តាមក្រុមខ្នងផ្ទះ តាមកន្លែងប្រមូលផ្តុំក្នុងភូមិ និងតាមកន្លែងក្លឹបសិក្សា ឬកន្លែងអានផ្សេងទៀត
- ផ្សព្វផ្សាយដល់មាតាបិតាសិស្ស មេឃុំ មេភូមិ គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ ក្រុមបណ្តាញដើម្បីបង្កើតក្លឹបសិក្សា និងមណ្ឌលអាន និងជាអ្នកជំរុញកូនចៅ និងផ្តល់ឱកាសឱ្យកូនៗបានមកចូលអានគ្រប់ៗគ្នានៅពេលទំនេរ និងជួយពន្យល់បន្ថែមរាល់ចំណុចណាដែលសិស្សមិនចេះអាន
- គ្រូបន្ទុកថ្នាក់ជួឱ្យសិស្សតែងអត្ថបទ សរសេររឿងនិទាន គូររូបភាពជារឿងខ្លីៗតាម រយៈសកម្មភាពរៀនក្នុងសាលា ដើម្បីបានជាឯកសារមកដាក់ប្រើប្រាស់នៅតាមកន្លែងអានក្នុងភូមិ
- រៀបចំឱ្យសាលារៀនមានការទទួលខុសត្រូវ លើការរៀបចំឱ្យមានក្រុមទទួលខុសត្រូវ និងការតាមដានមណ្ឌលអាន ផ្តល់ឯកសារផ្សេងៗសម្រាប់អានដូចជា៖ សៀវភៅពុម្ពរបស់ក្រសួងអប់រំ យុវជន និងកីឡា កាសែត ទស្សនាវដ្តី រឿងនិទាន ឯកសារចងក្រងរៀនតាមបែបស្រាវជ្រាវដែលផលិតដោយស្នាដៃសិស្ស...

---

[82] Journal/Vol.7/N°3/Year 2017 Parental Involvement as an Important Factor for Successful Education

[83] Parent Relation, Mississippi Department of Education, Henry L. Johnson, 2004, http://www.mde.k12.ms.us

- ប្រធានក្រុមត្រូវរៀបចំសៀវភៅសម្រាប់ស្រង់ពាក្យណាដែលសិស្សមិនចេះអាន ឬមិនយល់ដាក់ក្នុងសៀវភៅ និងសរសេរលើក្តារខៀន...។ ប្រធានក្រុមត្រូវរៀបចំសៀវភៅកត់ត្រាចំនួនអ្នកចូលអាន និងកត់ត្រាពីចំនួនអ្នកដែលបានចូលអាន ព្រមជាមួយនិងការស្រង់ពាក្យណាដែលមិនចេះអានរាយការណ៍មកគ្រូ និងនាយកសាលាដើម្បីអាចឱ្យគ្រូជួយសិស្សពេលរៀនក្នុងម៉ោងសិក្សាតាមថ្នាក់។

លើសពីនេះទៅទៀត ក្នុងគណៈកម្មការអភិវឌ្ឍន៍សាលារៀនក៏បានរៀបរាប់ពីក្រុមការពារមួយទៀតពាក់ព័ន្ធនឹងការឃោសនាអប់រំ និងបណ្តុះបណ្តាលដល់សហគមន៍មានតួនាទីភារកិច្ច ព្រមទាំងសមាសភាពក្រុមការងាររួមមាន៖ ១. ក្រុមប្រឹក្សាឃុំទទួលបន្ទុកការងារឃោសនាអប់រំជាប្រធាន ២. គ្រូបង្រៀនបន្ទុក ជាអនុប្រធាន ៣. មេភូមិ ចំណុះឱ្យសាលារៀនជាសមាជិក ៤. គ្រូបង្រៀន ជាសមាជិក ៥. ម៉ែបង្គោលជាសមាជិក ៦.ក្រុមប្រតិបត្តិក្រុមប្រឹក្សាយុវជន និងកុមារជាសមាជិក ហើយមានភារកិច្ចដូចជា៖

- បង្កើតឱ្យមានសកម្មភាពឃោសនាអប់រំដល់ឪពុកម្តាយ ស្តីពីសារៈប្រយោជន៍នៃការអប់រំកូន
- ឃោសនាអប់រំអំពីការអភិវឌ្ឍកុមារក្នុងពិធីបុណ្យសាសនានៅទីវត្តអារាម សហគមន៍ និងការប្រជុំរបស់អាជ្ញាធរជាមួយប្រជាជនតាមឃុំ តាមភូមិ តាមសាលា តាមមណ្ឌលសុខភាព និងតាមខ្នងផ្ទះ។
- ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធព័ត៌មានអប់រំ
- សរសេរពាក្យស្លោកដាក់ទីសាធារណៈដូចជា៖ សាលាឃុំ សាលារៀន វត្តអារាម ទីផ្សារ រមណីយដ្ឋាន
- ចងក្រងក្រុមម៉ែៗក្នុងភូមិ និងរៀបចំរចនាសម្ព័ន្ធសម្រាប់ឱ្យគាត់បានប្រជុំគ្នារវាងម៉ែបង្គោល និងក្រុមម៉ែៗផ្សេងទៀតក្នុងភូមិ អំពីការប្រាស្រ័យទាក់ទងជាមួយកូនប្រកបដោយសីលធម៌ កាយវិការទន់ភ្លន់ សមសួន និងមានចរិតលក្ខណៈល្អ សម្រាប់ជាគំរូពីសំណាក់ឪពុកម្តាយ
- រៀបចំបង្កើត និងពង្រីកកន្លែងជួបជុំរបស់ក្មេងៗនៅតាមក្រុមផ្ទះ តាមភូមិដើម្បីជួបជុំជាមួយគ្រូម៉ែបង្គោល ក្រុមម៉ែៗ(អយក, ២០១៧)[84]។

## គ. ការពង្រឹងតម្លាភាព គណនេយ្យភាព និងស្វ័យភាព

ការគ្រប់គ្រងតាមសាលារៀននឹងមានប្រសិទ្ធភាពដោយត្រូវប្រើអភិក្រម ស្វ័យភាព និងគណនេយ្យភាពរបស់បុគ្គលិកអប់រំប្រកបដោយ សមត្ថភាពតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន ព្រោះ ការធ្វើឱ្យការគ្រប់គ្រងដឹកនាំថ្នាក់រៀន បានឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់សិស្ស និងគ្រូបង្រៀនបានទាន់ពេលវេលាតាមរយៈកំណត់ទិន្នន័យ និងព័ត៌មានពិតដែលបានមកពីការវាយតម្លៃសិស្ស គ្រូបង្រៀន និងសាលារៀន ហើយព័ត៌មានទាំងនោះត្រូវផ្សព្វផ្សាយជាសាធារណៈ។ ការប្រើប្រាស់ និងផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានពិតជាប្រចាំ ព្រមទាំងការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព និងធ្វើឱ្យសហគមន៍បុគ្គលិកអប់រំ មានទំនុកចិត្តលើសាលារៀន ធ្វើឱ្យបុគ្គលិកអប់រំជឿទុកចិត្តគ្នាទៅវិញទៅមក ជាពិសេសធ្វើឱ្យមាតា

[84] ឯកសារប្រតិបត្តិគណៈកម្មការអភិវឌ្ឍសាលារៀន, បោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា, ២០១៧, ទំព័រ ១០

បិតា អ្នកអាណាព្យាបាលសិស្សមានទំនុកចិត្តលើគ្រូបង្រៀន និងសាលារៀន(អយក, ២០១៨)[85]។ ការចូលរួមរបស់សហគមន៍ជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ផ្លូវការ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសប្បុរសជនទាំងអស់ ពិតជាបានរួមចំណែកយ៉ាងសកម្មក្នុងការស្តារ ការកសាងនិងការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៅកម្ពុជាដោយបានវិយោគ ផ្តល់ជំនួយឧបត្ថម្ភ និងការគាំទ្រគ្រប់បែបយ៉ាងទាំងខាងសម្ភារៈ ថវិកា និងបច្ចេកទេស(អូន, ២០២២)[86]។ ទន្ទឹមនឹងនេះ ឯកឧត្តមបានបន្ថែមទៀតថា សាលារៀនត្រូវធានាឱ្យបាននូវបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពអនុវត្តកម្មវិធីសិក្សាបង្រួញ និងអាចបត់បែនបាន ប្រើប្រាស់ខ្លឹមសារឌីជីថលសម្រាប់ការបង្រៀន និងការរៀនព្រមទាំងកែទម្រង់សាលារៀនដើម្បីធ្វើឱ្យសាលារៀនមានការទទួលខុសត្រូវចំពោះឳពុកម្តាយសិស្ស និងសហគមន៍តាមរយៈការផ្លាស់ប្តូរវប្បធម៌សាលារៀន និងការលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន និងការផ្តល់ការគាំទ្រសម្រាប់បរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព(អូន, ២០២២)[87]។ គំរូប្រព័ន្ធវដ្តបិទជិត ៣A កំណត់ក្របខ័ណ្ឌការងារដើម្បីឱ្យសាលារៀនមានស្វ័យភាព និងគណនេយ្យភាពក្នុងបរិបទគ្រប់គ្រងសាលានៃកម្មវិធីវិមជ្ឈការនាពេលបច្ចុប្បន្ន(អយក, ២០១៨)[88]។




(រូបភាពទី ១៥៖ប្រព័ន្ធបិទជិត ៣A អយក, ២០១៨)

---

[85] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨, ទំព័រ ១៩

[86] សុន្ទរកថាអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ក្នុងពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២០-២០២១ និងទិសដៅសម្រាប់ឆ្នាំសិក្សា ២០២១-២០២២ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ២៥ មេសា ២០២២

[87] សុន្ទរកថាអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ក្នុងពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២០-២០២១ និងទិសដៅសម្រាប់ឆ្នាំសិក្សា ២០២១-២០២២ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ២៥ មេសា ២០២២

[88] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨, ទំព័រ ១០

ប្រព័ន្ធវដ្តបិទជិត ៣A នេះ ត្រូវបានយកមកវិភាគការបង្កើនចូលរួមក្នុងដំណើរការសាលារៀន ដោយផ្តោតលើផលសម្រេចដែលកើតចេញពីការសម្រេចចិត្តរបស់មន្ត្រីនយោបាយ ថ្នាក់ដឹកនាំក្នុងការផ្លាស់ប្តូរសិទ្ធិអំណាចនៃរចនាសម្ព័ន្ធមានស្រាប់នៅសហគមន៍ (គណៈកម្មការគ្រប់គ្រងសាលារៀន) លើការបង្កើនការឡានុវត្តភាព ក្នុងការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស (Litvak&Seddon, 1999; Bardhan 2002)។ ការសម្រេចចិត្តផ្អែកលើអភិក្រមការគ្រប់គ្រងតាមសាលារៀនត្រូវធ្វើឡើងដោយគោរពតាមសមាសភាពទាំង ៥ដូចខាងក្រោម៖

១. ស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន

២. ស្វ័យភាពក្នុងការគ្រប់គ្រងបុគ្គលិក

៣. តួនាទីគណៈកម្មការគ្រប់គ្រងសាលារៀន(SMC) និងអភិបាលកិច្ចសាលារៀន

៤. ការវាយតម្លៃសាលារៀន និងសិស្ស

៥. គណនេយ្យភាពសាលារៀន

ការងារគ្រប់គ្រង ដឹកនាំសាលារៀនដែលគណៈគ្រប់គ្រងសាលា និងភាគីពាក់ព័ន្ធត្រូវធ្វើការសម្រេចចិត្តត្រូវផ្តោតលើផលប្រយោជន៍របស់សិស្សជាធំ ដោយត្រូវអនុវត្តតាមក្រុមការងារគណនេយ្យភាពសង្គមនៃគណៈកម្មការអភិវឌ្ឍសាលារៀន ហើយសមាសភាពក្រុមការងារនេះមាន៖ ១. គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ ជាប្រធាន ២. តំណាងមណ្ឌលសុខភាព ជាអនុប្រធាន ៣. នាយកសាលា ជាលេខាធិការ ៤. នារីភូមិ ជាសមាជិក ៥. គ្រូបង្រៀន ជាសមាជិក ៦. ក្រុមប្រឹក្សាយុវជន និងកុមារ ជាសមាជិក។ ដោយអ្នកទាំងនេះមានភារកិច្ច និងទំនួលខុសត្រូវសំខាន់ៗមានដូចតទៅនេះ៖

- ចាត់តាំងឱ្យមានអ្នកទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន អំពីស្ថានភាពថវិការបស់សាលារៀនទៅតាមសេចក្តីត្រូវការរបស់ប្រជាជនដែលចង់ដឹង
- រៀបចំឱ្យមានកន្លែងបិទផ្សាយបង្ហាញ និងទុកដាក់រាល់ប្រភពថវិការបស់អង្គភាពនៅលើក្តារខៀនព័ត៌មាន និងកន្លែងបិទផ្សាយនានាព្រមទាំងបង្ហាញពីប្រភពចំណូលដោយបង្កើតជារចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងថវិកា ដែលជាអ្នកចូលរួមក្នុងការសម្រេចចិត្តលើការចំណាយ និងចំណូលជាមួយ ឬរបស់សាលារៀន(អយក, ២០១៧)[89]។

## ២.៤. លទ្ធផលការសិក្សារបស់សិស្ស

លទ្ធផលនៃការសិក្សារបស់សិស្សគឺជា ក្តីរំពឹងទុកនូវផលសម្រេចរបស់អ្នកបណ្តុះបណ្តាល និងអ្នកសិក្សាចង់សម្រេចបាននៅពេលបង្រៀន និងរៀនចប់វគ្គសិក្សាណាមួយ។ ឧទាហរណ៍៖ នៅប្រទេសកម្ពុជា

[89] ឯកសារប្រតិបត្តិគណៈកម្មការអភិវឌ្ឍសាលារៀន, បោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា, ២០១៧, ទំព័រ ១០

អ្នកសិក្សាក្នុងគ្រឹះស្ថានសាធារណៈ និងឯកជននានានឹងត្រូវស្ថិតនៅក្នុងក្រោមប្រព័ន្ធអប់រំតែមួយដែលមានគោលដៅរួមសម្រាប់អ្នកអប់រំទាំងអស់គ្នា រីឯអ្នកសិក្សាវិញនឹងក្លាយជាពលរដ្ឋពេញលេញប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែកដែលមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទាមានសីលធម៌ និងអត្តចរិតល្អ ព្រមទាំងមានមនសិកាស្នេហាជាតិ និងមនុស្សជាតិដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចផងដែរ។

### ២.៤.១. លទ្ធផលប្រឡងបញ្ចប់

យោងតាមលទ្ធផលនៃការស្រាវជ្រាវស្តីពីប្រសិទ្ធភាព និងលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ ២០១៤ បានបង្ហាញថា សិស្សប្រឡងជាប់មិនដល់ពាក់កណ្តាលទេ។ អាស្រ័យហេតុនេះ ដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស កត្តាចម្បងត្រូវរៀបចំឯកសារពាក់ព័ន្ធដូចជា៖ ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស សៀវភៅលំហាត់អនុវត្ត សម្ភារឧបទេស មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងសៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាពសិស្សជាដើម។ ឯកសារទាំងនេះត្រូវតែរៀបចំឡើងដើម្បីឱ្យស្របទៅនឹងស្ថានភាពអប់រំនៃបណ្តាប្រទេសក្នុងសហគមន៍អាស៊ាន ដែលធានាឱ្យអ្នកសិក្សាមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន តម្រូវការទីផ្សារការងារក្នុងប្រទេស ក្នុងតំបន់ និងលើសកលលោក។ ទាក់ទងនឹងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវធ្វើចំពោះវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការវាយតម្លៃជាដំណើរការជានិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតសមត្ថភាពរបស់សិស្សក្រោយពីដំណើរការរៀន និងបង្រៀនទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។ ការវាយតម្លៃធ្វើឡើងដើម្បីកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងស្តង់ដាលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ ហើយសមត្ថភាពរបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិរួមមាន(អយក, ២០១៥)[90]៖

**តារាងទី ៣៖ សមត្ថភាពដែលស្តែងចេញពីលទ្ធផលសិក្សាតាមរយៈផលជះនៃការអនុវត្តកម្មវិធីសិក្សា**

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| – មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកអក្សរសាស្ត្រខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍន៍សុខភាពកាយសម្បទា និងសីលធម៌ | – មានបំណិនមូលដ្ឋានរឹងមាំច្បាស់លាស់ និងទូលំទូលាយផ្នែកអក្សរសាស្ត្រខ្មែរ(ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា) | – ស្រឡាញ់ និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត<br>– ស្គាល់ និងឱ្យតម្លៃសន្តានចិត្តមេត្តា និងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ |

[90] ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១៥, ទំព័រ អារម្ភកថា, ៣៧ និង៣៨

| | | |
|---|---|---|
| –មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍(ICT) និងភាសាបរទេស | – មានបំណិនមូលដ្ឋានរឹងមាំ និងច្បាស់លាស់ផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)<br>– មានបំណិនអនុវត្ត ចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) មូលដ្ឋាន<br>– មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហារឹងមាំ និងទូលំទូលាយ ទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ<br>– មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងការសិក្សា និងសង្គម<br>– មានបំណិនបង្ការ និងថែទាំសុខភាពបឋម(ការសង្គ្រោះបឋម)<br>– មានសមត្ថភាព និងសីលធម៌ក្នុងការការពារ និងពង្រីកភាពត្រឹមត្រូវ | – អភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ<br>– ស្រឡាញ់ និងឱ្យតម្លៃខ្ពស់ដល់បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>– ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ<br>– មានទម្លាប់ និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្ម និងហាត់កីឡា<br>– ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯង និងរបស់ក្រុមទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ |

ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២២ បានចេញសេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប)សម័យប្រឡង ២៧ ធ្នូ ២០២១ មានបេក្ខជនប្រឡងជាប់ចំនួន៧២,០១៦នាក់ ស្មើនឹង ៦៥, ៦៥ភាគរយ សិស្សជាប់និទ្ទេស A ចំនួន១,៧៥៣នាក់(MoEYS Cambodia, 2022)([91])។ យោងតាមទិន្នន័យនេះ លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាមានការប្រែប្រួលជាវិជ្ជមានជាបន្តបន្ទាប់ចាប់តាំងពីក្រោម៥0% នៅឆ្នាំ ២០១៤ រហូតមកដល់ជាប់បានលើសពាក់កណ្តាល ថែមទាំងទទួលបាននិទ្ទេស A មានចំនួនច្រើនទូទាំងប្រទេសផងដែរ។ សមិទ្ធិផលទាំងនេះ ដោយសារតែមានកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំទាំង១៥ចំណុច និងមូលដ្ឋានសរសរស្តម្ភទាំង៥ដើម្បីជានាគុណភាពអប់រំជាពិសេសគឺ៖ កំណែទម្រង់គុណវុឌ្ឍិគ្រូបង្រៀន ការ

[91] គេហទំព័រ https://www.facebook.com/moeys.gov.kh/posts/5521782944514941

ពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន និងការដាក់ឱ្យអនុវត្តអធិការកិច្ច ការពង្រឹងវង្វាយតម្លៃការសិក្សា( ការប្រឡង និងតេស្តស្តង់ដា ) និងគុណភាពឧត្តមសិក្សា។

| រាជធានី ខេត្ត | បឋមសិក្សា (ថ្នាក់ទី១ - ៦) | | | មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧ - ៩) | | | មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០ - ១២) | | | បេក្ខជនដែលប្រឡងជាប់ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ថ្នាក់ទី៦ | ថ្នាក់ទី៩ | ថ្នាក់ទី១២ |
| បន្ទាយមានជ័យ | 89.5 | 4.9 | 5.5 | 87.1 | 0.9 | 12.1 | 85.5 | 0.8 | 13.8 | 13 425 | 6 483 | 2 846 |
| បាត់ដំបង | 85.1 | 6.9 | 8.0 | 82.1 | 1.2 | 16.7 | 79.5 | 1.3 | 19.1 | 17 707 | 8 854 | 3 670 |
| កំពង់ចាម | 80.9 | 9.7 | 9.4 | 80.1 | 1.2 | 18.7 | 78.9 | 1.3 | 19.8 | 12 191 | 7 169 | 3 875 |
| កំពង់ឆ្នាំង | 87.7 | 8.3 | 4.0 | 81.0 | 0.7 | 18.3 | 74.0 | 1.1 | 24.9 | 9 809 | 4 566 | 1 835 |
| កំពង់ស្ពឺ | 86.1 | 5.7 | 8.2 | 71.6 | 0.7 | 27.7 | 68.5 | 0.7 | 30.8 | 11 387 | 3 827 | 1 599 |
| កំពង់ធំ | 83.3 | 7.7 | 9.0 | 81.2 | 0.8 | 18.0 | 80.1 | 0.8 | 19.2 | 8 944 | 5 990 | 2 725 |
| កំពត | 88.3 | 5.3 | 6.4 | 82.6 | 1.5 | 15.8 | 79.5 | 1.1 | 19.4 | 9 182 | 5 349 | 2 852 |
| កណ្ដាល | 84.9 | 11.5 | 3.6 | 87.7 | 1.1 | 11.2 | 81.3 | 0.9 | 17.8 | 21 715 | 11 868 | 5 397 |
| កែប | 87.4 | 5.5 | 7.1 | 86.9 | 2.8 | 10.3 | 90.4 | 0.1 | 9.5 | 605 | 324 | 259 |
| កោះកុង | 84.2 | 5.1 | 10.7 | 83.4 | 1.7 | 14.9 | 80.8 | 0.5 | 18.7 | 1 639 | 1 018 | 527 |
| ក្រចេះ | 80.0 | 9.8 | 10.2 | 78.6 | 1.3 | 20.1 | 83.1 | 0.4 | 16.5 | 5 259 | 2 410 | 1 273 |
| មណ្ឌលគិរី | 85.0 | 7.0 | 7.9 | 84.8 | 2.3 | 12.9 | 88.9 | 1.2 | 9.9 | 1 503 | 785 | 359 |
| ឧត្ដរមានជ័យ | 80.9 | 8.5 | 10.7 | 81.4 | 1.8 | 16.8 | 85.2 | 2.3 | 12.5 | 3 048 | 1 989 | 1 203 |
| ប៉ៃលិន | 80.2 | 8.2 | 11.6 | 80.4 | 2.2 | 17.4 | 82.3 | 2.1 | 15.5 | 882 | 663 | 355 |
| ភ្នំពេញ | 84.3 | 5.5 | 10.2 | 85.8 | 1.9 | 12.3 | 84.6 | 1.8 | 13.6 | 14 464 | 10 056 | 6 080 |
| ព្រះសីហនុ | 82.9 | 8.5 | 8.6 | 85.1 | 1.8 | 13.1 | 86.2 | 0.4 | 13.4 | 3 011 | 1 682 | 886 |
| ព្រះវិហារ | 80.7 | 11.0 | 8.3 | 85.1 | 0.5 | 14.4 | 76.9 | 0.5 | 22.6 | 3 674 | 2 274 | 893 |
| ព្រៃវែង | 86.0 | 7.8 | 6.2 | 81.1 | 0.4 | 18.5 | 78.5 | 0.9 | 20.6 | 17 432 | 8 411 | 4 049 |
| ពោធិសាត់ | 83.7 | 9.2 | 7.2 | 85.2 | 0.3 | 14.5 | 82.6 | 1.1 | 16.3 | 6 976 | 4 001 | 1 990 |
| រតនគិរី | 82.5 | 5.4 | 12.2 | 79.3 | 0.9 | 19.8 | 83.7 | 0.5 | 15.8 | 3 240 | 1 364 | 864 |
| សៀមរាប | 81.4 | 9.5 | 9.1 | 81.5 | 2.3 | 16.2 | 82.2 | 1.3 | 16.5 | 16 030 | 9 484 | 5 108 |
| ស្ទឹងត្រែង | 75.3 | 12.8 | 11.9 | 78.4 | 0.7 | 20.9 | 89.3 | 0.5 | 10.3 | 1 450 | 904 | 641 |
| ស្វាយរៀង | 88.0 | 5.7 | 6.3 | 77.2 | 0.5 | 22.2 | 74.8 | 0.4 | 24.8 | 8 772 | 4 028 | 1 835 |
| តាកែវ | 88.4 | 7.7 | 4.0 | 86.7 | 1.5 | 11.8 | 82.2 | 0.9 | 16.9 | 15 952 | 10 013 | 5 576 |
| ត្បូងឃ្មុំ | 80.9 | 8.4 | 10.8 | 77.3 | 1.4 | 21.2 | 77.9 | 1.2 | 20.9 | 9 422 | 4 303 | 2 207 |
| ទូទាំងប្រទេស | 84.9 | 8.0 | 7.2 | 82.2 | 1.2 | 16.6 | 80.4 | 1.1 | 18.5 | 217 719 | 117 815 | 58 904 |
| - តំបន់ទីប្រជុំជន | 83.5 | 7.4 | 9.0 | 86.2 | 1.8 | 11.9 | 82.7 | 1.5 | 15.8 | 36 392 | 26 854 | 17 035 |
| - តំបន់ជនបទ | 84.5 | 8.0 | 7.4 | 81.1 | 1.1 | 17.8 | 79.5 | 0.9 | 19.6 | 181 327 | 90 961 | 41 869 |

( រូបភាពទី ១៦៖ លំហូរសិស្ស និងសិស្សប្រឡងជាប់តាមកម្រិតសិក្សា អយក,២០២២ )

## ក.បង្ហាញពីអត្រាត្រួតថ្នាក់ថយចុះ

យោងតាមការអង្កេតអក្ខរកម្មនៅឆ្នាំ ២០០០របស់អង្គការ UNESCO/UNDP បានប៉ាន់ប្រមាណថា មានប្រជាជនតែ ៣៦%ប៉ុណ្ណោះដែលមានចំណេះដឹងទាក់ទងទៅនឹងសមត្ថភាពអក្ខរកម្ម( ចេះអក្សរ ) ដែលអាចប្រើប្រាស់សម្រាប់ជីវិតប្រចាំថ្ងៃ និងរបាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏បានបង្ហាញពីអត្រាអក្ខរកម្មជាតិ ស្ត្រី៤៥.១% និងបុរស២៤.៨%មិនចេះអក្សរក្នុងចំណោមប្រជាជនសរុប ៦.៥លាននាក់ដែលមានអាយុ១៥ឆ្នាំឡើង។ ប្រជាជនប្រមាណ២,៣៦លាននាក់ជាអនក្ខរជនទាំងស្រុង (ចៅ, ២០១៨)[92]។ ដោយសារអនក្ខរកម្មគឺជាបញ្ហាស្នូលរាំងស្ទះក្នុងការអភិវឌ្ឍខឿនសេដ្ឋកិច្ចប្រទេសជាតិនេះ ទើបរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដោយប្រកាន់យកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពចម្បងបំផុត និងក្រសួងអប់រំ យុវជន និងកីឡារៀបចំកំណែទម្រង់វិស័យអប់រំដោយឈរលើមូលដ្ឋានទស្សនៈអភិវឌ្ឍន៍ប្រកបដោយចីរភាព និងចក្ខុវិស័យថ្មីស្របតាមនិន្នាការអប់រំសម្រាប់ទាំងអស់គ្នា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០១៤ដល់ ឆ្នាំ ២០១៨ ផែនការពង្រឹងគុណភាពអប់រំ ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត ព្រម

[92] ឯកសារត្រៀមប្រឡងបរិញ្ញាបត្រជាន់ខ្ពស់, ចៅ ឧស្សាហ៍ ( 087 499 944 ), ២០១៨, ទំព័រ៨

ទាំងធានានូវភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣។ កាលានុវត្តភាពនៃនយោបាយឈ្នះ ឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលពីរទសវត្សនេះវិស័យអប់រំបានទទួលសមិទ្ធិផលជាផ្លែផ្កាចាប់ពីមានការចូលរៀនប្រកបដោយសមធម៌ មកដល់ការពង្រឹងគុណភាពអប់រំតួយ៉ាងបានបង្ហាញឱ្យឃើញថាសិស្សរៀនត្រួតថ្នាក់កាលពីឆ្នាំសិក្សា ២០១៨-២០១៩ មាន **១៥,២២៣**នាក់ ស្រី៥,១៦៧នាក់(សិស្សសរុប ៦២៨,៦៩៤នាក់/៣៣៧,១២២នាក់)(អយក, ២០២០)[93] និងឆ្នាំសិក្សា ២០២០-២០២១ មាន **៨៤៣៦**នាក់ ស្រី ៣៥១២នាក់(សិស្សសរុប ៦៨០, ៨០១នាក់/៣៦៣៩៩១នាក់) (អយក, ២០២២)[94]។ សូចនាករនេះ ពិតជាបានបញ្ជាក់ថារាល់កំណែទម្រង់វិស័យអប់រំ និងការចងក្រងគោលនយោបាយអប់រំ ការបង្កើតផែនការយុទ្ធសាស្ត្រ និងសេចក្តីណែនាំ គោលការណ៍ប្រតិបត្តិនានា មានប្រសិទ្ធភាព ព្រមទាំងភាពស័ក្តិសិទ្ធិក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

| រាជធានី ខេត្ត | ចំនួន សាលារៀន | សាលារៀន ជួបការលំបាក | ចំនួន ថ្នាក់រៀន | ចំនួន បន្ទប់រៀន | ថ្នាក់រៀន នៅក្នុងវត្ត | ចំនួនសិស្ស | | សិស្សរៀនត្រួតថ្នាក់ | | បុគ្គលិកបង្រៀន | | បុគ្គលិកមិនបង្រៀន | | បុគ្គលិកសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| បន្ទាយមានជ័យ | 30 | 0 | 692 | 687 | 0 | 31 897 | 17 592 | 252 | 104 | 1 330 | 535 | 197 | 55 | 1 527 | 590 |
| បាត់ដំបង | 29 | 0 | 877 | 817 | 0 | 41 587 | 22 710 | 565 | 282 | 1 456 | 668 | 232 | 76 | 1 688 | 744 |
| កំពង់ចាម | 43 | 0 | 1 095 | 1 026 | 10 | 48 289 | 26 749 | 705 | 359 | 2 078 | 952 | 463 | 202 | 2 541 | 1 154 |
| កំពង់ឆ្នាំង | 16 | 0 | 492 | 480 | 0 | 22 200 | 12 346 | 187 | 91 | 1 060 | 411 | 186 | 51 | 1 246 | 462 |
| កំពង់ស្ពឺ | 25 | 0 | 576 | 523 | 2 | 29 701 | 15 670 | 291 | 97 | 1 084 | 399 | 185 | 29 | 1 269 | 428 |
| កំពង់ធំ | 25 | 0 | 695 | 660 | 0 | 30 546 | 16 866 | 217 | 65 | 1 100 | 502 | 201 | 47 | 1 301 | 549 |
| កំពត | 24 | 0 | 1 603 | 594 | 0 | 25 504 | 13 387 | 387 | 164 | 1 258 | 499 | 231 | 63 | 1 489 | 562 |
| កណ្ដាល | 40 | 0 | 1 211 | 1 071 | 22 | 54 191 | 29 152 | 569 | 206 | 2 759 | 1 221 | 383 | 91 | 3 142 | 1 312 |
| កែប | 2 | 0 | 48 | 48 | 0 | 1 743 | 920 | 29 | 9 | 141 | 64 | 16 | 7 | 157 | 71 |
| កោះកុង | 12 | 0 | 183 | 153 | 0 | 6 598 | 3 394 | 75 | 27 | 313 | 116 | 42 | 13 | 355 | 129 |
| ក្រចេះ | 13 | 0 | 256 | 251 | 0 | 11 281 | 6 160 | 101 | 34 | 523 | 255 | 70 | 19 | 593 | 274 |
| មណ្ឌលគិរី | 6 | 0 | 98 | 90 | 0 | 4 315 | 2 269 | 75 | 26 | 185 | 74 | 22 | 3 | 207 | 77 |
| ឧត្ដរមានជ័យ | 9 | 0 | 215 | 208 | 0 | 9 331 | 4 939 | 237 | 90 | 311 | 109 | 46 | 14 | 357 | 123 |
| ប៉ៃលិន | 2 | 0 | 74 | 74 | 0 | 3 307 | 1 838 | 98 | 37 | 165 | 70 | 20 | 5 | 185 | 75 |
| ភ្នំពេញ | 41 | 0 | 1 817 | 1 303 | 12 | 86 732 | 43 543 | 1 367 | 573 | 4 916 | 2 199 | 482 | 158 | 5 398 | 2 357 |
| ព្រះសីហនុ | 9 | 0 | 223 | 221 | 0 | 9 600 | 4 949 | 131 | 44 | 460 | 159 | 52 | 9 | 512 | 168 |
| ព្រះវិហារ | 18 | 0 | 227 | 227 | 0 | 8 704 | 4 744 | 45 | 18 | 394 | 169 | 39 | 12 | 433 | 181 |
| ព្រៃវែង | 32 | 0 | 1 066 | 979 | 37 | 47 497 | 25 335 | 315 | 141 | 1 730 | 625 | 329 | 77 | 2 059 | 702 |
| ពោធិ៍សាត់ | 16 | 0 | 379 | 368 | 0 | 17 099 | 9 352 | 123 | 53 | 769 | 283 | 126 | 25 | 895 | 308 |
| រតនគិរី | 12 | 0 | 198 | 184 | 0 | 9 304 | 4 722 | 79 | 30 | 342 | 137 | 27 | 12 | 369 | 149 |
| សៀមរាប | 44 | 0 | 1 156 | 1 046 | 0 | 60 122 | 33 550 | 1 139 | 436 | 1 727 | 766 | 303 | 107 | 2 030 | 873 |
| ស្ទឹងត្រែង | 9 | 0 | 114 | 111 | 0 | 4 632 | 2 472 | 24 | 9 | 238 | 89 | 33 | 15 | 271 | 104 |
| ស្វាយរៀង | 21 | 0 | 684 | 667 | 30 | 26 114 | 13 403 | 168 | 53 | 1 300 | 416 | 227 | 69 | 1 527 | 485 |
| តាកែវ | 53 | 0 | 1 479 | 1 429 | 2 | 57 052 | 29 629 | 730 | 342 | 2 502 | 791 | 529 | 122 | 3 031 | 913 |
| ត្បូងឃ្មុំ | 28 | 0 | 768 | 700 | 0 | 33 455 | 18 300 | 527 | 222 | 1 104 | 444 | 187 | 47 | 1 291 | 491 |
| ទូទាំងប្រទេស | 559 | 0 | 16 226 | 13 917 | 115 | 680 801 | 363 991 | 8 436 | 3 512 | 29 245 | 11 953 | 4 628 | 1 328 | 33 873 | 13 281 |
| - តំបន់ទីប្រជុំជន | 116 | 0 | 4 391 | 3 723 | 12 | 201 854 | 104 509 | 3 124 | 1 251 | 10 119 | 4 470 | 1 277 | 448 | 11 396 | 4 918 |
| - តំបន់ជនបទ | 443 | 0 | 11 835 | 10 194 | 103 | 478 947 | 259 482 | 5 312 | 2 261 | 19 126 | 7 483 | 3 351 | 880 | 22 477 | 8 363 |

(រូបភាពទី ១៧៖ វិទ្យាល័យ ថ្នាក់រៀន សិស្ស និងបុគ្គលិក អយក, ២០២២)

[93] ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំសិក្សា ២០១៨-២០១៩, ២០២០, ទំព័រ ៦

[94] ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំសិក្សា ២០២០-២០២១, ២០២២, ទំព័រ ៦

## ខ.កាត់បន្ថយការបោះបង់ការសិក្សា

ការអនុវត្តផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវក្របខណ្ឌអាហារូបករណ៍ ដែលផ្តោតលើគោលការណ៍សមធម៌នៅកម្រិតមធ្យមសិក្សា និង ការធ្វើឱ្យសម្រេចនូវសូចនាករអាហារូបករណ៍ដើម្បីធានាឱ្យទទួលបានការអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិរបស់អ្នកដឹកនាំ និងគ្រប់គ្រងគ្រប់លំដាប់ថ្នាក់។ កម្មវិធីផ្តល់អាហារូបករណ៍សិស្សនៅមធ្យមសិក្សាជាកម្មវិធីមួយជួយបង្កើនការចូលរៀនប្រកបដោយសមធម៌ និងបរិយាបន្នរបស់ក្រុមសិស្សមកពីគ្រួសារក្រីក្រ គ្រួសារងាយរងគ្រោះ ជួបការលំបាកដើម្បីបានមកចូលរៀន និងអាចបន្តរៀនសូត្ររហូតចប់កម្រិតអប់រំមូលដ្ឋាន ព្រមទាំងបន្តដល់មធ្យមសិក្សាទុតិយភូមិ(អយក, ២០២១)[95]។ នៅឆ្នាំ២០២០-២០២១ កម្មវិធីអាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាទុតិយភូមិរបស់ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់អត្ថប្រយោជន៍ដល់សិស្សចំនួន ១១,០៧០នាក់(ប្រមាណ ១៦ភាគរយនៃចំនួនសិស្សសរុបដែលបានចុះឈ្មោះ)ក្នុងនោះ ៦០%ជាសិស្សស្រីដែលមានសាលារៀនចំនួន ២១៤ដោយម្នាក់ៗទទួលបាន ៣៦០,០០០រៀលក្នុងមួយឆ្នាំហើយត្រូវបានផ្តល់ជូនជាបីដំណាក់កាល។ កម្មវិធីនេះ ត្រូវបានផ្តល់ថវិកាទាំងស្រុងតាមរយៈថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡាហើយត្រូវបានអនុវត្តដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ(GSED) ក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានអប់រំ (DGE)។ ហិរញ្ញប្បទានរបស់កម្មវិធីនេះ ត្រូវបានព្រមព្រៀងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាផ្នែកមួយនៃដំណើរការថវិកាប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងគោលបំណងបង្កើនការចូលរៀនរបស់សិស្ស ទទួលបានការអប់រំកម្រិតមូលដ្ឋានដោយមិនបង់ប្រាក់ កុមារទាំងអស់ត្រូវទទួលបានការអប់រំ ចំណេះសម្បទា បំណិនសម្បទា និងឥរិយាបថសម្បទាប្រកបដោយគុណតម្លៃ ហើយជាយន្តការ៖

- រួមចំណែកការចូលរួមការរក្សាសិស្សក្រីក្រ សិស្សងាយរងគ្រោះ ខ្វះខាត និងជួបការលំបាកបន្តការសិក្សានៅក្នុងសាលារៀន
- រួមចំណែកដល់ការកើនឡើងនៃអត្រាបញ្ចប់ការសិក្សារបស់សិស្ស
- មានអត្រាឆ្លងភូមិសិក្សាកើនឡើង(អយក, ២០២១)[96]

ជាទឡ្ហីករណ៍ យោងតាមសូចនាករអប់រំឆ្នាំសិក្សា ២០១៨-២០១៩ មានអត្រាសិស្សបោះបង់ការសិក្សាចំនួន **១៦.៩%**(អយក, ២០២០)[97] និងឆ្នាំសិក្សា ២០២០-២០២១ បានបង្ហាញថាមានអត្រាសិស្សបោះបង់ការសិក្សាចំនួន **១៨.៥%**(អយក, ២០២២)[98] តួលេខនេះ សបញ្ជាក់ពីភាពថប់ថយនៃវត្តមានសិស្សចូលរៀនដែលបណ្តាលមកពីកត្តាជីវភាព បញ្ហាជំងឺរាតត្បាត(Covid-19)។ ប៉ុន្តែ លទ្ធផលសិក្សាមានការរីកចម្រើនដោយសារមានការចូលរួមភាគីពាក់ព័ន្ធ ក្នុងការពង្រឹងដំណើរការបង្រៀនក្នុងបរិ

[95] សៀវភៅណែនាំប្រតិបត្តិកម្មវិធីអាហារូបករណ៍មធ្យមសិក្សាចំណេះទូទៅ បោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ ២០២១ ទំព័រ អារម្ភកថា

[96] សៀវភៅណែនាំប្រតិបត្តិកម្មវិធីអាហារូបករណ៍មធ្យមសិក្សាចំណេះទូទៅ បោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ ២០២១ ទំព័រ អារម្ភកថា

[97] ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំសិក្សា ២០១៨-២០១៩, ២០២០, ទំព័រ ៤៦

[98] ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំសិក្សា ២០២០-២០២១, ២០២២, ទំព័រ ៤៦

បទកូវីដ ដោយប្រើវិធីសាស្ត្រចម្រុះដូចជា៖ ការសិក្សាពីចម្ងាយ ការសិក្សាតាមប្រព័ន្ធឌីជីថល ការសិក្សាផ្លាស់វេន និងការចុះទៅបង្រៀនតាមខ្នងផ្ទះរបស់សិស្សជាដើម។ ជាក់ស្ដែងតាមសូចនាករ និងស្ថិតិអប់រំសាធារណៈអត្រាឡើងថ្នាក់ នៅកម្រិតមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេសមានអត្រា **៨០.៤%** (អយក, ២០២២)[99] និងការប្រកាសលទ្ធផលប្រឡងបាក់ឌុបឆ្នាំសិក្សា ២០២០-២០២១ មានបេក្ខជនប្រឡងជាប់ជាស្ថាពរ **៦៥, ៦៥%** ។

| រាជធានី ខេត្ត | បឋមសិក្សា (ថ្នាក់ទី១ - ៦) | | | មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧ - ៩) | | | មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០ - ១២) | | | បេក្ខជនដែលប្រឡងជាប់ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ថ្នាក់ទី៦ | ថ្នាក់ទី៩ | ថ្នាក់ទី១២ |
| បន្ទាយមានជ័យ | 89.5 | 4.9 | 5.5 | 87.1 | 0.9 | 12.1 | 85.5 | 0.8 | 13.8 | 13 425 | 6 483 | 2 846 |
| បាត់ដំបង | 85.1 | 6.9 | 8.0 | 82.1 | 1.2 | 16.7 | 79.5 | 1.3 | 19.1 | 17 707 | 8 854 | 3 670 |
| កំពង់ចាម | 80.9 | 9.7 | 9.4 | 80.1 | 1.2 | 18.7 | 78.9 | 1.3 | 19.8 | 12 191 | 7 169 | 3 875 |
| កំពង់ឆ្នាំង | 87.7 | 8.3 | 4.0 | 81.0 | 0.7 | 18.3 | 74.0 | 1.1 | 24.9 | 9 809 | 4 566 | 1 835 |
| កំពង់ស្ពឺ | 86.1 | 5.7 | 8.2 | 71.6 | 0.7 | 27.7 | 68.5 | 0.7 | 30.8 | 11 387 | 3 827 | 1 599 |
| កំពង់ធំ | 83.3 | 7.7 | 9.0 | 81.2 | 0.8 | 18.0 | 80.1 | 0.8 | 19.2 | 8 944 | 5 990 | 2 725 |
| កំពត | 88.3 | 5.3 | 6.4 | 82.6 | 1.5 | 15.8 | 79.5 | 1.1 | 19.4 | 9 182 | 5 349 | 2 852 |
| កណ្ដាល | 84.9 | 11.5 | 3.6 | 87.7 | 1.1 | 11.2 | 81.3 | 0.9 | 17.8 | 21 715 | 11 868 | 5 397 |
| កែប | 87.4 | 5.5 | 7.1 | 86.9 | 2.8 | 10.3 | 90.4 | 0.1 | 9.5 | 605 | 324 | 259 |
| កោះកុង | 84.2 | 5.1 | 10.7 | 83.4 | 1.7 | 14.9 | 80.8 | 0.5 | 18.7 | 1 639 | 1 018 | 527 |
| ក្រចេះ | 80.0 | 9.8 | 10.2 | 78.6 | 1.3 | 20.1 | 83.1 | 0.4 | 16.5 | 5 259 | 2 410 | 1 273 |
| មណ្ឌលគិរី | 85.0 | 7.0 | 7.9 | 84.8 | 2.3 | 12.9 | 88.9 | 1.2 | 9.9 | 1 503 | 785 | 359 |
| ឧត្ដរមានជ័យ | 80.9 | 8.5 | 10.7 | 81.4 | 1.8 | 16.8 | 85.2 | 2.3 | 12.5 | 3 048 | 1 989 | 1 203 |
| ប៉ៃលិន | 80.2 | 8.2 | 11.6 | 80.4 | 2.2 | 17.4 | 82.3 | 2.1 | 15.5 | 882 | 663 | 355 |
| ភ្នំពេញ | 84.3 | 5.5 | 10.2 | 85.8 | 1.9 | 12.3 | 84.6 | 1.8 | 13.6 | 14 464 | 10 056 | 6 080 |
| ព្រះសីហនុ | 82.9 | 8.5 | 8.6 | 85.1 | 1.8 | 13.1 | 86.2 | 0.4 | 13.4 | 3 011 | 1 682 | 886 |
| ព្រះវិហារ | 80.7 | 11.0 | 8.3 | 85.1 | 0.5 | 14.4 | 76.9 | 0.5 | 22.6 | 3 674 | 2 274 | 893 |
| ព្រៃវែង | 86.0 | 7.8 | 6.2 | 81.1 | 0.4 | 18.5 | 78.5 | 0.9 | 20.6 | 17 432 | 8 411 | 4 049 |
| ពោធិ៍សាត់ | 83.7 | 9.2 | 7.2 | 85.2 | 0.3 | 14.5 | 82.6 | 1.1 | 16.3 | 6 976 | 4 001 | 1 990 |
| រតនគិរី | 82.5 | 5.4 | 12.2 | 79.3 | 0.9 | 19.8 | 83.7 | 0.5 | 15.8 | 3 240 | 1 364 | 864 |
| សៀមរាប | 81.4 | 9.5 | 9.1 | 81.5 | 2.3 | 16.2 | 82.2 | 1.3 | 16.5 | 16 030 | 9 484 | 5 108 |
| ស្ទឹងត្រែង | 75.3 | 12.8 | 11.9 | 78.4 | 0.7 | 20.9 | 89.3 | 0.5 | 10.3 | 1 450 | 904 | 641 |
| ស្វាយរៀង | 88.0 | 5.7 | 6.3 | 77.2 | 0.5 | 22.2 | 74.8 | 0.4 | 24.8 | 8 772 | 4 028 | 1 835 |
| តាកែវ | 88.4 | 7.7 | 4.0 | 86.7 | 1.5 | 11.8 | 82.2 | 0.9 | 16.9 | 15 952 | 10 013 | 5 576 |
| ត្បូងឃ្មុំ | 80.9 | 8.4 | 10.8 | 77.3 | 1.4 | 21.2 | 77.9 | 1.2 | 20.9 | 9 422 | 4 303 | 2 207 |
| **ទូទាំងប្រទេស** | 84.9 | 8.0 | 7.2 | 82.2 | 1.2 | 16.6 | 80.4 | 1.1 | 18.5 | 217 719 | 117 815 | 58 904 |
| - តំបន់ទីប្រជុំជន | 83.5 | 7.4 | 9.0 | 86.2 | 1.8 | 11.9 | 82.7 | 1.5 | 15.8 | 36 392 | 26 854 | 17 035 |
| - តំបន់ជនបទ | 84.5 | 8.0 | 7.4 | 81.1 | 1.1 | 17.8 | 79.5 | 0.9 | 19.6 | 181 327 | 90 961 | 41 869 |

(រូបភាពទី ១៨៖ អត្រាសិស្សបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សា អយក,២០២២)

[99] ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំសិក្សា ២០២០-២០២១, ២០២២, ទំព័រ ៥៥

| រាជធានី ខេត្ត | ថ្នាក់ទី៩ | | | ថ្នាក់ទី១០ | | | ថ្នាក់ទី១១ | | | ថ្នាក់ទី១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
| បន្ទាយមានជ័យ | 85.7 | 1.1 | 13.3 | 87.5 | 0.3 | 12.2 | 93.1 | 0.2 | 6.7 | 73.2 | 2.1 | 24.7 |
| បាត់ដំបង | 72.1 | 2.1 | 25.8 | 83.9 | 0.6 | 15.5 | 92.0 | 0.5 | 7.6 | 57.8 | 3.5 | 38.7 |
| កំពង់ចាម | 61.7 | 2.2 | 36.1 | 86.1 | 0.5 | 13.4 | 90.2 | 0.8 | 9.0 | 55.7 | 3.0 | 41.3 |
| កំពង់ឆ្នាំង | 68.2 | 0.9 | 30.9 | 83.2 | 0.1 | 16.6 | 85.1 | 0.1 | 14.8 | 49.1 | 3.6 | 47.3 |
| កំពង់ស្ពឺ | 45.2 | 1.6 | 53.2 | 77.6 | 0.6 | 21.8 | 86.5 | 0.6 | 13.0 | 36.0 | 1.1 | 62.9 |
| កំពង់ធំ | 73.2 | 1.3 | 25.5 | 85.7 | 0.4 | 13.9 | 91.5 | 0.2 | 8.3 | 58.9 | 1.9 | 39.2 |
| កំពត | 73.2 | 2.7 | 24.0 | 85.0 | 0.7 | 14.3 | 90.0 | 0.7 | 9.4 | 60.9 | 2.2 | 36.9 |
| កណ្ដាល | 84.0 | 1.3 | 14.7 | 87.6 | 0.7 | 11.7 | 89.3 | 0.3 | 10.4 | 63.4 | 1.9 | 34.6 |
| កែប | 79.6 | 9.1 | 11.3 | 91.8 | 0.0 | 8.2 | 94.1 | 0.0 | 5.9 | 84.6 | 0.3 | 15.0 |
| កោះកុង | 69.5 | 3.1 | 27.3 | 86.7 | 0.3 | 12.9 | 90.3 | 0.1 | 9.6 | 62.0 | 1.3 | 36.7 |
| ក្រចេះ | 70.0 | 3.0 | 27.0 | 85.9 | 0.0 | 14.1 | 92.2 | 0.0 | 7.8 | 69.0 | 1.2 | 29.7 |
| មណ្ឌលគិរី | 84.2 | 3.5 | 12.2 | 91.1 | 0.7 | 8.2 | 91.2 | 0.2 | 8.6 | 82.2 | 3.4 | 14.4 |
| ឧត្ដរមានជ័យ | 73.6 | 2.0 | 24.5 | 81.6 | 1.9 | 16.5 | 87.4 | 1.2 | 11.5 | 88.2 | 4.3 | 7.6 |
| ប៉ៃលិន | 71.6 | 5.1 | 23.3 | 84.8 | 2.0 | 13.2 | 88.2 | 0.9 | 10.9 | 71.7 | 3.8 | 24.4 |
| ភ្នំពេញ | 64.1 | 3.1 | 32.7 | 95.8 | 0.2 | 4.0 | n.a. | 0.1 | n.a. | 50.8 | 5.6 | 43.6 |
| ព្រះសីហនុ | 76.2 | 3.7 | 20.2 | 88.8 | 0.3 | 10.9 | 89.4 | 0.1 | 10.6 | 77.7 | 1.1 | 21.2 |
| ព្រះវិហារ | 81.5 | 0.6 | 17.9 | 80.0 | 0.6 | 19.4 | 87.6 | 0.1 | 12.3 | 59.5 | 0.9 | 39.5 |
| ព្រៃវែង | 63.9 | 1.1 | 35.0 | 84.2 | 0.2 | 15.6 | 90.2 | 0.2 | 9.6 | 57.1 | 2.8 | 40.1 |
| ពោធិ៍សាត់ | 79.8 | 0.8 | 19.5 | 87.5 | 0.0 | 12.5 | 91.8 | 0.0 | 8.2 | 66.1 | 3.7 | 30.2 |
| រតនគិរី | 58.9 | 3.1 | 38.0 | 82.3 | 0.3 | 17.4 | 88.8 | 0.0 | 11.2 | 79.3 | 1.6 | 19.1 |
| សៀមរាប | 68.6 | 2.3 | 29.1 | 87.6 | 1.1 | 11.3 | 91.8 | 0.9 | 7.3 | 62.7 | 2.0 | 35.2 |
| ស្ទឹងត្រែង | 65.8 | 0.9 | 33.3 | 88.1 | 0.1 | 11.8 | 94.7 | 0.1 | 5.2 | 84.9 | 1.5 | 13.6 |
| ស្វាយរៀង | 59.6 | 1.0 | 39.4 | 81.8 | 0.0 | 18.2 | 87.3 | 0.0 | 12.6 | 50.6 | 1.2 | 48.2 |
| តាកែវ | 77.8 | 1.3 | 20.9 | 89.3 | 0.3 | 10.4 | 89.3 | 0.3 | 10.4 | 65.3 | 2.2 | 32.5 |
| ត្បូងឃ្មុំ | 55.6 | 3.2 | 41.2 | 84.3 | 0.5 | 15.3 | 91.6 | 0.4 | 8.0 | 53.2 | 3.0 | 43.8 |
| **ទូទាំងប្រទេស** | 69.4 | 1.9 | 28.7 | 86.5 | 0.5 | 13.1 | 91.6 | 0.4 | 8.0 | 59.2 | 2.7 | 38.1 |
| - តំបន់ទីប្រជុំជន | 71.6 | 2.8 | 25.6 | 91.9 | 0.6 | 7.6 | 98.2 | 0.3 | 1.5 | 54.7 | 3.8 | 41.5 |
| - តំបន់ជនបទ | 68.7 | 1.7 | 29.6 | 84.4 | 0.4 | 15.2 | 88.8 | 0.4 | 10.8 | 61.3 | 2.3 | 36.5 |

(រូបភាពទី ១៩៖ អត្រាសិស្សឡើងថ្នាក់នៅកម្រិតមធ្យមសិក្សា អយក,២០២២)

| ក្រុង ស្រុក ខណ្ឌ | អត្រាគង់វង្ស ២០២០ - ២០២១ | | | | | | | | | | | | អត្រាបញ្ចប់ការសិក្សា ២០២១ - ២០២២ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់ទី ៥ | | | បឋមសិក្សា | | | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | | បឋមសិក្សា | | | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| បន្ទាយមានជ័យ | 79.1 | 77.5 | 80.6 | 74.1 | 73.0 | 75.3 | 54.1 | 55.1 | 52.9 | 38.4 | 40.4 | 35.9 | 82.2 | 86.2 | 78.6 | 44.9 | 51.0 | 39.4 | 25.5 | 30.8 | 20.6 |
| បាត់ដំបង | 78.3 | 82.3 | 73.8 | 71.5 | 75.9 | 66.7 | 40.8 | 45.5 | 36.1 | 23.4 | 26.6 | 20.3 | 109.7 | 114.3 | 105.5 | 61.2 | 68.7 | 54.2 | 35.5 | 40.8 | 30.5 |
| កំពង់ចាម | 79.2 | 84.3 | 70.6 | 74.3 | 78.8 | 66.5 | 36.2 | 45.1 | 26.7 | 18.0 | 23.0 | 12.8 | 103.7 | 104.3 | 103.2 | 61.1 | 67.8 | 54.5 | 40.1 | 45.8 | 34.5 |
| កំពង់ឆ្នាំង | 88.9 | 90.7 | 86.6 | 84.7 | 87.1 | 81.9 | 56.4 | 58.8 | 53.6 | 27.5 | 28.1 | 26.9 | 96.7 | 99.6 | 93.8 | 58.9 | 65.0 | 52.9 | 34.0 | 39.1 | 28.9 |
| កំពង់ស្ពឺ | 85.6 | 83.1 | 88.1 | 80.4 | 77.7 | 83.0 | 35.7 | 32.7 | 39.1 | 11.1 | 10.3 | 12.1 | 88.5 | 88.7 | 88.4 | 46.0 | 48.9 | 43.2 | 23.6 | 25.8 | 21.4 |
| កំពង់ធំ | 78.5 | 81.8 | 71.7 | 71.6 | 76.0 | 64.2 | 35.2 | 38.2 | 30.8 | 20.6 | 22.7 | 17.6 | 94.4 | 100.1 | 89.1 | 56.0 | 61.1 | 51.1 | 35.5 | 41.1 | 30.0 |
| កំពត | 81.7 | 81.2 | 82.2 | 77.4 | 77.1 | 77.7 | 48.9 | 52.5 | 45.3 | 28.5 | 30.4 | 26.7 | 89.6 | 89.0 | 90.1 | 58.5 | 62.8 | 54.3 | 37.8 | 41.0 | 34.6 |
| កណ្ដាល | 86.0 | 86.4 | 85.6 | 81.4 | 82.1 | 80.7 | 63.1 | 64.7 | 61.6 | 42.5 | 44.6 | 40.2 | 88.1 | 88.6 | 87.7 | 58.6 | 62.4 | 54.9 | 35.8 | 40.9 | 30.9 |
| កែប | 78.5 | 76.9 | 80.2 | 71.5 | 69.0 | 74.0 | 49.1 | 49.0 | 48.7 | 37.1 | 36.7 | 36.8 | 81.4 | 81.4 | 81.3 | 50.1 | 54.6 | 45.9 | 37.0 | 36.5 | 37.4 |
| កោះកុង | 71.4 | 69.0 | 73.7 | 66.6 | 63.8 | 69.4 | 36.3 | 34.2 | 38.4 | 20.5 | 20.6 | 20.3 | 90.2 | 93.6 | 87.2 | 58.2 | 62.5 | 54.5 | 32.6 | 35.9 | 29.7 |
| ក្រចេះ | 72.6 | 77.9 | 65.9 | 64.3 | 69.9 | 57.6 | 29.7 | 33.4 | 25.6 | 17.0 | 19.4 | 14.4 | 98.6 | 107.1 | 91.0 | 44.0 | 49.7 | 38.9 | 25.5 | 28.7 | 22.5 |
| មណ្ឌលគិរី | 76.2 | 73.4 | 79.6 | 67.3 | 65.8 | 69.0 | 42.5 | 43.2 | 41.8 | 31.2 | 26.7 | 36.2 | 98.7 | 119.3 | 81.1 | 46.4 | 53.9 | 40.1 | 26.3 | 31.2 | 22.0 |
| ឧត្ដរមានជ័យ | 73.5 | 70.8 | 76.0 | 66.9 | 64.9 | 68.7 | 31.1 | 32.0 | 29.9 | 17.2 | 18.2 | 15.9 | 84.9 | 93.1 | 77.7 | 46.6 | 55.1 | 39.1 | 25.2 | 28.7 | 22.0 |
| ប៉ៃលិន | 68.3 | 69.6 | 66.8 | 61.7 | 63.2 | 60.1 | 29.3 | 30.6 | 27.9 | 17.0 | 19.8 | 14.1 | 84.1 | 89.4 | 79.5 | 57.0 | 67.7 | 47.7 | 32.6 | 39.0 | 26.9 |
| ភ្នំពេញ | 76.4 | 76.1 | 76.8 | 72.5 | 72.3 | 72.5 | 44.3 | 44.6 | 44.0 | 0.0 | 28.9 | 0.0 | 41.5 | 40.9 | 42.2 | 34.5 | 35.4 | 33.6 | 28.7 | 29.3 | 28.0 |
| ព្រះសីហនុ | 74.3 | 72.2 | 76.4 | 68.3 | 66.3 | 70.2 | 42.9 | 41.0 | 44.7 | 27.0 | 26.2 | 27.7 | 55.4 | 61.8 | 50.2 | 37.0 | 39.8 | 34.6 | 21.7 | 25.9 | 18.3 |
| ព្រះវិហារ | 72.3 | 72.6 | 71.9 | 66.1 | 66.3 | 65.7 | 40.4 | 40.8 | 39.9 | 23.4 | 24.9 | 21.7 | 88.0 | 99.0 | 78.2 | 53.6 | 63.3 | 45.0 | 30.1 | 35.1 | 25.6 |
| ព្រៃវែង | 87.6 | 84.3 | 90.8 | 83.8 | 80.4 | 87.0 | 49.2 | 47.8 | 50.6 | 24.2 | 24.2 | 24.1 | 102.3 | 99.3 | 105.4 | 59.1 | 61.6 | 56.5 | 34.2 | 37.4 | 31.0 |
| ពោធិសាត់ | 79.3 | 82.2 | 75.3 | 73.9 | 77.0 | 69.7 | 44.1 | 47.7 | 40.0 | 28.5 | 29.6 | 27.1 | 107.1 | 113.6 | 100.9 | 61.3 | 66.3 | 56.5 | 34.8 | 39.1 | 30.7 |
| រតនគិរី | 66.4 | 62.9 | 69.8 | 57.8 | 54.8 | 60.7 | 30.1 | 30.0 | 30.0 | 13.4 | 14.5 | 12.3 | 114.2 | 125.8 | 104.1 | 50.2 | 54.9 | 46.1 | 29.3 | 31.7 | 27.2 |
| សៀមរាប | 77.4 | 78.5 | 76.3 | 71.5 | 73.2 | 69.7 | 39.0 | 42.9 | 34.9 | 22.5 | 26.0 | 18.8 | 106.7 | 113.5 | 100.4 | 65.6 | 75.8 | 56.1 | 43.3 | 51.8 | 35.2 |
| ស្ទឹងត្រែង | 70.8 | 72.1 | 68.8 | 64.1 | 65.4 | 62.3 | 21.7 | 22.7 | 20.5 | 12.1 | 14.3 | 9.9 | 92.5 | 105.3 | 81.4 | 42.6 | 46.3 | 39.3 | 23.6 | 26.8 | 20.8 |
| ស្វាយរៀង | 87.9 | 85.7 | 90.0 | 84.0 | 82.0 | 85.8 | 44.9 | 41.5 | 48.5 | 19.3 | 17.0 | 22.0 | 100.2 | 99.2 | 101.1 | 59.6 | 58.3 | 61.0 | 34.9 | 36.8 | 32.9 |
| តាកែវ | 89.1 | 86.6 | 91.5 | 85.9 | 83.7 | 88.0 | 64.5 | 62.6 | 66.5 | 40.8 | 39.0 | 42.8 | 91.1 | 91.0 | 91.2 | 65.7 | 68.0 | 63.5 | 46.5 | 49.8 | 43.2 |
| ត្បូងឃ្មុំ | 75.4 | 74.7 | 76.0 | 69.2 | 68.7 | 69.7 | 31.0 | 31.3 | 30.5 | 13.9 | 14.4 | 13.2 | 91.0 | 93.6 | 88.5 | 49.3 | 55.6 | 43.3 | 27.1 | 31.3 | 23.0 |
| ទូទាំងប្រទេស | 80.2 | 80.6 | 79.6 | 74.8 | 75.5 | 74.0 | 43.7 | 45.2 | 42.0 | 24.7 | 25.8 | 23.4 | 87.3 | 89.7 | 85.0 | 52.9 | 57.4 | 48.5 | 33.1 | 37.1 | 29.3 |
| - តំបន់ទីប្រជុំជន | 77.6 | 78.5 | 76.7 | 73.0 | 74.3 | 71.7 | 45.0 | 46.5 | 43.6 | 30.2 | 31.7 | 28.8 | 55.9 | 56.4 | 55.5 | 44.5 | 46.9 | 42.2 | 39.2 | 42.4 | 36.2 |
| - តំបន់ជនបទ | 80.7 | 81.0 | 80.2 | 75.2 | 75.7 | 74.5 | 43.1 | 44.7 | 41.3 | 22.7 | 23.9 | 21.5 | 98.8 | 101.9 | 95.8 | 55.9 | 61.3 | 50.8 | 30.9 | 35.2 | 26.7 |

(រូបភាពទី ២០៖ អត្រាគង់វង្ស បញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សា អយក,២០២២)

## គ.ទទួលបានអាហារូបករណ៍/កំណើនសិស្សពូកែ និងឆ្នើម

ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ រីឯរដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលបានការឧបត្ថម្ភដើម្បីបង្កើតមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ(រដ្ឋធម្មនុញ្ញ, ២០០៨)[100]។ ដើម្បីលើកទឹកចិត្តដល់អ្នកសិក្សា សប្បុរសជនបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់គុណភាពសិក្សារបស់សិស្សដោយផ្ដល់ជារង្វាន់លើកទឹកចិត្ត តាមរយៈការប្រកួតប្រជែងស្នាដៃតែងនិពន្ធ ការប្រឡងសិស្សពូកែ ប្រចាំសាលា ប្រចាំខេត្ត និងទូទាំងប្រទេស។ មិនតែប៉ុណ្ណោះ យោងតាមសេចក្ដីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡាលេខ ៩១ ចុះថ្ងៃ ២៨ ធ្នូ ឆ្នាំ ២០២០ បានជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រមិនបង់ថ្លៃសិក្សា ១០០% សម្រាប់ឆ្នាំសិក្សា ២០២១-២០២២ ចំនួនរហូតដល់ ៩៨១៨នាក់។ លើសពីនេះ និស្សិតដែលប្រឡងបាក់ឌុបបាននិទ្ទេស A ឬ B ពួកគេមានសិទ្ធិសម្រេចជ្រើសរើសមុខជំនាញ និងមហាវិទ្យាល័យដែលបានផ្ដល់អាទិភាពឱ្យពួកគេទៀតផង។ គ្រឹះស្ថានឧត្ដមសិក្សាសាធារណៈចំនួន ១៩ និងគ្រឹះស្ថានឧត្ដមសិក្សាឯកជនចំនួន ២០ បានបង្កើតនូវ

[100] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២០០៨, មាត្រា ៤៦ និង៤៩, ទំព័រ ១៨

លក្ខខណ្ឌនានាដើម្បីសម្រួលដល់និស្សិតគឺធ្វើយ៉ាងណា ដើម្បីឱ្យមានកំណើននិស្សិតចូលរៀនជំនាញផ្សេងៗនៅកម្រិតឧត្តម ដែលកត្តាទាំងនេះហើយអាចជួយពន្លឿនសេដ្ឋកិច្ចជាតិ និងជម្រុញប្រទេសឱ្យក្លាយទៅជាប្រទេសឧស្សាហកម្មនាពេលអនាគតដ៏ខ្លីយ៉ាងមុខនេះ(អយក, ២០២១)[101]។

### ឃ.អាត្រាសិស្សចូលរៀននៅឧត្តមសិក្សាកើនឡើង

ជាការឆ្លុះបញ្ចាំងពីកាលានុវត្តភាពក្នុងការចូលរៀនរបស់យុវជន នៅកម្រិតឧត្តមសិក្សាមកដល់ឆ្នាំ ២០១៩ បានចំនួន ១៥ភាគរយ។ អនុវិស័យឧត្តមសិក្សា ត្រូវពង្រីកវិសាលភាពសេវាដែលអាចធានាពីវត្តមាននិស្សិតមធ្យមសិក្សាឱ្យចូលរៀនបន្តបាន៤៥ភាគរយ ទៅ៥០ភាគរយនៅឆ្នាំ ២០៣០ ដោយរិះរកនូវយុទ្ធសាស្ត្រគន្លឹះដើម្បីបង្កើនការចូលរៀនដោយការពង្រឹងគុណភាព ការធានាឱ្យនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើត្រូវនឹងជំនាញក្រោយបញ្ចប់ពីការសិក្សាភ្លាម និងមានចំណូលខ្ពស់តាមស្តង់ដារបៀវត្សទីផ្សារការងារ។ ដោយប្រទេសកម្ពុជាយើង មានអត្រាចូលរៀននៅឧត្តមសិក្សាបានតែ ១៥ភាគរយ ហើយអត្រានេះត្រូវអភិវឌ្ឍន៍ឱ្យទាន់ប្រទេសថៃ (៤៩%) ឬម៉ាឡេស៊ី(៤៣%) នៅឆ្នាំ២០៣០ និងបន្តឈានទៅតាមឱ្យទាន់ប្រទេសសឹង្ហបុរី (៨៩%) នៅឆ្នាំ ២០៥០។ បរិមាណចូលរៀនត្រូវមានភាពស្របគ្នាជាមួយនឹងគុណភាពដែលបានកែលម្អ។ ដូចនេះ ការផ្តោតអាទិភាពលើការកែលម្អគុណភាពជាកត្តាគន្លឹះដែលនឹងនាំឱ្យមានឥទ្ធិពលលើការបង្កើនការចូលរៀននៅកម្រិតឧត្តមសិក្សានេះ(អយក, ២០២១)[102]។

**តារាងការចូលរៀនរបស់សិស្សនៅប្រទេសមួយចំនួនក្នុងតំបន់**

| ភូមិសិក្សា | កម្ពុជា | វៀតណាម | ថៃ | ម៉ាឡេស៊ី | សឹង្ហបុរី |
|---|---|---|---|---|---|
| កុមារតូច | ២៥ (១៩) | ៩៦ (១៩) | ៧៩ (១៩) | ៩៨ (១៩) | ១៣០ (១៩) |
| បឋមសិក្សា | ៩០ (១៨) | ៩៨ (១៣) | ៩៨ (០៩) | ១០០ (១៧) | ១០០ (១៧) |
| មធ្យមសិក្សា | ៤៥ (០៨) | ៥៨ (១៨) | ១១៥ (១៩) | ៨៤ (១៩) | ១០៦ (១៨) |
| ឧត្តមសិក្សា | ១៥ (១៩) | ២៩ (១៩) | ៤៩ (១៦) | ៤៣ (១៩) | ៨៩ (១៨) |

(រូបភាពទី ២១៖ អត្រាចូលរៀនតាមភូមិសិក្សា អយក,២០២១)

### ២.៤.២.ផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន

ការកសាងសង្គមមួយឱ្យមានពលរដ្ឋប្រកបដោយចំណេះដឹង ជំនាញ និងឥរិយាបថថ្លៃថ្នូរ ត្រូវទាមទារឱ្យមានការចូលរួមពីមន្ត្រីអប់រំគ្រប់លំដាប់ សហគមន៍ អ្នកអាណាព្យាបាល មាតាបិតា និងសិស្សានុសិស្សផ្ទាល់ ហើយទើបអាចជ្រោងគុណភាពអប់រំនេះបានប្រសើរឡើង ព្រមទាំងអាចជួយបង្កឱ្យមានផ្លែផ្កានៅក្នុងសង្គមជាក់ស្តែងរបស់សិស្សតាមរយៈឥរិយាបថជាលក្ខណៈសតិសម្បជ្ញៈ បញ្ញាស្មារតី

---

[101] សៀវភៅកម្រងព័ត៌មានសម្រាប់បេក្ខជនស្នើសុំអាហារូបករណ៍ចូលរៀនថ្នាក់បរិញ្ញបត្រមិនបង់ថ្លៃសិក្សា ១០០% ឆ្នាំសិក្សា ២០២១-២០២២

[102] សៀវភៅប្រតិបត្តិប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សា ដោយក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ ២០២១, ទំព័រ៦

បុគ្គលិកលក្ខណៈអន្តរបុគ្គល និងវិជ្ជាជីវៈក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ការប្រាស្រ័យទាក់ទងគ្នា ការសេពគប់ ការដោះស្រាយបញ្ហា ការគ្រប់គ្រងខ្លួនឯងដែលអាចរួមចំណែកលើកកម្ពស់ជីវិតប្រកបដោយផលិតភាព និងសុខុមាលភាពដើម្បីធានាភាពជោគជ័យក្នុងការដោះស្រាយបញ្ហាប្រឈមនានាក្នុងការរស់នៅប្រចាំថ្ងៃ (អយក, ២០០៦)[103]។ ដំណើរការបង្រៀន និងរៀនដែលមានប្រសិទ្ធផល និងគុណផលគឺតែងតែរំលេចឱ្យឃើញនូវការផ្លាស់ប្ដូរឥរិយាបថជាវិជ្ជមានរបស់អ្នកសិក្សា(សៀង, ២០២១)[104]។ យ៉ាងណាមិញ ការវាយតម្លៃលើប្រសិទ្ធភាពនៃការបង្រៀន និងរៀនរបស់គ្រូ ត្រូវតែពឹងផ្អែកលើធាតុចូល ដំណើរការបង្រៀន និងរៀន ផលសម្រេចនៃវគ្គសិក្សានេះតាមរយៈលទ្ធផលសិក្សារបស់សិស្សមានការប្រែប្រួលជាវិជ្ជមាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា(តារាងស្ដីពីសមត្ថភាពដែលស្ដែងចេញពីលទ្ធផលសិក្សារបស់សិស្ស ទំព័រ៦១)។ ឧទាហរណ៍៖ ការវាយតម្លៃសិស្សក្នុងការរៀនបំណិនជីវិត ការវាយតម្លៃសិស្សក្នុងការរៀនភាសាអង់គ្លេស ការវាយតម្លៃសិស្សក្នុងការរៀនមុខវិជ្ជាគណិតវិទ្យាជាដើម។ ការវាយតម្លៃសិស្សក្នុងការរៀនបំណិនជីវិតផ្ដោតលើទិដ្ឋភាពបីយ៉ាង៖

១. ការអភិវឌ្ឍចំណេះដឹង(វិជ្ជាសម្បទា) ជួយសិស្សឱ្យសម្រេចចិត្តបានត្រឹមត្រូវដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយព្រមទាំងប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍។

២. ការអភិវឌ្ឍបំណិនបុរេវិជ្ជាជីវៈ(បំណិនសម្បទា) ការគ្រប់គ្រងអាជីវកម្ម និងការងារព្រមទាំងជំនាញបច្ចេកទេសដែលជួយឱ្យជីវិត និងការងាររបស់សិស្សប្រកបដោយជោគជ័យ។

៣. ការអភិវឌ្ឍគុណតម្លៃផ្ទាល់ខ្លួន(ចរិយាសម្បទា) ជួយឱ្យសិស្សទទួលបាននូវសេចក្ដីថ្លៃថ្នូរ និងការគោរពពីអ្នកដទៃ និងចូលរួមប្រព្រឹត្តទង្វើល្អសម្រាប់សង្គម(អយក, ២០០៦)[105]។

## ក.សិស្សចូលចិត្តសាលារៀន និងស្វ័យសិក្សា

តបតាមការផ្លាស់ប្ដូរឥរិយាបថជាវិជ្ជមានគឺជា ការឆ្លុះបញ្ចាំងពីប្រសិទ្ធផលនៃការបង្រៀនរបស់អ្នកអប់រំ ក្នុងការអភិវឌ្ឍគុណតម្លៃរបស់សិស្ស ដោយជួយឱ្យពួកគេទទួលបាននូវស្វ័យសិក្សាយ៉ាងទៀងទាត់ដោយការលើកទឹកចិត្តរបស់គ្រូបង្រៀនឱ្យសិស្សចេះរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងការទទួលខុសត្រូវដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹងថ្មីៗសម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃដោយប្រើប្រាស់វិធីសាស្ត្រទំនើបដូចជា៖ សហការ អង្កេត គម្រោង។ ឆ្លើយតបទៅនឹងគោលនយោបាយទី ១ នៃវិស័យអប់រំជាតិដែលផ្ដោតលើការសិក្សាពេញមួយជីវិត គឺមានចក្ខុវិស័យអភិវឌ្ឍប្រជាជនកម្ពុជាគ្រប់រូបឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទាដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ច និងលើកកម្ពស់សុខដុមជីវិតបុគ្គល គ្រួសារ និងសង្គម តាមរយៈការផ្ដល់ឱកាសសិក្សាពេញមួយជីវិត គ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយដោយមានកិច្ចសហការ ឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ សប្បុរសជន អាជ្ញាធរមូលដ្ឋាន និងសហគមន៍ អ្នកអាណាព្យាបាលសិស្សដើម្បីផ្ដល់នូវសេវាអប់រំសម្បូរបែប និងមានភាពបត់បែន បង្កើតមជ្ឈមណ្ឌលសិក្សា ហេដ្ឋារចនាសម្ព័ន្ធ

---

[103] គោលនយោបាយអប់រំបំណិនជីវិត, ឆ្នាំ ២០០៦, ទំព័រ ៨

[104] បទបង្ហាញរបស់ សាស្ត្រាចារ្យ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា មុខវិជ្ជា ការអភិវឌ្ឍកម្មវិធីសិក្សា, ២០២១

[105] គោលនយោបាយអប់រំបំណិនជីវិត, ឆ្នាំ ២០០៦, ទំព័រ ៩

រូបវន្តដូចជា៖សួនអំណាន បណ្ណាល័យ មន្ទីរពិសោធន៍ បន្ទប់កុំព្យូទ័រ សួនជីវចម្រុះ និងសួនកសិកម្មជាដើម តាមរយៈការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងសិក្សាឱ្យសមស្រប(អយក, ២០១៩)[106]។ ជាពិសេស នៅក្នុងសាលាវិទ្យាល័យហ៊ុន សែនមិត្តភាព បានរៀបចំបង្កើតជាសួនអំណាន បណ្ណាល័យស្តង់ដា អាគារសង្គ្រោះបឋម បន្ទប់ទឹកស្តង់ដាខ្ពស់ សួនជីវៈចម្រុះ សួនកសិកម្មផងដែរ។

***ខ.មានជំនាញក្នុងការអាន សរសេរ ទំនាក់ទំនង និងលេខនព្វន្ត***

លទ្ធផលសិក្សារបស់សិស្ស គឺជាការបង្ស៊ីទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក្នុងការរស់នៅដែលបង្កើតឡើងដោយគោលការណ៍បង្រៀនភ្ជាប់ទៅនឹងភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីសិក្សាពី ភូមិសិក្សាមួយទៅភូមិសិក្សាមួយទៀតពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត និងភាពឆ្លើយតបនៃកម្មវិធីសិក្សាពីមធ្យមសិក្សាទៅឧត្តមសិក្សា និងទីផ្សារការងារក្នុងសម័យបច្ចេកវិទ្យាព័ត៌មានដូចជា៖ ការរៀបចំទម្រង់នៃប្រព័ន្ធអប់រំថ្មីតាមរចនាសម្ព័ន្ធ ដែលសិស្សនៅមធ្យមសិក្សាទុតិយភូមិចាប់ពីថ្នាក់ទី១០ឡើងទៅមានជម្រើសបីរួមមានវិទ្យាសាស្ត្រពិត វិទ្យាសាស្ត្រសង្គម និងអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយអនុលោមតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ ផលសម្រេចបាននៃកម្មវិធីសិក្សាចំណេះទូទៅ នឹងអាចឱ្យអ្នកសិក្សាទទួលបានសមត្ថភាពភាសាខ្មែរ និងភាសាបរទេសលើបំណិនទាំងបួន(ការស្តាប់ ការនិយាយ ការអាន និងការសរសេរ)បានច្បាស់លាស់សម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ និងការប្រាស្រ័យទាក់ទងក្នុងការសិក្សា និង ការរស់នៅប្រចាំថ្ងៃ ព្រមទាំងសម្រេចបាននូវចំណេះដឹងគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកទេស និងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ជាមូលដ្ឋានដល់ការយល់ដឹង ពន្យល់ បកស្រាយ ការពារ អំណះអំណាង ជជែកវែកញែក សម្របសម្រួលចរចារ បញ្ចុះបញ្ចូល ស្វែងយល់ និងដោះស្រាយបញ្ហាទាំងក្នុងការសិក្សា និងការបំពេញការងារវិជ្ជាជីវៈ(អយក, ២០១៥)[107]។

**គ.មានចរិយាថ្លៃថ្នូរ មនសិការស្នេហាជាតិ**

រាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងផ្តល់ឱកាសតាមគ្រប់រូបភាពដល់ប្រជាពលរដ្ឋគ្រប់រូបបានអភិវឌ្ឍចំណេះដឹងមូលដ្ឋានទាំងអស់គ្នា ដោយបើកយុទ្ធនាការរំដោះគ្រោះមិនចេះអក្សរ និងគ្រោះភ្លេចអក្សរតាមពាក្យស្លោកមួយចំនួនក្នុងន័យលើកកម្ពស់ការអប់រំដូចជា៖ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះគឺថារៀនហើយរៀនទៀត រៀនមិនចេះចប់" ដើម្បីជាគន្លឹះក្នុងជួយគ្នា សហការគ្នាប្រកបដោយភាតរភាពក្នុងការបណ្តុះស្មារតីស្នេហាជាតិ និងមនុស្សជាតិធ្វើឱ្យការរស់នៅក្នុងសង្គមប្រកបដោយសុខសន្តិភាព ព្រមទាំងមានសុខដុមនីយកម្ម(អយក, ២០១៩)[108]។ ប្រទេសមួយពិតជាប្រាថ្នាចង់បាន ពលរដ្ឋល្អដែលជាកោសិការបស់ជាតិ។ ពលរដ្ឋល្អត្រូវមានចំណេះដឹង ជំនាញ ឥរិយាបថ និងសីលធម៌ល្អ ហើយមានសាមគ្គីភាពមិនប្រកាន់វណ្ណៈ ឋានៈតួនាទី ជាតិសាសន៍ ពណ៌សម្បុរពោលគឺមានសមភាពយេនឌ័រ។ បុគ្គលមានចរិយាថ្លៃថ្នូរ ទឹកចិត្តស្រឡាញ់គ្នា ការជឿជាក់ស្មោះស្ម័គ្រ យោគយល់ អធ្យាស្រ័យ និងការចេះអនុគ្រោះគ្នាទៅវិញទៅមក។ កត្តាសំខាន់ៗទាំង

---

[106] គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត, ២០១៩, ទំព័រ ៦

[107] ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១៥, ទំព័រ ៧

[108] គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត, ២០១៩, ទំព័រ ៣

នេះ វានាំឱ្យបុគ្គល គ្រួសារ សហគមន៍ រស់នៅជាមួយគ្នាប្រកបដោយភាពសុខសាន្ត។ លទ្ធផលដែលសម្រេចបានពីការរៀនសូត្រ បទពិសោធន៍ក្នុងសង្គមរមែងតែងតែមានតម្លៃសោភ័ណដែលអាចផ្តើមពីការធ្វើឱ្យខ្លួននៃបុគ្គលម្នាក់ៗមានតម្លៃសម្រាប់គ្រួសារ សង្គមរស់នៅក្នុងភាពថ្លៃថ្នូរ ចូលរួមលើកកម្ពស់តម្លៃសីលធម៌ តម្លៃស្នាដៃសង្គមជាតិឱ្យមានវឌ្ឍនភាព និងកិត្តិយសឧត្តុង្គឧត្តមទៀតផង។

## ២.៤.៣.មានទំនុកចិត្ត និងឧត្តមភាពក្នុងការរស់នៅ

មនុស្សយើងម្នាក់ៗ មានទស្សនៈ ការគិត និងជំនឿមិនដូចគ្នាទេដោយយោងលើហេតុផល សមត្ថភាព និងផលសម្រេចផ្សេងៗគ្នាតាមការជឿជាក់ សេចក្តីសម្រេចចិត្តត្រឹមត្រូវ ព្រមទាំងសេចក្តីអំណត់អត់ធ្មត់ព្យាយាមប្រកបដោយក្តីសង្ឃឹមយ៉ាងមុតមាំរៀងៗខ្លួន ។ បុគ្គលគ្រប់រូប នឹងមានទំនុកចិត្ត និងឧត្តមភាពក្នុងជីវិតរស់នៅប្រចាំថ្ងៃ នៅពេលដែលគេទទួលបានការអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ឧត្តមភាពដោយមានរបរចិញ្ចឹមជីវិតស្របតាមសីលធម៌សង្គម និងមានទំនុកចិត្តព្រោះខ្លួនជាមនុស្សម្នាក់ដែលមានបញ្ញា ជំនាញក្នុងការសម្រេចចិត្ត គំនិតនវានុវត្តន៍។ ការអប់រំប្រកបដោយគុណភាព ជាចំណុចដៅមួយ ក្នុងចំណោមចំណុចដៅដទៃទៀតរបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់រាជរដ្ឋាភិបាលកម្ពុជា ព្រោះរាជរដ្ឋាភិបាលយល់ឃើញថា ការកសាងកម្លាំងពលកម្មឱ្យមានសមត្ថភាព ចំណេះដឹង ជំនាញបច្ចេកទេស និងគុណធម៌ នឹងអាចជួយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិបាន។ ក្នុងបរិបទសកលភាវូបនីយកម្ម អ្នកសិក្សាត្រូវតែពង្រឹងការរៀនសូត្ររបស់ខ្លួន ស្វែងយល់ពីប្រធានបទដែលត្រូវរៀន ស្រង់ព័ត៌មាន និងបទពិសោធន៍ពីសហគមន៍ រៀនវិភាគបញ្ហាដោយវិធីដើមឈើបញ្ហា រៀបចំដំណោះស្រាយ និងសកម្មភាពងាយៗ។ ប្រសិទ្ធផលសិក្សាដែលលេចចេញនៅក្នុងសង្គមទាំងនេះ អាចធ្វើសនិទានកម្មបានថា ពលរដ្ឋពេញលេញជាបុគ្គលដែលមានទំនុកចិត្តលើខ្លួនឯង មានជំនាញគ្រប់គ្រងខ្លួនឯង ធ្វើសេចក្តីសម្រេចចិត្ត ការប្រាស្រ័យទាក់ទង ការត្រិះរិះពិចារណា ការគោរពអ្នកដទៃ មានភាពជាអ្នកដឹកនាំ និងសហគ្រិនភាពទៀងផង។

### ក.ភាពមានការងារធ្វើ

ការផ្លាស់ប្តូរថ្មីៗនៃរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចក្នុងសង្គមកម្ពុជា កម្មវិធីពង្រីកសមត្ថភាពឧស្សាហកម្ម ដំណើរការសមាហរណកម្មអាស៊ាន និងការដាក់ចេញចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០ទាមទារជាបន្ទាន់ឱ្យមានការធ្វើកំណែទម្រង់វិស័យអប់រំនៅកម្ពុជាដើម្បីធានាឱ្យមានមូលធនមនុស្ស បំពាក់ដោយជំនាញចាំបាច់ដើម្បីលើកកម្ពស់ស្តង់ដានៃការរស់នៅ និងរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ(អយក,២០១៤) [109]។ ហេតុនេះ កំណែទម្រង់លើកម្មវិធីសិក្សាពិតជាអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងាររបស់សង្គមបាន ជាក់ស្តែងគោលបំណងនៃការអប់រំបំណិនជីវិតគឺឱ្យអ្នកសិក្សាទាំងពីរភេទ ស្រី និងប្រុសមានឱកាសស្មើគ្នាក្នុងការទទួលបានការសិក្សាផ្នែកចំណេះដឹង ជំនាញ និងការចូលរួមក្នុងជីវភាពសង្គម។ ទ្រឹស្តីទាំងនេះ ត្រូវផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែងដោយបណ្តុះបណ្តាលបំណិន អនុវត្តវិជ្ជាជីវៈស្របតាមធនធាន និងតម្រូវការក្នុងមូលដ្ឋានព្រមទាំងចំណង់ចំណូលចិត្តរបស់ខ្លួន ដើម្បីបង្កើនគុណភាពជីវិតរស់នៅដោយបង្ហាត់បង្រៀន ហ្វឹកហាត់នូវបំណិនវិជ្ជាជីវៈមូលដ្ឋានសម្រាប់ឈានទៅដល់អាជីពមួយច្បាស់

[109] គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា ២០៣០, ឆ្នាំ ២០១៤, ទំព័រ ៣

លាស់នាពេលអនាគតដូចជា៖ បំណិនអាជីពងាយ និងបំណិនវិជ្ជាជីវៈ ។ បំណិនអាជីពងាយគឺជាបំណិនទាំងឡាយណាដែលទាក់ទងនឹងមុខជំនាញសាមញ្ញ ដោយត្រូវការបណ្តុះបណ្តាលរយៈពេលខ្លី និងបច្ចេកទេសងាយៗសម្រាប់អ្នកសិក្សាមានលទ្ធភាពលើកកម្ពស់ជីវភាព ឬបង្កើនសេដ្ឋកិច្ចគ្រួសារ។ អ្នកសិក្សាម្នាក់ៗអាចអភិវឌ្ឍបំណិនអាជីពងាយមិនដូចគ្នាទេ អាស្រ័យលើធនធានតម្រូវការតាមមូលដ្ឋាន និងចំណង់ចំណូលចិត្តរបស់គេផ្ទាល់។ រីឯ បំណិនវិជ្ជាជីវៈ សំដៅដល់បំណិនដែលទាក់ទងទៅនឹងមុខជំនាញឯកទេសដោយត្រូវការការបណ្តុះបណ្តាលរយៈពេលមធ្យម ឬវែង និងជំនាញបច្ចេកទេសកម្រិតខ្ពស់សម្រាប់អ្នកសិក្សាធ្វើជាទុនក្នុងការប្រកបមុខរបរនានាដើម្បីចិញ្ចឹមជីវិត(អយក, ២០០៦)[110] ។

ជាសេចក្តីសន្និដ្ឋាន ភាពមានការងារធ្វើសម្រាប់យុវសិស្សគឺជាមាគ៌ាឈានឆ្ពោះទៅសម្រេចគោលដៅនៃការអភិវឌ្ឍជាតិ លើគ្រប់វិស័យឱ្យទទួលបានជោគជ័យដ៏ត្រចះត្រចង់តាមរយៈប្រសិទ្ធផលនៃលទ្ធផលសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិប្រកបដោយស្មារតីស្រឡាញ់ការសិក្សា ចំណេះដឹង និងមានជំនាញគ្រប់គ្រាន់ក្នុងការត្រៀមលក្ខណៈទទួលយករបត់នៃការផ្លាស់ប្តូរស្ថានភាពក្នុងជីវិតនាពេលអនាគត។

**ខ.ដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងភាពច្នៃប្រឌិត**

មនុស្សយើងធ្វើអ្វីក៏ដោយត្រូវមានឯករាជ្យភាព និងស្មារតីទទួលខុសត្រូវចំពោះកាតព្វកិច្ច ភារកិច្ចបេសកកម្មរបស់ខ្លួនដោយហ៊ានប្រឈមនឹងដំណោះស្រាយបញ្ហា ការតស៊ូលះបង់យ៉ាងប្តូរផ្តាច់ដើម្បីជោគជ័យ ហ៊ានបង្ហាញការពិតចំពោះទង្វើប្រព្រឹត្ត ចេះកែកំហុសខ្លួនមករកផ្លូវត្រូវឬផ្លូវល្អ ដើម្បីធ្វើខ្លួនជាមនុស្សមានសមត្ថភាព មានមនសិការក្នុងការងារ មានសីលធម៌ មានសាមគ្គីភាព ចេះរួមរស់ជាមួយគ្នាក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ។ បំណិនពិចារណា និងការបង្កើតថ្មី គឺជាលទ្ធផលអប់រំរំពឹងទុកក្នុងចំណោមបំណិនឯទៀតដែលអ្នកសិក្សាត្រូវសម្រេចបានបន្ទាប់ពីបញ្ចប់ការសិក្សានៅសាលា។ ពួកគេអាចប្រើចំណេះដឹងទៅវិភាគ ស្វែងយល់ពីទ្រឹស្តីបញ្ញត្តិ ប្រមើលមើលបញ្ហាប្រឈម រួចវាយតម្លៃព័ត៌មាន ពិចារណារកហេតុផលដើម្បីស្វែងរកដំណោះស្រាយ និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព។ រីឯគំនិតនវានុវត្តន៍របស់យុវសិស្សត្រូវបានលើកទឹកចិត្តក្នុងសហគមន៍ដោយបង្កើតលទ្ធភាព គំនិតនិងចំណេះដឹងថ្មីៗដោយឯករាជ្យ និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត(អយក, ២០១៥)[111]។

**គ.សេដ្ឋកិច្ចគ្រួសារសមរម្យ រស់នៅប្រកបដោយភាតរភាពក្នុងសង្គម**

សេដ្ឋកិច្ចគឺជាដង្ហើមនៃការរស់នៅប្រកបដោយតម្រូវការមូលដ្ឋានរបស់មនុស្ស។ លំហូរនៃចំណូលចំណាយអាចវិវត្តទៅបានគឺអាស្រ័យលើភាពមានការងារធ្វើរបស់បុគ្គលម្នាក់ៗនៅក្នុងសង្គមហើយកត្តានេះក៏អាចរុញច្រានឱ្យប្រទេសជាតិមានសេចក្តីសុខសប្បាយផងដែរ។ ទស្សនទាននេះ អាចឆ្លុះបញ្ចាំងតាមរយៈប្រតិបត្តិការរៀបចំតាក់តែងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សតាមរយៈការងាររៀនសូត្រ និងបង្រៀនឱ្យទទួលបានលទ្ធផលសិក្សាកាន់តែប្រសើរឡើង។ ជាក់ស្តែង សៀវភៅណែនាំស្តីពី "**មគ្គុទ្ទេសន៍អាជីព និងការផ្តល់ប្រឹក្សាណែនាំសម្រាប់មធ្យមសិក្សាទុតិយភូមិ**" គឺជាឯកសារថ្មីមួយ

---

110 គោលនយោបាយអប់រំបំណិនជីវិត, ឆ្នាំ ២០០៦, ទំព័រ ៨

111 ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១៥, ទំព័រ ៧

សម្រាប់បង្រៀនមេរៀនប្រឹក្សាអាជីព និងផ្តល់ការប្រឹក្សាយោបល់ដល់សិស្សានុសិស្សជាលក្ខណៈក្នុងថ្នាក់ផង និងឯកជនផងដែរជាពិសេសការរៀបចំផែនការអាជីព និងជំនាញក្នុងជីវិតការងារ(អយក, ២០១៨)[112] ។ ស្របគ្នានេះដែរ គោលនយោបាយអប់រំបំណិនជីវិតក៏បានបំពាក់បំប៉ននូវជំនាញទន់លើផ្នែកគំនិតច្នៃប្រឌិតប្រកបដោយប្រសិទ្ធភាព មានសមត្ថភាពក្នុងការគិតពិចារណាដោយម្ចាស់ការ ចេះផ្តល់គំនិតយោបល់ ចេះបត់បែនទន់ភ្លន់តាមកាលៈទេសៈ ចេះធ្វើការងារជាមួយគ្នា ចេះរស់នៅជាមួយគ្នា ចេះយោគយល់គ្នា ចេះធ្វើការសម្រេចចិត្ត ចេះរៀបចំសកម្មភាពផ្សេងៗ ចេះរៀបចំផែនការគ្រួសារ និងចេះកសាងខ្លួនឱ្យក្លាយជាមនុស្សស្រឡាញ់ការងារប្រកបដោយសម្មាអាជីវៈ(អយក, ២០០៦)[113]។

**២.៤.៤.ឆ្លើយតបទៅនឹងតម្រូវការសង្គម និងទីផ្សារការងារ**

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាយុទ្ធសាស្ត្រនូវការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ដើម្បីពង្រឹងគុណភាពវិស័យអប់រំ ដោយជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់សិស្សមធ្យមសិក្សាចំណេះទូទៅ។ អាស៊ានឯកភាពគ្នាបន្តពង្រឹង និងពង្រីកសកម្មភាពអប់រំដើម្បីរួមគ្នាដោះស្រាយ និងបំពេញភាពខ្វះខាតទាំងឡាយដែលនៅសេសសល់ដូចជា៖ ការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ ការតភ្ជាប់អាស៊ានទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងផ្នែកស្ថាប័ន ទាំងផ្នែកសហគ្រាសខ្នាតតូច និងមធ្យមដែលទាមទារឱ្យបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំបច្ចេកទេសឱ្យមានតួនាទីសំខាន់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ ជាពិសេសក្របខណ្ឌអភិវឌ្ឍន៍កម្មវិធីសិក្សានាពេលថ្មីៗនេះ គឺសំដៅដល់ការផ្តល់ការអប់រំមួយឱ្យសិស្សមានសមត្ថភាពជំនាញបច្ចេកទេសច្បាស់លាស់ ក្នុងគោលបំណងកាត់បន្ថយភាពគ្មានការងារធ្វើ និងជម្រុញឱ្យមានការងារធ្វើស្របតាមវ័យ ព្រមទាំងមានលទ្ធភាពកាត់បន្ថយការចំណាយផ្សេងៗក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងភាពក្រីក្រផងដែរ(អយក, ២០១៣)[114]។ លទ្ធផលសិក្សាដ៏មានគុណភាព នឹងជួយជម្រុញឱ្យកម្លាំងពលកម្មជំនាញមានការប្រែប្រួលទៅរកភាពស័ក្តិសិទ្ធិក្នុងការស្តារស្ថានភាពសេដ្ឋកិច្ចកម្ពុជា ពីប្រទេសដែលមានចំណូលមធ្យមទៅជាប្រទេសអភិវឌ្ឍន៍នាពេលអនាគតតាមរយៈប្រែក្លាយពលករជំនាញកម្រិតទាបទៅជាពលករជំនាញកម្រិតមធ្យម និងខ្ពស់តាមលទ្ធភាពជាបណ្តើរៗ ជាក់ស្តែងដូចការគូសបញ្ជាក់ក្នុងពីរ៉ាមីដជំនាញដូចខាងក្រោមនេះ(កបវ, ២០១៧)[115]៖

---

[112] សៀវភៅណែនាំស្តីពីមគ្គុទ្ទេសន៍អាជីព និងការផ្តល់ប្រឹក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិ, នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ, ២០១៨, ទំព័របុព្វកថា

[113] គោលនយោបាយអប់រំបំណិនជីវិត, ឆ្នាំ ២០០៦, ទំព័រ ៨

[114] គោលនយោបាយស្តីពី ការអប់រំបច្ចេកទេស, ឆ្នាំ ២០១៣, ទំព័រ ១

[115] គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧ ២០២៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ២០១៧, ទំព័រ ២




(រូបភាពទី ២២៖ កម្រិតជំនាញរបស់ពលករ កបប,២០១៧)

មូលដ្ឋានគ្រឹះនៃភាពជោគជ័យក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការអប់រំគឺជា យុទ្ធសាស្ត្រដ៏មានសក្តានុពលក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលបានកើតឡើងព្រោះ សង្គមត្រូវបានកកើតឡើងដោយពលរដ្ឋគ្រប់រូប ហើយបុគ្គលទាំងនេះត្រូវមានជំនាញបច្ចេកទេសវិជ្ជាជីវៈច្បាស់លាស់ ដោយធានាឱ្យអ្នកស្គាល់ផ្លូវសិក្សាយកជំនាញបច្ចេកទេស មានគំនិតច្នៃប្រឌិតប្រកបដោយគុណធម៌ និងមានស្មារតីសហគ្រិនភាពដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងមានសមត្ថភាពបន្តការសិក្សាពេញមួយជីវិត(អយក, ២០១៣)[116]។ ក្នុងការពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ជំនាញផ្អែកលើគុណភាពនៃលទ្ធផលសិក្សារបស់សិស្សត្រូវតែមានការឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មសម្រាប់ការងារសមរម្យ និងសមត្ថភាពដោះស្រាយបញ្ហាក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេប្រកបដោយសេចក្ដីថ្លៃថ្នូរ សមត្ថភាព ជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត(កបវ, ២០១៧)[117]។

## ក.បំពេញការងារមានប្រសិទ្ធភាព

នៅកម្ពុជា ការអប់រំចំណេះទូទៅជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលបានការបណ្តុះបណ្តាលផ្សេងៗទៀត ហើយការអប់រំមធ្យមសិក្សាត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណសម្បត្តិបន្តទៅឧត្តមសិក្សា ឬបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជី

[116] គោលនយោបាយស្តីពី ការអប់រំបច្ចេកទេស, ឆ្នាំ ២០១៣, ទំព័រ បុព្វកថា

[117] គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧ ២០២៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ២០១៧, ទំព័រ ចក្ខុវិស័យ

វៈ ឬចូលរួមក្នុងជីវភាពសង្គម[118]។ ការសិក្សាសតវត្សទី២១នេះ ផ្តោតលើសមត្ថភាពជំនាញបច្ចេកទេស ជំនាញទន់ដែលមានដូចជាៈជំនាញនៃការធ្វើសេចក្តីសម្រេចចិត្ត ការដោះស្រាយបញ្ហា ការសហការ និងការប្រាស្រ័យទាក់ទង។ ដើម្បីឆ្លើយតបទៅនឹងការប្រតិបត្តិការងារមានប្រសិទ្ធភាព នៅក្នុងផែនទីបង្ហាញផ្លូវការអប់រំនៅកម្ពុជាឆ្នាំ ២០៣០ បានគូសបញ្ជាក់ថា ការកសាងធនធានមនុស្សត្រូវតែបង្កើតឱ្យមានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិដោយបច្ចុប្បន្ននេះ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនៅខេត្តចំនួន៣ បាននឹងកំពុងផ្តល់វគ្គសិក្សាអប់រំបច្ចេកទេស និងវិជ្ជាជីវៈផ្នែកមុខជំនាញជាច្រើន។ ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិនឹងធ្វើបច្ចុប្បន្នភាព និងជំរុញការអនុវត្តវគ្គតម្រង់ទិសការសិក្សាទៅកាន់អាជីព និងពង្រីកការអប់រំបច្ចេកទេសឱ្យមានវិសាលភាពគ្រប់ដណ្តប់ទូទាំងប្រទេសតាមទស្សនទាន "ខេត្តមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលមធ្យម និងស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលវែង" ព្រមទាំងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន(អយក, ២០១៩)[119]។

**"វិជ្ជាជាអាហារ ប្រាជ្ញាជាអាវុធ ជាំនៅសាលា ផ្លែផ្កាក្នុងសង្គម"**

ប្រព័ន្ធអប់រំចំណេះទូទៅនៅកម្ពុជា បានបញ្ជ្រាបបំណិនសម្បទាដោយបញ្ចូលបំណិនមូលដ្ឋានដែលជាបំណិនចាំបាច់ដែលអ្នកសិក្សាគ្រប់រូប ត្រូវតែទទួលបានដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ការរស់នៅ។ ជាក់ស្តែងដូចជាបំណិនបុរេវិជ្ជាជីវៈសម្រាប់អ្នកសិក្សាចូលរួមក្នុងការងារពលកម្ម ឬសហគមន៍របស់គេបំណិនក្នុងការក្នុងការធ្វើទំនាក់ទំនង បំណិនគណិតវិទ្យា បំណិនក្នុងការដោះស្រាយបញ្ហា និងបំណិនក្នុងការចេះធ្វើការងារជាក្រុម(អយក, ២០០៦)[120]។ យុវជន យុវនារីដែលជាមូលធនមនុស្សដ៏សំខាន់មានចំណេះដឹង បំណិន និង បច្ចេកទេសវិជ្ជាជីវៈនោះ ជីវិតនឹងទទួលបានជោគជ័យក្នុងបទពិសោធន៍ការងារ និងការរស់នៅប្រចាំថ្ងៃ ព្រោះពួកគេចេះកំណត់គោលដៅជីវិតបានត្រឹមត្រូវ។ ការកំណត់គោលដៅរបស់បុគ្គល គឺជាការរៀបចំផែនការសម្រាប់អនុវត្តក្នុងដំណើរជីវិតរបស់គេម្នាក់ៗ ហើយវាអាចនាំឱ្យគេសម្រេចបានផលតាមបំណងប្រាថ្នា តែផ្ទុយទៅវិញ បើគេមិនមានការកំណត់គោលដៅទេ គេរស់នៅក្នុងភាពមិនប្រាកដប្រជាធ្វើឱ្យជីវិតសោត់អណ្តែតតាមយថាកម្ម ហើយការបំពេញការងារក៏មិនមានប្រសិទ្ធភាពដែរ។

## ខ.មានជំនាញបច្ចេកទេសច្បាស់លាស់

ជាការពិតណាស់ ប្រធានបទនេះ បកស្រាយពីកាតព្វកិច្ច និងទំនួលខុសត្រូវរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលភាគីខាងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ជាពិសេសភាគីសាលារៀនជាអ្នកអនុវត្តផ្ទាល់ ក្នុងការបណ្តុះបណ្តាលមូលធនមនុស្សឱ្យមានសមត្ថភាពជំនាញច្បាស់លាស់។ ដូចនេះ ការចូលរួមពីផ្នែកឧស្សាហកម្ម សហគមន៍ និងភាគីពាក់ព័ន្ធផ្សេងៗនឹងពង្រឹងលទ្ធផលនៃការហ្វឹកហ្វឺនជំនាញបច្ចេកទេសការងារ ដើម្បីពង្រឹងគុណភាពអប់រំបណ្តុះបណ្តាល

---

118 ច្បាប់ស្តីពីការអប់រំ, ឆ្នាំ ២០០៧, មាត្រា ១៧, ទំព័រ ៨

119 ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ ២០៣០, គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ៤, ទំព័រ ៥៨

120 គោលនយោបាយអប់រំបំណិនជីវិត, ឆ្នាំ ២០០៦, ទំព័រ ៦

បច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតសាលារៀនឱ្យស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស និងក្រៅប្រទេសដោយការកែលម្អគុណភាពអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ធានានូវសង្គតិភាព សេវាកម្មប្រកបដោយភាពស័ក្តិសិទ្ធិ ទំនុកចិត្ត សម្ភារៈបរិក្ខារ វិធីសាស្ត្របណ្ដុះបណ្ដាលសមស្របកម្មវិធីសិក្សា និងកម្មវិធីបណ្ដុះបណ្ដាលផ្សារភ្ជាប់នឹងការងារប្រព័ន្ធវាយតម្លៃជំនាញផ្អែកលើតម្រូវការអាជីវកម្ម និងឧស្សាហកម្ម ការផ្ដល់វិញ្ញាបនបត្រដល់កម្លាំងពលកម្មថ្មី និងមានស្រាប់តាមរយៈការទទួលស្គាល់សមត្ថភាព ការគាំទ្រការអភិវឌ្ឍសមត្ថភាពបុគ្គលិក ព្រមទាំងការរៀបចំការបណ្ដុះបណ្ដាលក្នុងកិច្ចសហការជាមួយសហគ្រិនឱ្យឆ្លើយតបនឹងតម្រូវការការងារជាក់ស្ដែង។ គុណភាពនៃកម្មវិធីបណ្ដុះបណ្ដាលនឹងត្រូវបានគាំទ្រដោយគ្រឹះស្ថានបណ្ដុះបណ្ដាល និងមានការទទួលស្គាល់ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់(កបវ, ២០១៧)[121]។ ជាក់ស្ដែងមានពំនោលរបស់អ្នកប្រាជ្ញខ្មែរ អ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយបានលើកឡើងថា៖

**"បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យចាំឱ្យស្ទាត់**

**កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ**

**ប្រាក់រត់តាមហៅ។..."**

## គ.ប្រតិបត្តិខ្លួនជាពលរដ្ឋពេញលេញ

លទ្ធផលអប់រំ ដែលអ្នកអប់រំចង់សម្រេចបាន និងលទ្ធផលសិក្សាដែលសិស្សានុសិស្ស និងអ្នកអាណាព្យាបាល មាតាបិតាសិស្សចង់ទទួលបាននោះគឺ ប្រព័ន្ធអប់រំផ្ដោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលសិស្សនឹងទទួលបានបន្ទាប់ពីបានរៀនចប់។ នៅពេលបញ្ចប់ពីសិក្សា យុវជននឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថសម្រាប់ប្រកបកិច្ចការរស់នៅប្រចាំថ្ងៃ និងសម្រាប់បន្តការសិក្សានៅកម្រិតឧត្តមសិក្សា និងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស។ នៅពេលប្រទេសមួយនេះ មានធនធានមនុស្សដែលពោរពេញមូលធនបញ្ញា ជំនាញបច្ចេកទេសច្បាស់លាស់ វឌ្ឍនភាពគ្រប់វិស័យនឹងកើតឡើង ហើយក៏អាចជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់បុគ្គលផង សង្គមគ្រួសារផង ប្រទេសជាតិផង។ ជាសក្ខីកម្ម ក្រោយបញ្ចប់ការសិក្សាសម្រាប់កម្មវិធីសិក្សាសតវត្សទី ២១នេះ លទ្ធផលសិក្សារបស់សិស្សនឹងស្ដែងចេញនូវសមត្ថភាពសំខាន់ៗដូចខាងក្រោម៖

- សមត្ថភាពអក្ខរសាស្ត្រ និងលេខសាស្ត្រ
- សមត្ថភាពភាសាបរទេស
- សមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT)
- បំណិនប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម
- បំណិនពិចារណា និងការបង្កើតថ្មី

---

[121] គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧ ២០២៥ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ២០១៧, ទំព័រ យុទ្ធសាស្ត្រ

- បំណិនអនុវត្តចំណេះដឹង និងជំនាញ
- បំណិនអភិវឌ្ឍន៍បុគ្គល គ្រួសារ និងសង្គម
- បំណិនសមត្ថភាពសហគ្រិនភាព និងភាពជាអ្នកដឹកនាំ

សេចក្តីសន្និដ្ឋាន សង្គមមួយដែលពោរពេញទៅដោយពលរដ្ឋពេញលេញ នោះការប្រាស្រ័យទាក់ទង សុខដុមនីយកម្ម និងអរិយធម៌ក្នុងការរស់នៅនឹងឆ្ពោះទៅរកភាពរុងរឿងដោយពឹងផ្អែកកោសិកាក្នុងសង្គម ជាបុគ្គលដែលប្រតិបត្តិខ្លួនប្រកបដោយសតិសម្បជញ្ញៈ មានការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចចំពោះខ្លួនឯង គ្រួសារ និងសង្គម មានការយល់ដឹងជ្រៅជ្រះ ការស្រឡាញ់ ការដឹងគុណ ការប្តេជ្ញាចិត្ត មានសីលធម៌រស់នៅ មានភារតភាពក្នុងការបំពេញសកម្មភាពនានា មានទំនាក់ទំនងគ្នាប្រកបដោយព្រហ្មវិហារ និងភាពស្មោះត្រង់ក្នុងគោលបំណងលើកកម្ពស់សេចក្តីសុខ និងសុភមង្គលផ្ទាល់ខ្លួន គ្រួសារ និងសង្គមជាតិផងដែរ(អយក, ២០១៥)[122]។ ជារួម ដំណើរការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាត្រូវធ្វើឡើងតាមការអប់រំ និងការបណ្តុះបណ្តាលដែលជាដំណោះស្រាយតែមួយគត់សម្រាប់លើកកម្ពស់ពលរដ្ឋពេញលេញស្របតាមតម្រូវការចាំបាច់ ជំរុញឱ្យមានគំនិតនវានុវត្តន៍ បំពាក់នូវកម្លាំងពលកម្មដែលមានបច្ចេកទេសវិជ្ជាជីវៈ និងជំនាញច្បាស់លាស់ដើម្បីជួយអភិវឌ្ឍសេដ្ឋកិច្ចជាតិ(អយក, ២០១៩)[123]។

## ២.៥. តួនាទី និងភារកិច្ចរបស់តួអង្គសំខាន់ៗក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

ការអប់រំ និងការបណ្តុះបណ្តាលគឺជាយុទ្ធសាស្ត្រសំខាន់ជាងគេដើម្បីសម្រេចគោលបំណងនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ ភស្តុតាងនៃការស្រាវជ្រាវ និងបទពិសោធន៍ជាច្រើនពីប្រទេសផ្សេងៗក្នុងសកលលោកបានបង្ហាញពីអានុភាពនៃការអប់រំ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅ ជួយមនុស្សឱ្យទទួលបានការងារសមរម្យ បង្កើនប្រាក់ចំណូលរបស់ពួកគេ និងបង្កើនផលិតភាពដែលជួយនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ចំណែកឯ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់បង្កលក្ខណៈឱ្យប្រជាពលរដ្ឋអាចប្រកបរបរចិញ្ចឹមជីវិតបានសមរម្យ ជាពិសេស អ្នករស់នៅជនបទដែលគ្មានទីពឹងបានទទួលបានការឧបត្ថម្ភដើម្បីបង្កើតមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ(រដ្ឋធម្មនុញ្ញ, ២០០៨)[124]។ តើតួអង្គសំខាន់ៗនៃសហគមន៍សាលារៀនមានតួនាទីដូចម្តេចខ្លះដើម្បីអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ?

---

[122] ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១៥, ទំព័រ ៧

[123] ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ ២០៣០, គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ៤, ទំព័រ ៥៨

[124] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២០០៨, មាត្រា ៤៦ និង៤៩, ទំព័រ ១៨

ដូចដែលបានរៀបរាប់ខាងលើ មជ្ឈដ្ឋានដែលពាក់ព័ន្ធនឹងការអប់រំ ការបណ្តុះបណ្តាលធនធានមនុស្សមានបីគឺ មជ្ឈដ្ឋានសាលារៀន មជ្ឈដ្ឋានគ្រួសារ និងសហគមន៍។




(រូបភាពទី ២៣៖ សហគមន៍សាលារៀន, ២០២២)

តាមរយៈគេហទំព័រ www.owlgen.com បានបង្ហាញថា៖ សហគមន៍មានតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអប់រំ។ សិស្ស គ្រូបង្រៀន និងអ្នកអាណាព្យាបាល មាតាបិតាសិស្សបានយល់ពីការឧបត្ថម្ភគាំទ្ររបស់សហគមន៍ថាជាភាពជោគជ័យដ៏ប្រត្យក្សរបស់សាលារៀន និងការសិក្សារបស់សិស្សផ្ទាល់។ សិស្សានុសិស្សជាច្រើនត្រូវបានសមាជិកសហគមន៍ជួយលើកទឹកចិត្ត ជំរុញឱ្យខំរៀនសូត្រ បើទោះបីជា ពួកគេមានអារម្មណ៍អាក់អន់ចិត្តនឹងថ្នាក់ដឹកនាំសហគមន៍របស់ពួកគេក៏ដោយ។ លើសពីនេះ សហគមន៍អាចជួយគាំទ្រសិស្សបាន មិនត្រឹមតែឪពុកម្តាយរបស់ពួកគេប៉ុណ្ណោះទេ ព្រោះអ្នកអាណាព្យាបាលរបស់ពួកគេគឺជាសមាជិកនៅក្នុងសហគមន៍ដែរ។ ក្នុងន័យនេះ សហគមន៍ពិតជាត្រូវរួបរួមគ្នាជួយគ្នាទៅវិញទៅមក ព្រមទាំងផលប្រយោជន៍របស់សិស្សដោយការស្វែងយល់ថា សេចក្តីស្រឡាញ់ និងការឧបត្ថម្ភគាំទ្ររបស់អ្នករាល់គ្នានៅជុំវិញនោះ។ ទង្វើដូចនេះ ធ្វើឱ្យពួកគេមានអារម្មណ៍ថា ក្តីលំបាកទាំងអស់មិនមែនជារបស់ពួកគេទៀតទេ គឺត្រូវចែករំលែកជាមួយអ្នកដែលពាក់ព័ន្ធ។ យោងតាមសេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍ បានរៀបរាប់ពីកត្តាសំខាន់ៗដែលនាំមកនូវភាពជោគជ័យក្នុងដំណើរការសាលារៀនគឺថ្នាក់ដឹកនាំគោលនយោបាយ មន្ត្រីអប់រំថ្នាក់ជាតិ និងក្រោមជាតិ នាយកសាលា និងគ្រូបង្រៀនបានបណ្តុះនូវសុជីវធម៌បុគ្គលធ្វើតែអំពើល្អដើម្បីប្រយោជន៍សិស្ស និងសហគមន៍ រួមសាមគ្គីគ្នាដើម្បីបុព្វហេតុតែមួយគឺ ផលប្រយោជន៍សិស្ស និងសហគមន៍។ ការខិតខំអនុវត្តនូវអំពើល្អទាំងនេះ ក្នុងរយៈពេលបីឆ្នាំកន្លងមកបាននាំមកនូវការកសាងគុណតម្លៃដោយចាប់ផ្តើមដំបូងពីបុគ្គលម្នាក់ៗ ហើយបច្ចុប្បន្នបានក្លាយទៅជាគុណតម្លៃរួមដែលទាំងអស់គ្នាទទួលស្គាល់។ សិស្សទទួលបាននូវយុត្តិធម៌ពីការខិតខំសិក្សាប្រឹងប្រែងរៀនសូត្រ នេះជាអ្វីដែលលើកឡើងដោយសិស្សមួយចំនួននាពេលឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី បានជួបពួកគេនៅ

សាលារៀន។ សិស្សពោលថា“បើអ្នកណាប្រឹងប្រែងរៀនសូត្រ អ្នកនោះនឹងបានធ្វើតេស្តស្តង់ដាប្រចាំខែជាប់ តែបើអ្នកណាមិនរៀនអ្នកនោះនឹងធ្លាក់”។ ជាមួយគ្នានោះ សិស្សបានសំណូមពរដល់ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ឱ្យក្រសួងអនុវត្តការងារកំណែទម្រង់នេះនៅគ្រប់សាលារៀនទាំងអស់នៅក្នុងប្រទេស។ ភាពពិតនៃសមធម៌អប់រំគឺការកើនឡើងទាំងបរិមាណ និងគុណភាពរៀនសូត្រ។ មាតាបិតាទាំងក្នុង និងក្រៅសហគមន៍របស់សាលារៀនបាននាំសិស្សមកចុះឈ្មោះចូលរៀននៅសាលារៀនដែលអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន(School-Based Management)។ ជាពិសេស អ្នកអប់រំ អាចបំលែងការងារបង្រៀននៅសាលារៀន និងថ្នាក់រៀនរបស់ពួកគេទៅជាតម្រូវការចាំបាច់របស់សហគមន៍ទាំងមូល (Wells, 1999)។ យ៉ាងណាមិញ ឥរិយាបថដ៏ប្រសើររបស់សិស្សក៏ត្រូវបានតម្រែតម្រង់ដោយមានការចូលរួមពីសហគមន៍ផងដែរ(Epstein, 1983; Grolnick et al, 1999; Harvard, 2007) ហើយសហគមន៍ក៏បានជួយសិស្សឱ្យបង្កើនសមត្ថភាពអានជាស្នាដៃអក្សរសិល្ប៍ថែមទៀតផង(Faires et al, 2000; Jordon et al, 2000)។ លើសពីនេះ ភាពរីកចម្រើនផ្នែកលេខនព្វន្ត ក៏ត្រូវបានរៀបចំជាឯកសារក្នុងការឆ្លុះបញ្ចាំងពីការចូលរួមរបស់សហគមន៍ជាមួយនឹងសិស្សពាក់ព័ន្ធនឹងការបង្កើតពុទ្ធិផ្ទាល់ខ្លួនក្នុងនាមជាអ្នកសិក្សា (Self-concept as learners)(Frome &Eccles, 1998) ហើយនៅក្នុងមុខវិជ្ជា វិទ្យាសាស្ត្រវិញ ឥរិយាបថរបស់អ្នកអាណាព្យាបាលពាក់ព័ន្ធនឹងមុខវិជ្ជា ត្រូវបានអ្នកស្រាវជ្រាវបង្ហាញថាពិតជាបានដើរតួយ៉ាងសំខាន់ដល់សមិទ្ធិផល និងចំណាប់អារម្មណ៍របស់សិស្សចំពោះមុខវិជ្ជានោះ(George and Kaplan, 1998)។ ការចូលរួមរបស់សហគមន៍ធ្វើឱ្យថយចុះនូវអត្រាអវត្តមានពីថ្នាក់រៀន ជួយពង្រឹងឥរិយាបថរៀនសូត្ររបស់សិស្ស ព្រមទាំងការសម្របខ្លួនទៅនឹងបរិស្ថានរៀនសូត្រជុំវិញផងដែរ(Saunders and Sheldon, 2009)។ នៅក្នុងប្រទេសអេស្ប៉ាញ សហគមន៍បានដើរតួនាទីជួយប្រឆាំងនឹងអំពើហិង្សាភេទ (Gender Violence)តាមរយៈការចូលរួមពីក្រុមផ្សេងៗរបស់ស្ត្រី (Soler, 2009)។ ទំនាក់ទំនងរបស់សហគមន៍ក៏បានជួយគាំទ្រកំណែទម្រង់សាលារៀន និងកម្មវិធីសិក្សា ព្រមទាំងដំណើរការប្រកបដោយចីរភាពផងដែរ(Arriaza, 2004)។ ក្នុងសមាសភាពជាសមាជិករបស់សហគមន៍ អ្នកអាណាព្យាបាល ក៏អាចអភិវឌ្ឍជំនាញការអានរបស់ពួកគេបានដែរ ដោយការផ្តល់នូវឱកាសដល់អ្នកមានជីវភាពខ្វះខាតបានឆ្លើយតបនឹងវប្បធម៌សហគមន៍បាន(Paratore et al, 1999) និងបង្កើនការពិភាក្សាដោយសមធម៌ក្នុងការចែករំលែកកម្មវិធីអក្សរសាស្ត្រផ្សេងៗ(Ponzetti &Dulin, 1997) ក្នុងកម្មវិធីអក្សរសាស្ត្រសម្រាប់គ្រួសារនឹងជួយអ្នកអាណាព្យាបាលរៀនសូត្រ ពីមធ្យោបាយគាំទ្រដល់ភាពរីកចម្រើនទៅមុខរបស់កូនៗក្នុងការសិក្សា (Tett, 2001)។ ដូចនេះសាលារៀនគឺជាកន្លែងដែលអាចកាត់បន្ថយភាពខ្វះចន្លោះក្នុងទំនាក់ទំនងទូទៅក្នុងសង្គមរវាងសាលារៀន និងខ្ទង់ផ្ទះរបស់ប្រជាពលរដ្ឋ(Gradstein &Justman, 2002)។ ជាមួយគ្នានេះដែរ តាមរយៈការស្រាវជ្រាវប្រធានបទ ការកំណត់តួនាទីរបស់ជនអន្តោប្រវេសន៍ និងគ្រួសារជនជាតិ

ភាគតិច និង សមាជិកសហគមន៍ក្នុងមជ្ឈមណ្ឌលសិក្សា(Placing Immigrant and Minority Family and Community Members at the School's Centre) តួនាទីរបស់សហគមន៍ដែលបានចូលរួមជាមួយនឹងក្រុមងាយរងគ្រោះបានលើកឡើងថា៖ សហគមន៍មានតួនាទីលើកកម្ពស់សមិទ្ធិផលសិក្សា និងរបៀបរៀនរបស់សិស្សបានប្រសើរឡើង(Javier Diez; Suzanne Gatt & Sandra R., 2011) និងបង្កើនឱកាសការងារ រកចំណូលបានល្អសមរម្យតាមកម្រិតវប្បធម៌នៅក្នុងសង្គមផងដែរ(Bourdieu, 2011)។ ជាក់ស្តែង នៅពេលគ្រួសារមួយមានបញ្ហាប្រឈមនឹងភាពក្រីក្រ ពួកគេមានថវិកាតិចជួយកូនទៅរៀន ពុំមានពេលគ្រប់គ្រងសហការនឹងសាលារៀន វានឹងនាំឱ្យលទ្ធផលសិក្សារបស់កូនពួកគេមិនបានល្អដែរ។ ដោយឡែកតាមទ្រឹស្តីរបស់លោក Vygotsky វិធីស្ថាបនាផ្នត់គំនិតបុគ្គលត្រូវពឹងផ្អែកលើការឆ្លើយតបបម្រែបម្រួលនៃឧបទ្ទវហេតុសង្គមទាំងបុគ្គលផ្ទាល់ និងជារចនាសម្ព័ន្ធផងដែរ(Vygotsky, 1978) ហើយទ្រឹស្តីនេះក៏សង្កត់ធ្ងន់លើសមត្ថភាពបុគ្គលចំពោះការតបតនឹង និន្នាការសង្គមចំពោះវិសមភាពដែលបានកើតឡើងវិញ(Beck, Giddens, Lash, 1994; Habermas, 1984; Giddens, 1984)។ ដូចនេះតាមរយៈការស្រាវជ្រាវជាច្រើន សុទ្ធតែអាចបញ្ជាក់បានថាសហគមន៍ និងគ្រួសារពិតជាបានជួយបង្កើនលទ្ធផលសិក្សារបស់សិស្សដោយមិនគិតពីទំហំគ្រួសារ សេដ្ឋកិច្ច កម្រិតវប្បធម៌ វ័យរបស់សិស្សឡើយ(Hedalgo et at, 2002; Delgado G., 1992; Gonzales, Moll & Amanti, 2005)។

មនុស្សអាចរស់នៅបានអាស្រ័យដោយការបំពេញការងារ និងមុខរបរចិញ្ចឹមជីវិតផ្សេងៗគ្នាតាមសម្មាអាជីវៈទៅតាមជំនាញ បំណិនផ្ទាល់ខ្លួន ភូមិសាស្ត្រ និងស្ថានភាពតំបន់របស់ពួកគេ។ មុខរបរសុចរិតសុទ្ធតែមានប្រយោជន៍ និងមានតម្លៃទាំងអស់ ដើម្បីមានវិជ្ជាជីវៈមួយដ៏សមស្របត្រឹមត្រូវ សិស្សានុសិស្សអាចពិគ្រោះយោបល់ជាមួយមាតាបិតា អ្នកអាណាព្យាបាល គ្រូបង្រៀន និងស្ថានភាពអាជីពជាក់ស្តែងក្នុងសហគមន៍របស់ពួកគេ។ ក្នុងន័យនេះ ភាគីដែលពាក់ព័ន្ធដល់កិច្ចដំណើរការអប់រំ បណ្តុះបណ្តាលពលរដ្ឋ អ្នកដែលទទួលបានផលប្រយោជន៍ពីការសិក្សារៀនសូត្រគឺជា សហគមន៍សាលារៀន (School Community) ហើយមានសមាសភាពដូចជា៖ ១. សាលារៀន៖ គណៈកម្មការទ្រទ្រង់សាលារៀនគណៈគ្រប់គ្រងសាលារៀន ក្រុមបច្ចេកទេស គ្រូបង្រៀន ក្រុមប្រឹក្សា កុមារ(សិស្ស) ២. អាជ្ញាធរដែនដី៖ មេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់ គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ ស្មៀនឃុំ មេភូមិ នារីភូមិ មណ្ឌលសុខភាពឃុំ នគរបាលប៉ុស្តិ៍រដ្ឋបាល ចៅអធិការវត្ត អាចារ្យ ចាស់ព្រឹទ្ធាចារ្យ ព្រមទាំងសប្បុរសជននានា(អយក, ២០១៧)[125]។ ដូចនេះ តួនាទី និងភារកិច្ចរបស់គណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតា/អ្នកអាណាព្យាបាលសិស្ស និងសិស្សមានដូចតទៅនេះ៖

[125] គណៈកម្មការអភិវឌ្ឍសាលារៀន, ២០១៧, ទំព័រ ៦

### ២.៥.១.តួនាទីរបស់នាយកសាលា

នាយកសាលាជាប្រតិភូរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាទទួលបន្ទុកអភិបាលសាលារៀនមួយ ។ ក្នុងនាមតំណាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នាយកសាលាជាប្រមុខអង្គភាពជាតំណាងអំណាចរដ្ឋបាល ដែលមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការចាត់ចែងការងារដឹកនាំ គ្រប់គ្រងសកម្មភាពរបស់សាលារៀនទាំងផ្នែករដ្ឋបាល បច្ចេកទេស និងផ្នែកទំនាក់ទំនង (នី, ២០២២)[126]។ ជំនួយការរបស់នាយកសាលាមាននាយករង គ្រូបង្រៀន និងបុគ្គលិករដ្ឋបាលដទៃទៀត។ នាយកសាលាត្រូវបានជ្រើសតាំងចេញពីនាយករងដែលមានសមត្ថភាពរដ្ឋបាល បច្ចេកទេស មានគុណធម៌ មនសិការវិជ្ជាជីវៈខ្ពស់ ព្រមទាំងមានបទពិសោធន៍ក្នុងការងារគ្រប់គ្រងអង្គភាព។ នាយករងត្រូវបានជ្រើសតាំងក្នុងចំណោមបុគ្គលិកអប់រំដែលមានសមត្ថភាពរដ្ឋបាលបច្ចេកទេស មានគុណធម៌ មនសិការវិជ្ជាជីវៈខ្ពស់ មានបទពិសោធន៍ និងទេពកោសល្យក្នុងការងារបង្រៀនសិស្សានុសិស្ស។ ការតែងតាំងមន្ត្រីអប់រំក្នុងមុខតំណែងចាប់ពីអនុប្រធានមន្ទីរ យុវជន និងកីឡារាជធានី ខេត្តចុះក្រោម ត្រូវធ្វើសំណើតែងតាំងជូនអភិបាលនៃគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងសម្រេចចេញដីកា។ ការតែងតាំងមន្ត្រីគ្រប់គ្រងទទួលបានប្រសិទ្ធភាពដោយមានការជ្រើសរើសមន្ត្រីឱ្យកាន់មុខតំណែងស្របតាមឧបនិស្ស័យ កម្រិតសញ្ញាបត្រ ជំនាញ សមត្ថភាពបំពេញការងារ បទពិសោធន៍ការងារ សមិទ្ធិផលការងារ និងបុគ្គលិកលក្ខណៈជាមន្ត្រីគ្រប់គ្រងប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ នីតិវិធីត្រូវបានអនុវត្តដោយមានការប្រជុំជ្រើសតាំងជៀសវាងនូវការឆ្លៀតឱកាសក្នុងការតែងតាំង ឬប្រកាន់បក្សពួកជាដើម(នៀ, ២០២២)[127]។

*ប្រសាសន៍សាស្ត្រាចារ្យ នី រដ្ឋា, ២០២២*

*"នាយកសាលាជាបេះដូងរបស់សាលារៀន"*

នាយកសាលាត្រូវតែយល់ដឹងកាន់តែខ្លាំងអំពីតួនាទីជាសារវន្តរបស់ខ្លួន ហើយខំព្យាយាមធ្វើខ្លួនឱ្យក្លាយជា **បេះដូងរបស់សាលារៀន** ដោយបំពេញតួនាទីជានាយកសាលាឱ្យបានខ្ជាប់ខ្ជួន។ តួនាទី នាយកសាលាសំដៅដល់អ្នកទទួលខុសត្រូវក្នុងការធ្វើអ្វីៗទាំងអស់ ដែលខ្លួនមានលទ្ធភាពអាចធ្វើបានដើម្បីសម្របសម្រួល និងជំរុញឱ្យបុគ្គលិកការិយាល័យ មន្ត្រីអប់រំក្រោមបង្គាប់ទាំងអស់ បំពេញការងារយ៉ាងរលូន និងជោគជ័យ។ តួនាទីរបស់នាយកសាលាទាំងនេះមានដូចតទៅនេះ៖

#### ២.៥.១.១.ជាអាជ្ញាធរអប់រំ

នាយកសាលាជាប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំ យុវជន និងកីឡាប្រចាំភូមិសាស្ត្រសិក្សារបស់សាលារៀននីមួយៗ ជាអ្នកជានាទំនាក់ទំនងការងាររវាងសាលារៀនជាមួយថ្នាក់លើ ជាអ្នកឃ្លាំមើល និងជា

---

126 បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២

127 បទបង្ហាញឧទ្ទេសចារ្យ ឯកឧត្តម នៀ សុផន មុខវិជ្ជា ការគ្រប់គ្រងធនធានមនុស្ស, ឆ្នាំទី ២ ឆមាសទី ១, ២០២២

អ្នកអនុវត្តបទបញ្ញាសិក្សា និងលិខិតបទដ្ឋាននានា។ នាយកសាលាដឹកនាំគ្រប់សកម្មភាព និងធានាឱ្យបាននូវប្រសិទ្ធភាពតាមគោលដៅអប់រំដែលបានគ្រោងទុក និងទទួលខុសត្រូវទាំងស្រុងចំពោះមុខសាលារៀន និងថ្នាក់លើនូវរាល់អ្វីដែលកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នាយកជាអ្នកសម្របសម្រួល និងបង្រួបបង្រួមគ្រប់កម្លាំងដើម្បីអនុវត្តការងារដោយរលូនជាមួយគ្នា។

**ក.ធ្វើផែនការសកម្មភាពសាលារៀន៖** ផែនការគឺជាត្រីវិស័យសម្រាប់នាយកសាលាប្រតិបត្តិដូចខាងក្រោម៖

- **ផែនការគោលនយោបាយរបស់សាលារៀន៖** នាយកសាលាផ្តោតលើការចូលរៀនរបស់សិស្ស(អត្រាត្រួតថ្នាក់ បោះបង់ អត្រាឡើងថ្នាក់) លទ្ធផលតេស្តតាមមុខវិជ្ជា។
- **ផែនការបង្រៀន និងបំណែងចែកកម្មវិធីសិក្សារបស់គ្រូ៖** នាយកសាលារៀបចំផែនការការងារ(ដើមឆ្នាំ កណ្តាលឆ្នាំ ចុងឆ្នាំ ឆមាស ត្រីមាស) បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជាតាមកម្រិតថ្នាក់ ពិនិត្យកិច្ចតែងការបង្រៀននៃមុខវិជ្ជា និងតាមកម្រិតថ្នាក់ លទ្ធផលសិក្សារបស់សិស្ស ចំនួនម៉ោងសិក្សា។
- **ផែនការជួបជាមួយមាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ៖** នាយកសាលារៀបចំកម្មវិធីប្រជុំពិគ្រោះយោបល់រវាងមាតាបិតាសិស្ស គ្រូបង្រៀន សិស្ស គណៈកម្មការទ្រទ្រង់សាលារៀន។
- **ផែនការសិស្ស និងសេវាជួយសិស្ស៖** នាយកសាលារៀបចំប្រើប្រាស់បណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ បន្ទប់ភាសាបរទេស ថ្នាក់ដែលមានក្រុមសិស្សជួយសិស្ស ក្រុមប្រឹក្សាកុមារយុវជន កម្មវិធីជួយសិស្សរៀនយឺត ស្ថានភាព និងការសិក្សារបស់សិស្សអាហារូបករណ៍ កម្មវិធីទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន ទស្សនកិច្ចសិក្សារបស់សិស្ស ប្រអប់សង្គ្រោះបឋម។
- **ផែនការប្រមូល និងលើកទឹកចិត្តសិស្សពិការបានចូលរៀន៖** ស្រង់ទិន្នន័យកុមារ/យុវជនដែលមានបញ្ហាក្នុងការសិក្សា(បញ្ហាបញ្ញា បញ្ហាមើល បញ្ហាស្តាប់)កុមារ/យុវជនពិការ កំព្រា ទីទ័លក្រ ឬស្ថិតក្នុងគ្រួសារផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ គ្មានទីពឹង សិស្សងាយរងគ្រោះ ជនជាតិភាគតិចជាដើម ដែលស្ថិតក្នុងផែនទីខ្នងផ្ទះរបស់សាលារៀន។
- **ផែនការដឹកនាំ និងគ្រងគ្រង៖**នាយកសាលាត្រូវបង្កើតនូវចក្ខុវិស័យ បេសកកម្ម មានគោលដៅ គោលបំណង ការវិភាគមុខងារ ពណ៌នាមុខតំណែង រចនាសម្ព័ន្ធគ្រប់គ្រង និងផែនការអភិវឌ្ឍន៍របស់អង្គភាពច្បាស់លាស់។ រៀបចំរដ្ឋបាលសាលារៀន(គណៈកម្មការទ្រទ្រង់សាលារៀន ទីចាត់ការ កម្រងស្ថិតិសិស្ស និងថ្នាក់ ដ្យាក្រាមស្ថិតិសិស្ស គ្រូ លទ្ធផលប្រឡង

តារាងព័ត៌មានបុគ្គលិកអប់រំ ផែនទីសិក្សាថ្មី របាយការណ៍ផ្សេងៗ)អធិការកិច្ចផ្ទៃក្នុង ប្រជុំក្រុមបច្ចេកទេស វាយតម្លៃប្រចាំឆ្នាំលើការអនុវត្តការងាររបស់គ្រូបង្រៀន ផែនការទប់ស្កាត់បាតុភាពមិនប្រក្រតី សាលាកុមារមេត្រី ការចុះជួយរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំមានផែនការកសាងសមត្ថភាពគ្រូបង្រៀនដោយរៀបចំកម្មវិធីបំប៉ន ការបញ្ជូនទៅចូលរួមក្នុងវគ្គបំប៉ននានា។

- **ផែនការធនធានមនុស្ស៖** នាយកសាលាប្រើប្រាស់ធនធានឱ្យបានសមស្របតាមនិយាម ដូចជា៖ ស្ថានភាពបុគ្គលិកអប់រំក្នុងសាលា បុគ្គលិកបង្រៀនសុទ្ធសាធ ផលធៀបសិស្ស-គ្រូ សិស្ស-ថ្នាក់ បន្ទប់រៀន-គ្រូ-ថ្នាក់ នាយក នាយករង បណ្ណារក្ស គណនេយ្យករ បេឡា និង លេខាធិការ។
- **ផែនការសម្ភារបង្រៀន និងរៀន៖** នាយកសាលារៀបចំច្នៃប្រឌិតសម្ភារឧបទេស សៀវភៅសិក្សាគោល សៀវភៅគ្រូតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ សៀវភៅតាមស្តង់ដាបណ្ណាល័យ។
- **ផែនការហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន៖** នាយកសាលារៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា៖ កសាង និងជួសជុលថ្នាក់រៀន បន្ទប់រៀន ផ្ទះគ្រូ បន្ទប់រដ្ឋបាល អគារបង្គន់អនាម័យ របង ខ្លោងទ្វារសាលារៀន ផ្លូវ ប្រព័ន្ធលូ បន្ទប់ទឹក ប្រព័ន្ធទឹក អណ្តូង រៀបចំកែលម្អសួនច្បារ សួនកសិកម្ម និងសួនជីវៈចម្រុះ ទីធ្លាសាលារៀន ខឿន ទីលានគោរពទង់ជាតិព្រមទាំងរូបសំណាកផ្សេងៗ...។
- **ផែនការហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ៖** នាយកសាលារៀបចំចាត់ចែង និងប្រើប្រាស់ថវិកាប្រចាំឆ្នាំ(ថវិការដ្ឋ សហគមន៍ សប្បុរសជន...)។ នាយកសាលាគប្បីរៀបចំផែនការសកម្មភាព អនុវត្តផែនការ ត្រួតពិនិត្យផែនការ និងវាយតម្លៃផែនការដើម្បីមានមូលដ្ឋានអនុវត្តបន្ត។

**ខ.វាយតម្លៃ និងលើកទឹកចិត្តបុគ្គលិក៖** នាយកសាលាជាអ្នកក្តាប់រួមនូវការបំពេញការងាររបស់គ្រូបង្រៀន និងបុគ្គលិកមិនបង្រៀន។ ការវាយតម្លៃរបស់នាយកត្រូវផ្តោតលើការអនុវត្តតួនាទីភារកិច្ចរបស់មន្ត្រីអប់រំដែលមានខ្លឹមសារទាក់ទងទៅនឹងការងាររៀន និងបង្រៀន ការងារគ្រប់គ្រងថ្នាក់រៀន ការងារវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការប្រើប្រាស់លទ្ធផលសិក្សារបស់សិស្ស ការងារជួយសិស្សរៀនយឺត និងរៀនលឿនដោយមានការចូលរួមពីប្រធានក្រុមបច្ចេកទេស(អយក,២០១៧)([128])។ បន្ទាប់ពីបានធ្វើការវាយតម្លៃ នាយក និងប្រធានក្រុមរួមគ្នារិះរកវិធីសាស្ត្រស្ថាបនាដើម្បីលើកទឹកចិត្តដល់គ្រូមុខវិជ្ជាពង្រឹងការ

128 ឯកសារប្រតិបត្តិការងារអធិការកិច្ចសាលារៀន, ឆ្នាំ ២០១៧, ទំព័រ ១១

បង្រៀនរបស់ខ្លួនឱ្យមានប្រសិទ្ធភាពតាមវិធីសាស្ត្របង្រៀនបែបស្តាបនា បែបចម្រុះ បែបរិះរក បែបដោះស្រាយបញ្ហា និងតាមបែបគម្រោងការជាដើម។

### ២.៥.១.២.ជាមន្ត្រីរដ្ឋបាល

នាយកសាលា ជាអ្នកណែនាំអនុវត្តរដ្ឋបាលសិក្សាទាំងអស់ ដែលធានាធ្វើឱ្យសម្រេចគោលនយោបាយអប់រំ ចាត់ចែងសកម្មភាព និងបែងចែកភារកិច្ចឱ្យបុគ្គលិកដោយរិះរកគ្រប់មធ្យោបាយ និងវិធានការចាំបាច់ដើម្បីឱ្យសកម្មភាពប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

**ក.ត្រួតពិនិត្យរបាយការណ៍សាលា(លទ្ធផលសិក្សា ថវិកា គម្រោងអភិវឌ្ឍសាលា)**

របាយការណ៍ និងកម្រងសំណុំឯកសារកាលប្បវត្តិ នាយកត្រូវធានានូវនីតិវិធីតាមបែបបទរដ្ឋបាលដូចមានការរៀបរាប់ខាងក្រោម៖

- **ការងារគ្រប់គ្រង និងប្រើប្រាស់ថវិកាតាមកម្មវិធី៖** នាយកសាលាត្រូវរៀបចំគម្រោងថវិកា និងគម្រោងចំណាយ ប្រចាំឆ្នាំតាមផែនការ រួចដកថវិកាមកប្រើប្រាស់តាមគម្រោងប្រកបដោយតម្លាភាពដោយមានគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ថវិកា ការទូទាត់ថវិកាឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។ កិច្ចបញ្ជីការគណនេយ្យត្រូវរៀបចំសៀវភៅតាមដានថវិកា មានប័ណ្ណចំណូល ប័ណ្ណចំណាយ ប័ណ្ណបញ្ចូលឃ្លាំង មានបញ្ចូលបញ្ចេញសម្ភារៈ និងបញ្ចូលសម្ភារៈ ត្រួតពិនិត្យបញ្ជីសារពើភ័ណ្ឌ ការទិញសម្ភារៈត្រូវមានវិក្កយបត្រច្បាស់លាស់ ធ្វើតុល្យភាពចំណូល និងចំណាយដោយមានរបាយការណ៍ និងចងក្រងសំណុំឯកសារឱ្យបានត្រឹមត្រូវ។
- **ការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ៖** នាយកសាលាត្រូវពិនិត្យទំហំផ្ទៃដីសាលារៀន និងធ្វើប្លង់កាន់កាប់ឱ្យបានទាន់ពេលវេលា ពិនិត្យអគារមានគ្រប់គ្រាន់ និងស្អាត រៀបចំបន្ទប់ព័ត៌មានវិទ្យាដោយបំពាក់កុំព្យូទ័រ សេវាអ៊ីនធើណេត មានបន្ទប់ទីចាត់ការសមរម្យ រៀបចំបន្ទប់សាស្ត្រាចារ្យ បន្ទប់ពិសោធន៍ បន្ទប់កាត់ដេរ បន្ទប់រោងជាង បន្ទប់សិល្បៈ បន្ទប់តាំងពិពណ៌ស្នាដៃសិស្ស ឃ្លាំងសម្ភារៈប្រកបដោយសុវត្ថិភាព ផ្ទះបាយ អាហារដ្ឋានស្អាត បន្ទប់អនាម័យ មានការថែទាំ មានប្រព័ន្ធទឹកស្អាត អគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ទីលានកីឡាអត្តពលកម្ម ប្រព័ន្ធលូរទឹក របងព័ទ្ធជុំវិញ ខ្លោងទ្វារ ផ្លូវទៅកាន់អគារនីមួយៗ ដងទង់ជាតិ ទីធ្លាសិស្សឈរសមស្រប សួនច្បារដ៏ទាក់ទាញអារម្មណ៍ សួនកសិកម្ម និងដំណើរការ។

**ខ.បំពេញការងារក្នុងបែបបទរដ្ឋបាល/ ការងារគ្រប់គ្រងលិខិត និងឯកសារនានា៖** នេះជាផ្នែកសំខាន់បំផុត នៃការងារលិខិតបទដ្ឋាននាយកសាលាត្រូវរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវរួមមានដូចជា៖ សៀវភៅកត់ត្រាលិខិតចេញ ចូល(កម្រងលិខិតចេញ ចូល)សៀវភៅទទួល និងបែងចែកសម្ភារៈ សៀវភៅ

បំណែងចែកការកិច្ចបុគ្គលិក សៀវភៅអត្តលេខសិស្ស សៀវភៅប្រវត្តិសាលារៀន សៀវភៅក្រាំងមាស សៀវភៅអនុសាសន៍ សៀវភៅបែងចែកផែនការសិក្សារបស់សិស្ស សៀវភៅបញ្ជូនលិខិត សៀវភៅព្យាបាលរោគ សៀវភៅបែងចែកផែនការបង្រៀន សៀវភៅទំនាក់ទំនងមាតាបិតាសិស្ស សៀវភៅប្រជុំបច្ចេកទេស សៀវភៅប្រជុំប្រចាំខែ ប្រចាំឆមាស សៀវភៅកត់ត្រាការអនុវត្តកម្មវិធីសិក្សា សៀវភៅកត់ត្រាកម្រងស្នាដៃសិស្ស តារាងលិខិតផ្សេងៗ បញ្ជីនានាតាមប្រភេទ។

### ២.៥.១.៣.ជាទីប្រឹក្សាគរុកោសល្យ

#### ក.ចែករំលែកបទពិសោធន៍ការងារ ការប្រើប្រាស់សម្ភារឧបទេស

ក្នុងឋានៈជានាយក នាយិការ គ្រូបង្រៀនដែលមានបទពិសោធន៍ត្រូវយកចិត្តទុកដាក់ផ្តល់ព័ត៌មាន និងមានសិទ្ធិអំណាចណែនាំគរុកោសល្យដល់គ្រូបង្រៀនក្រោមឱវាទអំពីល្បិច តាក់តិចនៃការបង្រៀន ព្រមទាំងគន្លឹះល្អៗនៃការបង្រៀនព្រមទាំងស្វ័យសិក្សាក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាគ្រូបង្រៀនដោយខ្លួនឯង។ ជាទូទៅ ដើម្បីផលិតបានកិច្ចតែងការបង្រៀនមួយ ឬអនុវត្តចប់មួយវដ្តនៃការសិក្សាស្រាវជ្រាវមេរៀនក្រុមគ្រូបង្រៀនត្រូវអនុវត្ត និងជួយផលិតសម្ភារៈបង្រៀនដោយមានការសម្របសម្រួលពីនាយក ប្រធានក្រុមបច្ចេកទេស និងអ្នកពាក់ព័ន្ធជាបួនដំណាក់កាលគឺៈ ការរៀបចំមេរៀន ការអនុវត្តការបង្រៀន និងការសង្កេត ការពិភាក្សាលើការបង្រៀន និងរៀន ការធ្វើសកម្មភាពកែលម្អបន្ត ក្រោមការពិភាក្សា និងសម្រេចចុងក្រោយ(អយក, ២០២១)[(129)]។

#### ខ.ធ្វើថ្នាក់និទស្សន៍

ការសង្កេតថ្នាក់ និងការធ្វើថ្នាក់និទស្សន៍ ត្រូវបានធ្វើឡើងដើម្បីជាយន្តការក្នុងការចែករំលែកបទពិសោធន៍ ជួយរកចំណុចល្អ និងចំណុចខ្វះខាតនៃការបង្រៀន និងរៀន ក្នុងគោលបំណងចុងក្រោយគឺដើម្បីអភិវឌ្ឍលទ្ធផលសិក្សារំពឹងទុកដ៏ល្អដល់សិស្ស។ ការងារនេះ នាយកអាចរៀបចំជាសហគមន៍សិក្សាវិជ្ជាជីវៈដែលមានគ្រូប្រឹក្សាសម្រាប់សហគមន៍សិក្សាគ្រូ សហការជាមួយនាយក នាយករងទទួលបន្ទុកបច្ចេកទេសដែលជាគ្រូប្រឹក្សាប្រចាំសាលារៀនដើម្បីផ្តល់ដំបូន្មាន និងការគាំទ្រដល់គ្រូបង្រៀន ធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាបាននូវប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ ការចុះសង្កេតថ្នាក់ត្រូវមានឧបករណ៍សង្កេត និងមានផែនការច្បាស់លាស់ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង ជាពិសេសត្រូវធ្វើថ្នាក់និទស្សន៍គ្រូចេញថ្មី មានបទពិសោធន៍តិច ឬទទួលបានលទ្ធផលសិក្សាទាប។ ក្រោយពីការអង្កេតថ្នាក់ គ្រូប្រឹក្សា ឬនាយករងដែលទទួលបន្ទុកការងារបច្ចេកទេសត្រូវជួយសម្របសម្រួលធ្វើការឱ្យគ្រូ ដែលត្រូវអភិវឌ្ឍសមត្ថភាពបង្រៀនមកចូលសង្កេតការបង្រៀនណាម្នាក់ដែលមានបច្ចេកទេសខ្ពស់ក្នុងសាលា ឬក្នុងកម្រងសាលាតាមលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ រាល់ព្រឹត្តិប័ត្រសង្កេតថ្នាក់ត្រូវមានការឯកភាពពីគ្រូ

---

[129] សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ, ២០២១, ទំព័រ ៦

បង្រៀនដែលបានសង្កេត និងត្រូវរក្សាទុកដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន(Teacher Portfolio) (អយក, ២០២១)[130]។

**គ.ជំរុញ និងលើកទឹកចិត្តបុគ្គលឱ្យអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈជាប្រចាំ**

បន្ទាប់ពីធ្វើថ្នាក់និទស្សន៍ នាយក និងប្រធានក្រុមបច្ចេកទេសត្រូវផ្តល់ព័ត៌មានត្រឡប់ដើម្បីរិះគន់ស្ថាបនាវិធីសាស្ត្របង្រៀនឱ្យមានប្រសិទ្ធភាព ជំរុញ និងលើកទឹកចិត្តគ្រូឱ្យអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំព្រោះគ្រូបង្រៀនសតវត្សទី២១នេះត្រូវតែមានចំណេះដឹងទូលំទូលាយ ជំនាញអាជីពច្បាស់លាស់ឆ្លងកាត់វគ្គវិក្រឹត្យការគរុកោសល្យជាដើម។ ការផ្តល់ព័ត៌មានត្រឡប់គឺជាការទទួលស្គាល់ភាពវិជ្ជមាន ឬការរិះគន់ស្ថាបនាទៅលើបំណិន ឬកិច្ចការដែលបានបំពេញដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាត ព្រមទាំងផ្តល់នូវអនុសាសន៍បន្ទាប់ពីសង្កេតការបង្រៀន មានកំណត់ត្រាព័ត៌មានជាក់លាក់អំពីឥរិយាបថរបស់គ្រូបង្រៀនដើម្បីជួយអភិវឌ្ឍវិធីសាស្ត្រ និងបច្ចេកទេសបង្រៀន និងរៀនឱ្យមានការកែប្រែប្រកបដោយភាពវិជ្ជមាន។ ការជម្រុញ និងការលើកទឹកចិត្តបុគ្គលម្នាក់ឱ្យអភិវឌ្ឍសមត្ថភាពអាជីព នៅពេលដែលគេបានធ្វើស្វ័យវាយតម្លៃខ្លួនឯងពីភាពអវិជ្ជមាន ដើម្បីធ្វើការកែលម្អ ទទួលយកបទពិសោធន៍ ការណែនាំថ្មីចំណុចល្អការបណ្តុះគំនិតច្នៃប្រឌិត និងទទួលបានការលើកទឹកចិត្តពីបម្រែបម្រួលឥរិយាបថបង្រៀនរបស់គេ។ ដើម្បីឱ្យការផ្តល់ព័ត៌មានត្រឡប់មានប្រសិទ្ធភាពខ្ពស់ នាយកត្រូវអនុវត្តដូចខាងក្រោម៖

- **ទី១** ផ្តល់ឱកាសដល់គ្រូបង្រៀនបញ្ចេញទស្សនៈពីចំណុចខ្លាំង និងចំណុចខ្វះខាតរបស់គាត់ ហើយនាយកត្រូវស្តាប់ដោយយកចិត្តទុកដាក់បំផុត
- **ទី២** ផ្តល់ជូនគ្រូបង្រៀននូវការសង្កេតជាវិជ្ជមាន(ផ្តោតលើចំណុចខ្លាំង)
- **ទី៣** ផ្តល់នូវព័ត៌មានស្ថាបនាលើចំណុចខ្សោយ(ផ្តោតការយកចិត្តទុកដាក់លើចំណុចគន្លឹះមួយចំនួនតូចដែលអាចកែលម្អបាន ផ្តល់នូវវិធីនានា ឬគំនិតជួយទ្រទ្រង់ដែលអាចយកទៅអនុវត្តបាន
- **ទី៤** បញ្ចប់ការប្រជុំដោយផ្តល់ជូនគ្រូបង្រៀននូវភាពវិជ្ជមានចំពោះការសង្កេត(បង្ហាញនូវសង្កេតផ្សេងទៀត និងកំណត់ពេលវេលាជាក់លាក់សម្រាប់កែលម្អទៅអនាគត)

**២.៥.១.៤.ជាអធិការអេចិន្ត្រៃយ៍**

នាយកសាលារៀបចំផែនការធ្វើអធិការកិច្ចច្បាស់លាស់ រួចផ្សព្វផ្សាយដល់គ្រូបង្រៀន និងមានសិទ្ធិត្រួតពិនិត្យកែលម្អសកម្មភាព អប់រំ ជាពិសេសសកម្មភាពបង្រៀន និងរៀន បន្ទាប់ពីធ្វើអធិការកិច្ចរួចនាយកសាលាតែងតែធ្វើការណែនាំដើម្បីជួយកែលម្អ និងវាយតម្លៃឱ្យមានការអភិវឌ្ឍ។

[130] សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ, ២០២១, ទំព័រ ១៦

**ក.ចុះសង្កេតថ្នាក់រៀន៖** ការសង្កេតការបង្រៀន និងរៀនដើម្បីជួយទ្រទ្រង់គឺជាការស្វែងយល់ពីការបង្រៀន និងបញ្ហានានាដែលទាក់ទងទៅនឹងការរៀន និងរកដំណោះស្រាយទៅលើបញ្ហាដែលកើតមានឡើង មិនមែនជាឱកាសសម្រាប់អ្នកត្រួតពិនិត្យមកធ្វើការវិនិច្ឆ័យគ្រូ ឬរកកំហុសទៅលើការបង្រៀនទេគឺដើម្បីជួយកែលម្អនូវការបង្រៀនរបស់គ្រូពិសេសត្រូវផ្តោតទៅលើការសិក្សារបស់សិស្សថាតើសិស្សបានរៀនអ្វីខ្លះ និងត្រូវរកឱ្យឃើញថាតើគ្រូត្រូវជួយនូវអ្វីបន្ថែមទៀតសម្រាប់ការរៀនរបស់ពួកគេ។ ដូចនេះ នាយកត្រូវរៀបចំផែនការធ្វើអធិការកិច្ចឱ្យបានច្បាស់លាស់ និងផ្សព្វផ្សាយដល់គ្រូបង្រៀនបានត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការចុះសង្កេតថ្នាក់របស់គណៈគ្រប់គ្រង ក៏ដូចជាប្រធានក្រុមបច្ចេកទេសផងដែរ។

**ខ.ផ្តល់យោបល់កែលម្អការបង្រៀន និងរៀន៖** ការផ្តល់យោបល់កែលម្អការបង្រៀន និងរៀននឹងត្រូវធ្វើឡើងបន្ទាប់ពីការចុះសង្កេតថ្នាក់ ដូចនេះនាយកចាំបាច់ត្រូវតែរៀបចំផែនការចុះសង្កេតមានការប្រមូលទិន្នន័យ វិភាគព័ត៌មានដែលទទួលបានពីតារាងទម្រង់សង្កេតងាយស្រួលក្នុងការផ្តល់ព័ត៌មានត្រឡប់។ ដើម្បីជានាដល់ការសង្កេតមានប្រសិទ្ធភាព អ្នកសង្កេតការបង្រៀន និងរៀនគប្បីអនុវត្តដូចខាងក្រោម៖

- **ទី១៖** សូមពិនិត្យរកនូវគ្រប់សកម្មភាពរបស់គ្រូបង្រៀនដែលលើកទឹកចិត្តឱ្យសិស្សគិតកម្រិតខ្ពស់ ហើយកត់ត្រាចំណុចនេះ គ្រូប៉ិនប្រសព្វប្រើសំណួរបើក រុករកបន្ត ឱ្យសិស្សគិតជាដៃគូ ហៅសិស្សឆ្លើយដោយចៃដន្យ ឱ្យសិស្សពន្យល់សមាជិករបស់ពួកគេ ឱ្យសិស្សសង្ខេបដើម្បីលើកកម្ពស់ការ ស្តាប់ និងផ្តល់យោបល់វិញ ឱ្យសិស្សម្នាក់ៗសួរសិស្សម្នាក់ទៀត។
- **ទី២៖** កត់ត្រានូវរាល់ការសរសើររបស់គ្រូចំពោះសិស្សដែលគិតបានល្អ
- **ទី៣៖** កត់ត្រានូវចំនួនសំណួរបិទ និងសំណួរបើកដែលគ្រូសួរសិស្ស
- **ទី៤៖** ពិនិត្យមើលចំនួនសិស្សដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀន និងបង្ហាញនូវការប្រមូលអារម្មណ៍ពេញលេញក្នុងការរៀន( សិស្សមានសកម្មភាពស្តាប់ មើល អាន ពិភាក្សា សួរ ឆ្លើយ សង្ខេប សំដែងតួ...ដោយសប្បាយរីករាយ )។
- **ទី៥៖** កត់ត្រានូវអ្វីទាំងអស់ដែលគ្រូធ្វើដើម្បីទ្រទ្រង់ការរៀនជាបុគ្គលរបស់សិស្ស គ្រូមានសកម្មភាពជួយសិស្សពូកែឱ្យកាន់តែពូកែ ជួយសិស្សរៀនយឺតដោយហៅសិស្សដែលរៀនយឺតឱ្យបានញឹកញាប់ លើកទឹកចិត្តសិស្សពូកែ និងជួយសិស្សរៀនយឺត...។
- **ទី៦៖** ពិនិត្យមើល និងកត់ត្រានូវវិធីដែលគ្រូប្រើដើម្បី កែលម្អ វិធីដែលគាត់ជួយសិស្ស ឱ្យសិស្សគិតកាន់តែស៊ីជម្រៅ( ការគិតកម្រិតខ្ពស់ ឧស្សាហ៍ដើរទៅជិតសិស្សឱ្យបានគ្រប់ៗគ្នា )

### ២.៥.១.៥.ជាអ្នកចរចារ

**ក.ផ្ដល់គំនិតយោបល់ដល់បុគ្គលិកដែលមានបញ្ហា**

នៅក្នុងការអនុវត្តជាក់ស្ដែងនៃការដឹកនាំ គ្រប់គ្រងលើធនធានមនុស្សតែងតែមានភាពសាំញ៉ាំច្រើន ព្រោះថាមនុស្សម្នាក់ មានការគិត និងជំនឿផ្សេងពីម្នាក់ទៀត។ ដូចនេះ នាយកសាលាត្រូវតែជាអ្នកមានទេពកោសល្យក្នុងការដោះស្រាយវិវាទបុគ្គលិក និងវិវាទការងារផ្សេងៗដោយសន្តិវិធីដែលកើតមានឡើងនៅក្នុងអង្គភាព។ ជាក់ស្ដែង ដើម្បីក្ដាប់ព័ត៌មានឱ្យជុំ និងផ្ដល់ការរិះគន់ស្ថាបនាប្រកបដោយភាពស័ក្ដិសិទ្ធិ នាយកត្រូវមានបទបញ្ញាសំខាន់ៗ មួយចំនួនក្នុងការផ្ដល់ព័ត៌មានត្រឡប់ទៅបុគ្គលិកក្រោមបង្គាប់ដូចជា៖

- ស្វែងរកចំណុចវិជ្ជមានដើម្បីលើកទឹកចិត្ត
- ធានាឱ្យប្រាកដថា គ្រូបង្រៀនមានអារម្មណ៍ធូរស្រាលក្នុងចិត្ត និងកក់ក្ដៅដោយមានអ្នកយល់ចិត្ត
- លើកទឹកចិត្តបុគ្គលិកអប់រំឱ្យនិយាយអំពីការគិតផ្ទាល់ខ្លួនរបស់គេ
- កំណត់នូវចំណុចដែលត្រូវកែលម្អដោយស្របគ្នា
- ឱ្យគ្រូមើលកំណត់ត្រានាយកសាលា ធ្វើដូចនេះគ្រូនឹងឃើញថាមិនមានអ្វីជាការសម្ងាត់ទេ
- ចំពោះការទិះទៀន ស្នើសុំធ្វើដោយទន់ភ្លន់
- ការប្រជុំផ្ដល់ព័ត៌មានត្រឹមតែ ១៥នាទី (អាចយូរជាងនេះបន្តិច)

**ខ.ជួយចែករំលែក និងដោះស្រាយបញ្ហា**

នាយកត្រូវបានជ្រើសឡើងដើម្បីដឹកនាំ និងគ្រប់គ្រងកិច្ចដំណើរការសាលារៀន។ តួនាទីភារកិច្ចរបស់នាយកត្រូវជួយសម្របសម្រួលការងាររដ្ឋបាល បច្ចេកទេសបង្រៀន និងរៀន ព្រមទាំងវិវាទការងារ និងទំនាស់បុគ្គលក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ ក្រៅពីការងារលិខិតស្នាមផ្សេងៗ នាយកសាលាត្រូវ ៖

- រៀបចំផ្សព្វផ្សាយជូនដំណឹងឱ្យអ្នកអាណាព្យាបាល មាតាបិតា និងសហគមន៍នាំកូនមកចូលរៀន
- ធានានិយ័តភាពក្នុងការសិក្សា
- ធានាឱ្យសាលារៀនបំពេញបាននូវការផ្ដល់សេវាកម្មសាធារណៈមានប្រសិទ្ធភាព ស្វែងយល់ពីភាពខ្វះចន្លោះនៃលទ្ធផលការសិក្សារបស់សិស្ស ក៏ដូចជាការបំពេញតួនាទីរបស់គ្រូផងដែរ
- ជួយចែករំលែក និងលើកទឹកចិត្តបុគ្គលិកដែលអសកម្ម
- ធ្វើជាអាជ្ញាកណ្ដាលផ្សះផ្សារទំនាស់ផ្សេងៗដែលកើតមានឡើងក្នុងសាលារៀន
- ជំរុញឱ្យមានការសិក្សាស្រាវជ្រាវមេរៀន( LS and IBL)

- ជំរុញការស្រាវជ្រាវតាមរយៈការចូលអានសៀវភៅនៅបណ្ណាល័យ និងបណ្ណាល័យបច្ចេកវិទ្យា (Website Online Internet, ICT)
- សហការជាមួយគ្រូបង្រៀនទាំងអស់ដើម្បីពង្រឹងគុណភាពបង្រៀន និងរៀន
- ណែនាំគ្រូឱ្យបង្រៀនគ្រប់មុខវិជ្ជាចៀសវាងការរំលងមុខវិជ្ជាណាមួយដែលខ្លួនមិនពេញចិត្ត ឬមិនមានបំណិនស្រាប់
- ផ្តល់យោបល់ និងជួយគ្រូក្នុងការអនុវត្តវិជ្ជាជីវៈដំបូងរបស់ខ្លួនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ
- រក្សាឱ្យបាននូវបរិយាកាសគរុកោសល្យក្នុងសាលារៀន និងថ្នាក់រៀន

**២.៥.១.៦.ជាអ្នកអប់រំ**

នាយកសាលាជាអ្នកដឹកនាំគ្រប់គ្រងអប់រំ និងបណ្តុះបណ្តាលបុគ្គលិកគ្រូបង្រៀនដើម្បីអភិវឌ្ឍធនធានមនុស្ស។ នាយកត្រូវសហការជាមួយមន្ត្រីថ្នាក់ការិយាល័យ មន្ទីរដើម្បីបំប៉នសមត្ថភាពគ្រូរបស់ខ្លួនទាំងវគ្គបណ្តុះបណ្តាលផ្លូវការ និងមិនផ្លូវការ ការតម្រង់ទិសវិជ្ជាជីវៈបច្ចេកទេសនៅនឹងកន្លែង និងតាមរយៈការប្រជុំ ឬសិក្ខាសាលានានានៅក្នុងអង្គភាព ឬក្រៅអង្គភាព។ ជារួម នាយកសាលា ត្រូវតាំងខ្លួនជាប្រធានអ្នករៀន។

**២.៥.១.៧.ជាអ្នកផ្តល់សេវា និងទំនាក់ទំនងសហគមន៍**

នាយកសាលាជាអ្នកផ្តួចផ្តើមគំនិត និងផ្តល់សកម្មភាពជាសេវាកម្មឱ្យបុគ្គលិកបំពេញការងារអភិវឌ្ឍសមត្ថភាពជំនាញ ការងារពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការងារបរិស្ថាន និងការផ្តល់លទ្ធផលសិក្សាប្រកបដោយគុណភាព។ ការរៀបចំកិច្ចការទៅតាមបែបបែនទាំងនេះ ជាការលើកកម្ពស់ចំណេះដឹងផ្នែកនីតិវិធីការងារ ក្រៅពីការងារស្នូលរបស់ខ្លួន ប្រសើរជាងទុកពេលវេលាទំនេរឥតប្រយោជន៍។

**ក.ផ្តល់ព័ត៌មានត្រឡប់ស្តីពីលទ្ធផលសិក្សា និងអាកប្បកិរិយាដល់អ្នកអាណាព្យាបាលសិស្ស**

តួនាទី និងការទទួលខុសត្រូវរបស់នាយកសាលាជា កត្តាសំខាន់ក្នុងការបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ដំណើរការងារសាលារៀនក្នុងការកាត់បន្ថយអត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់។ ជោគជ័យនៃការសិក្សារបស់សិស្សបានផ្តល់សេចក្តីជឿទុកចិត្តដល់គ្រួសារ សហគមន៍ និងប្រទេសជាតិ។ ដូចនេះ នាយកត្រូវត្រួតពិនិត្យរបាយការណ៍កិច្ចការបន្ទុកថ្នាក់របស់គ្រូបន្ទុកដើម្បីផ្តល់ព័ត៌មានត្រឡប់ទៅឪពុកម្តាយ អ្នកអាណាព្យាបាលសិស្សបានទាន់ពេលវេលា។ គណនេយ្យភាពនៃលទ្ធផលសិក្សារបស់សិស្សអាចនាំឱ្យមានការទុកចិត្តពីសាធារណជន ហើយក៏អាចជួយតម្រែតម្រង់នូវអាកប្បកិរិយាអវិជ្ជមាននានារបស់សិស្សបានផងដែរ។

**ខ.បង្កើតកម្មវិធីសំណេះសំណាលដើម្បីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស កត្តាគំរាមកំហែង**

ការប្រាស្រ័យទាក់ទង គឺជាមធ្យោបាយមួយនាំឱ្យការអប់រំនៅកម្រិតសាលារៀនមានប្រសិទ្ធភាព។ នាយកសាលាត្រូវរៀបចំកម្មវិធីជួបអ្នកអាណាព្យាបាលដើម្បីចែករំលែកពីវឌ្ឍនភាព និង សេចក្តីត្រូវការរបស់សាលា។ កម្មវិធីជួបសំណេះសំណាលនេះដើម្បីស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគំរាមកំហែងដែលសាលាកំពុងជួបប្រទះ។ កិច្ចប្រជុំជាមួយគណៈកម្មការទ្រទ្រង់សាលាគណៈកម្មការគ្រប់គ្រងសាលា គណៈកម្មការអភិវឌ្ឍន៍សាលា និងគណៈកម្មការគ្រប់គ្រងថវិកា ត្រូវអញ្ជើញសមាជិក ឬអ្នកតំណាង ឬប្រធានគណៈកម្មការទាំងនេះមកចូលរួមស្តាប់ និងស្វែងរកដំណោះស្រាយរួមគ្នាពោលគឺ **"រួមគិត រួមគូរ រួមទទួលផល"** ។

**២.៥.១.៨.ជាអ្នកពិគ្រោះយោបល់ និងចូលរួមធ្វើផែនការសហគមន៍**

បំណិននៃការត្រិះរិះពិចារណា គឺជាកត្តាជួយដល់បុគ្គលដោះស្រាយបញ្ហាមានភាពស័ក្តិសិទ្ធិ និងមានប្រសិទ្ធភាព។ នាយកសាលាជាអ្នកជួយផ្តល់គំនិតយោបល់ដល់បុគ្គលិក គ្រូបង្រៀនឱ្យចេះដោះស្រាយបញ្ហាផ្ទាល់ខ្លួនក្តី ការងារក្តីត្រូវធ្វើឡើងដោយប្រើវិចារណញ្ញាណឆ្ពោះទៅរកការឯកភាពគ្នា និងជួយគ្នាទៅវិញទៅមក។

**ក.ផ្តល់ឱកាសដល់បុគ្គលិកបានបញ្ចេញមតិ៖** នៅក្នុងរបៀបវារៈប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ និងជំនួបរួមផ្សេងៗ ត្រូវមានប្រធានបទមតិផ្សេងៗក្នុងអង្គប្រចាំ ដើម្បីឱ្យបុគ្គលិកបានបញ្ចេញយោបល់ និងទស្សនៈផ្ទាល់ខ្លួននៅក្នុងការបំពេញតួនាទីបង្រៀន និងរៀនក្នុងសាលា។ នាយកត្រូវយកចិត្តទុកដាក់ស្តាប់ពីអ្វីដែលគ្រូបង្រៀន បុគ្គលិកបានលើកឡើង ហើយត្រូវស្វែងរកដំណោះស្រាយប្រកបការទទួលខុសត្រូវមិនត្រូវបង្ហាញនូវភាពមិនពេញចិត្ត ឬអាក់អន់ចិត្តដោយប្រការណាមួយឡើយ។ ការបញ្ចេញមតិអាចមានជាលក្ខណៈរួម និងជាបុគ្គល។

**ខ.ពិភាក្សា និងផ្តល់ជម្រើស៖** បន្ទាប់ពីបានត្រង់ត្រាប់ស្តាប់ និងកត់ត្រាពីការបញ្ចេញមតិរបស់គ្រូបង្រៀន និងបុគ្គលិក គណៈគ្រប់គ្រងត្រូវសហការគ្នាជាមួយបុគ្គលិកក្នុងការពិភាក្សារកដំណោះស្រាយ និងរកជម្រើសឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ជម្រើសត្រូវតែសមស្របទៅនឹងស្ថានការណ៍ជាក់ស្តែង និងអាចធ្វើទៅបាន គឺចៀសវាងពីមានតែអនុសាសន៍តែគ្មានការអនុវត្តនោះឡើយ។ កិច្ចពិភាក្សា និងការដោះស្រាយទំនាស់នេះអាចធ្វើជាលក្ខណៈឯកជនផង និងសាធារណៈផងតបតាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ។

**២.៥.១.៩.ជាភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍**

នាយកសាលាមានទំនាក់ទំនងល្អជាមួយគ្រួសារ សហគមន៍ អាជ្ញាធរដែនដី និងស្ថាប័ននានាដើម្បីជាគុណប្រយោជន៍ដល់បុគ្គលិក គ្រូបង្រៀន និងអង្គភាពរបស់ខ្លួន។

**ក.លើកកម្ពស់កិច្ចសហការជាមួយភាគីពាក់ព័ន្ធ៖** នាយកសាលាជាស្ថាបនិកដួងព្រលឹងរបស់មនុស្សដែលរស់នៅក្នុងសហគមន៍របស់សាលារៀន ដូចនេះគាត់ក៏ជាភ្នាក់ងារដ៏សំខាន់នៃការអភិវឌ្ឍសង្គមជាតិ ជាពិសេសចិត្តគំនិត បញ្ញាស្មារតី និងបំណិនជីវិតជាមូលដ្ឋានដទៃទៀតផងដែរ។ នាយកសាលាជាអ្នកផ្តួចផ្តើមបង្កើតឱ្យមានសកម្មភាពចូលរួមរបស់សហគមន៍ ក្នុងបុព្វហេតុការសិក្សារៀនសូត្ររបស់កុមារយុវជននៅក្នុងសហគមន៍ពេលគឺ "**ការអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់ការអប់រំ**"។

**ខ.បំផុសគំនិតក្នុងការផ្សារភ្ជាប់លទ្ធផលសិក្សា និងតម្រូវការសង្គម៖** នាយកសាលាត្រូវចំណាយពេលជួបសំណេះសំណាលជាមួយសិស្ស គ្រូបង្រៀន បុគ្គលិកមិនបង្រៀន អ្នកលក់ដូរនំចំណី និងអញ្ជើញពួកគាត់ចូលរួមប្រជុំដើម្បីស្វែងរកការអភិវឌ្ឍសាលារួមគ្នា។ ពេលខ្លះ អាចទៅជួបពិភាក្សាជាមួយសិស្សអំពីការសិក្សារបស់ពួកគេ បង្កឱកាសឱ្យគ្រូបង្រៀនពិភាក្សាគ្នាជាមួយនាយក រក្សាភាតរភាពការងារជាជាងការស្តីបន្ទោស ដោយចែករំលែកនូវបទពិសោធន៍ គំនិតថ្មីៗ។ ក្រៅពីនេះ នាយកសាលាត្រូវជួបជាមួយគ្រូ ព្រមទាំងអ្នកអាណាព្យាបាល មាតាបិតាសិស្ស និយាយជាមួយពួកគាត់ពេលជូនកូន និងមកទទួលកូនចេញពីសាលា។

សរុបសេចក្តីមក ក្នុងនាមជាគណៈគ្រប់គ្រងសាលា ត្រូវប្រតិបត្តិការងារខាងក្នុងសាលាផង និងខាងក្រៅសាលាផង ការងារទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅរួមមាន៖

- មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស
- សហគមន៍ សប្បុរសជនថ្នាក់ជាតិ និងអន្តរជាតិ
- អាជ្ញាធរដែនដី ភូមិ ឃុំ សង្កាត់ ក្រុងស្រុក ខណ្ឌ រាជធានី ខេត្ត និងភ្នាក់ងារស្ថាប័ននានាក្នុងស្រុក ភូមិ គ្រូពេទ្យ សមាគមវប្បធម៌ សមាគមកីឡា....ជាដើម
- ព្រះគ្រូចៅអធិការព្រះសង្ឃ គណៈកម្មការលោកអាចារ្យវត្ត។

## ២.៥.២.តួនាទីរបស់គ្រូបង្រៀន (មុខវិជ្ជា បន្ទុកថ្នាក់)ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

គ្រូបង្រៀនសំដៅដល់បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំ នៅគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជនដែលមានអាជ្ញាប័ណ្ណអប់រំ(អនក្រ/បក១២៦, ២០០៨)([131])។ គ្រូបង្រៀនត្រូវមានចំណេះដឹងវិជ្ជាជីវៈសម្បូរបែបដោយត្រូវយល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ហើយមានការពេញចិត្តក្នុងការអនុវត្តការងារនៅសាលារៀនទៅលើចំណេះដឹងធ្វើផែនការបង្រៀន ចំណេះដឹងធ្វើកិច្ចតែងការបង្រៀន និងចំណេះដឹងខាងចិត្តគរុកោសល្យជាដើម(អយក, ២០១០)([132])។

[131] អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, លេខ១២៦អនក្រ.បក, ២០០៨, មាត្រា ៤, ទំព័រ ៤

[132] ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ១០

**២.៥.២.១.ការស្វែងយល់ពីសហគមន៍ និងការផ្តល់ចំណេះដឹងប្រកបដោយវិជ្ជាជីវៈ**

គ្រូបង្រៀនត្រូវស្តាប់ ពិនិត្យ ឱ្យដំបូន្មាន ឬធ្វើជាអ្នកអាណាព្យាបាលអ្នកសិក្សាទូទៅដោយមិនលម្អៀង និងមិនប្រកាន់អំពីប្រភព អាយុ ភេទ ភាសា ពូជសាសន៍ ដើមកំណើតជាតិ ពណ៌សម្បុរ ពិការភាព យេនឌ័រ ជំនឿ សាសនា និន្នាការនយោបាយ ឬឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតនៅក្នុងការអប់រំ និងសេវាអប់រំ(អនក្រ/បក១២៦, ២០០៨)([133])គ្រូបង្រៀនជាសិក្ខាបនធារី ជាកម្លាំងអប់រំចម្បងជួយសិស្សានុសិស្សដោយផ្ទាល់ឱ្យសម្រេចភារកិច្ចរៀនសូត្ររបស់ខ្លួនដែលជាភារកិច្ចស្នូលរបស់សាលារៀន(នី, ២០២២)([134])។

**ក.បង្រៀនចំមុខវិជ្ជាឯកទេស៖** គ្រូបង្រៀនត្រូវយកចិត្តទុកដាក់ក្នុងការពន្យល់ ការបកស្រាយ និងសម្របសម្រួលដល់អ្នកសិក្សានូវចំណេះដឹងនានាស្របតាមមុខវិជ្ជា ឬឯកទេសរបស់ខ្លួនដោយជួយអ្នកសិក្សា មាតាបិតា ឬអ្នកអាណាព្យាបាលអ្នកសិក្សាដោយមិនរើសអើង(អនក្រ/បក១២៦, ២០០៨)([135]) ។ ថ្នាក់នីមួយៗមានកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំខែតាមមុខវិជ្ជានីមួយៗ និងមានម៉ោងសម្គាល់ មានវិធីសាស្ត្របង្រៀន មានវត្ថុបំណងនៃមេរៀន មានលំហាត់/សំណួរអនុវត្តដែលក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់ ព្រមទាំងមានសិស្សានុសិស្សពី ៣០នាក់ទៅ៤០នាក់ដែលមានចិត្តសាស្ត្រមិនដូចគ្នា និងមានស្ថានភាពគ្រួសារមិនដូចគ្នាទេ(នី, ២០២២)([136])។ ដូចនេះ គ្រូបង្រៀនត្រូវតែចេះច្នៃការងារបង្រៀនឱ្យមានភាពទាក់ទង និងវត្ថុបំណងច្បាស់លាស់។

**ខ.ស្គាល់ពីសិស្ស(សិស្ស គ្រួសារ ចំណេះដឹង)៖** គ្រូបង្រៀនត្រូវតែដឹងច្បាស់ពីតម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សាច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗ ហើយត្រូវស្វែងយល់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស(យេនឌ័រ ពិការភាព និងក្រុមងាយរងគ្រោះ ជនជាតិភាគតិច...)ព្រមទាំងសិក្សារកវិធីដោះស្រាយបញ្ហាប្រឈមទាំងនោះ(អយក, ២០១០)([137]) ។ ក្នុងថ្នាក់រៀន ជាការពិត នឹងមានសិស្សមានកម្រិតយល់ដឹងមិនស្មើគ្នា ចម្រុះវប្បធម៌ របៀបរស់នៅ និងចិត្តសង្គមផ្សេងៗគ្នា ហេតុនេះ គ្រូត្រូវតែស្គាល់ប្រភេទសិស្សឱ្យបានច្បាស់ ដឹងពីរបៀបរៀនរបស់សិស្ស ទើបការផ្ទេរចំណេះដឹងរបស់គ្រូមានប្រសិទ្ធភាព និងគុណភាព។

**គ.អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន៖** គ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សា។ដូច្នេះ គ្រូត្រូវតែស្វ័យសិក្សា វាយតម្លៃការបង្រៀនដើម្បីអភិវឌ្ឍខ្លួនឯង និង ប្រើ

---

[133] អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, លេខ១២៦អនក្រ.បក, ២០០៨, មាត្រា ៧, ទំព័រ ៦

[134] បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២

[135] អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, លេខ១២៦អនក្រ.បក, ២០០៨, មាត្រា ៧, ទំព័រ ៦

[136] បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២

[137] ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ១១

ប្រាស់ផែនការអាជីពសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំស្របតាមជីវភាពរស់នៅជាក់ស្តែង។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា សារគមនាគមន៍និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀតក្នុងសហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងការស្រាវជ្រាវប្រភពឯកសារផ្សេងៗដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន ហើយត្រូវមានចំណងមិត្តភាពល្អជាមួយបុគ្គលិករួមអាជីព(អយក, ២០១០)[138]។

### *២.៥.២.២.ការទំនាក់ទំនងជាមួយសហគមន៍ និងការប្រតិបត្តិវិជ្ជាជីវៈ*

ការបំពេញសកម្មភាពការងាររបស់គ្រូបង្រៀន ត្រូវប្រតិបត្តិតាមជំនាញឯកទេសរបស់ខ្លួន បូកផ្សំនឹងចំណេះដឹងទូទៅតាមបរិបទនៃការរីកចម្រើនរបស់ប្រទេសជាតិ និងសង្គមដូចជា៖ ចំណេះដឹងផ្នែកបច្ចេកវិទ្យា ICT និងភាសាបរទេសក្នុងការបង្រៀន និងស្រាវជ្រាវ យល់ពីតម្រូវការសង្គម ព្រមទាំងគោលដៅអប់រំជាតិ គោលបំណងអប់រំនៅសាលាចំណេះទូទៅផងដែរ( នី, ២០២២)[139]។

**ក.រៀបចំកិច្ចតែងការឱ្យមានប្រសិទ្ធភាព៖** គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាពស្របតាមកម្មវិធីសិក្សាដោយផ្អែកលើសៀវភៅសិស្ស សៀវភៅគ្រូនិងសម្ភារៈសិក្សាផ្សេងៗទៀតដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារៈបង្រៀន និងរៀនដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗគ្នាដែលស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់គេ(អយក, ២០១០)[140]។

**ខ.គ្រប់គ្រងថ្នាក់រៀន បរិស្ថានសិក្សា និងរៀបចំសម្ភារៈឧបទេស៖** គ្រូបង្រៀនត្រូវផ្តល់ឱ្យសិស្សគ្រប់រូបនូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀនដើម្បីគាំទ្រការសិក្សា និងសុខុមាលភាពរបស់សិស្ស និងគ្រូបង្រៀនដទៃទៀត។ គ្រូបង្រៀនត្រូវចេះប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែបដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចបានវត្ថុបំណងមេរៀន។ ម្យ៉ាងទៀត គ្រូត្រូវមានសមត្ថភាពក្នុង ការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែបដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់ដោយច្នៃប្រឌិត ព្រមទាំងត្រូវចេះប្រើបច្ចេកវិទ្យាព័ត៌

[138] ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ១៦
[139] បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២
[140] ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ១១

មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យ បើមានលទ្ធភាពដើម្បីជួយគាំទ្រការបង្រៀន និងរៀនមានប្រសិទ្ធផល និងគុណភាព(អយក, ២០១០)[141]។

**គ.តាមដាន និងចូលរួមពង្រីកចំណេះដឹងសិស្ស៖** គ្រូបង្រៀនត្រូវដឹកនាំសកម្មភាពសិក្សាក្នុងថ្នាក់ និងក្រៅថ្នាក់ និងលើកទឹកចិត្តដល់អ្នកសិក្សាជាប់ជាប្រចាំដោយមិនត្រូវដាក់សម្ពាធយកជាប្រយោជន៍ទៅលើអ្នកសិក្សាឡើយ គឺត្រូវជួយបង្រៀនបន្ថែមដល់អ្នកសិក្សារៀនយឺត(អនក្រ/បក១២៦, ២០០៨)[142]។ ការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស គ្រូគឺជាតួអង្គដ៏មានសក្តានុពលចំពោះការតាមដានការចូលរួមការងារក្នុងថ្នាក់ផ្ទាល់តាមរយៈការអង្កេត និងធ្វើតេស្ត ការប្រឡងប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ដោយមានកំណត់ត្រាជាព្រឹត្តិប័ត្រពិន្ទុជាប្រចាំស្តីពីសមិទ្ធផល និងការរីកចម្រើនបានពីសកម្មភាពសិក្សារបស់សិស្ស។

**ឃ.សហការជាមួយអ្នកអាណាព្យាបាលសិស្សបានល្អ៖** គ្រូបង្រៀនត្រូវជួយសម្រួលដល់អ្នកសិក្សាក្នុងការទទួលបាននូវផលប្រយោជន៍សង្គមដោយមិនលម្អៀង និងមានទំនាក់ទំនងជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សដើម្បីតាមដានរាល់សកម្មភាពសិក្សា(អនក្រ/បក១២៦, ២០០៨)[143]។គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអ្នកអាណាព្យាបាល អំពីការអភិវឌ្ឍចំណេះដឹងបំណិន និងឥរិយាបថរបស់សិស្ស(អយក, ២០១០)[144]។ ទំនាក់ទំនងជាមធ្យោបាយក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ព្រោះថាការផ្តល់ព័ត៌មានត្រឡប់ជាព្រឹត្តិប័ត្រពិន្ទុ មូលវិចារពីវឌ្ឍនភាពរបស់សិស្សឱ្យសិស្សបានដឹង ជូនព័ត៌មានដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សអំពីការអភិវឌ្ឍចំណេះដឹងបំណិន និងឥរិយាបថរបស់សិស្សជាទំនួលខុសត្រូវការងារដែលគ្រូម្នាក់ៗត្រូវតែធ្វើជាក់ស្តែងគ្រូត្រូវ៖ ផ្តល់ព័ត៌មានដោយការនិយាយផ្ទាល់ ដាក់មូលវិចារណ៍សមស្របជាលាយលក្ខណ៍អក្សរ នៅលើសន្លឹកកិច្ចការរបស់សិស្សជាពិសេសលើសៀវភៅទំនាក់ទំនង ព្រមទាំងមានជារបាយការណ៍ប្រចាំខែ និងអាចទៅជួបផ្ទាល់បើចាំបាច់(អយក, ២០១០)[145]។

**ង.ចូលរួមសកម្មភាពអភិវឌ្ឍន៍សាលារៀន៖** ការគ្រប់គ្រងបរិស្ថានសិក្សាក៏ជាផ្នែកមួយសំខាន់ ដែលគ្រូបង្រៀនត្រូវចូលរួមសកម្មភាពក្នុងការអភិវឌ្ឍសាលារៀនដូចជា៖ ចូលរួមដឹកនាំសិស្សធ្វើពលកម្ម សម្អាតទីធ្លាសាលារៀន បំផុសគំនិតច្នៃប្រឌិត ផ្តួចផ្តើមការដាំផ្កា ដើមឈើធ្វើជាសួនជីវៈចម្រុះ សួនច្បារ និងសួនកសិកម្ម ការជួសជុសគ្រឿងសង្ហារឹម ព្រមទាំងការថែទាំផងដែរ។

---

141 ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ១១

142 អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, លេខ១២៦អនក្រ.បក, ២០០៨, មាត្រា ១៧, ទំព័រ ១០

143 អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, លេខ១២៦អនក្រ.បក, ២០០៨, មាត្រា ១៨, ទំព័រ ១០

144 ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ១០

145 ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ១៣

### ២.៥.២.៣.ការបណ្តុះសីលធម៌ដល់សហគមន៍ដោយប្រកាន់ភ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈ

សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែលជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្ស ការប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។ ក្រមសីលធម៌វិជ្ជាជីវៈនេះ គ្រូបង្រៀនត្រូវប្រកាន់នូវសីលធម៌បុគ្គល ស្មារតីយុត្តិធម៌ ការស្រឡាញ់ និងការថ្នាក់ថ្នមសិក្សា ភាពម៉ឺងម៉ាត់ គួបផ្សំនឹងចិត្តទូលាយ ទឹកមុខស្រស់រាយរាក់ទាក់ មានភក្តីភាព ជាពិសេសគឺត្រូវមានមនសិការវិជ្ជាជីវៈខ្ពស់(នី, ២០២២)(146)។

**ក.ប្រកាន់ភ្ជាប់គោលការណ៍គណនេយ្យភាព តម្លាភាព និងយុត្តិធម៌៖** គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន។ គ្រូត្រូវធ្វើខ្លួនជាបុគ្គលម្នាក់ដែលមានទំនួលខុសត្រូវខ្ពស់ មានព្រហ្មវិហារចំពោះអ្នកជុំវិញខ្លួនរួមទាំងសិស្ស មានស្មារតីស្រឡាញ់យុត្តិធម៌ព្រោះយុត្តិធម៌គឺជាប្រភពនៃសេចក្តីសុខក្នុងសង្គម។ អំពើអយុត្តិធម៌ក្នុងសាលានឹងបង្កឱ្យសិស្ស និងមិត្តរួមអាជីពមានការឈឺចាប់ ការបែកបាក់ គំនុំគុំគួនតាមការស្តែងចេញនៃអាជីពរបស់គ្រូដូចជា៖ ការដាក់ពិន្ទុ ការដាក់ពិន័យ ការសរសើរជាដើម។ អំពើទាំងនេះនឹងធ្វើឱ្យសិស្សធាប់ចាប់អារម្មណ៍ ផ្ទុះការតវ៉ា និងឥរិយាបថស្អប់គ្រូបង្រៀនទៀតផង។ ជារួម គ្រូបង្រៀនត្រូវតែបំពេញការងារប្រកបដោយសុទិដ្ឋិនិយមលើអាជីព និងសមត្ថភាពរបស់ខ្លួន(នី, ២០២២)( 147 )។ គ្រូបង្រៀនត្រូវវាយតម្លៃលទ្ធផលសិក្សាសិស្សប្រកបដោយយុត្តិធម៌ និងតម្លាភាពដោយបង្ហាញពីភាពស្មោះត្រង់ក្នុងមុខវិជ្ជាជីវៈខ្លួន គ្រូក៏ប្រកាន់ភ្ជាប់នូវគោលការណ៍អព្យាក្រិត្យ មិនលំអៀង ផ្តល់ឱកាសដល់សិស្សគ្រប់រូបតាមលទ្ធភាព ពេលវេលា និងធនធានស្មើគ្នា(អយក, ២០១០)(148)។

**ខ.ធ្វើជាគំរូដល់សិស្ស និងសហគមន៍របស់ខ្លួន៖** ផ្តើមចេញពីគ្រូបង្រៀនដែលមានមនសិការវិជ្ជាជីវៈខ្ពស់ ការអប់រំនឹងទទួលបានជោគជ័យគ្រប់ជំហានព្រោះវាជាគន្លឹះដែលធ្វើឱ្យមនុស្សគ្រប់រូបទទួលបានការលើកទឹកចិត្ត និងប្រសិទ្ធផលក្នុងការងារ។ គ្រូបង្រៀនត្រូវតែមានសតិសម្បជញ្ញៈលើទង្វើ និងអាកប្បកិរិយារបស់ខ្លួន ព្រោះគ្រូជាគំរូចំពោះមុខសិស្ស ចំពោះអ្នកអាណាព្យាបាលសិស្ស ចំពោះសង្គមជាតិ និងសហគមន៍ទាំងមូល(នី, ២០២២)(149)។ ដូចនេះ គ្រូត្រូវបង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងល្អជាមួយសិស្ស សហការី និងសហគមន៍ជានិច្ច។

---

[146] បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២

[147] បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២

[148] ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ២០១០, ទំព័រ ២១

[149] បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២

### ២.៥.៣. តួនាទីរបស់អ្នកអាណាព្យាបាល/មាតាបិតាក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

ច្បាប់ស្តីពីការអប់រំ នៅមាត្រា ៣៦ចែងពី សិទ្ធិ និងករណីយកិច្ចរបស់មាតាបិតា ឬអ្នកអាណាព្យាបាល ចំពោះការអប់រំរបស់អនីតិជនដែលស្ថិតក្នុងបន្ទុកមានដូចតទៅ( នស/រកម/១២០៧/០៣២, ២០០៧)[150]៖

- សិទ្ធិក្នុងការជ្រើសរើសកម្មវិធីអប់រំ និងគ្រឹះស្ថានសិក្សាសម្រាប់អ្នកសិក្សាឱ្យចូលសិក្សា
- សិទ្ធិទទួលបានព័ត៌មាន និងរបាយការណ៍នៃការសិក្សាពីគ្រឹះស្ថានសិក្សារបស់អ្នកសិក្សាដែលស្ថិតក្នុងបង្អុក
- សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់សាលារៀន និងថ្នាក់ជាតិដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន។

ករណីយកិច្ចមាតាបិតា ឬអ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជនដែលស្ថិតក្នុងបន្ទុក

- នាំកុមារដែលមានអាយុចាប់ពីប្រាំមួយឆ្នាំ ឬយ៉ាងទាបបំផុត ចិតសិបខែឡើង ទៅចុះឈ្មោះចូលសិក្សានៅថ្នាក់ទី ១នៃកម្មវិធីអប់រំចំណេះទូទៅនៅសាលារៀនដែលមានអាជ្ញា ប័ណ្ណអប់រំ
- ខិតខំឱ្យអស់ពីលទ្ធភាពដើម្បីគាំទ្រការសិក្សារបស់អ្នកសិក្សា ជាពិសេសចំពោះការអប់រំកម្រិតមូលដ្ឋាន
- យកចិត្តទុកដាក់ផ្សារភ្ជាប់សាលា គ្រួសារ និងសហគមន៍ដើម្បីចូលរួមជួយបណ្តុះបណ្តាល និងកែលម្អបរិស្ថានសិក្សា។

#### ២.៥.៣.១.ការបរិច្ចាគថវិកាសម្រាប់ការសិក្សារបស់សិស្ស

**ក.គ្រោងចំណាយលើសម្ភារៈសិក្សា និងមធ្យោបាយធ្វើដំណើរ៖** កាតព្វកិច្ចនៃការចិញ្ចឹមបីបាច់ថែរក្សាកូន និងរៀបចំទំនប់បម្រុង ក្នុងនាមជាឪពុកម្តាយ/អ្នកអាណាព្យាបាលត្រូវតែគិតគូរឱ្យបានវែងឆ្ងាយទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ការចំណាយដែលត្រូវរិះគិតមានការហូបចុក សម្លៀកបំពាក់ សម្ភារៈសិក្សា និងការធ្វើដំណើរ។ ការរៀបចំផែនការចំណាយបានត្រឹមត្រូវ អាចជួយសម្រួលដល់ការរៀនសូត្ររបស់សិស្សឱ្យដំណើរការទៅបានរលូន ដោយពួកគេមិនចាំបាច់មានការព្រួយបារម្ភពីតម្រូវការចាំបាច់នានាសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃដូចជា៖ ប៊ិច សៀវភៅ ឯកសណ្ឋាន សំពាធ ការទៅរៀនបានទៀងទាត់ និងទាន់ពេលវេលា។

**ខ.ថ្លៃវគ្គបំប៉នមុខវិជ្ជាបន្ថែម៖** ការសិក្សាអាចទទួលបានលទ្ធផលល្អ លុះត្រាតែមានការសហការពីអ្នកអាណាព្យាបាល/មាតាបិតាជួយឧបត្ថម្ភគាំទ្រជាធនធានសម្ភារៈ ថវិកា កម្លាំងតាមលទ្ធភាពដែលអាចធ្វើបាន។ សមត្ថភាពសិស្ស ក្នុងការត្រង់ត្រាប់ស្តាប់គ្រូពន្យល់អាចមានចន្លោះខ្វះខាត។ ដូចនេះ គ្រូ និងអ្នក

---

150 ព្រះរាជក្រម ច្បាប់ស្តីពីការអប់រំ, ឆ្នាំ ២០០៧, មាត្រា ៣៦, ទំព័រ ១៥

អាណាព្យាបាលត្រូវតែស្វែងយល់ពីសមត្ថភាពយល់ដឹងរបស់សិស្ស ហើយរួមគ្នាជួយពង្រឹងពុទ្ធិ និងឱ្យសិស្សហ្វឹកហាត់ អនុវត្តបន្ថែម។ ការសិក្សានៅបរិបទសង្គមឌីជីថល ឪពុកម្ដាយ/អ្នកអាណាព្យាបាលសិស្សអាចជ្រើសរើសគ្រឹះស្ថានឯកជនណាដែលខ្លួនពេញចិត្តដើម្បីបំពេញបំណងរបស់ខ្លួន កាលបើចង់ឱ្យកូនរៀនភាសាបរទេស បច្ចេកវិទ្យាព័ត៌មានវិទ្យា ឬជំនាញគិតលេខបានដោយត្រូវគិតគូរធ្វើផែនការចំណាយឱ្យបានត្រឹមត្រូវ ព្រោះថាការសិក្សានាពេលបច្ចុប្បន្ន ពិតជាមានភាពសម្បូរបែប ហើយមានគុណភាពនិងអាជ្ញាប័ណ្ណអប់រំត្រឹមត្រូវ។

**គ.វិភាគទានផ្សេងៗ៖** ការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស ត្រូវពឹងផ្អែកលើការចូលរួមពីឪពុកម្ដាយតាមរយៈការចូលរួមកម្មវិធីសាលារៀនដូចជា៖ ពិធីបុណ្យផ្កា ការជួបសំណេះសំណាលជាមួយសហគមន៍ ការចែកប័ណ្ណសរសើរ ចែករង្វាន់ដល់សិស្សពូកែ ឬឆ្នើម ទិវារំលឹកគុណគ្រូ កម្មវិធីបរិស្ថានសាលា និងសហគមន៍ជាដើម។ ការគាំទ្រថវិកាអាចជាការបង្កើតរៀបចំជាមូលនិធិសមធម៌សង្គមជាមួយសាលាដោយស្ម័គ្រចិត្តក្នុងនាមជាសប្បុរសជនក្នុងការបរិច្ចាគប្រាក់អំណោយ ក្នុងការកសាងបំណិនជីវិតសិស្សដើម្បីអនុវត្តផែនការសកម្មភាពផ្សេងៗនៅក្នុងសាលា(អយក, ២០១៦)[151]។

**ឃ.ការពិនិត្យតាមដានការសិក្សារបស់កូន៖** មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាគ្រូដើមដែលបានបង្រៀនកូនៗ ចាប់តាំងពីកំណើតមកដល់វ័យសិក្សាទើបច្បាប់តម្រូវឱ្យយកកូនមកចុះឈ្មោះចូលរៀន។ ពាក្យចាស់ថា "**នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយតែមួយ** " អាចវិនិច្ឆ័យបានថា បើសិស្សមកដល់សាលាហើយ ពួកគេត្រូវរៀនរួមគ្នា គ្រូជាមួយគ្នា ការសិក្សារៀនសូត្ររបស់ពួកគេទទួលបាននៅសាលារៀនមានកម្រិតដូចគ្នាទៅតាមថ្នាក់ និងឆ្នាំសិក្សានីមួយៗ។ ដោយឡែកនៅពេល ពួកគេត្រឡប់ទៅផ្ទះវិញ មានតែឪពុកម្ដាយទេតែអាចតាមដានការសិក្សាបន្ថែមនៅផ្ទះរៀងៗខ្លួន ដោយមានមាតាបិតាជាគ្រូដើមនេះឯង។ កម្មវិធីស្វ័យសិក្សារៀនសូត្របន្ថែម នឹងត្រូវជួយពិនិត្យ និងក្រើនរំលឹកដោយឪពុកម្ដាយព្រោះកូនៗជាទីពំណាក់អាស្រ័យនាពេលអនាគតរបស់ពួកគាត់។ ជារួម នៅផ្ទះ មាតាបិតា អ្នកអាណាព្យាបាលអាចត្រួតពិនិត្យសៀវភៅសិក្សារបស់កូន សាកសួរកូនថារៀនបានអ្វីខ្លះ ឱ្យកូនរៀនសង្ខេបពីសកម្មភាពរៀនសូត្ររបស់គេ ចំណាយពេលមើលកូនអានសៀវភៅ មើលកូនធ្វើលំហាត់ សុំកូនមើលសៀវភៅតាមដាន ព្រឹត្តិប័ត្រពិន្ទុប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំជាដើម។

**ង.ឆ្លៀតពេលក្នុងការពិភាក្សាពីការសិក្សាជាមួយកូន៖** ឪពុកម្ដាយ ត្រូវពង្រឹងការសិក្សារបស់កូនតាមរយៈស្វែងយល់ពីចំណង់ចំណូលចិត្តរបស់កូន ព្រោះបុគ្គលម្នាក់ៗតែងតែមានទំនោរ និងចំណូលចិត្តផ្សេងៗគ្នាជាពិសេសបំណិនអាជីព និងទេពកោសល្យរបស់គេ។ ការពិភាក្សាការសិក្សាជាមួយកូន មាតាបិតា និងអ្នកអាណាព្យាបាលអាចស្វែងរកឃើញនូវចំណុចខ្លាំង ចំណុចខ្សោយរបស់កូន ហើយអាចជួយ

---

[151] គោលនយោបាយស្ដីពីសាលារៀនជំនាន់ថ្មី, ឆ្នាំ ២០១៦, ទំព័រ ៦

ដោះស្រាយបញ្ហានេះបានទាន់ពេលវេលា ព្រមទាំងអាចកាត់បន្ថយពីការគេចវេសការសិក្សារបស់កូនផង ដែរ។

**២.៥.៣.២.ត្រួតពិនិត្យការសិក្សា និងតាមដានលទ្ធផលសិក្សាជាប្រចាំ**

**ក.ជួយអង្កេត និងលើកកម្ពស់សកម្មភាពស្វ័យសិក្សានៅផ្ទះ៖** បន្ទាប់ពីសកម្មភាពអាជីពការងារចិញ្ចឹមជីវិតប្រចាំថ្ងៃ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលត្រូវអង្កេតមើល និងជួយលើកកម្ពស់ការសិក្សារបស់កូន ជាពិសេស ការធ្វើកិច្ចការសាលាដែលគ្រូបានដាក់ឱ្យ ការអានអត្ថបទ និងរៀនធ្វើលំហាត់អនុវត្តផ្សេងៗ ត្រូវផ្តល់កម្លាំងចិត្តដល់ពួកគេតាមករយៈការសរសើរ និងលើកឡើងពីគុណប្រយោជន៍ការសិក្សារៀនសូត្រ ជាក់ស្តែងដូចជាពំនោលចាស់ថា៖ "វិជ្ជាជាអាហារ ប្រាជ្ញាជាអាវុធ" "វិជ្ជាជាទ្រព្យជាប់នឹងប្រាណចោរលួចមិនបាន" "ប្រើច្រើនចេះច្រើន" ជាដើម។

**ខ.ទំនាក់ទំនងជាមួយគ្រូមុខវិជ្ជា គ្រូបន្ទុក និងនាយកបើចាំបាច់៖** គ្រូទទួលភារកិច្ចក្នុងការបណ្តុះបណ្តាលអប់រំសិស្សឱ្យក្លាយជាពលរដ្ឋល្អ ដោយមានការសហការពីមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស។ រាល់មន្ទិលសង្ស័យដែលកើតមានពាក់ព័ន្ធនឹងការសិក្សារបស់កូនៗ ពួកគាត់ត្រូវតែជួបផ្ទាល់ជាមួយគ្រូមុខវិជ្ជា គ្រូបន្ទុក និងគណៈគ្រប់គ្រងសាលាបើចាំបាច់។ ទំនាក់ទំនងល្អ នាំឱ្យភាពធកល្វែងនៃដំណើរការសិក្សារបស់សិស្សត្រូវបានរឹតបន្តឹង និងលើកកម្ពស់ឱ្យមានលទ្ធផលល្អប្រសើរ ហើយទំនាក់ទំនងនេះ អាចធ្វើដោយផ្ទាល់ និងប្រយោលតាមរយៈ បច្ចេកវិទ្យាទំនើបដូចជា៖ ទូរស័ព្ទ ប្រព័ន្ធសារអេឡិចត្រូនិច និងបណ្តាញសង្គមជាដើម។

**២.៥.៣.៣.ការលើកទឹកចិត្ត**

ការលើកទឹកចិត្តជាកម្លាំងចលករក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈ និងដំណើរការសកម្មភាពអ្វីមួយទៅបានរលូន មិនថាក្នុងបរិបទការងារក្តី ក្នុងគ្រួសារក្តី និងបុគ្គលក្តី។ ការលើកទឹកចិត្តអាចត្រូវបានគេប្រតិបត្តិដោយផ្ទាល់ និងប្រយោល។

**ក.ចូលរួមកម្មវិធីសំណេះសំណាលនៅសាលា**(បុណ្យផ្កា បើកបវេសនកាលថ្មី ចែករង្វាន់សិស្សឆ្នើមពូកែ....)៖ នៅពេលឪពុកម្តាយ និងអ្នកអាណាព្យាបាលបានចូលរួមក្នុងសកម្មភាពរបស់សាលា និងសហគមន៍ដូចជា៖ បុណ្យផ្កាសាមគ្គី ការប្រជុំមាតាបិតាសិស្ស កម្មវិធីសប្បុរសធម៌សង្គម/សាលារៀន កម្មវិធីបើកបវេសនកាលថ្មី ពិធីចែករង្វាន់ និងការចូលរួមវិភាគទានផ្សេងៗជាមួយសាលា...។ រូបភាពទាំងនេះ គឺជាគំរូដ៏ល្អក្នុងគុណតម្លៃនៃការសិក្សាស្វែងយល់ពីបំណិនជីវិតរស់នៅក្នុងសង្គម និងសហគមន៍ប្រកបដោយសុខសន្តិភាព និងការចេះជួយរំលែកទុក្ខលំបាក រួមសុខជាមួយសមាជិកក្នុងសង្គមដល់សិស្ស។ សិស្សនឹងមានអារម្មណ៍កក់ក្តៅថា រាល់សកម្មភាពសិក្សារបស់ពួកគេត្រូវបានមនុស្សគ្រប់គ្នាក្នុងសហគមន៍ និងគ្រួសារមានការយកចិត្តទុកដាក់ខ្លាំង។

**ខ.សម្តែងការកោតសរសើរ និងលើកទឹកចិត្ត៖** ការលើកទឹកចិត្តដោយផ្ទាល់ នឹងត្រូវឪពុកម្តាយ ឬអ្នកអាណាព្យាបាលអាចប្រើពាក្យសម្ដីសរសើរដល់កូន និងលើកទឹកចិត្តនូវរាល់សកម្មភាពដែលកូនបានប្រឹងប្រែងធ្វើ បើទោះបីលទ្ធផលដែលទទួលបាននោះ មិនសូវល្អ និងសមតាមបំណងក៏ដោយ។ ពួកគាត់ត្រូវផ្តល់កម្លាំងចិត្តឱ្យកូនខិតខំព្យាយាមបន្តទៀត ហើយអាចណែនាំពួកគេថា"កូនធ្វើបានល្អហើយ! លទ្ធផលទាំងនេះគឺជាបទពិសោធន៍សម្រាប់កូន"។ ការសរសើរ និងការលើកទឹកចិត្ត អាចជម្រុញឱ្យបុគ្គលម្នាក់បន្តអនុវត្តសកម្មភាពអ្វីមួយទៅមុខបន្ថែម ហើយទទួលបានល្អប្រសើរជាងពេលមុនៗ។

**គ.តម្រង់ទិសបំណិនជីវិតរបស់កូន៖** កុមារ/យុវសិស្សមិនទាន់មានបទពិសោធន៍ការងារនៅឡើយទេ មានតែឪពុកម្តាយ ឬអ្នកអាណាព្យាបាលជួយតម្រង់ទិសពីបំណិនជីវិតទាំងនេះដល់ពួកគេតាមរយៈការផ្តល់ជាគំរូអាជីព និងគុណតម្លៃនៃអាជីពនោះ។ នៅពេលបច្ចុប្បន្ននេះ មានឪពុកម្តាយមួយចំនួនជ្រើសយកកម្មវិធីបច្ចេកវិទ្យាដើម្បីប្រមើរមើលពីជំនាញ និងភាពខ្លាំងរបស់កូនឈ្មោះថា **ប្រេនស្កែន** (BrainScan)។

### ២.៥.៤. តួនាទីរបស់សិស្សក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់ខ្លួន

ច្បាប់ស្តីពីការអប់រំ មាត្រា ៣៥បានចែងថា អ្នកសិក្សាត្រូវបានផ្តល់សិទ្ធិទាក់ទងនឹងការអប់រំមានដូចតទៅ(នស/រកម/១២០៧/០៣២, ២០០៧)[152]៖

- សិទ្ធិបញ្ចេញទស្សនៈសិក្សាដោយសេរី
- សិទ្ធិមានសេរីភាពខាងការសិក្សា
- សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព
- សិទ្ធិប្រមូលផ្តុំជាក្រុមអ្នកសិក្សា ឬក្លឹបអ្នកសិក្សាក្នុងគោលបំណងសម្រាប់ការអប់រំ
- សិទ្ធិពិនិត្យមើល និងចម្លងកំណត់ត្រាផ្ទាល់ខ្លួនស្តីពីការអប់រំ
- សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់គ្រឹះស្ថានសិក្សា និងថ្នាក់ជាតិដោយផ្ទាល់ ឬតាមរយៈតំណាងខ្លួន
- សិទ្ធិទទួលបានការគោរព និងការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្ស ជាពិសេសសិទ្ធិមានសេចក្តីថ្លៃថ្នូរ សិទ្ធិរួចផុតពីអំពើទារុណកម្ម ឬការដាក់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី។ ទន្ទឹមនឹងសិទ្ធិខាងលើ អ្នកសិក្សាត្រូវប្រកាន់ខ្ជាប់នូវករណីកិច្ចរបស់ខ្លួនដូចតទៅ៖
- គោរពបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សា តម្លៃខាងសមធម៌យេនឌ័រ ដោយអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងគោរពសិទ្ធិអ្នកដទៃ
- ខិតខំសិក្សាឱ្យអស់ពីលទ្ធភាពរបស់ខ្លួនដើម្បីទទួលបានការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាព បញ្ញា និងសេចក្តីថ្លៃថ្នូរ។

---

152 ព្រះរាជក្រម ច្បាប់ស្តីពីការអប់រំ, ឆ្នាំ ២០០៧, មាត្រា ៣៦, ទំព័រ ១៤

សិស្សានុសិស្សជាទំពាំងស្នងឬស្សីសម្រាប់ប្រទេសជាតិ ជាអ្នកស្រេកឃ្លានការសិក្សា និងត្រូវទទួលការអប់រំជាចាំបាច់ ព្រមទាំងត្រូវចូលរៀនតាមគ្រឹះស្ថានសិក្សាដែលស្ថិតនៅជិតផ្ទះបំផុតរបស់ខ្លួនតាមការពេញចិត្ត និងត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់សាលាឱ្យបានខ្ជាប់ខ្ជួន(នី, ២០២២)[153]។

**២.៥.៤.១.ការចូលរួមការងារសហគមន៍ និងការគោរពវិន័យ៖** សម្លៀកបំពាក់សមរម្យតាមឯកសណ្ឋានសាលា ចូលរួមគោរពទង់ជាតិ រក្សាសណ្តាប់ធ្នាប់ វិន័យក្នុងទីធ្លាគ្រឹះស្ថានសិក្សា ក្នុងបន្ទប់រៀន ពេលកំពុងរៀនសូត្រ មិនត្រូវឡូឡារំខានដល់អ្នកដទៃ។

**ក.ម៉ោងសិក្សា៖** គោរពពេលវេលាចេញចូល មករៀនឱ្យបានទៀងទាត់ទៅតាមកាលវិភាគដែលបានកំណត់។ ការគោរពពេលវេលា គឺជាប្រតិបត្តិវិន័យផ្ទាល់ខ្លួននាំឱ្យសិស្សមានឥរិយាបថល្អក្នុងការងារនាពេលអនាគត។

**ខ.ចូលរួមបោសសម្អាតបរិស្ថានថ្នាក់ សាលារៀន និងការងារសង្គម៖** ចូលរួមធ្វើពលកម្មជាមួយមិត្តភក្តិឯទៀតៗ ដើម្បីស្វែងយល់ពីការងារក្រុម បញ្ហាអនាម័យ និងសុខភាពនៅក្នុងជីវភាពរស់ជាក់ស្តែង។ ការផ្តល់តម្លៃដល់ខ្លួនឯង(Self-Esteem) និង ចំណេះដឹងបុគ្គល(Self-Concept) អាចជួយមនុស្សយល់ពីសមត្ថភាពយល់ដឹង បំណិនជីវិតដែលខ្លួនមានទៅប្រៀបធៀបខ្លួនឯង ទៅនឹងអ្នកដទៃជុំវិញខ្លួនដើម្បីវិនិច្ឆ័យព័ត៌មាន ពុទ្ធិដែលខ្លួនមានហើយអាចជួយអភិវឌ្ឍខ្លួនឯងនូវសមត្ថភាព ឥរិយាបថ និងការប្រតិបត្តិ(Social Comparison)(Robert, 2005)[154]។

**គ.រក្សាសណ្តាប់ធ្នាប់នៃការសិក្សា៖** ស្លៀកពាក់ឯកសណ្ឋានសាលាឱ្យបានត្រឹមត្រូវមាន អនាម័យស្អាតជានិច្ច តុបតែងខ្លួនឱ្យបានសមរម្យ សិស្សប្រុសត្រូវកាត់សក់ខ្លី រីឯសិស្សស្រីត្រូវចងសក់ឱ្យបានត្រឹមត្រូវចៀសវាងការតុបតែងខ្លួនឱ្យឆើតឆាយហួសហេតុ(ការលាបពណ៌សក់ ការលាបក្រចក ផាត់ម្សៅលាបគ្រែម ពាក់គ្រឿងអលង្ការ សំពត់ខើចជាដើម។

**២.៥.៤.២.ស្មារតីទទួលខុសត្រូវចំពោះសហគមន៍ និងការសិក្សារបស់ខ្លួន**

**ក.ធ្វើស្វ័យសិក្សា៖** រៀនថ្ងៃមិនគ្រប់ រៀនយប់បន្ថែម គឺរៀនអនុវត្តទ្រឹស្តីដែលគ្រូបានបង្រៀនកាលពីថ្ងៃនៅក្នុងសាលាដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការហ្វឹកហាត់ពោលគឺរៀនច្រើន ចេះច្រើន ធ្វើច្រើន យល់ច្រើនប្រសើរច្រើន។

**ខ.វិន័យផ្ទាល់ខ្លួន៖** ការប្រតិបត្តិរបស់សិស្សម្នាក់ៗតែងតែខុសគ្នាទាំងការឥរិយាបថផ្ទាល់ខ្លួន និងសង្គម។ ដូចនេះ សិស្សណាមានវិន័យផ្ទាល់ខ្លួន នោះនឹងអាចបង្ហាញថាការសិក្សារបស់គេមានភាពល្អប្រសើរច្រើនជាងអ្នកដែលមិនមានគោលដៅ និងឆន្ទៈសិក្សារបស់គេ។ វិន័យផ្ទាល់ខ្លួនរបស់សិស្ស វានាំឱ្យ

---

153 បទបង្ហាញឧទ្ទេសចារ្យ បណ្ឌិត នី រដ្ឋា មុខវិជ្ជា ការគ្រប់គ្រងការបំពេញការងារក្នុងសាលា, ឆ្នាំទី ២ ឆមាសទី ១, ២០២២

154 Educational Psychology Robert E. Slavin, Theory and Practice, 8th edition, Allyn&Bacon, 2005,ទំព័រ ៨០

ដំណើរការបង្រៀន និងរៀនវិវត្តទៅបានរលូន និងមានការផ្លាស់ប្តូរជាវិជ្ជមាននូវវិជ្ជាសម្បទា បំណិន សម្បទា និងចរិយាសម្បទា។

**គ.ផែនការសិក្សា (ត្រៀមប្រឡង និងវាយតម្លៃ)៖** ផែនការ គឺជាត្រីវិស័យជួយជម្រុញឱ្យអ្នករាល់គ្នាឆ្ពោះសម្រេចគោលដៅតាមបំណងប្រាថ្នា។ ការធ្វើផែនការសិក្សា សិស្សម្នាក់ៗត្រូវតែប្រតិបត្តិឱ្យទើបការរៀនសូត្រឆ្លើយតបទៅនឹងតម្រូវការបុគ្គល គ្រួសារ និងសង្គម។ សិស្សត្រូវបែងចែកពេលវេលាឱ្យបានល្អ និងអនុវត្តផែនការសិក្សាទៅតាមតារាងពេលវេលាដែលបានរៀបចំរួច នោះទើបការប្រឡងទទួលបានពិន្ទុល្អ។ ក្រោយពីប្រឡងប្រចាំខែ ឆមាស និងប្រចាំឆ្នាំ អ្នកសិក្សាអាចត្រួតពិនិត្យ និងវាយតម្លៃពីការសិក្សារបស់ខ្លួនដើម្បីឆ្លុះបញ្ចាំងពីចំណុចខ្លាំង និងខ្សោយរបស់ខ្លួនដើម្បីធ្វើការកែប្រែឱ្យបានប្រសើរជាងមុនមួយជំហានទៀត។

### ២.៥.៤.៣.កិច្ចខិតខំសិក្សាអស់ពីលទ្ធភាពរបស់ខ្លួន

**ក.បង្កើតក្លឹបសិក្សា៖** សិស្សត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តឱ្យបង្កើតក្រុមសិក្សា ដើម្បីផ្លោះប្តូរយោបល់គ្នា អនុវត្តធ្វើលំហាត់ ពិភាក្សាគ្នាពីខ្លឹមសារមេរៀនដែលបានរៀនរួច និងមេរៀនដែលនឹងត្រូវរៀននៅថ្ងៃបន្តបន្ទាប់។ ការបង្កើតក្លឹបសិក្សាគឺអាចសិស្សបានរៀនរួមគ្នាតាមបែបសហការ បង្កើតនូវសាមគ្គីភាព និងបង្កើនភាពជឿជាក់ក្នុងការរៀនសូត្ររបស់ពួកគេ។ ការសិក្សាមិនត្រឹមតែត្រូវសិក្សាស្វែងតែពីគ្រូបង្រៀនប៉ុណ្ណោះទេ ក៏ត្រូវរៀនពីអ្នកនៅជុំវិញខ្លួន អាចជារៀមច្បង សិស្សពូកែ សិស្សឆ្នើមមានវប្បធម៌ចែករំលែកនូវបទពិសោធន៍ តិចនិចក្នុងការដោះស្រាយលំហាត់ និងរូបមន្តនៃភាពជោគជ័យជាពេលប្រឡងជាដើម។

**ខ.ចូលរួមដោះស្រាយបញ្ហារបស់មិត្តរួមថ្នាក់** (មិត្តជួយមិត្ត)៖ ស្រឡាញ់យកអាសារមិត្តភក្តិ មានសាមគ្គី ចេះជួយគ្នាទៅវិញទៅមក ស្មោះត្រង់ចំពោះគ្នា និងគ្រឹះស្ថានសិក្សាដោយមិនធ្វើអ្វីឱ្យប៉ះពាល់ដល់កិត្តិយសសាលាឡើយ។ ការរៀនតាមបែបសហការ រិះរក និងស្ថាបនារៀនដោយផ្សារភ្ជាប់ទ្រឹស្តីទៅការរស់នៅប្រចាំថ្ងៃ នឹងនាំឱ្យពួកគេកាន់តែមានបំណិនក្នុងការដោះស្រាយបញ្ហា និងបញ្ហាប្រឈមដែលពួកគេនឹងជួបប្រទះក្នុងសង្គមជាក់ស្តែង។

## ២.៦. សារៈសំខាន់នៃការចូលរួមរបស់គ្រួសារ និងសហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

ការអប់រំនៅផ្ទះ(home education)បានបង្ហាញពីផលជះផ្សេងៗក្នុងការផ្តល់ចំណេះដឹងដល់សិស្សតាមរយៈបរិយាកាសគ្រួសារ ក៏ដូចជាសហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សដោយសកម្មភាពចូលរួមធ្វើការសម្រេចចិត្ត ការបរិច្ចាគ ឥរិយាបថរបស់ឪពុកម្តាយក្នុងការលើកកម្ពស់របស់សិស្ស

(Ardita&Rabije, 2016)[155]។ សារៈសំខាន់នៃទំនាក់ទំនងរបស់ឪពុកម្តាយ អ្នកអាណាព្យាបាលរបស់សិស្សជាកត្តាធ្វើឱ្យមានការរីកចម្រើនដល់ការសិក្សារបស់សិស្សដូចជាៈ កាត់បន្ថយអត្រាបោះបង់ការសិក្សា បន្ថយអត្រារៀនត្រួតថ្នាក់ និងលុបបំបាត់អត្រាមិនចូលរៀន។ អាស្រ័យហេតុនេះ អ្នកសិក្សាស្រាវជ្រាវភាគច្រើន បានចាប់ផ្តើមផ្តោតលើវត្តមាននៃការចូលរួមរបស់គ្រួសារ និងសហគមន៍មកលើភាពរីកចម្រើនលើលទ្ធផលសិក្សារបស់សិស្ស(ផាន់, ២០២០)[156]។ ម្យ៉ាងវិញទៀត គ្រួសារជាផ្នែកមួយនៃសហគមន៍ ហើយសាលារៀនក៏ជាផ្នែកមួយនៃសង្គម ដូចនេះសាលារៀន សហគមន៍ និងគ្រួសារសុទ្ធតែមានទំនាក់ទំនងនឹងគ្នាដោយមិនអាចខ្វះផ្នែកណាមួយឡើយ ពោលគឺៈ សហគមន៍ត្រូវតែមានគ្រួសារ និងសាលារៀន សាលារៀនត្រូវតែមានវត្តមានសិស្ស។ យោងតាមកិច្ចការស្រាវជ្រាវរបស់រៀមច្បង ផាន់ សំអាត ក៏បានលើកឡើងដែរថា សារៈសំខាន់នៃការចូលរួមរបស់គ្រួសារ និងសហគមន៍ជាដំណើរការមួយដែលមានផលជះបំពេញឱ្យគ្នាទៅវិញទៅមកដូចជា *"សហគមន៍ជួយដល់សាលារៀន សាលារៀនជួយដល់សហគមន៍"*។

**១. បង្កើនប្រសិទ្ធភាពនៃការប្រតិបត្តិផែនការអភិវឌ្ឍន៍សាលា**(អយក, ២០១៧)[157]

- អាចពិនិត្យមើលការអនុវត្តការងាររបស់សាលារៀន
- ឃ្លាំមើល វាយតម្លៃការអភិវឌ្ឍរបស់សាលារៀន
- ផ្តល់ព័ត៌មានទាក់ទងនឹងតម្រូវការអប់រំដែលអាចប្រើជាមូលដ្ឋានក្នុងការកសាងផែនការសម្រាប់ឆ្នាំបន្តបន្ទាប់
- ជួយសម្របសម្រួលនូវរាល់សកម្មភាពទាំងអស់ទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្សបានទាន់ពេលវេលា
- ជួយផ្សព្វផ្សាយពីលទ្ធផលនៃវឌ្ឍនភាពរបស់សាលាដល់អ្នកពាក់ព័ន្ធ
- ផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធ សប្បុរសជនដទៃទៀតបានរួមចំណែកជាមតិយោបល់ អំពីការអនុវត្តផែនការ ព្រមទាំងចូលរួមធ្វើកំណែលម្អផែនការទៅអនាគត

**២. ចូលរួមលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស**

- ជួយសាលារៀបចំក្រមសីលធម៌ សេចក្តីណែនាំផ្តោតលើការពារផលប្រយោជន៍សិស្ស
- រក្សាបាននូវវប្បធម៌សង្គមក្នុងការជួយឧបត្ថម្ភគាំទ្រដល់ការកសាងសមត្ថភាពគ្រូ និងគុណភាពអប់រំរបស់សិស្សក្នុងសាលា
- ជួយដោះស្រាយពីសុខមាលភាពរបស់សិស្ស និងគ្រូបង្រៀន(គោលការណ៍ថែទាំសុខភាពសិស្ស និងបុគ្គលិកសិក្សា)

---

[155] The Study of The Role of Parents in the Education of Children, Ardita Ceka& Rabije Marati, Journal of Education and Practice Vol.7, No 5, 2016

[156] និក្ខេបបទ ស្តីពី ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង, ផាន់ សំអាត, ២០២១

[157] ឯកសារប្រតិបត្តិ ការរៀបចំផែនការអភិវឌ្ឍសាលារៀន, ឆ្នាំ ២០១៧, ទំព័រ ៥

- ជួយឧបត្ថម្ភគាំទ្រ និងកៀរគរធនធានផ្សេងៗដើម្បីលើកកម្ពស់ការសិក្សា និងបង្កើនប្រសិទ្ធភាពលទ្ធផលសិក្សារបស់សិស្ស(គណៈកម្មការចុះជួយការងារខេត្ត គណៈអភិបាលខេត្ត)

### ៣. អភិវឌ្ឍបរិស្ថានសិក្សាប្រកបដោយចីរភាព

ដើម្បីស្ថិរភាព និងការអភិវឌ្ឍបរិស្ថានសិក្សានៅក្នុងសាលារៀនមួយត្រូវពឹងផ្អែកលើគណៈគ្រប់គ្រងសាលា គណៈកម្មការអភិវឌ្ឍសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការគ្រប់គ្រងមូលនិធិសាលា ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀតចូលរួមនូវ៖

- សកម្មភាពដោះស្រាយបញ្ហាបន្ទាន់ដូចជា៖គ្រោះមហន្តរាយ ជំងឺអាសន្នរោគ ជំងឺរាតត្បាត និងភាពវិករវនានាដែលកើតមានឡើងក្នុងសហគមន៍សាលារៀន
- សកម្មភាពនានាដែលគាំទ្រដល់ការងារគណនេយ្យភាពសង្គមដូចជា៖ មានអ្នកទទួលខុសត្រូវការងារគណនេយ្យច្បាស់លាស់ មានរបាយការណ៍ចំណូល ចំណាយត្រឹមត្រូវ មានការបិទផ្សាយព័ត៌មានជាសាធារណៈពីផលសម្រេចរបស់សាលារៀន និងវឌ្ឍនភាពរបស់សាលា
- សកម្មភាពផ្សព្វផ្សាយនូវសមធម៌ក្នុងការទទួលសេវាអប់រំសម្រាប់ទាំងអស់គ្នា ដោយដើរប្រកូកប្រកាសព័ត៌មានស្ដី ពីការចូលរៀន ការទទួលបានអាហារូបករណ៍ ជំនួយសប្បុរសជន
- សកម្មភាពរៀបចំ ជួសជុល កសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងសាលាដូចជា៖ បង្គន់ទឹកប្រុសស្រី/ជនពិការ មានបំពាក់ឧបករណ៍ជំនួយភ្នែក ត្រចៀក សួនច្បារ សួនជីវចម្រុះ សួនអំណាន និងបណ្ណាល័យជាដើម
- សកម្មភាពការងារលុបបំបាត់អំពើពាលាអាវ៉ាសែ និងហិង្សាផ្សេងៗដូចជា៖ អំពើហិង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ជួយរាយការណ៍ពីសកម្មភាពល្មើស និងងាយរងគ្រោះផ្សេងៗ
- សកម្មភាពលើកទឹកចិត្តដល់អ្នកមានស្នាដៃ សមាជិកឆ្នើម ជួយទុក្ខធុរៈគ្នាក្នុងគ្រាអាសន្ន
- សកម្មភាពកៀរគរធនធានមកកសាងបរិស្ថានសាលា ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ
- សកម្មភាពគ្រប់គ្រងដឹកនាំការងារអប់រំ សុខាភិបាល សេដ្ឋកិច្ចសង្គមដូចជា៖ ជួយគាំទ្រដល់ការចាក់វ៉ាក់សាំងការពារជំងឺ យុទ្ធនាការទំលាក់ព្រូន ទិវាអក្ខរកម្ម ទិវាអំណាន កម្មវិធីសន្សំលុយ
- សកម្មភាពការងារសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធមានដូចជា៖ ជួយគាំទ្រនូវការរៀបចំឧបករណ៍អាសន្ន សម្ភារៈសង្គ្រោះបន្ទាន់ ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយសុវត្ថិភាព កៀរគរធនធានសម្ភារៈកែលម្អហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន

លើសពីនេះ យោងតាមការស្រាវជ្រាវបរទេសមួយបានលើកឡើងដោយសារ ការចូលរួមរបស់គ្រួសារនាំឱ្យកើតមាននូវការផ្លាស់ប្ដូរដូចជា៖ ពង្រឹងលទ្ធផលសិក្សារបស់សិស្សជាវិជ្ជមានទទួលបានជោគជ័យក្នុងការសិក្សាឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍរបស់សិស្ស ស្របជាមួយនឹងឥរិយាបថ និងការប្រតិបត្តិតួនាទីរបស់ឪពុកម្ដាយ/អ្នកអាណាព្យាបាល។ ការឧបត្ថម្ភគាំទ្រនេះ បានសម្ដែងជា៖

- ឥរិយាបថ គុណតម្លៃ ការប្រតិបត្តិតួនាទីរបស់មាតាបិតា/អ្នកអាណាព្យាបាលជួយបង្កើនឱ្យសិស្សមានទំនាក់ទំនងល្អជាមួយគ្រួសារ និងផ្សារភ្ជាប់ខ្លួនទៅនឹងសហគមន៍
- សម្ព័ន្ធភាពនៃការអប់រំនៅផ្ទះ(Parent-Child Relationship) ជាទំនាក់ទំនងផ្លូវការផង និងក្រៅផ្លូវការផងរវាងការបង្កើតការអប់រំនិង គ្រួសារ(ទំនាក់ទំនង ការចូលរួមក្នុងព្រឹត្តិការណ៍សាលារៀន និងកម្មវិធីសំណេះសំណាលមាតាបិតា/អ្នកអាណាព្យាបាលសិស្សជាផ្លូវការ)

ជាទិដ្ឋភាពរួមនៃការចូលរួមរបស់ឪពុកម្តាយ/អ្នកអាណាព្យាបាល ជាទីតាំងសិក្សាមួយត្រូវធ្វើឡើងនៅផ្ទះ និងសហគមន៍មានដូចជា៖ ការលើកកម្ពស់បំណិនសិក្សាតាំងពីកុមារភាព(ជួយឱ្យសិស្សអានអក្សរ ជួយសិស្សធ្វើកិច្ចការផ្ទះ រៀបចំគ្រប់គ្រងការសិក្សាសិស្ស និងគាំទ្រនូវក្តីរំពឹងមួយដ៏ធំធេង)(Harvard, 2006/07)[158]។

## ២.៧. គោលការគ្រប់គ្រងតាមសាលារៀន(School-Base Management) មានប្រសិទ្ធភាព

**ការគ្រប់គ្រងតាមសាលារៀន** (SBM) គឺជាការធ្វើវិមជ្ឈការការគ្រប់គ្រង (Decentralizes Control) ពីការិយាល័យកណ្តាល មកថ្នាក់សាលារៀននីមួយៗដែលជាមធ្យោបាយមួយដើម្បីផ្តល់ធម្មនុញ្ញឱ្យសាលារៀន។ គណៈនាយក/នាយិកា គ្រូបង្រៀន មាតាបិតាសិស្ស សមាជិកសហគមន៍ ហើយក្នុងសាលារៀនខ្លះទៀត សិស្សក៏ត្រូវចូលរួមគ្រប់គ្រងអ្វីៗដែលមានក្នុងសាលារៀនផងដែរ។ ស្ថានភាពនេះគឺជាការលើកកម្ពស់ស្វ័យភាព (Autonomy)។ នៅពេលសាលារៀនមានស្វ័យភាពច្រើន វានឹងកសាងសិទ្ធិអំណាច (Empower) ដល់អ្នកពាក់ព័ន្ធ និងកសាងបាននូវកម្មសិទ្ធិភាព (Ownership) យ៉ាងច្រើនចំពោះសាលារៀន។ អ្នកគាំទ្រ **ការគ្រប់គ្រងតាមសាលារៀន** (SBM) អះអាងថាការបង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធនៅកម្រិតសាលារៀន ទៅលើការគ្រប់គ្រងសាលារៀននឹងបង្កើនសមត្ថភាពសាលារៀនឱ្យចេះធ្វើការកែលម្អជាប្រចាំបានល្អប្រសើរ។ លទ្ធផលនេះកើតឡើងពីព្រោះកម្មសិទ្ធភាពបង្កើននូវគណនេយ្យភាព (Accountability) ដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីប្រឹងប្រែងសម្រេចនូវស្តង់ដាការបំពេញការងារ (Performance Standards) សាលារៀនដែលពួកគេបានកំណត់។ អ្នកគាំទ្រគោលការណ៍គ្រប់គ្រងតាមសាលារៀន អះអាងថា ការបង្ករឱ្យមានទស្សនៈចូលរួមកាន់តែទូលំទូលាយពីគ្រប់អ្នកពាក់ព័ន្ធដើម្បីធ្វើសេចក្តីសម្រេចចិត្ត នឹងបង្កើតឱ្យមានលទ្ធផលសម្រេចចិត្តកាន់តែល្អប្រសើរ ឆ្លើយតបនឹងតម្រូវការសហគមន៍សាលារៀននៅមូលដ្ឋាន។

ទោះបីយ៉ាងណាក៏ដោយ គ្មានវិធីសាស្ត្រណាមួយដែលល្អឥតខ្ចោះនោះទេ តែងតែមានគុណសម្បត្តិ និងគុណវិបត្តិ។ ដូច្នេះ **ការគ្រប់គ្រងតាមសាលារៀន** (SBM) ក៏មិនខុសអ្វីពីវិធីសាស្ត្រទាំងនោះដែរ

[158] Family Involvement Makes A Difference (Harvard Family Research, 2006/07)

តែងតែមានហានិភ័យជាប់មកជាមួយ ដូចជាភាពអនាធិបតេយ្យអាចកើតឡើង ការសម្រេចអ្វីមួយអាចត្រូវការពេលវេលាច្រើន ការយល់ច្រឡំពីតួនាទី និងការទទួលខុសត្រូវថ្មីៗរបស់អ្នកអនុវត្ត និង តម្រូវការអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈបុគ្គលិកក៏កើនឡើងដែរ។

ក្រសួងអប់រំ យុវជន និងកីឡាក៏បានអនុវត្តគោលការណ៍គ្រប់គ្រងតាមសាលារៀននៅក្នុងគម្រោងផ្សេងៗផងដែរ ជាពិសេស ក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី។ សាលារៀនជំនាន់ថ្មីទទួលបាននូវស្វ័យភាព (សេរីភាព) ខ្ពស់ក្នុងផ្នែកសំខាន់ៗនៃប្រតិបត្តិការសាលារៀនទាំងមូលរួមមានដូចជាៈ (១) ការគ្រប់គ្រងបុគ្គលិក (២) ការគ្រប់គ្រងការបង្រៀន-រៀន (៣) ការគ្រប់គ្រងថវិកា (៤) ការថែទាំនិងហេដ្ឋារចនាសម្ព័ន្ធ និង (៥) ការគ្រប់គ្រងរដ្ឋបាល ការពិនិត្យតាមដាន និងការទំនាក់ទំនងសហគមន៍។ ដូចការលើកឡើងខាងដើម ស្វ័យភាពសាលារៀន ជាបុរេលក្ខខណ្ឌដ៏ចាំបាច់បំផុតសម្រាប់អនុវត្តគោលការណ៍ **ការគ្រប់គ្រងតាមសាលារៀន (SBM)** ឱ្យមានប្រសិទ្ធភាព។ លើសពីនេះថែមទៀត ស្វ័យភាពសាលារៀន និងបរិយាកាសអំណោយផល ក៏មានទំនាក់ទំនងគ្នាយ៉ាងខ្លាំងក្នុងការអនុវត្តគោលការណ៍ **ការគ្រប់គ្រងតាមសាលារៀន (SBM)** ឱ្យជោគជ័យ។ សាលារៀនណាមានសេរីភាពច្រើនលើផ្នែកផ្សេងៗនៃប្រតិបត្តិការសាលារៀននោះក៏នឹងមានបរិយាកាសអំណោយផល "ខ្លាំង" ក្នុងការអនុវត្ត **ការគ្រប់គ្រងតាមសាលារៀន (SBM)** ខណៈដែលសាលារៀនណាមានសេរីភាពតិច ក៏នឹងមានបរិយាកាសអំណោយផល "ខ្សោយ" ក្នុងការអនុវត្ត **ការគ្រប់គ្រងតាមសាលារៀន (SBM)** ទៅតាមនោះដែរ។ កម្រិតស្ថានភាពនីមួយៗនេះ យើងហៅថា តំណសម្ព័ន្ធនៃបរិយាកាសអំណោយផល (Continuum of Enabling Environment)។ ជាក់ស្តែង នៅក្នុងឯកសារបណ្តុះបណ្តាលអំពី ការគ្រប់គ្រងតាមសាលារៀន ក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីគឺផ្តោតទៅលើប្រធានបទសំខាន់ៗរួមមាន (១) និយមន័យការគ្រប់គ្រងតាមសាលារៀនៈស្វ័យភាព គណនេយ្យភាព កម្មសិទ្ធិភាព... (២) ការធ្វើស្វ័យវាយតម្លៃអំពីកម្រិតស្វ័យភាព និងផែនការកែលម្អកម្រិតស្វ័យភាពរបស់សាលានីមួយៗ (៣) រចនាសម្ព័ន្ធគ្រប់គ្រងសំខាន់ៗ សម្រាប់អនុវត្ត**ការគ្រប់គ្រងតាមសាលារៀន (SBM)** (៤) ការរៀបចំប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ CPD(Continutinum Professional Development) (៥) ការរៀបចំនិងដំណើរការធ្វើផែនការអភិវឌ្ឍន៍សាលារៀន (៦) ការធ្វើផែនការតាមវិធីសមហេតុសមផល Logical Framework Approach (៧) ការបង្ហាញ និងអនុវត្តសូចនាករដើម្បីធ្វើការវិភាគលទ្ធផល (៨) ការប្រើប្រាស់ម៉ឺនុយសកម្មភាពសម្រាប់ធ្វើផែនការអភិវឌ្ឍន៍ និង (៩) ការ

គ្រប់គ្រងការផ្លាស់ប្តូរ[159]។ ទន្ទឹមនឹងនេះ ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព(SBM)ត្រូវផ្តោតលើគោលការណ៍ចំនួន៥គឺ(ហង់, ២០២២)[160]៖

**គោលការណ៍ទី១៖** គណនេយ្យភាព(Accountability) សំដៅដល់នាយកសាលាត្រូវមានគណនេយ្យភាពចំពោះមាតាបិតាសិស្សដោយបង្កើតគណៈកម្មការសាលារៀន និងចុះកិច្ចសន្យាលទ្ធផលការងារប្រចាំឆ្នាំ ការប្រជុំវាយតម្លៃ និងស្វ័យវាយតម្លៃ ដើម្បីសម្រេចស្តង់ដាសាលារៀនមានប្រសិទ្ធភាព។

**គោលការណ៍ទី ២៖** ស្វ័យភាព(Autonomy) ផ្តោតលើសាលារៀបចំផែនការកែលម្អសាលារៀន ដើម្បីដោះស្រាយបញ្ហាចំពោះមុខ ជាពិសេសដើម្បីជួយបង្កើតបរិស្ថានអំណោយផលសម្រាប់ការរៀនសូត្រ ជួយគាំទ្រគ្រូ កែលម្អវប្បធម៌សាលារៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមរយៈកម្មវិធីលើកកម្ពស់គុណវុឌ្ឍិនាយក(LUP)។

**គោលការណ៍ទី ៣៖** វង្វាយតម្លៃ(Assessment) ជាការរៀបចំតេស្តស្តង់ដាមានតម្លាភាព និងយុត្តិធម៌ដើម្បីកែលម្អការបង្រៀន ដោយបង្រៀនបន្ថែមជួយដល់សិស្សរៀនយឺត និងផ្សព្វផ្សាយលទ្ធផលជាសាធារណៈ និងផ្តល់ព័ត៌មានពីលទ្ធផលសិក្សាដល់មាតាបិតា។

**គោលការណ៍ទី ៤៖** ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន(Attention to Teachers) ជាយន្តការមួយ គ្រូប្រើលទ្ធផលតេស្តដើម្បីកែលម្អការបង្រៀន ការចុះកិច្ចសន្យាវាយតម្លៃលទ្ធផលការងារ និងការបង្កើនគុណវុឌ្ឍិគ្រូតាមរយៈកម្មវិធីបង្កើនគុណវុឌ្ឍិគ្រូ(TUP)

**គោលការណ៍ទី ៥៖** ការចូលរួម(Participation) សំដៅដល់មាតាបិតាចូលរួមគាំទ្រសាលាដើម្បីរួមគ្នាអភិវឌ្ឍន៍សាលារៀន។

សរុបសេចក្តីមក សហគមន៍ពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រោះតាមការឆ្លុះបញ្ចាំង និងបកស្រាយខាងលើកិច្ចការងារអប់រំបណ្តុះបណ្តាលជាច្រើន សុទ្ធតែត្រូវមានភារកិច្ច និងទំនួលខុសត្រូវរៀងៗខ្លួនក្នុងការជួយឱ្យផែនការអភិវឌ្ឍន៍សាលារៀនទាំងហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត និងលទ្ធផលសិក្សារបស់សិស្ស។ ដូចនេះ តួអង្គសំខាន់ៗរួមមាន៖ សិស្ស គ្រូបង្រៀន គណៈនាយកសាលា ឪពុកម្តាយ/អ្នកអាណាព្យាបាល សហគមន៍ និងសប្បុរសជនពាក់ព័ន្ធទាំងអស់ ត្រូវតែរួមគ្នាអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយជំនាញបច្ចេកទេសច្បាស់លាស់សម្រាប់ជួយបង្កើនសេដ្ឋកិច្ចជាតិកម្ពុជា ឱ្យប្រែក្លាយជាប្រទេសឧស្សាហកម្មនៅឆ្នាំ ២០២២ ហើយក៏ក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ ២០៥០ផងដែរ។

---

[159] សិក្ខាសាលាការគ្រប់គ្រងតាមសាលារៀន, កំពង់ចាម, ថ្ងៃទី៣-៥ ខែមករា ឆ្នាំ២០២២

[160] ប្រសាសន៍ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាក្នុងពិធីបើកសន្និបាតបូកសរុបការងារអប់រំនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២២

# ជំពូកទី ៣

# ពិធីសាស្ត្រ
# ស្រាវជ្រាវ

# ជំពូកទី ៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. គម្រោងនៃស្រាវជ្រាវ

ដើម្បីធ្វើការស្រាវជ្រាវលើប្រធានបទដែលទាក់ទងនឹង "**តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**" នេះកិច្ចការស្រាវជ្រាវត្រូវអនុលោមទៅតាមទម្រង់ និងលំដាប់លំដោយដូចតទៅនេះ៖

## ៣.២. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបចម្រុះគឺប្រើគុណវិស័យ និងបរិមាណវិស័យ(Qualitative & Quantitative Research) ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវនៅក្នុងជំពូកទី១ នៃនិក្ខេបបទនេះ ហើយផ្ដោតទៅលើឥរិយាបថរបស់សហគមន៍ក្នុងកិច្ចសហការជាមួយសាលារៀនមានដូចជា៖ ១. ការចូលរួម ២. ការទំនាក់ទំនង ៣. ការលើកទឹកចិត្ត និងផ្ដល់គុណតម្លៃ ៤. ការផ្សព្វផ្សាយ និងកៀរគរធនធាន។ សហគមន៍ក្នុងសំណេរនិក្ខេបបទនេះមានវិសាលភាពលើអាជ្ញាធរដែនដី(មេភូមិ មេឃុំ ក្រុមប្រឹក្សាឃុំសង្កាត់) គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកអាណាព្យាបាល/មាតាបិតាសិស្ស និងសិស្សានុសិស្សតាមសាលាគោលដៅនៅក្នុងក្រុងព្រះសីហនុ។

### ៣.២.១. ទីកន្លែងសិក្សាស្រាវជ្រាវ

ដោយសារបញ្ហាប្រឈមមួយចំនួន ក្នុងដំណាក់កាលប្រមូលព័ត៌មានតាមក្រុមគោលដៅដូចជា៖ ការងារបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ពេលវេលា ធនធានសម្ភារៈ អាកាសធាតុ និងថវិការបស់អ្នកសិក្សាស្រាវជ្រាវផ្ទាល់ កិច្ចការសម្ភាសនេះ នឹងត្រូវធ្វើដោយការសម្ភាសផ្ទាល់មាត់ក្នុងរយៈពេលបីសប្ដាហ៍ ឈរលើគោលការណ៍សុក្រឹតភាពនៃការស្រាវជ្រាវ ការជ្រើសរើសទីកន្លែងនៃការសិក្សាស្រាវជ្រាវ នឹងប្រព្រឹត្តទៅដល់មូលដ្ឋាននៃទីតាំងសាលារៀន **វិទ្យាល័យហ៊ុន សែនមិត្តភាព វិទ្យាល័យហ៊ុន សែនឃ្លាំងលើ និងវិទ្យាល័យក្រុងព្រះសីហនុ** ដែលមានទីតាំងក្នុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ក្នុងគោលបំណងប្រមូលព័ត៌មាននានាដែលពាក់ព័ន្ធនឹងប្រធានបទ។

- ផែនទីសិក្សានៃខេត្តព្រះសីហនុ




(រូបភាពទី ២៤៖ ផែនទីសិក្សានៃខេត្តព្រះសីហនុ, ២០២២)

- ផែនទីសិក្សានៃវិទ្យាល័យហ៊ុន សែនមិត្តភាព




(រូបភាពទី ២៥៖ ផែនទីសិក្សានៃវិទ្យាល័យហ៊ុន សែនមិត្តភាព,

- ផែនទីសិក្សានៃវិទ្យាល័យក្រុងព្រះសីហនុ




(រូបភាពទី ២៦៖ ផែនទីសិក្សានៃវិទ្យាល័យក្រុងព្រះសីហនុ, ២០២២)

- ផែនទីសិក្សានៃវិទ្យាល័យហ៊ុន សែនឃ្លាំងលើ




(រូបភាពទី ២៧៖ ផែនទីសិក្សានៃវិទ្យាល័យហ៊ុន សែនឃ្លាំងលើ, ២០២២)

## ៣.២.២. ការជ្រើសរើសក្រុមគោលដៅសម្ភាសន៍

ការជ្រើសរើសអ្នកផ្តល់ព័ត៌មាន អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធី ជ្រើសរើសដោយចៃដន្យ (Probability Sampling) តាមការកំណត់ចំនួនអ្នកផ្តល់ព័ត៌មានពីសហគន៍(អាជ្ញាធរដែនដី មេឃុំ មេភូមិ) គណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតា/អ្នកអាណាព្យាបាលសិស្ស និងសិស្សក្នុងស្ថានភាពជាក់ស្តែងបត់បែនតាមកាលៈទេស ដោយកំណត់យកក្រុមអ្នកផ្តល់ព័ត៌មានមកពីសហគមន៍សាលារៀន ក្នុងសង្កាត់លេខមួយ លេខពីរ លេខបី និងលេខបួន សាលាវិទ្យាល័យទាំងបីក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងមានលក្ខណៈភូមិសាស្ត្រក្នុងទី

ប្រជុំជន ដោយជ្រើសរើសតាមវិធី (Purposive Sampling)។ ការចុះប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ នឹងត្រូវកំណត់ការជ្រើសយកវិទ្យាល័យចំនួនបីដែលចំណុះឱ្យភូមិសិក្សានៃក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ដើម្បីគោរពតាមគោលការណ៍នៃការសរសេរកិច្ចការស្រាវជ្រាវ ករណីសិក្សានេះ នឹងត្រូវកំណត់យកក្រុមគោលដៅសម្រាប់សម្ភាសន៍ប្រមូលទិន្នន័យពី អាជ្ញាធរចំនួន៣នាក់ គណៈគ្រប់គ្រងសាលា៦នាក់ មាតាបិតា/អ្នកអាណាព្យាបាលសិស្ស ១៨នាក់ គ្រូបង្រៀន ១៨នាក់ និងសិស្សានុសិស្សដែលកំពុងរៀននៅថ្នាក់ទី ១០ ទី១១ និងទី១២ ចំនួន១៨នាក់ ក្នុងឆ្នាំសិក្សា ២០២១-២០២២។ ដំណើរការនៃការប្រមូលទិន្នន័យដោយការចុះសម្ភាសន៍នឹងប្រព្រឹត្តតាមកាលវិភាគខាងក្រោម៖

**តារាងទី ៤៖ កាលបរិច្ឆេទនៃការសម្ភាសក្រុមគោលដៅផ្តល់ព័ត៌មាន**

| កាលបរិច្ឆេទ | ទីតាំងគោលដៅ | អ្នកផ្តល់ការសម្ភាស | ចំនួនគ្រោង | លទ្ធផល | |
|---|---|---|---|---|---|
| | | | | ផ្ទាល់មាត់ | បំពេញចម្លើយ |
| 7-11/06/2022 | វិទ្យាល័យហ៊ុន សែនមិត្តភាព | សហគមន៍/អាជ្ញាធរ | ១ | ១ | ០ |
| | | គណៈគ្រប់គ្រងសាលា | ២ | ១ | ១ |
| | | អ្នកអាណាព្យាបាល/មាតាបិតា | ៦ | ២ | ៤ |
| | | គ្រូបង្រៀន | ៦ | ២ | ៤ |
| | | សិស្ស | ៦ | ២ | ៤ |
| 13-18/06/2022 | វិទ្យាល័យហ៊ុន សែនឃ្លាំងលើ | សហគមន៍/អាជ្ញាធរ | ១ | ១ | ០ |
| | | គណៈគ្រប់គ្រងសាលា | ២ | ១ | ១ |
| | | អ្នកអាណាព្យាបាល/មាតាបិតា | ៦ | ៣ | ៣ |
| | | គ្រូបង្រៀន | ៦ | ៣ | ៣ |
| | | សិស្ស | ៦ | ៣ | ៣ |
| 20-25/06/2022 | វិទ្យាល័យក្រុង ព្រះសីហនុ | សហគមន៍/អាជ្ញាធរ | ១ | ១ | ០ |
| | | គណៈគ្រប់គ្រងសាលា | ២ | ២ | ០ |
| | | អ្នកអាណាព្យាបាល/មាតាបិតា | ៦ | ៣ | ៣ |
| | | គ្រូបង្រៀន | ៦ | ៣ | ៣ |
| | | សិស្ស | ៦ | ៣ | ៣ |
| **សរុប** | | | **៦៣** | **៣១** | **៣២** |

ក្នុងការជ្រើសរើសអ្នកផ្តល់ព័ត៌មានដល់ការសម្ភាស អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីជ្រើសរើសដោយចៃដន្យ(Unpurposive Sampling)។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ក្នុងការស្រាវជ្រាវលើប្រធានបទនេះ កិច្ចការជម្រើសទី១ នឹងចុះទៅជួបជាមួយមន្ត្រីការិយាល័យមធ្យមសិក្សាទុតិយភូមិនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ និងការិយាល័យក្រុង ខេត្តព្រះសីហនុ ដើម្បីស្នើសុំប្រភពទិន្នន័យដែលអាចជឿទុកចិត្តបានពាក់ព័ន្ធនឹងគុណភាពនៃការស្រាវជ្រាវ។ ការស្នើសុំរបាយការណ៍ស្ដីពីលទ្ធផលសិក្សាប្រចាំឆ្នាំរបស់សិស្សដើម្បីសិក្សាស្វែងយល់ពីប្រសិទ្ធភាពលើការគ្រប់គ្រងរបស់សាលាវិទ្យាល័យទាំងបីក្នុងក្រុងព្រះសីហនុនាឆ្នាំសិក្សាកន្លងមក។ កិច្ចការជម្រើសទី២ គឺជាការប្រើប្រាស់ឧបករណ៍ស្រាវជ្រាវជា **កម្រងសំណួរសម្ភាសន៍**(Interview Protocol) ដោយអ្នកស្រាវជ្រាវរៀបចំបង្កើតជាកម្រងសំនួរមានលក្ខណៈជាសំណួរ(ជីក)ផង ដែលមានទម្រង់ជាលក្ខណៈសំណួរបិទ និងសំណួរបើកដែលផ្ដោតលើទស្សនៈយល់ឃើញរបស់ក្រុមអ្នកផ្ដល់ព័ត៌មានទាក់ទងទៅនឹងតួនាទីរបស់ខ្លួន និងអ្នកពាក់ព័ន្ធក្នុងដំណើរការរៀនសូត្ររបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងតំបន់ក្រុងព្រះសីហនុ ក៏ដូចជាសហគមន៍សាលារៀននៃក្រុងព្រះសីហនុផងដែរ។ អ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរសម្ភាសន៍ដោយបែងចែកជា **ប្រាំក្រុមគោលដៅអ្នកផ្តល់ព័ត៌មាន**(Key Informant) ផ្សេងៗគ្នាមានដូចជា៖ **១. កម្រងសំណួរសម្ភាសន៍សម្រាប់សហគមន៍(អាជ្ញាធរដែនដី) ២. កម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រង(នាយក/នាយករង) ៣. កម្រងសំណួរសម្ភាសន៍សម្រាប់គ្រូបង្រៀន ៤. កម្រងសំណួរសម្ភាសន៍សម្រាប់មាតាបិតា/អ្នកអាណាព្យាបាលសិស្ស ៥. កម្រងសំណួរសម្ភាសន៍សម្រាប់សិស្ស** ។ កម្រងសំណួរសម្ភាសន៍នឹងត្រូវបានរៀបចំឡើងដូចតទៅ៖

### ៣.៣.១. កម្រងសំណួរសម្ភាសន៍សម្រាប់សហគមន៍(អាជ្ញាធរដែនដី)

ចំពោះកម្រងសំណួរសម្ភាសន៍នេះ អ្នកសិក្សាបានរៀបចំឡើងជាបីផ្នែក និងមានសំណួរចំនួន ២២ សំណួរដែលមានខ្លឹមសារដូចខាងក្រោម៖

ផ្នែកទី១៖ ព័ត៌មានទូទៅ៖ អ្នកសិក្សាចង់ដឹងអំពីកម្រិតវប្បធម៌ អង្គភាព/ស្ថាប័ន និងតួនាទី។

ផ្នែកទី២៖ តួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស៖ ផ្នែកនេះ អ្នកសិក្សាចង់ស្វែងយល់អំពីការបំពេញតួនាទីរបស់សហគមន៍ ហើយត្រូវបានតាក់តែងឡើងនូវចំណុចស្ដីពី ការផ្ដល់ជាតុចូល គណៈកម្មការសាលារៀន/ថ្នាក់រៀន និងការលើកទឹកចិត្ត និងកៀរគរធនធាន

ផ្នែកទី៣៖ ការផ្ដល់មតិយោបល់៖ អ្នកសិក្សាចង់ស្វែងយល់អំពីស្ថានភាពទូទៅនៃសហគមន៍ តួនាទីភារកិច្ចរបស់សហគមន៍ ទស្សនៈឆ្លុះបញ្ចាំងពីភាគីពាក់ព័ន្ធចំពោះការបំពេញតួនាទីរបស់សហគមន៍ កិច្ចសហការ និងការចូលរួម ព្រមទាំងបញ្ហាប្រឈម និងសំណូមពរផងដែរ ។

### ៣.៣.២. កម្រងសំណួរសម្ភាសន៍សម្រាប់គណៈគ្រប់គ្រងសាលា(នាយក/នាយករង)

ចំពោះកម្រងសំណួរសម្ភាសន៍នេះ អ្នកសិក្សាបានរៀបចំឡើងជាបីផ្នែក និងមានសំណួរចំនួន ២៩ សំណួរដែលមានខ្លឹមសារដូចខាងក្រោម៖

ផ្នែកទី១៖ ព័ត៌មានទូទៅ៖ ផ្នែកនេះ ត្រូវរៀបចំឡើងជាប្រាំចំណុចដោយលើកឡើងពីកម្រិតវប្បធម៌ អង្គភាព/ស្ថាប័ន និងតួនាទី។

ផ្នែកទី២៖ តួនាទីរបស់គណៈគ្រប់គ្រងសាលា ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស៖ ផ្នែកនេះ ត្រូវបានតាក់តែងឡើងនូវចំណុចស្ដីពី ជាអាជ្ញាធរអប់រំ និងជាគំរូល្អក្នុងសហគមន៍ ជាទីប្រឹក្សាគរុកោសល្យ ជាអ្នកអប់រំ ជាអធិការអេចិន្ត្រៃយ៍ ជាអ្នកចរចារ ជាអ្នកផ្ដល់សេវា និងទំនាក់ទំនងសហគមន៍ ជាអ្នកពិគ្រោះយោបល់ និងចូលរួមធ្វើផែនការសហគមន៍ និងជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍

ផ្នែកទី៣៖ ការផ្ដល់មតិយោបល់៖ ផ្នែកនេះ ត្រូវបានកសាងសំណួរដែលមានលក្ខណៈជាសំណួរបើកដើម្បីឱ្យអ្នកផ្ដល់ព័ត៌មានរៀបរាប់ពីទស្សនៈយល់ឃើញស្ថានភាពទូទៅនៃសាលារៀន តួនាទី និងភារកិច្ចក្នុងសាលារៀន ទស្សនៈឆ្លុះបញ្ចាំងពីតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស កិច្ចសហការ និងការចូលរួម បញ្ហាប្រឈម និងសំណូមពរ។

### ៣.៣.៣. កម្រងសំណួរសម្ភាសន៍សម្រាប់គ្រូបង្រៀន

ចំពោះកម្រងសំណួរសម្ភាសន៍នេះ អ្នកសិក្សាបានរៀបចំឡើងជាបីផ្នែក និងមានសំណួរចំនួន ២២ សំណួរដែលមានខ្លឹមសារដូចខាងក្រោម៖

ផ្នែកទី១៖ ព័ត៌មានទូទៅ៖ ផ្នែកនេះពណ៌នាអំពីកម្រិតវប្បធម៌ អង្គភាព/ស្ថាប័ន និងតួនាទី។

ផ្នែកទី២៖ តួនាទីរបស់គ្រូបង្រៀនក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស៖ ផ្នែកនេះ ត្រូវបានតាក់តែងឡើងនូវចំណុចស្ដីពី ការស្វែងយល់ពីសហគមន៍ និងការផ្ដល់ចំណេះដឹងប្រកបដោយវិជ្ជាជីវៈ ទំនាក់ទំនងជាមួយសហគមន៍ និងការប្រតិបត្តិវិជ្ជាជីវៈ ការបណ្ដុះសីលធម៌សហគមន៍ដោយប្រកាន់ភ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈ។

ផ្នែកទី៣៖ ការផ្ដល់មតិយោបល់៖ ផ្នែកនេះ ត្រូវបានកសាងសំណួរដែលមានលក្ខណៈជាសំណួរបើកដើម្បីឱ្យអ្នកផ្ដល់ព័ត៌មានរៀបរាប់ពីទស្សនៈយល់ឃើញពីស្ថានភាពទូទៅក្នុងសាលារៀន តួនាទី និងភារកិច្ចរបស់គ្រូបង្រៀនក្នុងការអភិវឌ្ឍលទ្ធផលសិក្សាសិស្ស ទស្សនៈឆ្លុះបញ្ចាំងពីតួនាទីរបស់សហ គមន៍ កិច្ចសហការ និងការចូលរួម បញ្ហាប្រឈម និងសំណូមពរ។

### ៣.៣.៤. កម្រងសំណួរសម្ភាសន៍សម្រាប់មាតាបិតា/អ្នកអាណាព្យាបាលសិស្ស

ចំពោះកម្រងសំណួរសម្ភាសន៍នេះ អ្នកសិក្សាបានរៀបចំឡើងជាបីផ្នែក និងមានសំណួរចំនួន ២១ សំណួរដែលមានខ្លឹមសារដូចខាងក្រោម៖

ផ្នែកទី១៖ ព័ត៌មានទូទៅ៖ ផ្នែកនេះពណ៌នាអំពី កម្រិតវប្បធម៌ អង្គភាព/ស្ថាប័ន និងតួនាទី។

ផ្នែកទី២៖ តួនាទីរបស់មាតាបិតា/អ្នកអាណាព្យាបាលសិស្សក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស៖ ផ្នែកនេះ ត្រូវបានតាក់តែងឡើងនូវចំណុចស្ដីពី ការបរិច្ចាគថវិកាសម្រាប់ការសិក្សារបស់សិស្ស ការពិនិត្យតាមដានការសិក្សារបស់សិស្ស និងការលើកទឹកចិត្ត។

ផ្នែកទី៣៖ ការផ្ដល់មតិយោបល់៖ ផ្នែកនេះ ត្រូវបានកសាងសំណួរដែលមានលក្ខណៈជាសំណួរបើកដើម្បីឱ្យអ្នកផ្ដល់ព័ត៌មានរៀបរាប់ពីទស្សនៈយល់ឃើញពីស្ថានភាពទូទៅក្នុងសហគមន៍ តួនាទី និងភារកិច្ចរបស់មាតាបិតា/អ្នកអាណាព្យាបាលសិស្សក្នុងការអភិវឌ្ឍលទ្ធផលសិក្សាសិស្ស ទស្សនៈឆ្លុះបញ្ចាំងពីតួនាទីរបស់សហគមន៍ កិច្ចសហការ និងការចូលរួម បញ្ហាប្រឈម និងសំណូមពរ។

### ៣.៣.៥. កម្រងសំណួរសម្ភាសន៍សម្រាប់សិស្ស

ចំពោះកម្រងសំណួរសម្ភាសន៍នេះ អ្នកសិក្សាបានរៀបចំឡើងជាបីផ្នែក និងមានសំណួរចំនួន ២១ សំណួរដែលមានខ្លឹមសារដូចខាងក្រោម៖

ផ្នែកទី១៖ ព័ត៌មានទូទៅ៖ ផ្នែកនេះផ្តោតលើ កម្រិតវប្បធម៌ អង្គភាព/ស្ថាប័ន និងតួនាទី។

ផ្នែកទី២៖ តួនាទីរបស់សិស្សក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស៖ ផ្នែកនេះ ត្រូវបានតាក់តែងឡើងនូវចំណុចស្តីពី ការចូលរួមការងារសហគមន៍ និងការគោរពវិន័យសាលា ស្មារតីទទួលខុសត្រូវចំពោះសហគមន៍ និងការសិក្សារបស់ខ្លួន ការខិតខំសិក្សារអស់ពីលទ្ធភាពរបស់ខ្លួន។

ផ្នែកទី៣៖ ការផ្តល់មតិយោបល់៖ ផ្នែកនេះ ត្រូវបានកសាងសំណួរដែលមានលក្ខណៈជាសំណួរបើកដើម្បីឱ្យអ្នកផ្តល់ព័ត៌មានរៀបរាប់ពីទស្សនៈយល់ឃើញពីស្ថានភាពទូទៅក្នុងសាលារៀន តួនាទី និងភារកិច្ចរបស់សិស្សក្នុងការអភិវឌ្ឍលទ្ធផលសិក្សាខ្លួន ទស្សនៈឆ្លុះបញ្ចាំងពីតួនាទីរបស់សហគមន៍ កិច្ចសហការ និងការចូលរួម បញ្ហាប្រឈម និងសំណូមពរ។

## ៣.៤. ដំណើរការនៃការប្រមូលព័ត៌មាន

ក្រោយពីបង្កើតកម្រងសំណួរសម្ភាសន៍រួចរាល់ដោយមានពិនិត្យ និងការពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណែនាំរួចមក អ្នកស្រាវជ្រាវបានរៀបចំនូវលិខិតឧទ្ទេសនាម និងលិខិតបទដ្ឋានគតិយុត្តិតាមលំហូរនីតិវិធីរដ្ឋបាលជាលំដាប់លំដោយពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មកតាមវិទ្យាល័យគោលដៅដើម្បីចុះទៅប្រមូលព័ត៌មាននៅតាមសាលារៀននីមួយៗដូចដែលបានកំណត់។ បន្ទាប់ពីបានបំពេញនូវលក្ខខណ្ឌនានាតាមនីតិវិធីរដ្ឋបាលរួចមក គណៈគ្រប់គ្រងក៏បានទទួលយកការស្នើសុំ និងបន្តសហការក្នុងដំណើរការសម្ភាសជាមួយនឹងគណៈនាយក គ្រូបង្រៀន សិស្សានុសិស្សចាប់ពីថ្នាក់ទី ១០ ដល់ទី ១២ ព្រមទាំងសហគមន៍ផងដែរ។ ដោយឡែក ការចុះទៅសម្ភាសន៍សហគមន៍ និងមាតាបិតា/អ្នកអាណាព្យាបាលសិស្សត្រូវធ្វើតាមក៏ស្នើជាក់ស្តែងដែលមានកូនរៀននៅតាមវិទ្យាល័យក្នុងភូមិសាស្ត្រសិក្សា។

ជាលទ្ធផល ការចុះទៅសម្ភាសន៍បានទទួលព័ត៌មានពីអ្នកផ្តល់ព័ត៌មានបានគ្រប់ចំនួនដែលបានកំណត់ខាងលើ។

### ៣.៥. ព័ត៌មានដែលទទួលបាន

ក. របាយការណ៍ស្តីពីលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៃវិទ្យាល័យទាំងបី

តារាងទី ៥៖ របាយការណ៍ស្តីពីលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

| របាយការណ៍ឆ្នាំ | វិទ្យាល័យហ៊ុន សែន មិត្តភាព | | វិទ្យាល័យក្រុងព្រះសីហនុ | | វិទ្យាល័យហ៊ុន សែនឃ្លាំងលើ | |
|---|---|---|---|---|---|---|
| | ភាគរយប្រឡងជាប់ | និទ្ទេស A | ភាគរយប្រឡងជាប់ | និទ្ទេស A | ភាគរយប្រឡងជាប់ | និទ្ទេស A |
| ២០១៤ | 30.40 | 0 | 19.70 | 0 | មិនទាន់បង្កើតវិទ្យាល័យ | |
| ២០១៥ | 50.79 | 1 | 48.47 | 1 | មិនទាន់បង្កើតវិទ្យាល័យ | |
| ២០១៦ | 81.22 | 2 | 66.88 | 2 | មិនទាន់បង្កើតវិទ្យាល័យ | |
| ២០១៧ | 84.28 | 1 | 77.81 | 7 | មិនទាន់បង្កើតវិទ្យាល័យ | |
| ២០១៨ | 88.72 | 0 | 75.56 | 2 | មិនទាន់បង្កើតវិទ្យាល័យ | |
| ២០១៩ | 87.17 | 2 | 65.03 | 5 | មានត្រឹមថ្នាក់ទី ១០ | |
| ២០២០ | 100 | 0 | 100 | 0 | មានត្រឹមថ្នាក់ទី ១១ | |
| ២០២១ | 86.98 | 3 | 75.00 | 7 | 25 | 0 |

ខ. ក្រុមគោលដៅអ្នកផ្តល់ព័ត៌មានដែលបានផ្តល់ព័ត៌មាន

តារាងទី ៦៖ ក្រុមគោលដៅអ្នកផ្តល់ព័ត៌មានដែលបានផ្តល់ព័ត៌មាន

| ក្រុមគោលដៅអ្នកផ្តល់ព័ត៌មាន | បរិមាណគ្រោងទុក | លទ្ធផលសម្រេចបាន |
|---|---|---|
| សហគមន៍ | ៣ | ៣ |
| គណៈនាយក | ៦ | ៦ |
| គ្រូបង្រៀន | ១៨ | ១៨ |
| មាតាបិតា/អ្នកអាណាព្យាបាលសិស្ស | ១៨ | ១៨ |
| សិស្សានុសិស្សថ្នាក់ទី ១០, ១១, ១២ | ១៨ | ១៨ |

## ៣.៦. ការវិភាគទិន្នន័យ និងព័ត៌មាន

លទ្ធផលដែលទទួលបានខាងលើ អ្នកស្រាវជ្រាវត្រូវយកមកបញ្ចូលក្នុងតារាង Microsoft Excel ហើយធ្វើការវិភាគទិន្នន័យរកមធ្យមភាគពិន្ទុ( Mean ) និងគម្លាតស្តង់ដា( Data Deviation ) ដើម្បីធ្វើជាជំនួយដល់ការបកស្រាយខ្លឹមសារនៃសូចនាករត្រង់ផ្នែកទី១ និងទី២នេះក្នុងទម្រង់សំណួរបិទ ហើយនៅផ្នែកទី៣ ត្រូវធ្វើការបកស្រាយតាមគុណវិស័យដែលនឹងបង្ហាញពីនីតិវិធីដូចខាងក្រោមនេះ៖

### ៣.៦.១. ការវិភាគទិន្នន័យតាមបរិមាណវិស័យ

ក្នុងការវិភាគទិន្នន័យលើការបំពេញកម្រងសំណួរបិទរបស់អ្នកផ្តល់ព័ត៌មាន អ្នកស្រាវជ្រាវរៀបចំជាកម្រិតចង្អុលបង្ហាញដោយប្រើប្រាស់ក្នុងទម្រង់សូចនាករជាតួលេខដាក់លាក់ជា ៥កម្រិត( Likert Scale ) ដែលបានប្រើក្នុងទម្រង់សំណួរស្រាប់។ លទ្ធផលជាតួលេខដែលបានគណនានៅក្នុងកម្មវិធី Microsoft Excel ត្រូវយកមកវាស់វែងសូចនាករ វាយតម្លៃលើកម្រិតនៃការបំពេញតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅវិទ្យាល័យទាំងបីក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ក្នុងកិច្ចការស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរបិទនីមួយៗមាន ៥កម្រិតចាប់ពីទាបបំផុត( E=១ ) ទៅដល់ខ្ពស់បំផុត( A=៥ ) ដែលមានកម្រិតដៅបង្ហាញដូចខាងក្រោមនេះ៖

| តួអក្សរឡាតាំង | ពិន្ទុ | អត្ថន័យ |
|---|---|---|
| E | ១ | មិនដែល |
| D | ២ | កម្រ |
| C | ៣ | ជួនកាល |
| B | ៤ | ញឹកញាប់ |
| A | ៥ | គ្រប់ពេល |

ក្នុងការដាក់កម្រិតទៅពិន្ទុដែលបានគណនាលើទិន្នន័យដែលទទួលបានដើម្បីវិភាគគឺត្រូវអនុវត្តទៅតាមរូបមន្ត( Best, 1981 )លើមធ្យមពិន្ទុដែលទទួលបានក្នុងការគណនាដោយកុំព្យូទ័រដូចតទៅនេះ៖ ពិន្ទុខ្ពស់បំផុត ដកនឹង ពិន្ទុទាបបំផុត រួចចែកនឹង ចំនួនកម្រិត គឺ៖ **៥ - ១ = ៤/៥ = 0.៨0**

**តារាងទី ៧៖ កម្រិតមធ្យមពិន្ទុ និងអត្ថន័យ**

| កម្រិតមធ្យមពិន្ទុ | អត្ថន័យ |
|---|---|
| ១.00-១.៨0 | ខ្សោយណាស់ |
| ១.៨១-២.៦0 | ខ្សោយ |
| ២.៦១-៣.៤0 | មធ្យម |
| ៣.៤១-៤.២0 | ល្អបង្គួរ |
| ៤.២១-៥.00 | ល្អ |

**&Best, 1981)**

### ៣.៦.២. ការវិភាគទិន្នន័យតាមគុណវិស័យ

ក្រោយពីបានប្រមូលព័ត៌មានតាមរយៈកម្រងសំណួរសម្ភាសន៍រួចមក អ្នកសិក្សាបានរៀបចំការវិភាគព័ត៌មាននឹងធ្វើឡើងតាម **គុណវិស័យ**(Qualitative Research) ក្រោយពីប្រមូលទិន្នន័យរួចតាមរយៈលទ្ធផលដែលបានមកពីការបំពេញកម្រងសំណួររបស់ នាយក នាយករង លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស មាតាបិតា/អ្នកអាណាព្យាបាលសិស្ស ព្រមទាំងសហគមន៍នៃវិទ្យាល័យទាំងបីក្នុងក្រុងព្រះសីហនុ ។ ដើម្បីឱ្យឆ្លើយតបទៅនឹងប្រធានបទស្រាវជ្រាវដែលស្តីពី៖ "**តួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ** " ការវិភាគព័ត៌មានតាមការពិនិត្យ និងការអង្កេត(Observation Protocol) ក្នុងអំឡុងពេលសម្ភាសន៍នោះ មកពិចារណាដោយយកចិត្តទុកដាក់ អានជាច្រើនដង ច្រើនសារដើម្បីកំណត់យកគំនិតសំខាន់ៗ (Themes) រួចយកទៅបកស្រាយជាជំហានៗដូចជា៖ ១. រៀបចំព័ត៌មានដោយកំណត់ខ្លឹមសារ (Transcript) ២. កំណត់ក្របខណ្ឌវិភាគព័ត៌មានដោយដាក់កូដសញ្ញាណដូចគ្នា (Coding and Consolidation) ៣. សំយោគក្របខណ្ឌនៃគោលគំនិតរួម(Themes) តាមរយៈការវិភាគពិពណ៌នាបកស្រាយខ្លឹមសារនៃបញ្ញត្តិ (Content Analysis) ឱ្យឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរ៖

ក/. តើសហគមន៍មានតួនាទីធ្វើអ្វីខ្លះដើម្បីអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស?

លទ្ធផលនៃការផ្តល់ព័ត៌មានចំពោះសំណួរនឹងត្រូវប្រើអក្សរតំណាង ១. តួនាទីរបស់សហគមន៍ គឺៈ CR(Community's Roles) ២. ការចូលរួមៈ P(Participation), ៣. ការទំនាក់ទំនងគឺៈ C(Communication), ៤. ការលើកទឹកចិត្តៈ M(Motivation), ៥. ការផ្សព្វផ្សាយៈ A(Advocacy), ៦. ការកៀរគរធនធានគឺៈ F(Fundraising)។ រីឯ អ្នកផ្តល់ព័ត៌មានវិញមានដូចជា៖ ១. សហគមន៍= C(Community) ២. គណៈនាយក =D(Directors) ៣. គ្រូបង្រៀន=T(Teachers) ៤. មាតាបិតា/អ្នកអាណាព្យាបាល=G(Guardians) ៥. សិស្សានុសិស្ស=S(Students)

**តារាងទី ៨៖លទ្ធផលនៃការសម្ភាសពីតួនាទីរបស់សហគមន៍**

| តួនាទីរបស់សហគមន៍(CR) | C | D | T | G | S |
|---|---|---|---|---|---|
| ការចូលរួម (P) | 1,3 (2) | 1,2,3, 4,5,6 (6) | 1,2,3,4 6,7,8,9 15,17(9) | 1,2,6,8,10, 13,15,16,18 (9) | 1,2,4,5,8,10, 11,12,13,14, 15,18(12) |
| ការទំនាកទំនង(C) | 1,2,3 (3) | 1,2,3, 4,5,6 (6) | 2,3,4,5,16, 17,18 (8) | 1,2,3,4,5,6, 7,11,13,15, 17,18(12) | 1,2,6,7,8,10, 14,15,16,17, 18(11) |
| ការលើកទឹកចិត្ត(M) | 1,2,3 (3) | 1,2,3, 4,5,6 (6) | 1,2,3,4,5,6, 7,8,9,10,11 12,13,14,15, 16 | 1,2,3,4,5,6, 7,9,11,12,1 3,14,15,16, 17,18(18) | 1,2,3,4,5,6,7 ,8,9,10,11,12 ,13,14,15,16, 17,18(18) |

| | | | | | |
|---|---|---|---|---|---|
| | | | 17,18(18) | | |
| ការផ្សព្វផ្សាយ(A) | 1,2,3 (3) | 1,2,3, 4,5,6 (6) | 4,7,8,10,13, 14,15,18 (8) | 1,4,6,8,12, 13,15,16,17 ,18 (10) | 1,5,7,10,13, 14,15,16,17, 18(10) |
| ការកៀរគរធនធាន(F) | 1,3 (2) | 1,2,3, 4,5,6 (6) | 2,3,4,6,7,9, 10,12,13,16, 17,18 (12) | 2,4,5,7,8, 10,11,12,14, 15,17,18 (12) | 1,2,5,6,7,10, 11,12,15,16 (10) |

៥/. តើសហគមន៍ និងសាលារៀនត្រូវចូលរួមដោះស្រាយយ៉ាងដូចម្ដេចខ្លះ ដើម្បីឱ្យការគ្រប់គ្រងនៅកម្រិតសាលារៀនមានប្រសិទ្ធភាព?

លទ្ធផលនៃការផ្ដល់ព័ត៌មានចំពោះសំណួរនឹងត្រូវប្រើអក្សរតំណាង ១. ការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព គឺ: SBM(School-Based Management) ២. គណនេយ្យភាព AI(Accountability), ៣. ស្វ័យភាពគឺ: AII(Autonomy), ៤. វង្វាយតម្លៃ AIII(Assessment), ៥. ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន TI(Teacher Inspiration), ៦. ការចូលរួម I(Involvement)។ រីឯ អ្នកផ្ដល់ព័ត៌មានវិញមានដូចជា៖ ១. សហគមន៍= C(Community) ២. គណៈនាយក =D(Directors) ៣. គ្រូបង្រៀន=T(Teachers) ៤. មាតាបិតា/អ្នកអាណាព្យាបាល=G(Guardians) ៥. សិស្សានុសិស្ស=S(Students)

**តារាងទី ៩៖លទ្ធផលនៃការសម្ភាសពីការគ្រប់គ្រងនៅកម្រិតសាលារៀន**

| ការគ្រប់គ្រងនៅកម្រិតសាលារៀនមានប្រសិទ្ធភាព គឺ: (SBM) | C | D | T | G | S |
|---|---|---|---|---|---|
| គណនេយ្យភាព (AI) | 1,2,3 (3) | 1,2,3, 4,5,6 (6) | 1,2,3,4,6,7,8 ,9,10,11,12, 13,14,15,16, 17(17) | 1,2,4,8,10, 13,15 (7) | 1,2,5,8 11,12,14 (7) |
| ស្វ័យភាព (AII) | 1,2,3 (3) | 1,2,3, 4,5,6 (6) | 2,3,4,5,7,8, 16,17,18 (9) | 4,5,6,7,11,1 3,15 (8) | 2,6,7,8 10,118 (7) |
| វង្វាយតម្លៃ (AIII) | 1,2 (2) | 1,2,3, 4,5,6 (6) | 1,2,3,4,5,6, | 5,7,9,11, 12,13,15 (7) | 1,2,3,4,5,6,7 ,8,9,10,11,12 |

| | | | | | |
|---|---|---|---|---|---|
| | | | 7,8,9,10,11, 12,13,14,15,16,17,18(18) | | ,13,14,15,16, 17,18(18) |
| ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន (TI) | 1,2,3 (3) | 1,2,3, 4,5,6 (6) | 1,2,3,4,5,6, 7,8,9,10,11, 12,13,14,15,16,17,18(18) | 1,4,6,8,12, 13,15,16, 17,18 (10) | 1,2,4,7,10, 13,14,16,17, 18(10) |
| ការសហការ I(Involvement) | 1,2, 3 (3) | 1,2,3, 4,5,6 (6) | 1,2,3,4,7,9, 10,12,13,16, 17,18 (12) | 1,2,4,5,7,8, 9,10,11,12,14,15,17,18 (14) | 1,2,4,5,6,7, 9,10,11,12, 15,16,18 (13) |

## ៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ

ដើម្បីរក្សាបាននូវក្រមសីលធម៌ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមែប្រមូលឯកសារយោងជាតិ និងអន្តរជាតិមានទាំងកិច្ចការស្រាវជ្រាវជាភាសាអង់គ្លេស និងជាភាសាខ្មែររបស់រៀមច្បង រួមជាមួយនឹងលិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល និងគោលនយោបាយ ឯកសារប្រតិបត្តិ និងសេចក្តីណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។ អ្នកសិក្សាស្រាវជ្រាវបានរៀបចំលិខិតស្នាមតាមនីតិវិធីរដ្ឋបាលចាប់តាំងពីការចេញលិខិតឧទ្ទេសនាមរបស់រដ្ឋមន្ត្រី សេចក្តីជូនដំណឹងរបស់មន្ទីរអប់រំ ទៅកាន់សាលាគោលដៅ លិខិតស្នើសុំគ្រូដឹកនាំគោល និងរងក្នុងមូលដ្ឋានក្នុងការបំពេញក្រុបខណ្ឌនៃការចុះប្រមូលព័ត៌មានដោយអនុវត្តតាមក្រមសីលធម៌នៃការស្រាវជ្រាវបានយ៉ាងល្អ។ ជាការឆ្លើយតបជាវិជ្ជមាន និងប្រកបដោយភាតរភាពនៃអាជីពជាគ្រូបង្រៀន និងបុគ្គលយកចិត្តទុកដាក់លើការងារអប់រំដូចគ្នា ជំនួបជាមួយនឹងក្រុមគោលដៅអ្នកផ្តល់ព័ត៌មានបានដំណើរការទៅយ៉ាងរលូន ថ្វីត្បិតដំណើរការសម្ភាសនេះ ស្ថិតក្នុងបរិបទទើបតែធូរស្រាលនៃជំងឺកូវីដ ១៩ និងស្របគ្នានឹងស្ថានការណ៍បោះឆ្នោតជ្រើសរើសឃុំសង្កាត់ក៏ដោយ ក៏តំណាងសហគមន៍ គណៈនាយក គ្រូបង្រៀន សិស្សានុសិស្ស មាតាបិតា/អ្នកអាណាព្យាបាលបានចូលរួមផ្តល់ព័ត៌មានយ៉ាងពិតប្រាកដតាមខ្លឹមសារនៃកម្រងសំណួរសម្ភាសន៍។ អ្នកសិក្សាស្រាវជ្រាវ ក៏បានសម្តែងការគោរព និងថ្លែងអំណរគុណប្រកបដោយគុណធម៌ សុជីវធម៌តាមក្រមសីលធម៌ជាអ្នកស្រាវជ្រាវដោយរក្សានូវការសម្ងាត់រាល់ព័ត៌មានរបស់ពួកគាត់មិនបញ្ចេញឈ្មោះ អត្តសញ្ញាណ ព្រមទាំងលើកទឹកចិត្តដល់ពួកគាត់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបញ្ចេញទស្សនៈ ក្នុងន័យស្ថាបនាគុណភាពអប់រំសម្រាប់យុវជនជំនាន់ក្រោយៗទៀតឱ្យកាន់តែមានភាពល្អប្រសើរឡើងជានិរន្តន៍ និងប្រកបដោយចីរភាព។

# ជំពូកទី ៤

# លទ្ធផល

# និង

# ការពិភាក្សា

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

## ៤.១. ស្ថានភាពទូទៅនៃសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ

### ៤.១.១. កម្រិតគុណវុឌ្ឍិសមាជិកសហគមន៍

សាលារៀន គឺជាមូលដ្ឋានគ្រឹះក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យក្លាយជាមូលធនក្នុងការអភិវឌ្ឍខឿនសេដ្ឋកិច្ចជាតិ។ នាយកសាលា គឺជាវីរៈបុរសដែលត្រូវកាន់ និងកាច់ចង្កូតនាវាសិក្សានេះទៅរកភាពរីកចម្រើនក្រោមប្រតិភូកម្មសិទ្ធិអំណាច និងសេចក្តីទុកចិត្តពីរាជរដ្ឋាភិបាលក៏ដូចជាពលរដ្ឋនៅក្នុងសហគមន៍នោះដែរ។ ដូចនេះ នាយកសាលាត្រូវដឹកនាំរៀបចំ ចងក្រង និងផ្សព្វផ្សាយ គោលការណ៍ និងសេចក្តីណែនាំផ្សេងៗដល់អ្នកពាក់ព័ន្ធប្រកបដោយតម្លាភាព និងគណេយ្យភាពដើម្បីធ្វើឱ្យសាលារៀនសម្រេចប្រសិទ្ធផលសិក្សា ទទួលបានជោគជ័យក្នុងការកិច្ចប្រមូលកុមារគ្រប់វ័យសិក្សាឱ្យចូលរៀន ព្រមទាំងបង្កើនគុណភាពលទ្ធផលសិក្សារបស់សិស្ស។ យោងតាមព័ត៌មានទូទៅដែលទទួលបានបានបង្ហាញថា ៖ "**នាយកទាំងបីសាលាវិទ្យាល័យនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុបានបញ្ចប់ការសិក្សាដល់កម្រិតឧត្តម បីនាក់ និងក្រោយឧត្តមបីនាក់**" ។ ទាំងនេះ បានបង្ហាញថា គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈកម្រិតមធ្យមសិក្សាទុតិយភូមិ ជាធនធានមនុស្សដ៏មានសក្តានុពលក្នុងការដឹកនាំគ្រប់គ្រង អភិវឌ្ឍន៍សាលារៀន។ ម្យ៉ាងវិញទៀត គ្រូបង្រៀននៅវិទ្យាល័យទាំងបីនេះ ក៏បានបញ្ចប់វគ្គបណ្តុះបណ្តាលគរុកោសល្យ និងសម្រួចគុណវុឌ្ឍិវិជ្ជាជីវៈរបស់ខ្លួនដល់កម្រិតឧត្តមសិក្សាចំនួន ៧នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៩នាក់ ក្នុងចំណោមអ្នកផ្តល់ព័ត៌មានទាំង ១៨ នាក់។ លើសពីនេះទៅទៀត សមាជិកគណៈកម្មការអភិវឌ្ឍន៍សាលារៀនដែលជាសហគមន៍វិញ ក៏ជាអ្នកមានចំណេះវិជ្ជាក្នុងការមើលថែទាំភូមិដ្ឋានបានល្អតាមបទពិសោធន៍ការងារជាច្រើនឆ្នាំ ជាក់ស្តែង ចៅសង្កាត់រងមួយរូបក្នុងភូមិសិក្សាខាងលើបានអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនបានកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ផងដែរ។

ដូចនេះ សហគមន៍មួយនេះ នឹងអាចបង្កឱកាសអំណោយផលដល់ការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិបានល្អប្រសើរជាបណ្តើរៗ និងសម្រេចបានប្រសិទ្ធផលតាមការគ្រោងទុកនាពេលអនាគតដ៏ខ្លីខាងមុខ។ ជាក់ស្តែងមានអ្នកអាណាព្យាបាលសិស្ស និងសិស្សានុសិស្សមួយចំនួនបានលើកឡើងថា៖

*"....សហគមន៍របស់ពួកខ្ញុំ ចេះជួយយកអាសារគ្នាណាស់ ជួយផ្តល់អំណោយ ដើរប្រកូកប្រកាសប្រាប់ឱ្យពួកខ្ញុំនាំកូនទៅរៀន និងហៅពួកខ្ញុំចូលរួមប្រជុំជីវភាព.........."*

(CR@A#C3D6T8G10S10)

### ៤.១.២. ស្ថានភាពទូទៅនៃសហគមន៍សាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ

វិទ្យាល័យមួយក្នុងចំណោមវិទ្យាល័យទាំងបីមានគណៈគ្រប់គ្រងទាំងបីជាបុរស អាយុចន្លោះពី៤៥ ឆ្នាំ ដល់ ៥៥ឆ្នាំ ប្រធានគណៈកម្មការអភិវឌ្ឍន៍សាលារៀន ជាមន្ត្រីមកពីសាលាក្រុងព្រះសីហនុមានតំណែងជាអភិបាលរងក្រុងព្រះសីហនុ។ រីឯ សមាជិក សមាជិកា សប្បុរសជននៃសហគមន៍សាលារៀនជាប្រជាពលរដ្ឋដែលមានមុខរបរជាអាជីវករ មន្ត្រីស្ថាប័នរដ្ឋ និងបុគ្គលិកឯកជន និងទីលំនៅបច្ចុប្បន្នក្នុងក្រុងព្រះសីហនុ ជាពិសេសភាគីពាក់ព័ន្ធទាំងនេះភាគច្រើនជាអតីតសិស្សនៃវិទ្យាល័យនេះតែម្តង។ នៅពេលសម្ភាស នាយកម្នាក់ក្នុងចំណោមនាយកទាំងបី បានប្រសាសន៍ថា៖ "....**ទោះបី មានគ្រូមួយចំនួនតូចមិនសូវចូលរួម ក៏សាលាយើងបានអភិវឌ្ឍទៅបានល្អជាបណ្តើរៗដោយសារមានការចូលរួម ឧបត្ថម្ភគាំទ្រពីប្រធានសហគមន៍ ថ្នាក់ដឹកនាំក្រសួង មន្ទីរ និងក្រុមការងារចុះជួយខេត្តផងដែរ.....** "។ ដោយយោងតាមលក្ខខណ្ឌទាំងនេះ ការអភិវឌ្ឍលទ្ធផលសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅសាលារៀនមានភាពល្អប្រសើរជាក់ស្តែងតាមតារាងទី៥ ស្តីពីរបាយការណ៍លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការកើនឡើងជាលំដាប់ពី **៣០.៤០%** នៅឆ្នាំ ២០១៤ និង **៨៦.៩៨%** នៅឆ្នាំ ២០២១ និងមានបេក្ខជនប្រឡងជាប់និទ្ទេស A តាំងពីគ្មានសូម្បីម្នាក់នៅឆ្នាំ ២០១៤ រហូតបាន ៣នាក់នៅឆ្នាំ ២០២១។

ចំណែកឯ វិទ្យាល័យមួយទៀត មានគណៈគ្រប់គ្រងសាលា ជានាយិកា និងនាយករង ពីរនាក់ជាបុរស ហើយមានប្រធានគណៈកម្មការអភិវឌ្ឍន៍សាលាជាស្ត្រី ក្នុងតួនាទីជាចៅសង្កាត់រង ហើយពួកគាត់មានអាយុស្របាលគ្នាចន្លោះពី៤៥ឆ្នាំ ទៅ ៥៥ឆ្នាំ។ ដៃគូអភិវឌ្ឍន៍សាលារៀន សប្បុរសជន និងប្រជាពលរដ្ឋភាគច្រើន ជាអ្នករស់នៅក្នុងក្រុងព្រះសីហនុ ហើយការរៀបចំផែនការនានារបស់សាលា នាយិកាតែងតែអំពាវនាវដល់សប្បុរសជន និងភាគីពាក់ព័ន្ធមកចូលរួមប្រជុំ ព្រមទាំងផ្សព្វផ្សាយរកការគាំទ្រពីអតីតសិស្សដែលមានធនធាន កិត្តិយស និងតួនាទីដំណែងខ្ពស់ក្នុងសង្គម។ ជាលទ្ធផល សាលាវិទ្យាល័យនេះមានការប្រែប្រួលជាវិជ្ជមានលើលទ្ធផលសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចបានបង្ហាញក្នុងតារាងទី ៥ គឺ៖ អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ **១៩.៧០%** នៅឆ្នាំ ២០១៤ និង **៧៥%** នៅឆ្នាំ ២០២១ ព្រមទាំងបានពង្រឹងគុណភាពការប្រឡងរបស់បេក្ខជនតាំងពីគ្មាននិទ្ទេស A នៅឆ្នាំ ២០១៤ រហូតបេក្ខជនប្រឡងជាប់និទ្ទេស A បាន ប្រាំពីរនាក់នៅឆ្នាំ ២០២១។ តាមរយៈការសម្ភាសផ្ទាល់ នាយិកាបានលើកឡើងថា៖ " **...សាលាយើង តែងតែទទួលបានការឧបត្ថម្ភគាំទ្រពីសប្បុរសជន មន្ត្រីពាក់ព័ន្ធក្នុងខេត្ត ជាពិសេសពួកគេជាអតីតសិស្ស មានតំណែងតួនាទីខ្ពស់ក្នុងសង្គម ទើបការអំពាវនាវនេះមានការយកចិត្តទុកដាក់ជួយពីអ្នកគ្រប់គ្នា...** "។

ចំពោះ វិទ្យាល័យទី ៣ គឺជាសាលាដែលទើបតែបង្កើតឡើងនៅឆ្នាំ ២០១៨ ហើយមាននាយកសាលាម្នាក់ និងនាយករងពីរនាក់ ដែលពួកគាត់ជាបុរសមានវ័យពី ៤៥ឆ្នាំ ដល់ ៥៥ឆ្នាំ។ រីឯ ប្រធានសហគមន៍សាលា ជាស្ត្រីមេភូមិ អាយុពី ៤៥ឆ្នាំ ដល់ ៥៥ឆ្នាំ រៀនបានថ្នាក់ទី ១០ក្នុងសម័យសង្គមរាស្ត្រនិយម ហើយប្រជាពលរដ្ឋក្នុងភូមិគឺភាគច្រើនជាអ្នកចំណូលស្រុក ប្រកបមុខរបរជាកម្មករ កម្មការីនីរោងចក្រ។ នាយកម្នាក់ក្នុងចំណោមនាយកទាំងបីបានលើកឡើងថា៖ " **....ពួកយើងបានខិតខំអំពាវនាវ ណែនាំសិស្ស និងអ្នកអាណាព្យាបាលរបស់ពួកគេពីការចូលរៀន ប៉ុន្តែសិស្សនៅតែមានអវត្តមានច្រើន...**"។ គុណភាពសិក្សានៅសាលាវិទ្យាល័យនេះ ទទួលបានសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទាបជាងវិទ្យាល័យទាំងពីរខាងលើ បើយោងតាមតារាងទី ៥៖ របាយការណ៍ស្តីពីលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ គឺសាលានេះមានភាគរយបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិតែ ២៥% ប៉ុណ្ណោះ ហើយក៏មិនមានបេក្ខជនប្រឡងជាប់បាននិទ្ទេស A ដែរ។

ដូចនេះ យោងតាមលទ្ធផល និងការពិភាក្សាខាងលើ កត្តាជីវភាព មុខរបរ និងបម្លាស់ទីលំនៅគឺជាបញ្ហាប្រឈមក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស និងការគ្រប់គ្រងតាមសាលារៀន។

## ៤.២. ការពិភាក្សាពីតួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សតាមបរិមាណវិស័យ

តារាងទី ១០៖ ការវិភាគ និងការពិភាក្សាលទ្ធផលស្តីពីតួនាទីរបស់សហគមន៍តាមបរិមាណវិស័យ

| ល.រ | បរិយាយ | សហគមន៍ | | |
|---|---|---|---|---|
| តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស | | មធ្យមពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| **១** | **ការផ្តល់ជាតុចូលដើម្បីរៀបចំផែនការរបស់សាលារៀន** | **៣.៦០** | **១.១៩** | **ល្អបង្គួរ** |
| | ចូលរួមធ្វើផែនការសាលារៀន | ៣.៦៦ | ១.១៥ | ល្អបង្គួរ |
| | ចូលរួមធ្វើគោលនយោបាយសាលារៀន | ៣.៣៣ | ១.៥២ | មធ្យម |
| | ចូលរួមគ្រោងថវិកាសាលារៀន | ៣.៦៦ | ១.១៥ | ល្អបង្គួរ |
| | ចូលរួមអនុវត្តផែនការសកម្មភាពសាលារៀន | ៣.៣៣ | ១.៥២ | មធ្យម |
| | ចូលរួមរៀបចំផែនការកសាង ថែរក្សារចនាសម្ព័ន្ធសាលា | ៤.០០ | ១.០០ | ល្អបង្គួរ |
| **២** | **ការពិនិត្យតាមដានការអនុវត្តផែនការសាលារៀន** | **៣.៥៥** | **១.២៧** | **ល្អបង្គួរ** |
| | ប្រជុំស្តីពីការអនុវត្តការងាររបស់គ្រូបង្រៀន | ៣.៣៣ | ១.៥២ | មធ្យម |
| | ចុះអង្កេតថ្នាក់រៀន | ៣.៣៣ | ១.៥២ | មធ្យម |
| | ពិនិត្យតាមដានលទ្ធផលសិក្សារបស់សិស្ស | ៣.០០ | ១.០០ | មធ្យម |
| **៣** | **ការលើកទឹកចិត្ត និងកៀរគរធនធាន** | **៣.៨៨** | **១.៣០** | **ល្អបង្គួរ** |

| | | | | |
|---|---|---|---|---|
| | ទាក់ទងអ្នកជំនាញ ឥស្សរជន សប្បុរសជនដើម្បីចូលរួមកម្មវិធីនានារបស់សាលា | ៤.៣៣ | ១.១៥ | ល្អបង្គួរ |
| | លើកកម្ពស់ការទទួលខុសត្រូវរបស់អ្នកអាណាព្យាបាលចំពោះការសិក្សារបស់សិស្ស | ៤.៣៣ | ០.៥៧ | ល្អ |
| | ទទួលរបាយការណ៍គ្រប់គ្រងពីការគ្រប់គ្រងសាលារៀន | ៣.៦៦ | ១.១៩ | ល្អបង្គួរ |

**តារាងទី ១១៖ ការវិភាគ និងការពិភាក្សាលទ្ធផលស្តីពីកិច្ចសហការរបស់ភាគីពាក់ព័ន្ធតាមបរិមាណវិស័យ**

| កិច្ចសហការរបស់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស | | | | |
|---|---|---|---|---|
| ការអនុវត្តការកិច្ចរបស់មាតាបិតា/អ្នកអាណាព្យាបាល | | មាតាបិតា/អ្នកអាណាព្យាបាល | | |
| ១ | ការបរិច្ចាគសម្រាប់ការសិក្សារបស់សិស្ស | ៤.១៦ | ០.៧០ | ល្អ |
| ២ | ការពិនិត្យតាមដានការសិក្សារបស់សិស្ស | ៣.៥៥ | ០.៨៨ | ល្អបង្គួរ |
| ៣ | ការលើកទឹកចិត្ត | ៣.៥៣ | ០.៩៣ | ល្អបង្គួរ |
| ការប្រតិបត្តិតួនាទីរបស់គណៈគ្រប់គ្រងសាលារៀន | | គណៈគ្រប់គ្រងសាលារៀន | | |
| ១ | អ្នកផ្តល់សេវាអប់រំ និងទំនាក់ទំនងសហគមន៍ | ៤.១២ | ០.៧១ | ល្អបង្គួរ |
| ២ | អ្នកពិគ្រោះយោបល់ និងចូលរួមធ្វើផែនការសហគមន៍ | ៤.២៥ | ០.៤៦ | ល្អ |
| ៣ | អ្នកអប់រំ និងជាគំរូល្អក្នុងសហគមន៍ | ៣.៩១ | ០.៩៣ | ល្អបង្គួរ |
| ៤ | ភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍ | ៤.០៤ | ០.៦៣ | ល្អបង្គួរ |
| ការបំពេញតួនាទីរបស់គ្រូបង្រៀន | | គ្រូបង្រៀន | | |
| ១ | ការស្វែងយល់ពីសហគមន៍ និងការផ្តល់ចំណេះដឹងប្រកបដោយវិជ្ជាជីវៈ | ៤.០៩ | ០.៧០ | ល្អបង្គួរ |
| ២ | ការទំនាក់ទំនងជាមួយសហគមន៍ និងការប្រតិបត្តិវិជ្ជាជីវៈ | ៤.០៣ | ០.៦៣ | ល្អបង្គួរ |
| ៣ | ការបណ្តុះសីលធម៌ដល់សហគមន៍ដោយប្រកាន់ភ្ជាប់ក្រមសីលធម៌ | ៤.៥៨ | ០.៦២ | ល្អ |
| ការប្រតិបត្តិកាតព្វកិច្ចរបស់សិស្ស | | សិស្សានុសិស្ស | | |
| ១ | ការចូលរួមការងារសហគមន៍ និងការគោរពវិន័យសាលា | ៤.៤៦ | ០.៥៨ | ល្អ |
| ២ | ស្មារតីទទួលខុសត្រូវចំពោះសហគមន៍ និងការសិក្សារបស់ខ្លួន | ៤.១៤ | ០.៧៥ | ល្អបង្គួរ |
| ៣ | កិច្ចខិតខំសិក្សាអស់ពីលទ្ធភាពរបស់ខ្លួន | ៣.៧៩ | ០.៩០ | ល្អបង្គួរ |

### ៤.២.១ ការបំពេញតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

យោងតាមតារាងទី ១០ ការផ្តល់ធាតុចូលដើម្បីរៀបចំផែនការរបស់សាលារៀន មានមធ្យមពិន្ទុ ៣.៦០ និងគម្លាតស្តង់ដា ១.១៩ មានន័យថាការចូលរួមរៀបចំផែនការអភិវឌ្ឍន៍សាលារៀន រៀបចំថវិកាមូលនិធិសាលា មានភាពល្អបង្គួរ។ ក្នុងតារាងទី ១០ នេះដែរបានឆ្លុះបញ្ចាំងពី ការពិនិត្យតាមដានការអនុវត្តផែនការសាលារៀនក្នុងមធ្យមភាគពិន្ទុ ៣.៥៥ និងគម្លាតស្តង់ដា ១.២៧ គឺមានភាពល្អបង្គួរផងដែរ។ យ៉ាងណាមិញ ចំពោះសូចនាករ ការលើកទឹកចិត្ត និងកៀរគរធនធានមធ្យមពិន្ទុដែលទទួលបានគឺ ៣.៨៨ និងគម្លាតស្តង់ដា ១.៣០ ត្រូវចង្អុលបង្ហាញត្រូវអត្ថន័យល្អបង្គួរ។ ដូចនេះ ការអនុវត្តតួនាទីរបស់សហគមន៍ពាក់ព័ន្ធនឹងការចូលរួមធ្វើផែនការនានាជាមួយសាលារៀន និងការពិនិត្យតាមដានការអនុវត្តផែនការ ក៏ដូចជាការលើកកម្ពស់ប្រសិទ្ធភាពការបង្រៀន និងរៀនរបស់អ្នកសិក្សាគឺមានភាពល្អបង្គួរដោយពឹងផ្អែកទិន្នន័យដែលទទួលបានពីការប្រមូលព័ត៌មានខាងលើ ប៉ុន្តែការនៅមានភាពខ្វះចន្លោះមួយចំនួនផងដែរ ពីព្រោះមធ្យមពិន្ទុ និងគម្លាតស្តង់ដានៅមានភាពល្មៀងនៅឡើយ ជាក់ស្តែង មធ្យមពិន្ទុខ្ពស់បំផុតគឺ ៣.៨៨ នៃសូចនាករការលើកទឹកចិត្ត និងកៀរគរធនធាន រីឯមធ្យមពិន្ទុដែលទាបបំផុតគឺ ៣.៦០ នៃសូចនាករ ការចូលរួមរៀបចំផែនការអភិវឌ្ឍន៍សាលារៀន។

### ៤.២.២ ការបំពេញតួនាទីរបស់ភាគីពាក់ព័ន្ធចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

**ក. ការអនុវត្តភារកិច្ចរបស់មាតាបិតា/អ្នកអាណាព្យាបាល៖** យោងតាមតារាងទី ១១ ដែលចង្អុលបង្ហាញសូចនាករ ការបរិច្ចាគថវិកាសម្រាប់ការសិក្សារបស់សិស្សមានមធ្យមពិន្ទុ ៤.១៦ និងគម្លាត ស្តង់ដា ០.៧០ ហើយតួលេខនេះបានបញ្ជាក់ថា មាតាបិតា/អ្នកអាណាព្យាបាលសិស្សបានរៀបចំផែនការថវិកាសម្រាប់ការសិក្សាបានល្អ។ លើសពីនេះ មធ្យមពិន្ទុនៃ ការពិនិត្យតាមដានការសិក្សាគឺ ៣.៥៥ ដែលមានគម្លាតស្តង់ដា ០.៨៨ ហើយវាបានឆ្លុះបញ្ចាំងបានថា មាតាបិតា/អ្នកអាណាព្យាបាលបានពិនិត្យតាមដានការរៀនសូត្ររបស់កូនៗ បានល្អបង្គួរ។ រីឯ ការលើកទឹកចិត្តមានមធ្យមពិន្ទុ ៣.៥៣ និងគម្លាតស្តង់ដា គឺ ០.៩៣ ដែលមានន័យ ពួកគាត់បានជួយជ្រោមជ្រែងលើកទឹកចិត្តឱ្យខំសិក្សាបានល្អបង្គួរ។ ក្នុងន័យនេះ ការប្រតិបត្តិតួនាទីរបស់អ្នកអាណាព្យាបាលមានភាពល្អបង្គួរ ដោយត្រូវរិះរកពេលវេលាបន្ថែមទៀតដើម្បីចូលរួមតាមដាន និងលើកទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រទាំងនៅផ្ទះ និងនៅសាលាគឺធ្វើយ៉ាងណាឱ្យពួកគេទទួលបានលទ្ធផលសិក្សាគួរជាទីពេញចិត្ត។

**ខ. ការប្រតិបត្តិតួនាទីរបស់គណៈគ្រប់គ្រងសាលារៀន៖** ចំពោះសូចនាករ ការទំនាក់ទំនងសហគមន៍ ក្នុងនាមជាអ្នកផ្តល់សេវាកម្មអប់រំមានមធ្យមពិន្ទុ ៤.១២ និង គម្លាតស្តង់ដា ០.៧១ ដែលបង្ហាញថាល្អបង្គួរ (យោងតាមតារាងទី ១១) ហើយមធ្យមពិន្ទុនៃសូចនាករ អ្នកពិគ្រោះយោបល់ និងចូលរួមធ្វើផែនការសហគមន៍គឺ ៤.២៥ និងមានគម្លាតស្តង់ដា ០.៤៦ តួលេខនេះបញ្ជាក់ថាគណៈគ្រប់គ្រងសាលា

រៀនបានចូលរួមកសាងផែនការនានាដើម្បីអភិវឌ្ឍសាលារៀនបានល្អ។ ទន្ទឹមនឹងនេះ យោងតាមតារាងទី ១១ នៃមធ្យមពិន្ទុដែលពណ៌នាពីសូចនាករ អ្នកអប់រំ និងធ្វើជាគំរូល្អក្នុងសហគមន៍គឺ **៣.៩១** មានគម្លាតស្តង់ដា **០.៩៣** បានបង្ហាញថាឥរិយាបថរបស់នាយកសាលាគឺល្អបង្គួរ។ លើសពីនេះ ផ្អែកតាមមធ្យមពិន្ទុក្នុងតារាងទី **១១** សូចនាករ ភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍មាន **៤.០៤** និងគម្លាតស្តង់ដាគឺ**០.៦៣** មានន័យថាគណៈគ្រប់គ្រងសាលាបានប្រតិបត្តិខ្លួនជាភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍បានល្អបង្គួរ។ ផ្អែកតាមមធ្យមពិន្ទុនៃការបកស្រាយសូចនាករទាំងនេះ នាយកសាលាបានបំពេញតួនាទីល្អបង្គួរក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ដោយគួសបញ្ជាក់ពីចំណុចគួរពង្រឹងវឌ្ឍនភាពបន្ថែមនោះគឺសូចនាករ **អ្នកអប់រំ និងធ្វើជាគំរូល្អក្នុងសហគមន៍** ព្រោះកម្រិតមធ្យមពិន្ទុទាបជាងគេ។

**គ. ការបំពេញតួនាទីរបស់គ្រូបង្រៀន៖** ផ្អែកតាមទិន្នន័យក្នុងតារាងទី ១១ សូចនាករ ការស្វែងយល់ពីសហគមន៍ និងការផ្តល់ចំណេះដឹងប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនគឺ **៤.០៩** មានគម្លាតស្តង់ដា **០.៧០** ដែលបង្ហាញថាល្អបង្គួរ។ ចំពោះសូចនាករស្តីពី ការទំនាក់ទំនងជាមួយសហគមន៍ និងការប្រតិបត្តិវិជ្ជាជីវៈមានមធ្យមពិន្ទុ **៤.០៣** និងគម្លាតស្តង់ដា **០.៦៣** ហើយវាមានន័យថាល្អបង្គួរផងដែរ។ម្យ៉ាងវិញទៀត សូចនាករ ការបណ្តុះសីលធម៌ដល់សហគមន៍ដោយប្រកាន់ភ្ជាប់ក្រមសីលធម៌មានមធ្យមពិន្ទុ **៤.៥៨** និងគម្លាតស្តង់ដា **០.៦២** វាបង្ហាញថា គ្រូបង្រៀនបានបំពេញតួនាទីបានល្អក្នុងការអប់រំសីលធម៌ល្អៗដល់សហគមន៍របស់ពួកគាត់ដោយប្រកាន់ភ្ជាប់ឥរិយាបថប្រកបដោយក្រមសីលធម៌។

**ឃ. ការប្រតិបត្តិកាតព្វកិច្ចរបស់សិស្ស៖** តាមការបកស្រាយទិន្នន័យក្នុងតារាងទី១១ ការចូលរួមការងារសហគមន៍ និងការគោរពវិន័យមានមធ្យមពិន្ទុ **៤.៤៦** និងគម្លាតស្តង់ដា **០.៥៨** ដែលមានន័យថាល្អ ហើយសូចនាករស្តីពី ស្មារតីទទួលខុសត្រូវចំពោះសហគមន៍ និងការសិក្សារបស់សិស្សទទួលបានមធ្យមពិន្ទុ **៤.១៤** និងមានគម្លាតស្តង់ដា **០.៧៥** ដែលឆ្លុះបញ្ចាំងថា ល្អបង្គួរ។ យ៉ាងណាមិញផ្អែកតាមតារាងទី ១១ នេះ សិស្សបានប្រឹងប្រែងរៀនសូត្រដោយស្មារតីទទួលខុសត្រូវ និងប្រើគ្រប់វិធីដើម្បីការសិក្សារបស់ពួកគេទទួលបានលទ្ធផលល្អ ព្រោះមធ្យមពិន្ទុដែលស្តីពី កិច្ចខិតខំសិក្សាអស់ពីលទ្ធភាពរបស់ខ្លួនមានតួលេខទាបជាងគេបំផុតក្នុងការអនុវត្តតួនាទីរបស់ខ្លួនគឺ **៣.៧៩** រួមនឹងគម្លាតស្តង់ដា **០.៩០** បើមធ្យមពិន្ទុនៃសូចនាករនេះគឺ ល្អបង្គួរ ក៏សិស្សត្រូវលះបង់ពេលវេលា និងយកចិត្តទុកដាក់រៀនសូត្របន្ថែមទៀតដើម្បីឱ្យប្រសិទ្ធផលសិក្សាបានល្អប្រសើរជាងនេះ។

## ៤.៣. ការពិភាក្សាពីតួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សតាមគុណវិស័យ

### ៤.៣.១ ការចូលរួមរបស់សហគមន៍

ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន៦៣នាក់ស្ដី ពីតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សានៅសាលាមធ្យមសិក្សាទុតិយភូមិបានលើកឡើងថា៖ សហគមន៍ពីរនាក់បានទទួលស្គាល់ថា តួនាទីរបស់ពួកគាត់គឺត្រូវចូលរួមធ្វើផែនការអភិវឌ្ឍន៍សាលា តាមដានការបំពេញការងាររបស់គ្រូបង្រៀន លើកបញ្ហាអប់រំទៅពិភាក្សាក្នុងអង្គប្រជុំ រក្សាសណ្ដាប់ធ្នាប់ជុំវិញសាលា និងគ្រប់សកម្មភាពនានាដើម្បីលើកកម្ពស់គុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្នស្របនឹងគោលនយោបាយអប់រំ ហើយខាងគណៈគ្រប់គ្រងសាលាក៏បានអះអាងថាការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធពិតជាអាចកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងលទ្ធផលសិក្សារបស់សិស្ស ស្របគ្នានឹងការយល់ឃើញរបស់គ្រូបង្រៀន និងមាតាបិតា/អ្នកអាណាព្យាបាលសិស្សមួយចំនួនក៏យល់ដូចនេះដែរ។ រីឯ សិស្សភាគច្រើនបានសង្កត់ធ្ងន់ថា៖

*"…….ពួកខ្ញុំសប្បាយចិត្ត និងមានកម្លាំងចិត្តខំរៀន នៅពេលអ្នកទាំងអស់បាននាំគ្នាយកចិត្តទុកដល់ការសិក្សារបស់ពួកខ្ញុំ អ្នកភូមិបាននាំកូនទៅរៀន លោកគ្រូអ្នកគ្រូចូលរួមពន្យល់ និងបង្រៀនបានល្អ ប៉ាម៉ាក់តែងសួរនាំពីក្រដាសព្រឹត្តិប័ត្រពិន្ទុ ព្រមទាំងការសិក្សារបស់ពួកខ្ញុំ……..”*

CR@P#C2D6T9G9S12

តាមរយៈការសម្ភាស ការចូលរួមរបស់សហគមន៍ អ្នកផ្ដល់ព័ត៌មានបានលើកឡើងពី៖ការចូលរួមកសាងផែនការអភិវឌ្ឍន៍សាលា ផ្ដល់ធាតុចូលក្នុងការកំណត់ចក្ខុវិស័យ បេសកកម្មរបស់សាលា តាមដានការសិក្សា ជួយណែនាំបង្កើតជាក្លឹបសិក្សា និងស្វ័យសិក្សា ជួយរកការងារសមរម្យ ជួយបង្ហាត់បង្រៀនបំណិនជីវិត (ការដាំដំណាំ ការចំហិនម្ហូប កិច្ចការងារផ្ទះ និងការកាត់ដេរ)សហការណ៍ជាមួយស្ថាប័នផ្សេងៗ ដើម្បីផ្ដល់ការអប់រំពីបំណិនជីវិត ផលប៉ះពាល់គ្រឿងញៀន ភាពក្រីក្រ អំពើហិង្សា ច្បាប់ចរាចរណ៍ ព្រមទាំងចូលរួមប្រជុំផ្សេងៗតាមការអញ្ជើញរបស់គណៈនាយកសាលា និងគ្រូបង្រៀន។ ប៉ុន្តែផ្ទុយទៅវិញ ការបំពេញតួនាទីជាក់ស្ដែងតែងតែប្រទើសនឹងកិច្ចការងារស្នូល ដែលនាំឱ្យពិបាកចូលរួមតាមការកោះអញ្ជើញរបស់គណៈកម្មការ និងនាយកសាលា ដោយពួកគាត់បានលើកឡើងថា៖

*"…….ការងាររវល់ខ្លាំងណាស់ ម្យ៉ាងផ្ញើរបាយការណ៍ជូនមេ ពិបាកដកឃ្លាចូលរួមស្ដាប់ការប្រជុំដោយផ្ទាល់ ពេលខ្លះ ខាងនាយកផ្ញើរបាយការណ៍ទើបដឹងថាមានការប្រជុំ……….”*

CR@P#C2D6T9G9S12

ដូចនេះ ការបំពេញភារកិច្ចរបស់សហគមន៍ទាក់ទងនឹងការផ្តល់ជាតុចូល គឺមិនទាន់ល្អប្រសើរនៅឡើយទេ ព្រោះអ្នកពាក់ព័ន្ធមួយចំនួនមានភាពមមាញឹកច្រើននឹងការងារស្នូល ពេលខ្លះក៏បានចូលរួម ហើយពេលខ្លះក៏ត្រូវអាក់ខាន។ ក្នុងន័យនេះ ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅមានកម្រិតនៅឡើយ។

### ៤.៣.២. ការទំនាក់ទំនងរបស់សហគមន៍

ក្រៅពីការផ្តល់ជាតុចូល តួនាទីរបស់សហគមន៍គឺត្រូវមានទំនាក់ទំនងគ្នាជាមួយគ្រួសារ និងសាលារៀនព្រមទាំងសប្បុរសជននានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន៦៣នាក់ស្តីពី ករណីយកិច្ចរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សានៅមធ្យមសិក្សាទុតិយភូមិបានលើកឡើងថា៖ ទំនាក់ទំនងគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីឱ្យភាគីពាក់ព័ន្ធបានស្វែងយល់ពីគ្នាបានច្បាស់ទាំងការងារផ្ទាល់ខ្លួន ទាំងផលប្រយោជន៍រួម។ សហគមន៍បានទទួលស្គាល់តួនាទីរបស់ពួកគាត់ត្រូវទាក់ទងជាមួយអ្នកទាំងអស់គ្នា ដើម្បីលើកស្ទួយគុណភាពអប់រំដោយការផ្តល់ពេលវេលាឱ្យគ្នាទៅវិញទៅមក ឆ្លៀតឱកាសជួបពិភាក្សាជាមួយសាលា គ្រូបន្ទុក និងនាយក មានសាមគ្គីភាព និងការសហការគ្នាល្អ ទាក់ទងគ្នាដោយស្វែងយល់ពីគណនេយ្យភាពនៃលទ្ធផលសិក្សារបស់សិស្ស។ តាមរយៈការសម្ភាស អ្នកផ្តល់ព័ត៌មានភាគច្រើនបានឱ្យតម្លៃលើការទំនាក់ទំនងដោយបានលើកឡើងថា៖

*"……..ពួកខ្ញុំសប្បាយចិត្តណាស់ ព្រោះរៀងរាល់ចុងខែ ឬដើមខែកូនៗបានបង្ហាញពីព្រឹត្តិប័ត្រពិន្ទុមកឱ្យមើល ។ ពួកខ្ញុំ បានទទួលការអញ្ជើញចូលរួមប្រជុំស្តាប់ការណែនាំ ពីព័ត៌មានផ្សេងៗនៅសាលា ពេលទៅដល់សាលារៀន ពិតជាមានបរិស្ថានស្អាត សួនច្បារ និងផ្លូវដើរចាក់បេតុង…………."*

CR@C#C3D6T8G12S11

ប៉ុន្តែ្តត្បិតតែ សហគមន៍បានស្គាល់ពីតួនាទីរបស់ខ្លួនក្នុងការអភិវឌ្ឍសាលារៀនតាមរយៈការទំនាក់ទំនងក៏ដោយ ការប្រាស្រ័យទាក់ទងគ្នារបស់សមាជិក និងអ្នកពាក់ព័ន្ធមានចន្លោះខ្វះខាតមួយចំនួនដែលលើកមកពិភាក្សាគ្នាក្នុងការស្វែងរកចំណុចរួមជាឯកច្ឆ័ន្ទក្នុងការរក្សាព័ត៌មាន និងកិច្ចសហការដំណើរទៅបានរលូន។ ផ្អែកតាមព័ត៌មានដែលសម្ភាសន៍បាន បង្ហាញថា៖

*"……យើងទាំងអស់គ្នា បានប្រើទូរស័ព្ទស្មាតហ្វូន និងបានមើលព័ត៌មានខ្លះតាមគ្រុបសាលារៀន ពេលខ្លះ មើលឃើញសារ ប៉ុន្តែកម្មវិធីត្រូវបានធ្វើរួចរាល់ទៅហើយ ពេលខ្លះ សុខភាពមានបញ្ហា……ហ៊ឺ! ការងារច្រើនណាស់…"*

CR@C#C3D6T8G12S11

យ៉ាងណាមិញ វត្តមានសិស្សនៅក្នុងសាលាក៏ត្រូវអាក់ខានដោយអន្លើផងដែរ ដោយសារបញ្ហាជីវភាព ព្រោះការរស់នៅក្នុងទីប្រជុំជនត្រូវចំណាយច្រើនលើការស្នាក់នៅ អាហារ ថ្លៃធ្វើដំណើរ និង ប្រាក់ឧបត្ថម្ភគាំទ្រសម្រាប់កូនរៀនសូត្រប្រចាំថ្ងៃ ប្រចាំខែ។ អ្នកអាណាព្យាបាលមួយចំនួនបានលើកឡើងថា៖ *"គាត់ត្រូវនាំកូនទៅជួយលក់ដូរចំណីនៅពេលល្ងាចរហូតដល់យប់ជ្រៅទើបត្រឡប់មកផ្ទះវិញ ពេលខ្លះត្រូវឱ្យកូនជួយមើលប្អូន និងមើលការខុសត្រូវក្នុងផ្ទះទៀតផង"* ។

សរុបសេចក្តីមក ការងារប្រាស្រ័យទាក់ទងគ្នាក្នុងសហគមន៍សាលារៀននៅមានកម្រិតនៅឡើយ ដោយសារតែកត្តាជីវភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ភាពក្រីក្រនៅតែបន្តជាបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍគុណភាពអប់រំ ព្រោះសហគមន៍នៅមានពលករខ្វះជំនាញ និងជំនាញទាបក្នុងការប្រកបរបរចិញ្ចឹមជីវិតដោយសារមាតាបិតា និងអ្នកអាណាព្យាបាលរបស់សិស្សមួយចំនួនរៀនបានត្រឹមកម្រិតបឋមភូមិ និងជាអ្នកចំណាកស្រុក។

### ៤.៣.៣. ការលើកទឹកចិត្តរបស់សហគមន៍

យោងតាមទស្សនៈដែលអ្នកផ្តល់ព័ត៌មានបានផ្តល់ឱ្យ អាចបញ្ជាក់បានថាសហគមន៍មានការយល់ដឹងពីគុណតម្លៃនៃការសិក្សា ពីមូលធនមនុស្សទើបព័ត៌មានសម្រង់ទាំងនេះមានលក្ខណៈវិជ្ជមានច្រើនតាមសូចនាករលើការលើកទឹកចិត្តរបស់អ្នកពាក់ព័ន្ធនឹងការងារអប់រំ។ ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន៦៣នាក់ស្តីពី ការលើកទឹកចិត្តនៅមធ្យមសិក្សាទុតិយភូមិចំពោះការអភិវឌ្ឍលទ្ធផលសិក្សាជាកាតព្វកិច្ចសម្រាប់យើងទាំងអស់គ្នា ដោយភ្ជាប់នឹងទស្សនៈយល់ឃើញថា៖ ការប្រតិបត្តិខ្លួនជាពលរដ្ឋល្អ កូនល្អ សិស្សល្អ និងមិត្តល្អ មានគម្រោងចំណាយសម្រាប់ការឧបត្ថម្ភគាំទ្រដល់ដំណើរការរៀនសូត្រ ផ្តល់ការសរសើរ ផ្តល់ការលើកទឹកចិត្តចំពោះវឌ្ឍនភាពនៃការសិក្សា ជួយលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន រៀបចំកម្មវិធីផ្សេងៗសម្រាប់អ្នកមានស្នាដៃ សប្បុរសជនដូចជា៖ទិវារំលឹកគុណគ្រូ កម្មវិធីអាហារសាមគ្គី ទស្សនៈកិច្ចសិក្សា កម្មវិធីចែករង្វាន់ និងលិខិតកិត្តិយសជាដើម វានឹងអាចជ្រោងគុណតម្លៃសង្គម និងវឌ្ឍនភាពគ្រប់វិស័យផងដែរ។ ជាទឡ្ហីករណ៍នៃការសម្ភាស សហគមន៍បានរំលេចព័ត៌មានដ៏មានអានុភាពសម្រាប់ការប្រតិបត្តិថា៖

*"....វាជាវប្បធម៌ចែករំលែកមួយ ដែលពួកយើងបានបរិច្ចាគធនធានខ្លះ ដល់អ្នកដែលមានស្នាដៃ សិស្សពូកែ សិស្សឆ្នើម ពលរដ្ឋល្អ កូនល្អ មិត្តល្អតាមរយៈការប្រកួតប្រជែង វេទិកាសាធារណៈ ការចែករំលែកបទពិសោធ...."*

CR@M#C3D6T18G18S10

ភាពជាវិជ្ជមានចំពោះការលើកទឹកចិត្តរបស់សហគមន៍ ឪពុកម្តាយ/អ្នកអាណាព្យាបាលសិស្ស គណៈគ្រប់គ្រងសាលា គ្រូបង្រៀន ភាគីពាក់ព័ន្ធបានបង្កឱ្យមាននូវកាលានុវត្តភាពលើការសិក្សាពេញមួយ

ជីវិតក្នុងបរិបទប្រកួតប្រជែងសមត្ថភាព ជំនាញបច្ចេកទេស និងទីផ្សារការងារ។ ជាក់ស្តែង តាមព័ត៌មានសម្ភាសន៍ភាគីពាក់ព័ន្ធក្នុងសហគមន៍សុទ្ធតែអះអាងថា៖

*"....ពួកខ្ញុំខិតខំរាល់ថ្ងៃដើម្បីផលប្រយោជន៍ខ្លួនឯងផង ប្រយោជន៍រួមផង ... បើពួកយើងពូកែមានស្នាដៃ ខ្លួនឯងក៏ទទួលបានការគាំទ្រ គោរពស្រឡាញ់ លើកទឹកចិត្តជារង្វាន់ ឯសាលារៀនយើងមានកេរ្តិ៍ឈ្មោះល្បី...."*

CR@M#C3D6T18G18S10

ក្នុងការសន្និដ្ឋានលើព័ត៌មានខាងលើនេះ សហគមន៍បានឯកភាពថាពួកគាត់ត្រូវលើកទឹកចិត្តដល់ការកសាងសមត្ថភាពបុគ្គលិកអប់រំ សប្បុរសជន និងសិស្សានុសិស្សតាមការឧបត្ថម្ភគាំទ្រធនធានដែលមានស្រាប់ទៅតាមលទ្ធភាពរបស់ខ្លួនដូចជា៖ការចែកប័ណ្ណសរសើរ ប័ណ្ណកិត្តិយសស្នាដៃ ផ្តល់អាហារូបករណ៍ក្នុង និងក្រៅតំបន់ ព្រមទាំងការបណ្តុះបណ្តាលវគ្គបង្កើនគុណវឌ្ឍីនៅនឹងកន្លែងតាមតែអាចធ្វើទៅបានផងដែរ។

### ៤.៣.៤. ការផ្សព្វផ្សាយរបស់សហគមន៍

ទាក់ទងនឹងមជ្ឈដ្ឋានជុំវិញ អង្គប្រាស្រ័យទាក់ទងគ្នាអាចនឹងត្រូវប្រព្រឹត្តទៅក្នុងមជ្ឈដ្ឋានខាងក្រៅ (ប្រយោល) និងខាងក្នុង (ដោយផ្ទាល់)។ ជាការលើកកម្ពស់ដល់គុណភាពអប់រំ ត្រូវទាមទារឱ្យមានការចូលរួម ការទំនាក់ទំនងល្អពីគ្រប់ភាគីពាក់ព័ន្ធដើម្បីធ្វើការផ្សព្វផ្សាយនូវការបើកបវេសនកាលថ្មីក្នុងប្រព័ន្ធក្រៅប្រព័ន្ធ ផ្លូវការ និងមិនផ្លូវការក្នុងចេតនាប្រមូលកុមារ សិស្សឱ្យបានចូលរួមទាំងអស់គ្នាពោលគឺការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។ ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន៦៣នាក់ស្តីពី តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សានៅមធ្យមសិក្សាទុតិយភូមិបានលើកឡើងថា៖ ការផ្សព្វផ្សាយត្រូវធ្វើឡើងយ៉ាងទៀងទាត់ និងដល់ក្រុមគោលដៅទោះនៅតំបន់ចុងកាត់មាត់យកយ៉ាងណាក្តី ព្រោះវាជាទំនួលខុសត្រូវរបស់សហគមន៍យើងក្នុងការលើកកម្ពស់ចំណេះដឹងសហគមន៍ពីគុណតម្លៃនៃការអប់រំ ផលវិបាកនៃគ្រឿងញៀន ល្បែងស៊ីសង ផ្សព្វផ្សាយពីការចូលរៀនតាមទីសាធារណៈ ផ្សព្វផ្សាយពីគុណតម្លៃរបស់សាលារៀនដល់ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ។ ប្រធានភូមិម្នាក់បានលើកឡើងពីការព្រួយបារម្ភរបស់សិស្សក្នុងភូមិគាត់ពាក់ព័ន្ធការប្រើប្រាស់គ្រឿងញៀន ល្បែងស៊ីសង និងសុវត្ថិភាពធ្វើដំណើរ ដោយនិយាយថា៖

*"......ឃើញសិស្សមួយចំនួន ទៅកន្លែងស្ងាត់ធ្វើរឿងផ្តេសផ្តាស បើកបរលឿនៗ អសីលធម៌...ខ្ញុំដឹងហើយថា គ្រូ ម៉ែឪ បាននាំគ្នាអប់រំណាស់តែមិនសូវបានផលសោះ តាមទីសាធារណៈមានខិតប័ណ្ណព័ត៌មាន........"*

ព័ត៌មាននេះ អាចឆ្លុះបញ្ចាំងបានថា ការផ្សព្វផ្សាយព័ត៌មានរបស់សហគមន៍ស្តីពីការអប់រំ ការលើកកម្ពស់ចំណេះដឹងសាធារណៈនៅមានចន្លោះប្រហោង និងអ្នកពាក់ព័ន្ធមិនរួមសហការ។ យ៉ាងណាមិញ គណៈនាយក និងគ្រូបង្រៀនបានសង្កត់លើការមិនអើពើរបស់ឪពុកម្តាយមួយចំនួនចំពោះការសិក្សារបស់កូនតែម្តង ដោយលើកការអះអាងថា៖

*".....ខាងសាលាបានអញ្ជើញសហគមន៍ និងមាតាបិតា/អ្នកអាណាព្យាបាលសិស្សមកប្រជុំផ្សព្វផ្សាយពីផែនការដែលត្រូវធ្វើ បានផ្សព្វផ្សាយពីបទបញ្ជា វិន័យសាលាយ៉ាងទៀងទាត់ ប៉ុន្តែរបៀបរៀបរយ និងសណ្តាប់ធ្នាប់នៅតែមិនឆ្លើយតបសោះ.....*

CR@A#C3D6T8G10S10

ជាលទ្ធផល ការបំពេញតួនាទីរបស់សហគមន៍ និងមន្ត្រីអប់រំ ត្រូវបានប្រតិបត្តិតាមទំនួលខុសត្រូវការងាររបស់ខ្លួន បើទោះបី ឥរិយាបថរបស់សិស្ស និងយុវជនមួយចំនួនមិនទាន់មានការកែប្រែជាវិជ្ជមាននៅឡើយក៏ដោយ ព្រោះរាល់ការផ្លាស់ប្តូរមិនអាចមើលឃើញតែមួយជ្រុងនោះទេ ហើយវាក៏អាចវាយតម្លៃក្នុងរយៈពេលដ៏ខ្លីនេះដែរ។ ក្នុងន័យនេះ សហគមន៍ត្រូវតែបន្តធ្វើការងាររបស់ខ្លួន និងបំពេញតួនាទីក្នុងគោលដៅរួមឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រោះអ្វីៗ ត្រូវការពេលវេលា។

### ៤.៣.៥. ការកៀរគរធនធានរបស់សហគមន៍

ផែនការមួយអាចសម្រេចបានជោគជ័យគឺត្រូវពឹងផ្អែកលើធាតុចូល និងដំណើរការដែលមានជាធនធានមនុស្ស ធនធានសម្ភារៈ និងពេលវេលាកំណត់សម្រាប់ការអនុវត្តសកម្មភាព នោះផែនការនោះលេចចេញជារូបរាង និងជាផ្លែផ្កា។ ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន ៦៣ នាក់ស្តីពីតួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សាបានបង្ហាញថា៖ ការចែកចាយព័ត៌មានពីការណែនាំគុណសម្បត្តិ និងចំណុចខ្វះខាតរបស់សាលាដល់អ្នកពាក់ព័ន្ធ ការធ្វើបទបង្ហាញពីភាពចាំបាច់នៃតម្រូវការកម្មវិធីអភិវឌ្ឍន៍គុណភាពសិក្សា និងហេដ្ឋារចនាសម្ព័ន្ធជាកត្តាមួយដែលអាចកៀរគរធនធានពីសប្បុរសជន ពាណិជ្ជករ ថ្នាក់ដឹកនាំគ្រឹះស្ថានសាធារណៈ និងឯកជនសម្រាប់អភិវឌ្ឍសាលារៀន។ ជាភស្តុតាង សហគមន៍ និងគណៈនាយកសាលាបានយល់ស្របនូវចំណុចនេះ ហើយផ្តល់ព័ត៌មានថា៖

*".......ការអភិវឌ្ឍសាលារៀន បានដំណើរការទៅបានដោយមានការឧបត្ថម្ភគាំទ្រពីថ្នាក់ដឹកនាំ គ្រូបង្រៀន សប្បុរសជនជាអតីតសិស្ស អ្នកមុខអ្នកការនៅតាមគ្រឹះស្ថាននានា....."*

CR@R#C2D6T12G12S10

តាមរយៈការកៀរគរធនធានរបស់សហគមន៍ នាំឱ្យមានការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់សាលាដូចជា៖ អគារសិក្សា បន្ទប់ទឹក ប្រព័ន្ធទឹកស្អាត ទីធ្លាកីឡា សួនច្បារ និងបរិស្ថានសាលា ព្រមទាំងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស តាមរយៈការបំពាក់បំប៉នសមត្ថភាពគ្រូបង្រៀន សម្ភារឧបទេស

បណ្ណាល័យ សួនអំណាន សួនកសិកម្មជាដើម។ ទាំងអស់នេះ គឺជាចលករគន្លឹះក្នុងការរុញច្រានឱ្យសាលាមានកំណើនសិស្ស កំណើនភាគរយសិស្សប្រឡងជាប់ជាបន្តបន្ទាប់ កំណើនការឧបត្ថម្ភគាំទ្រទាំងកម្លាំងពលកម្ម ធនធានហិរញ្ញវត្ថុ និងបញ្ញាស្មារតី។ ជាអំណះអំណាង ក្នុងរបាយការណ៍របស់សាលាវិទ្យាល័យហ៊ុន សែនមិត្តភាព បានបង្ហាញថាភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការកើនឡើងរហូតពី **៣០.៤០%** នៅឆ្នាំ ២០១៤ រហូតដល់ **៨៦.៩៨%** នៅឆ្នាំ ២០២១។

ឆ្លងតាមការបកស្រាយព័ត៌មានដែលទទួលបានខាងលើ តួនាទីរបស់សហគមន៍ក្នុងការអភិវឌ្ឍលទ្ធផលសិក្សានៅមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុត្រូវបានអ្នកសិក្សាសន្និដ្ឋានបានថា "**ការពង្រឹងលទ្ធផលសិក្សារបស់សិស្ស ត្រូវតែមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៃសហគមន៍សិក្សានោះ**"។ ព្រោះថានៅសាលាវិទ្យាល័យមួយទៀតមានអត្រាប្រឡងជាប់ប្រែប្រួលចុះឡើងៗ ដោយសារតែការបំពេញតួនាទីនេះនៅមានកម្រិត រីឯសាលាវិទ្យាល័យមួយមានអត្រាភាគរយសិស្សប្រឡងជាប់នៅទាបនៅឡើយ។

## ៤.៤. ការពិភាក្សាពីការគ្រប់គ្រងតាមសាលាមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្ស

### ៤.៤.១ គណនេយ្យភាព

ការងារគ្រប់គ្រងតាមសាលារៀន ត្រូវផ្ដើមចេញពីការទទួលខុសត្រូវរបស់សមាជិក សមាជិកាដែលមានតួនាទីជាក់លាក់ និងភាគីពាក់ព័ន្ធតាមបទពិពណ៌នាការងារ ព្រមទាំងផែនការសកម្មភាពនៃកម្មវិធីទាំងនោះ។ គណនេយ្យភាព ជាផ្នែកមួយនៃការប្រតិបត្តិតួនាទីរបស់គណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការអភិវឌ្ឍន៍សាលារៀនដោយមានចងភ្ជាប់នូវសេចក្ដីណែនាំ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗពាក់ព័ន្ធនឹងការសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ គឺសាលារៀននេះឯង។ ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន៦៣នាក់ ស្ដីពីការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាពនៅមធ្យមសិក្សាទុតិយភូមិចំពោះការអភិវឌ្ឍលទ្ធផលសិក្សា សហគមន៍បានរៀបរាប់ពីទំនួលខុសត្រូវក្នុងកិច្ចការសាលារៀនមានដូចជា៖ ការកសាងផែនការអភិវឌ្ឍន៍សាលា ផែនការថវិកា ការស្ដារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការប្រើប្រាស់មូលនិធិសាលារៀន និងការផ្សព្វផ្សាយព័ត៌មាន។ យោងតាមអំណះអំណាងក្នុងការសម្ភាសព័ត៌មាន អ្នកផ្ដល់ព័ត៌មាននៃសហគមន៍សិក្សាទាំងបីខាងលើបានគូសបញ្ជាក់ថា៖

*"...........រាល់ផែនការដែលបានបង្កើតឡើង ត្រូវស្វែងរកថវិកាគាំទ្រ អ្នកទទួលខុសត្រូវច្បាស់លាស់ ហើយរាល់សកម្មភាពអនុវត្ត ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ ដំណើរការចំណូលចំណាយច្បាស់លាស់......."*

SBM@AI#C3D6T16G7S7

មតិយោបល់នេះ ឆ្លុះបញ្ចាំងពីសាលារៀន និងសហគមន៍ត្រូវសហការគ្នាកសាងផែនការសាលារៀន រួមគ្នាអនុវត្តកិច្ចការងារទៅតាមតួនាទី និងទំនួលខុសត្រូវរៀងៗខ្លួន ដែលផ្តោតទៅលើសកម្មភាពចម្បងៗដូចតទៅនេះ៖

- ធ្វើផែនការ គ្រោងថវិកា រាយការណ៍ និងគ្រប់គ្រងការអនុវត្តផែនការរបស់មន្ត្រី
- ជូនព័ត៌មានពីស្ថានភាពនៃដំណើរការអនុវត្តកម្មវិធី
- បង្កើកម្មវិធីសិក្សាទៅនឹងតម្រូវការមូលដ្ឋាន
- ត្រួវពិនិត្យ និងតាមដានពីវឌ្ឍនភាពនៃគម្រោង
- កត់ត្រាធាតុចូល ថវិកា និងលទ្ធផល/ផលសម្រេចដើម្បីផ្សព្វផ្សាយជាសាធារណៈ

ជាបដិបក្ខនៃការលើកឡើងខាងលើ សហគមន៍បានរៀបរាប់ថា ការរៀបចំនូវរបាយការណ៍ត្រូវចំណាយពេលវេលាច្រើន និងត្រូវកំណត់ឱ្យត្រឹមត្រូវតាមទម្រង់របាយការណ៍ដែលបានកំណត់។ ដូចនេះ កិច្ចការនេះ តម្រូវឱ្យមានការយកចិត្តទុកខ្ពស់លើការបំពេញកាតព្វកិច្ចការងាររបស់មន្ត្រីអប់រំ ទើបអាចទទួលបានផលសម្រេចឆ្លើយតបទៅនឹងផែនការ។ ជាក់ស្តែងភាគី ខាងឪពុកម្តាយ/អ្នកអាណាព្យាបាលសិស្ស និងសិស្សានុសិស្សខ្លួនឯង នៅមិនទាន់បានបំពេញនូវចំណុចគណនេយ្យភាពនេះនៅឡើយទេ ដោយអះអាងថា៖

*"........អាជ្ញាធរ និងគ្រូបង្រៀនត្រូវតែពង្រឹងវិន័យ ជួយបង្ហាត់បង្រៀនសិស្ស ឱ្យមានសុជីវធម៌ គុណធម៌ ឱ្យប្រឡងជាប់ទាំងអស់គ្នា ពួកយើងបានតែបញ្ជូនកូនទៅរៀន និងគាំទ្រថវិកាទេ ព្រោះរវល់ការងារផ្ទះផង រកស៊ីផង....."*

SBM@AI#C3D6T16G7S7

ទស្សនៈដែលទទួលបានពីការសម្ភាសខាងលើនេះ អាចសន្និដ្ឋានបានថា សហគមន៍សិក្សាដែលមានភាពរីកចម្រើនទៅបានត្រូវតែមានការស្វែងយល់ និងឱ្យតម្លៃលើការទទួលខុសត្រូវការងារលើការអភិវឌ្ឍលទ្ធផលសិក្សានេះស្របគ្នា មិនអាចនិយាយថា វាជាការងាររបស់អ្នកនេះ មិនមែនជាការងាររបស់អ្នកនោះនោះទេ ព្រោះ " **ការងារអប់រំជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប**" ។

### ៤.៤.២. ស្វ័យភាព

កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលលើប្រព័ន្ធមជ្ឈការទៅជាវិមជ្ឈការ និងវិសហមជ្ឈការក្នុងទិសទៅបង្ខិតសេវាសាធារណៈទៅដល់ថ្នាក់មូលដ្ឋាន។ ការគ្រប់គ្រងតាមសាលារៀន(SBM) ជាយន្តការប្រេតិភូកម្មការសម្រេចចិត្តទៅថ្នាក់សាលារៀនគឺ គណៈនាយកនេះឯង ដែលត្រូវពង្រឹងការដឹកនាំគ្រប់គ្រង និងអភិវឌ្ឍន៍សាលាឱ្យមានប្រសិទ្ធភាពដែលសិទ្ធិក្នុងការសម្រេចចិត្តទាំងនេះមានដូចជា៖ ការរៀបចំផែនការមួយផែនការថវិកាមួយ របាយការណ៍មួយ គណៈកម្មការគ្រប់គ្រងសាលាសម្រេចចិត្តលើផែនការ និងថវិកា

សម្រាប់អនុវត្តកម្មវិធី ការបែងចែកមន្ត្រីមានប្រសិទ្ធភាព អនុវត្តការងាររបស់មន្ត្រីគាំទ្រដល់សិស្សដែលរៀនយឺតជាដើម។ ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន៦៣នាក់ស្តីពីការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព នៅមធ្យមសិក្សាទុតិយភូមិចំពោះការអភិវឌ្ឍលទ្ធផលសិក្សាបានលើកឡើងថា៖

*"........យើងបានចែកលិខិតអញ្ជើញសមាជិកគណកម្មការអភិវឌ្ឍន៍សាលារៀន អ្នកពាក់ព័ន្ធ និងសប្បុរសជនជាអតីតសិស្ស មកចូលរួមវេទិកាសំណេះសំណាល បង្ហាញពីផែនការអភិវឌ្ឍន៍សាលា បទពិសោធន៍ និងចំណេះដឹងទូទៅ......"*

SBM@AII#C3D6T9G8S7

លំនាំនៃដំណើរការ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍកម្មវិធីផ្សេងៗជំនួយដល់ការលើកកម្ពស់ការសិក្សារៀនសូត្រ គោលនយោបាយអប់រំនៅកម្រិតសាលារៀន ព្រមទាំងការផ្តល់សេវាអប់រំត្រូវបានធ្វើការសម្រេចចិត្តនៅត្រឹមថ្នាក់ក្រោមជាតិគឺគណៈគ្រប់គ្រងសាលារៀន និងត្រឹមថ្នាក់ដឹកនាំការិយាល័យ មន្ទីរតាមរាជធានី ខេត្តប៉ុណ្ណោះ។ ជាក់ស្តែង គណៈនាយកបួនរូបនៃវិទ្យាល័យទាំងបីខាងលើបានគូសបញ្ជាក់ថា៖

*"............សាលាយើងបានកសាងបណ្ណាល័យ បន្ទប់ទឹក សម្ភារបរិក្ខាររៀនសូត្រ និងការឧបត្ថម្ភគាំទ្រដល់គ្រូជួបទុក្ខលំបាក សិស្សក្រីក្រពីសប្បុរសជន និងវគ្គបំប៉នសិស្សថ្នាក់ទី ១២ ពីគណៈកម្មការចុះជួយការងារខេត្ត ផែនការទាំងនេះ យើងបានសម្រេចចិត្តដោយមានការឯកភាពពីគណៈកម្មការសាលា........"*

SBM@AII#C3D6T9G8S7

ដូចនេះ ក្នុងការប្រតិបត្តិផែនការមូលនិធិកែលម្អសាលារៀន បំប៉នសមត្ថភាពគ្រូបង្រៀននៅនឹងកន្លែង ធ្វើឱ្យប្រសើរនូវការសិក្សា និងជួយសិស្សរៀនយឺត គណៈនាយកបានធ្វើការសម្រេចចិត្តក្នុងក្របខណ្ឌប្រជុំសម្រេចចិត្តជាមួយសហគមន៍ មាតាបិតា គ្រូបង្រៀន និងតំណាងសិស្សដើម្បីបំពេញតម្រូវការរបស់សិស្ស ព្រមទាំងទទួលបានប្រសិទ្ធផល និងគុណផលសិក្សាជាទីគាប់ចិត្ត។

### ៤.៤.៣. វាយតម្លៃ

ការវាយតម្លៃគឺជាយន្តការក្នុងការត្រួតពិនិត្យដំណើរការបង្រៀន និងរៀនរបស់អ្នករៀនសូត្រ និងមន្ត្រីអប់រំតាមរយៈការប្រឡងប្រណាំង ការធ្វើតេស្តជាប្រចាំ និងតាមកាលកំណត់។ ក្នុងទិន្នន័យអប់រំ ការវាយតម្លៃត្រូវបានយកមកវាស់វែងការបំពេញការងារកិច្ចការគម្រោង វត្តមាន ផលិតផលគ្រូសិស្ស និងព្រឹត្តិប័ត្រពិន្ទុ អត្រាឡើងថ្នាក់ អត្រាបោះបង់ការសិក្សា និងត្រួតថ្នាក់ផងដែរ។ យ៉ាងណាមិញ ផ្អែកតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកចូលរួមចំនួន៦៣នាក់ ស្តីពីការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព នៅមធ្យមសិក្សាទុតិយភូមិចំពោះការអភិវឌ្ឍលទ្ធផលសិក្សាបានលើកឡើងថា៖ ការអនុវត្តរបស់សាលា

រៀន ការអនុវត្តរបស់សិស្ស និងសមត្ថភាពរបស់គ្រូបង្រៀន ការរៀបចំ និងផលិតសៀវភៅលំហាត់ និងឧបករណ៍បង្រៀន ពិន្ទុតេស្តប្រើសម្រាប់ផ្តល់រង្វាន់ដល់គ្រូបង្រៀន និងសិស្សគឺជាវង្វាយតម្លៃការងារអប់រំមួយដ៏មានប្រសិទ្ធភាព។ នេះ ជាសំដីដែលអ្នកផ្តល់ព័ត៌មានមួយចំនួនបានប្រាប់ដោយទឹកមុខសប្បាយរីករាយ និងពេញចិត្តចំពោះចំណាត់ការនេះគឺ៖

*"........ការធ្វើតេស្ត ពួកខ្ញុំបានទៅមើល និងចូលរួមជួយរៀបចំបន្ទប់ប្រឡង ជួយបិទឈ្មោះ ជួយបូកស្រង់ ដោយប្រើកុំព្យូទ័រ ពួកខ្ញុំសប្បាយចិត្តណាស់ ដែលបានធ្វើការងារទាំងនេះ ........"*

SBM@AIII#C2D6T18G7S18

វង្វាយតម្លៃដែលបានធ្វើដូចព័ត៌មានដែលគណៈនាយក គ្រូបង្រៀន សិស្សានុសិស្ស និងសហគមន៍បានផ្តល់មក វាពិតជាបានផ្តល់នូវប្រសិទ្ធភាព និងប្រសិទ្ធផលសិក្សាជាប្រព័ន្ធ ព្រោះកិច្ចការងារទាំងនេះអាចមានការចូលរួមពិនិត្យតាមដានការអនុវត្ត និងតម្លាភាពសាលារៀនដោយបង្កើតបរិយាកាសការងារជាក្រុម និងបំណិនជីវិតមូលដ្ឋានដល់សិស្សផងដែរ។ ផ្ទុយទៅវិញ វង្វាយតម្លៃដែលមិនមានភាពយុត្តិធម៌ និងតម្លាភាព នឹងនាំឱ្យសហគមន៍ និងសិស្សានុសិស្សបាត់បង់ទំនុកចិត្ត ព្រមទាំងបាក់ទឹកចិត្តក្នុងការខិតខំប្រឹងប្រែងរៀនសូត្រដោយសារតែមានការរើសអើងអ្នកមាន និងអ្នកក្រ អ្នករៀនគួរ និងអ្នកមិនរៀនគួរជាដើម។ សហគមន៍ និងសិស្សានុសិស្សមួយចំនួនបានបញ្ចេញយោបល់ថា៖

*"......សូមគ្រូ បង្រៀនសិស្សឱ្យអស់ពីសមត្ថភាពទាំងក្នុងម៉ោងរដ្ឋ និងម៉ោងក្រៅ កុំឱ្យមានការរើសអើង លំហាត់ប្រឡងមានស្តង់ដាពីរ ដាក់ពិន្ទុលំអៀង សួរតែសិស្សមិនរៀនគួរ ព្រមទាំងប្រើពាក្យអសុរោះជាដើម......"*

SBM@AIII#C2D6T18G7S18

ការវាយតម្លៃសាលារៀន និងលទ្ធផលសិក្សារបស់សិស្ស ត្រូវតែធ្វើឡើងដោយគោរពតាមក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ និងមានការទទួលស្គាល់របាយការណ៍សិក្សាព្រមទាំងត្រូវផ្សព្វផ្សាយជាសាធារណៈដល់គណៈកម្មការគ្រប់គ្រងសាលារៀនផងដែរ។

### ៤.៤.៤. ការយកចិត្តទុកដាក់ដល់គ្រូ

បេសកកម្មសាលារៀនគឺត្រូវផ្តល់ការអប់រំមានគុណភាពខ្ពស់ដល់សិស្សគ្រប់រូប។ តើនរណាជាអ្នកធ្វើឱ្យការសិក្សានេះមានប្រសិទ្ធផល និងគុណផល? ជាការពិតណាស់ គឺគ្រូបង្រៀន និងសិស្សានុសិស្សគឺជាតួអង្គចម្បងក្នុងការបន្តេរ និងទទួលចំណេះដឹង បំណិន និងឥរិយាបថជាវិជ្ជមានតាមរយៈដំណើរការបង្រៀន និងរៀន។ ដូចនេះ លទ្ធផលសិក្សាមានប្រសិទ្ធភាព អ្នកផ្តល់ព័ត៌មានទាំង ៦៣ នាក់បានលើកឡើងថា៖ ត្រូវរៀបយន្តការលើកទឹកចិត្តគណៈនាយក គ្រូបង្រៀន និងសិស្ស ផ្តល់រង្វាន់ដល់គ្រូបង្រៀន

ដោយបំប៉នវិជ្ជាជីវៈនៅនឹងកន្លែង ឬវគ្គវិក្រឹត្យ ការពង្រឹងសមត្ថភាពជាដើម។ យ៉ាងណាមិញ អ្នកពាក់ព័ន្ធក្នុងសហគមន៍ភាគច្រើនបានបញ្ជាក់ថា៖

*"....ពីមុន សាលាយើងមានត្រឹមគ្រូកម្រិតមូលដ្ឋាន តែក្រោយមកមានការរៀនវគ្គពន្លឿនបំពេញក្របខណ្ឌជាគ្រូវិទ្យាល័យ ហើយអ្នកខ្លះក៏បានបន្តអភិវឌ្ឍជំនាញអាជីពដល់ថ្នាក់អនុបណ្ឌិតទៀត ផងដោយមានការជួយសម្របសម្រួល និងលើកទឹកចិត្តពីគណៈនាយក គ្រូបង្រៀន ជាពិសេសថ្នាក់ដឹកនាំក្រសួងយើង...."*

SBM@TI#C3D6T18G10S10

ជារួម ការយកចិត្តទុកដាក់ដល់គ្រូបង្រៀនត្រូវរៀបចំឡើងជាយុទ្ធសាស្ត្រឱ្យស្របតាមការគ្រប់គ្រងថ្នាក់រៀន និងគុណភាពទិន្នន័យតេស្តសិស្សព្រោះថា បើគ្រូពូកែ សិស្សក៏ពូកែដែរ។ ក្រៅពីនេះ គ្រូបង្រៀនក៏ត្រូវបានរដ្ឋ និងដៃគូអភិវឌ្ឍន៍អន្តរជាតិជួយឧបត្ថម្ភគាំទ្រជាមូលនិធិ ជាកញ្ចប់អាហារូបករណ៍ក្នុង និងក្រៅប្រទេស ប៉ុន្តែការអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀននេះ ក៏នៅមានជាបញ្ហានៅត្រង់បុគ្គលផ្ទាល់មិនទទួលយកឱកាសដោយមានមតិមួយចំនួនតូចលើកឡើងថា៖

*".....ពួកខ្ញុំចង់ទៅបន្តការសិក្សាដែរ ប៉ុន្តែដោយសារកត្តាជីវភាព និងសុខភាព ធ្វើឱ្យបាត់បង់ឱកាសសិក្សាទាំងនេះ ហើយពេលបញ្ចប់ការសិក្សាក៏នៅតែជាគ្រូដដែលហ្នឹង!......."*

SBM@TI#C3D6T18G10S10

ការបណ្ដុះបណ្ដាលធនធានមនុស្សក្នុងវិស័យអប់រំ ត្រូវតែដោយមានចូលរួមប្រកបដោយឆន្ទៈសតិសម្បជញ្ញៈ និងការទទួលខុសត្រូវខ្ពស់ពីបុគ្គលផ្ទាល់ទើបការលើកទឹកចិត្តមានប្រសិទ្ធភាព ព្រោះបើបុគ្គលម្នាក់មិនមានការផ្លាស់ប្ដូរផ្នត់គំនិតអវិជ្ជមានទេ ការលើកទឹកចិត្តក៏មិនមានអានុភាពដែរ។ ដូចនេះ ការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍសមត្ថភាពការងាររបស់បុគ្គលិកអប់រំឱ្យមានគុណភាព មានភាពស័ក្តិសិទ្ធិ និងជំនឿចិត្តពីមជ្ឈដ្ឋានជុំវិញ នៅមានបញ្ហាប្រឈមមួយចំនួនដែលកើតឡើងដោយកត្តាបុគ្គលផ្ទាល់ពាក់នឹងជីវភាពខ្វះខាត និងបញ្ហាសុខភាពមិនល្អ។

### ៤.៤.៥. ការសហការ

ការសហការសំដៅលើ ការចូលរួមក្នុងសកម្មភាពនានាក្នុងដំណើរការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សពីសហគមន៍ជាតិ និងគ្រប់ភាគីពាក់ព័ន្ធ។ យោងតាមព័ត៌មានដែលទទួលបានពីការសម្ភាសអ្នកផ្ដល់ព័ត៌មានចំនួន៦៣នាក់ស្ដីពី ការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាពនៅមធ្យមសិក្សាទុតិយភូមិចំពោះការអភិវឌ្ឍលទ្ធផលសិក្សាបានលើកឡើងថា៖ ការសហការត្រូវធ្វើគ្រប់ដំណាក់កាល ទាំងការផ្ដល់ធាតុចូល ដំណើរការអនុវត្ត និងការទទួលបានផលសម្រេចដូចជា៖ ការកសាង និងការអនុវត្តផែនការសាលារៀន ការប្រមូល និងការជំរុញកុមារឱ្យចូលរៀន ការតាមដានសកម្មភាពសិក្សា ការកៀរគរស្វែងរក

ថវិកា ការគ្រប់គ្រងចំណូលចំណាយដោយមានគណនេយ្យភាព និងតម្លាភាព ការលះបង់ពេលវេលាក្នុងការជួសជុល ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការទប់ស្កាត់បាតុភាពមិនប្រក្រតី។ សហគមន៍ត្រូវតាមដានប្រតិទិនសិក្សារបស់សិស្សជាពិសេសមាតាបិតា/អ្នកអាណាព្យាបាល ព្រោះ នៅពេលសិស្សចេញពីផ្ទះមិនប្រាកដថាពួកគេសំដៅមកសាលា ឬចូលសិក្សានោះដែរ។ តាមការសម្ភាស ភាគីពាក់ព័ន្ធមួយចំនួនធំបានបញ្ជាក់ថា៖

*"......ដើម្បីការរៀនសូត្រមានប្រសិទ្ធភាព ឪពុកម្ដាយត្រូវសហការជាមួយសាលា និងតាមដានសកម្មភាពរបស់កូនផង គួរឆ្លៀតពេលមើលសៀវភៅរបស់កូន អង្កេតអាកប្បកិរិយា......"*

SBM@I#C3D6T12G14S13

តាមទឡ្ហីករណ៍នេះ ការគ្រប់គ្រងនៅកម្រិតសាលាត្រូវបង្កើនការទំនាក់ទំនងជាមួយសហគមន៍ និងមាតាបិតា/អ្នកអាណាព្យាបាលសិស្សដើម្បីផ្លាស់ប្តូរព័ត៌មានគ្នាជាប្រចាំ ដើម្បីសហការពង្រឹងការសិក្សារៀនសូត្ររបស់សិស្ស។ ខាងឪពុកម្ដាយ និងអ្នកអាណាព្យាបាលសិស្សត្រូវឆ្លៀតឱកាសមកជួបជាមួយសាលាដើម្បីស្នើសុំលេខទូរសព្ទទាក់ទងគ្នា ជាពិសេសនៅពេលដាក់ពាក្យចូលរៀន។ ដោយមានទំនាក់ទំនងគ្នាតាមលេខទូរសព្ទ ការរាយការណ៍ពីវត្តមាន ពីសកម្មភាពមិនប្រក្រតីរបស់សិស្សដល់អ្នកអាណាព្យាបាលបានទាន់ពេលវេលា ហើយវាក៏ងាយស្រួលក្នុងការអញ្ជើញពួកគាត់ចូលរួមប្រជុំ និងជំនួបសំណេះសំណាលផងដែរ។ ម្យ៉ាងវិញទៀត អ្នកផ្ដល់ព័ត៌មានមួយចំនួនបានសម្ដែងការមិនពេញចិត្តពីសុវត្ថិភាព សម្លេងរំខាន និងសណ្ដាប់ធ្នាប់ជុំវិញសាលាព្រោះវាបង្កឱ្យមានផលប៉ះពាល់ដល់ការសិក្សារបស់សិស្សដោយលើកឡើងថា៖

*".........ពួកខ្ញុំចង់ឱ្យអ្នកពាក់ព័ន្ធទាំងអស់ ផ្ដល់ការយកចិត្តទុកដាក់លើផលប្រយោជន៍សិស្សជាធំ ដោយសហការគ្នាលើកកម្ពស់បរិស្ថានសិក្សាទាំងក្នុងសាលា និងជុំវិញបរិវេណសាលា......."*

SBM@I#C3D6T12G14S13

តាមរយៈមតិលើកឡើងខាងលើនេះ សហគមន៍ត្រូវផ្ដួចផ្ដើមគំនិតថ្មីៗ ដើម្បីទាក់ទងជាមួយសាលា និងសាធារណជនជុំវិញសាលាឱ្យសហការគ្នាទប់ស្កាត់ល្បែងពាលា គ្រឿងញៀន និងភាពមិនប្រក្រតីផ្សេងៗ និងជួយរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយ និងសុវត្ថិភាពរបស់សិស្ស។ អាស្រ័យហេតុនេះ ដើម្បីឱ្យការគ្រប់គ្រងនៅកម្រិតសាលារៀនមានប្រសិទ្ធិភាព សហគមន៍ មាតាបិតា/អ្នកអាណាព្យាបាល ភាគីពាក់ព័ន្ធទាំងអស់ត្រូវចូលរួមសហការគ្នាដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងបណ្ដុះបណ្ដាលនូវធនធានមនុស្សដ៏មានសក្ដានុពលសម្រាប់សេដ្ឋកិច្ចគ្រួសារ និងភាពរីកចម្រើននៃប្រទេសជាតិទាំងមូលផងដែរ ។

ឆ្លងតាមការពិភាក្សាខាងលើ ការគ្រប់គ្រងសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានភាពល្អប្រសើរច្រើន ប៉ុន្តែនៅមានបញ្ហារាំងស្ទះមួយចំនួនដែលចាំបាច់ត្រូវដោះស្រាយ ដើម្បីបង្កើនការប្រតិបត្តិការងារគ្រប់គ្រងរបស់សាលា តាមរយៈពង្រឹងគណនេយ្យភាព ស្វ័យភាព វង្វាយតម្លៃ ការយកចិត្តទុកដាក់លើគ្រូបង្រៀន និងការចូលរួមពីអ្នកពាក់ព័ន្ធ។

តាមព័ត៌មានដែលទទួលបាន អាចឆ្លុះបញ្ចាំងពីបញ្ហាប្រឈមរបស់អ្នកពាក់ព័ន្ធ ក្នុងការអភិវឌ្ឍលទ្ធផលសិក្សាសិស្សវិទ្យាល័យនៅក្រុងព្រះសីហនុមានដូចខាងក្រោមនេះ៖

**ចំណុចគួរកែលម្អ**

- មិនសូវបានទាក់ទងជាមួយគ្រូបង្រៀន និងនាយក
- បញ្ហាជីវភាពខ្វះខាត
- មមាញឹកនឹងការងារស្មូល
- គ្មានជំនាញក្នុងការអប់រំ និងបង្រៀនកូននៅផ្ទះ
- ទស្សនៈថាការងាររៀនសូត្រជាកាតព្វកិច្ចរបស់គ្រូបង្រៀន ការសិក្សានៅសាលាគឺគ្រប់គ្រាន់ហើយ
- ឱ្យកូនជួយការងារផ្ទះ និងរកលុយបន្ថែម
- ខ្វះពេលវេលាបង្រៀនកូន ខ្វះទំនាក់ទំនងគ្នា
- មិនបានតាមដានកូនឱ្យបានដិតដល់

## ៤.៥. អនុសាសន៍ស្តីពីតួនាទីសហគមន៍ និងការគ្រប់គ្រងតាមសាលាក្នុងការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាឱ្យមានប្រសិទ្ធភាព

ការគ្រប់គ្រងនៅកម្រិតសាលារៀន (School-Based Management) មានប្រសិទ្ធភាពទៅបានលុះត្រាតែមានការចូលរួមពីសហគមន៍ គណៈកម្មការគ្រប់គ្រងសាលា គណៈកម្មការទ្រទ្រង់សាលា និងក្រុមប្រឹក្សាភិបាលសាលានៅកម្រិតមូលដ្ឋាន។ ការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងនេះ ត្រូវតែបំពេញតួនាទីរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវខ្ពស់ដើម្បីអភិវឌ្ឍន៍សាលារៀន ក៏ដូចជាលទ្ធផលសិក្សារបស់សិស្សប្រកបដោយតម្លាភាព គណនេយ្យភាព ស្វ័យភាព និងអភិបាលកិច្ចល្អ។ ដូចនេះ ដើម្បីឱ្យការគ្រប់គ្រងនៅកម្រិតសាលារៀន និងការបំពេញតួនាទីរបស់សហគមន៍បានល្អ ភាគីពាក់ព័ន្ធត្រូវអនុវត្តតាមអនុសាសន៍ដូចខាងក្រោម៖

### ៤.៥.១. ដំណើការនៃការបង្កើតយន្តការគ្រប់គ្រង និងភាពជាដៃគូក្នុងសហគមន៍

- ជ្រើសរើសគណៈកម្មការសាលារៀនឱ្យបានហ្មត់ចត់ និងតាមនីតិវិធី
- កៀរគរ ទំនាក់ទំនងស្វែងរកសប្បុរសជនដែលមានសក្តានុពលក្នុងសហគមន៍

- ពង្រឹងការប្រាស្រ័យទាក់ទង កសាងភាពជាដៃគូអភិវឌ្ឍន៍ជាមួយសហគមន៍ជាតិ និងអន្តរជាតិ (អង្គការក្នុង និងក្រៅរដ្ឋាភិបាល ADB, UNICEF, JICA, ...)

### ៤.៥.២. គណនេយ្យភាពចំពោះតួនាទីរបស់អ្នកពាក់ព័ន្ធ

- សមាជិក សមាជិកាក្នុងរចនាសម្ព័ន្ធគណកម្មការគ្រប់គ្រងសាលាត្រូវមានទំនួលខុសត្រូវលើភារកិច្ចរបស់ខ្លួន
- ធ្វើស្វ័យវាយតម្លៃលើការងាររបស់ខ្លួនជាប្រចាំដើម្បីកែប្រែ និងអភិវឌ្ឍ
- រៀបចំរបាយការណ៍ច្បាស់លាស់ និងបិទផ្សាយជាសាធារណៈ
- ចូលរួមប្រជុំ សំណេះសំណាល និងលើកកម្ពស់ឱកាសស្វែងយល់ពីគ្នាដោយភាតរភាព និងភាពស្មោះត្រង់

### ៤.៥.៣. ស្វ័យភាព និងការលើកទឹកចិត្តក្នុងដំណើរការបង្រៀន និងរៀនដែលមានភាពច្នៃប្រឌិត

- រៀបចំគណកម្មការសម្រេចលើការលើកទឹកចិត្តអ្នកសកម្មនឹងការងារ សិស្សពូកែដូចជា៖ ការផ្តល់ប្រាក់លើកទឹកចិត្ត រង្វាន់ លិខិតសរសើរ ឱកាសបន្តការសិក្សា វគ្គបំប៉នសមត្ថភាពតួយ៉ាងគឺការផ្តល់ប្រាក់លើកទឹកចិត្តគ្រូបង្រៀនដើម្បីលើកកម្ពស់ការបំពេញភារកិច្ច ហើយឈានទៅលុបបំបាត់ការបង្រៀនសិស្សលក្ខណៈឯកជន ឬក្រៅម៉ោងបន្ថែម
- ធ្វើការវាយតម្លៃ និងប្រាក់លើកទឹកចិត្តគ្រូល្អ គ្រូឆ្នើម និងសិស្សផងដែរ
- ជំរុញ និងលើកទឹកចិត្តអ្នកដែលមានរំបកគំហើញថ្មី ចេះច្នៃប្រឌិតក្នុងការបង្រៀន និងរៀនដោយប្រើបច្ចេកវិទ្យាស្របតាមបរិបទការអប់រំតាមប្រព័ន្ធឌីជីថល

### ៤.៥.៤. ការលើកកម្ពស់បំណិនអាជីពរបស់សិស្ស

- បង្ហាត់បង្រៀនសិស្សឱ្យចូលរួមក្នុងសកម្មភាពសាលារៀនផ្សេងៗដូចជា៖ ដើរតួជាគណៈមេប្រយោគ អប្បមាត គណៈកម្មការបូកស្រង់ពិន្ទុជាអាទិ៍
- លើកកម្ពស់សិស្សឱ្យអនុវត្តតួនាទីក្នុងការគ្រប់គ្រងសម្ភារៈ សេវាកម្មអាហារ ភេសជ្ជៈ សួនកសិកម្ម
- រៀបចំផ្តល់ទីកន្លែងឱ្យសិស្សធ្វើផែនការសកម្មភាពដោយប្រើមូលនិធិសាលា ឬប្រាក់សន្សំរបស់សិស្ស
- ពង្រឹងការផ្តល់សេវាប្រឹក្សាអាជីព និងយោបល់ផ្សេងៗ ទាំងការសិក្សា និងបញ្ហាប្រឈមខាងក្រៅរបស់សិស្ស

### ៤.៥.៥. ធ្វើការតស៊ូមតិនឹងការគិតបែបអវិជ្ជមានរបស់សហគមន៍

- ផ្សព្វផ្សាយពីតម្រូវការចាំបាច់របស់សាលាដល់សហគមន៍  និងពន្យល់បកស្រាយប្រកបដោយគណនេយ្យភាពខ្ពស់
- រៀបចំទស្សនកិច្ចសិក្សា និងអញ្ជើញចូលរួមកម្មវិធីផ្សេងៗរបស់សាលា
- ទស្សនកិច្ចលើសមិទ្ធិផលដែលសាលាបានសម្រេចបាន
- បិទផ្សាយរបាយការណ៍ស្តីពីចំណូល ចំណាយ ព្រមទាំងលទ្ធផលសិក្សារបស់សិស្សជាសាធារណៈ
- ប្តូរទស្សនៈភ័ន្តច្រឡំ ឱ្យមកគិតថា "ការអប់រំគឺជាភារកិច្ចរបស់យើងទាំងអស់គ្នា"

### ៤.៥.៦. បង្កើត និងលើកកម្ពស់ឱកាសសិក្សាប្រកបដោយសមធម៌ និងបរិយាបន្ន

- បង្កើតមូលនិធិសមធម៌សង្គមជួយដល់សិស្សក្រីក្រ
- ជំរុញឱ្យមានការចូលរួមពីសហគមន៍ក្រីក្រ និងគ្រួសារងាយរងគ្រោះ
- ផ្តល់ការលើកទឹកចិត្តដល់គ្រួសារក្រីក្រដើម្បីផ្តល់ឱកាសកូនបានមករៀនទៀងពេល
- លុបបំបាត់ចោលឱ្យបានដាច់ខាតការយកកម្រៃក្រៅផ្លូវការពាក់ព័ន្ធនឹងគុណភាពសិក្សា
- ផ្តល់ការអប់រំបន្ថែមដល់សិស្សក្រីក្រ សិស្សរៀនយឺត
- រៀបចំយុទ្ធសាស្រ្តមូលនិធិសិក្សា

# ជំពូកទី ៥

# សេចក្ដី

# សន្និដ្ឋាន

# និង

# សំណូមពរ

# ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្ដីសន្និដ្ឋាន

តួនាទីរបស់សហគមន៍ ពិតជាបានលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងក្រុងព្រះសីហនុ នៅខេត្តព្រះសីហនុ ហើយក៏បានពង្រឹងការប្រតិបត្តិការគ្រប់គ្រងនៅកម្រិតសាលាឱ្យមានប្រសិទ្ធភាព និងនិរន្តរភាពផងដែរ ព្រោះតាមការស្រាវជ្រាវខាងលើ ឆ្លុះបញ្ចាំងថា **លទ្ធផលសិក្សារបស់សិស្សត្រូវពឹងផ្អែកលើតួអង្គសំខាន់មានដូចជា៖ នាយកល្អ គ្រូបង្រៀនល្អ សិស្សានុសិស្សល្អ មាតាបិតា និងសហគមន៍ល្អ។** ក្នុងការសិក្សាស្រាវជ្រាវនេះ ក៏បានបង្ហាញពីលទ្ធផលសិក្សារបស់សិស្សមានគុណភាពប្រកបដោយភាពស័ក្ដិសិទ្ធិល្អប្រសើរ នៅពេលដែលប្រធាន និងសមាជិកក្នុងគណៈកម្មការអភិវឌ្ឍន៍សាលា គណៈកម្មការទ្រទ្រង់សាលា ក៏ដូចជាក្រុមការងារផ្សេងៗរបស់សាលា មានអតីតសិស្សចូលរួម ហើយសមាជិកទាំងនោះជាបុគ្គលដែលមានកិត្តិយសល្អ ឋានៈ អំណាចព្រមទាំងជាអ្នកមានធនធានក្នុងសង្គម។ ការបំពេញតួនាទីរបស់ភាគីពាក់ព័ន្ធចំពោះការអភិវឌ្ឍគុណភាពអប់រំ នៅកម្រិតវិទ្យាល័យត្រូវតែអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនតួយ៉ាងគឺ៖១. សហគមន៍មានតួនាទីជាអ្នកផ្តល់ជាតុចូលនូវការកសាងផែនការអភិវឌ្ឍន៍សាលា ជាគណៈកម្មការថ្នាក់រៀន ជួយលើកទឹកចិត្ត និងកៀរគរធនធាន ២. គណៈនាយក ត្រូវបំពេញតួនាទីរៀបចំផែនការអភិវឌ្ឍន៍សាលារៀន គ្រប់គ្រងបុគ្គលិក ពិនិត្យតាមដាន និងវាយតម្លៃ ផ្តល់សេវាអប់រំ ធ្វើការទំនាក់ទំនងសហគមន៍ដោយផ្តល់ការពិគ្រោះយោបល់ដើម្បីចូលរួមធ្វើផែនការអភិវឌ្ឍន៍សហគមន៍ផងដែរ ៣. គ្រូបង្រៀន(មុខវិជ្ជា បន្ទុកថ្នាក់) មានតួនាទីស្វែងយល់ពីសហគមន៍ ផ្តល់ចំណេះដឹងប្រកបដោយវិជ្ជាជីវៈ ទាក់ទងជាមួយមាតាបិតា/អ្នកអាណាព្យាបាលសិស្សតាមការប្រតិបត្តិវិជ្ជាជីវៈខ្លួនឱ្យល្អ ព្រមទាំងបណ្តុះសីលធម៌ដល់សហគមន៍ដោយប្រកាន់ភ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈ ៤. មាតាបិតា/អ្នកអាណាព្យាបាលមានតួនាទីក្នុងការបរិច្ចាគថវិកាសម្រាប់សិក្សារបស់សិស្ស ត្រួតពិនិត្យ និងតាមដានលទ្ធផលសិក្សាជាប្រចាំ ជម្រុញលើកទឹកចិត្តកូន និង៥.សិស្សត្រូវមានតួនាទីចូលរួមការងារសហគមន៍ និងគោរពវិន័យសាលា ទទួលខុសត្រូវចំពោះសហគមន៍ និងការសិក្សារបស់ខ្លួន ហើយក៏ត្រូវខិតខំសិក្សាឱ្យអស់ពីលទ្ធភាពផងដែរ។ ហេតុនេះហើយ ការចូលរួមរបស់សហគមន៍ និងគ្រួសារពិតជាមានសក្តានុពលក្រៃលែងក្នុងការពង្រឹងការសិក្សាឱ្យទទួលបានលទ្ធផលល្អប្រសើរ ហើយសហគមន៍ក៏បានទទួលស្គាល់ពីតួនាទីរបស់ពួកគាត់ ក្នុងការចូលរួមដំណើរការគ្រប់គ្រងសាលារៀនឱ្យមានប្រសិទ្ធភាពដោយពង្រឹងនូវគោលការណ៍ទាំងប្រាំដូចជា៖ ១. គណនេយ្យភាព ២. ស្វ័យភាព ៣. វង្វាយតម្លៃ ៤. ការយកចិត្តទុកដាក់ដល់គ្រូ ៥. ការសហការ។ អាស្រ័យហេតុនេះ យោងតាមការសិក្សាស្រាវជ្រាវនេះ ការបំពេញតួនាទីរបស់សហគមន៍របស់វិទ្យាល័យពីរបានល្អប្រសើរ និងសូមបន្តឧត្តមានុវត្តន៍ការងារទាំងនេះដែលអាចឱ្យសាលារៀនដទៃទៀតប្រតិបត្តិតាមដើម្បីអភិវឌ្ឍគុណភាពសិក្សា និង ការគ្រប់គ្រងតាមសាលា

រៀនមានប្រសិទ្ធភាពស្របតាម សៀវភៅណែនាំស្តីពីការគ្រប់គ្រងសាលារៀនចង់សម្រេចបាននូវគោលការណ៍បីគឺ៖ ១. ការពង្រឹងសមត្ថភាពប្រព័ន្ធអប់រំដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន ទី ២. ការពង្រឹងប្រសិទ្ធភាពគ្រូបង្រៀនតាមរយៈការអនុវត្តការគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន និងទី ៣. ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងស្វ័យភាព និងគណនេយ្យភាពសាលារៀនទៀងផង។

សរុបជារួម កិច្ចការស្រាវជ្រាវនេះ បានបង្ហាញថា សហគមន៍បានបំពេញតួនាទីរបស់ខ្លួនបានល្អប្រសើរច្រើនក្នុងការជួយជម្រុញសិស្សឱ្យទទួលបានលទ្ធផលសិក្សាល្អ ដោយរួមផ្សំនឹងការងារគ្រប់គ្រងនៅកម្រិតសាលារៀនមានប្រសិទ្ធភាពជាងមុនផងដែរ។ ក្រៅពីលទ្ធផលសិក្សាស្រាវជ្រាវបានបង្ហាញពីទំនួលខុសត្រូវរបស់សហគមន៍មានភាពល្អប្រសើរក៏ដោយ ប៉ុន្តែបញ្ហាប្រឈមមួយចំនួនក៏ត្រូវតែរួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលាមានដូចជា៖ ការទំនាក់ទំនងរវាងសាលារៀន និងសហគមន៍នៅមានកម្រិត ភាពមិនច្បាស់លាស់ពីតួនាទីរបស់ខ្លួន កម្រិតជីវភាពនៅមានបញ្ហា ការផ្លាស់ទីលំនៅញឹកញាប់នាំឱ្យប៉ះពាល់ដល់ការចាប់យកឱកាសសិក្សា ភាពមមាញឹកនឹងអាជីពបុគ្គលមិនសូវមានពេលវេលាចូលរួមជាមួយសាលាជាដើម។

## ៥.២. សំណូមពរ

ផ្អែកតាមទទ្បីករណ៍បង្ហាញ ក្នុងកិច្ចការសិក្សាស្រាវជ្រាវ និស្សិតប្រតិបត្តិក្នុងការសរសេរនិក្ខេបបទនេះ សូមលើកឡើងនូវគំនិតយោបល់មួយចំនួន សម្រាប់ស្ថាប័នពាក់ព័ន្ធនឹងខ្លឹមសារនេះ ក្នុងគោលបំណងលើកកម្ពស់នូវការបំពេញតួនាទីរបស់សហគមន៍ គណៈនាយក គ្រូបង្រៀន មាតាបិតា/អ្នកអាណាព្យាបាលសិស្ស និងសិស្សានុសិស្ស ព្រមទាំងការគ្រប់គ្រងនៅកម្រិតសាលារៀនដែលជាកត្តាជម្រុញឱ្យការសិក្សាមានការរីកចម្រើនប្រកបដោយគុណភាព និងចីរភាព។ សំណូមពរទាំងនេះ សូមលើកឡើងដូចតទៅនេះ៖

### ៥.២.១. សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

- ផ្តល់ថវិកាដល់មន្ទីរអប់រំ និងការិយាល័យអប់រំសម្រាប់ចុះជួយ និងបំពេញតម្រូវការពេលខ្វះជាតុចូលដល់សាលារៀន
- ជួយស្វែងរកជំនួយក្នុងការបណ្តុះបណ្តាលគ្រូ និងបំប៉នសមត្ថភាពអាជីពក្នុងការងារអប់រំ
- លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឱ្យបានសញ្ញាប័ត្រយ៉ាងទាបត្រឹមកម្រិតបរិញ្ញាបត្រអប់រំលើឯកទេសរបស់ខ្លួន

### ៥.២.២. សម្រាប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

- ធ្វើការផ្សព្វផ្សាយពីតម្រូវការគ្រូឱ្យត្រូវតាមនិយាម និងឯកទេសដើម្បីបំពេញតម្រូវការនៅមូលដ្ឋានជាក់ស្តែង

- លើកកម្ពស់ការយល់ដឹងពីគោលនយោបាយអប់រំដល់អ្នកពាក់ព័ន្ធ ជាពិសេសគឺការងារគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការអភិវឌ្ឍន៍សាលារៀន
- ចុះទៅបណ្តុះបណ្តាលសហគមន៍ពីតួនាទីភារកិច្ចក្នុងការចូលរួមអភិវឌ្ឍសាលារៀន និងការសិក្សារបស់សិស្ស
- បង្កើតយន្តការលុបបំបាត់ការបង្រៀនក្រៅម៉ោង និងជំនួសដោយវគ្គបំប៉នសិស្សអាហារូបករណ៍តាមមូលនិធិសាលា

### ៥.២.៣. សម្រាប់គណៈគ្រប់គ្រងសាលា

- ជួយផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកក្រោមបង្គាប់មានឱកាសអភិវឌ្ឍន៍គុណវុឌ្ឍិរបស់ខ្លួន
- បង្កើនការងារទំនាក់ទំនង និងពង្រឹងការគ្រប់គ្រងនៅកម្រិតសាលារៀនឱ្យកាន់តែប្រសើរ
- រៀបចំយន្តការលើកទឹកចិត្តសិស្សឆ្នើម គ្រូឆ្នើម សប្បុរសជន វាគ្មិនកិត្តិយសក្នុងកម្មវិធីសាលា
- បិទប្រកាសជាសាធារណៈពីចំណូល ចំណាយថវិកាសាលារៀនប្រកបដោយតម្លាភាព និងគណនេយ្យភាព
- មានផ្នត់គំនិតជាអ្នកគ្រប់គ្រងដឹកនាំប្រកបដោយគុណធម៌ និងព្រហ្មវិហារធម៌
- បង្កើតកំណត់ត្រាលេខទំនាក់ទំនង ឬក្រុមសារអេឡិចត្រូនិច(Telegram&Messenger) ជាមួយសហគមន៍ មាតាបិតាសិស្ស សប្បុរសជន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសិស្សផងដែរ

### ៥.២.៤. សម្រាប់សហគមន៍ និងមាតាបិតាសិស្ស

- គាំទ្រ និងជួយដល់ការរកមូលនិធិសាលារៀន
- ចូលរួមប្រជុំ និងអនុម័តការកសាងផែនការសាលារៀន
- ជួយកៀរគរធនធានសម្រាប់អ្នកមានស្នាដៃ និងសិស្សពូកែ
- ជួយដោះស្រាយបញ្ហារបស់មាតាបិតា និងសិស្សដោយពិនិត្យតាមដានសាលារៀន និងថ្នាក់រៀន
- ជួយសម្របសម្រួល វាយតម្លៃ និងពិនិត្យតាមដានការអនុវត្តផែនការសាលារៀន
- ថែរក្សាសណ្តាប់ធ្នាប់ទីសាធារណៈ និងក្រៅបរិវេណសាលា

### ៥.២.៥. សម្រាប់គ្រូបង្រៀន

- គួរបន្តគោរពតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដោយមិនមានការរើសអើង មើលបំណាំគ្នា និងផ្លាស់ប្តូរផ្នត់គំនិតបែបអវិជ្ជមាន
- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ ត្រូវហ៊ានលះបង់ដើម្បីចាប់យកឱកាសក្នុងការលើកកម្ពស់គុណវុឌ្ឍិរបស់ខ្លួនស្របតាមគន្លងអាជីពគ្រូបង្រៀន

- មានភាពច្នៃប្រឌិតក្នុងដំណើរការងារបង្រៀន និងរៀនដោយប្រើវិធីសាស្ត្រចម្រុះស្របតាមកាលានុវត្តភាពនៃយុគសម័យឌីជីថល

### ៥.២.៦. សម្រាប់សិស្សានុសិស្ស

- ត្រូវគោរពតួនាទីរបស់ខ្លួនជាសិស្សល្អក្នុងសាលា
- ត្រូវខិតខំរៀនសូត្រឱ្យអស់ពីលទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់
- ពង្រឹងស្វ័យសិក្សា បង្កើតក្រុមសិក្សា រៀនតាមបែបសហការ និងស្ថាបនានិយម

### ៥.២.៧. សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ក្នុងបរិបទកំណែទម្រង់វិស័យអប់រំនាពេលបច្ចុប្បន្ន "**តួនាទីរបស់សហគមន៍ចំពោះការអភិវឌ្ឍលទ្ធផលសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ**" ជាប្រធានបទ ដែលថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាមានការចាប់អារម្មណ៍ខ្លាំង ហើយបានបង្កើតលិខិតបទដ្ឋានគតិយុត្តិនានាក្នុងការអនុវត្តគោលការណ៍គ្រប់គ្រងតាមបែបវិសហមជ្ឈការក្នុងវិស័យអប់រំ។ ដូចនេះ ការគ្រប់គ្រងអប់រំនៅកម្រិតសាលាជាយន្តការក្នុងការប្រតិបត្តិតួនាទីរបស់អ្នកពាក់ព័ន្ធ ប៉ុន្តែកិច្ចការស្រាវជ្រាវនេះ មិនអាចគ្របបានធំទូលាយក្នុងប្រទេសកម្ពុជាយើងទេ គឺការប្រមូលព័ត៌មានត្រូវស្រាវជ្រាវត្រឹមកម្រិតតំបន់តូចប៉ុណ្ណោះគឺវិទ្យាល័យបីក្នុងចំណោមវិទ្យាល័យទាំងប្រាំបីក្នុងខេត្តព្រះសីហនុ។ ឆ្លើយតបទៅនឹងភាពចាំបាច់នៃប្រធានបទនេះ អ្នកសិក្សាជំនាន់ក្រោយៗ អាចលើកយកប្រធានបទនេះទៅសិក្សាស្រាវជ្រាវបន្តដើម្បីឱ្យព័ត៌មានដែលទទួលបានកាន់តែច្បាស់លាស់ដោយពង្រីកវិសាលភាព និងចំនួនអ្នកផ្តល់ព័ត៌មានឱ្យបានច្រើនជាងនេះ ព្រមទាំងសំណូមពរឱ្យអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយស្វែងរកយុទ្ធសាស្ត្រល្អៗ សម្រាប់ពង្រឹងកិច្ចសហការរវាងសាលារៀន និងសហគមន៍ឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរជាងនេះទៀត។

# ៦. ឯកសារយោង

១. ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា(២០០៨), រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២០០៨។ រាជធានីភ្នំពេញ, កម្ពុជា។
២. ព្រះរាជាណាចក្រកម្ពុជា(២០០៧), ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ច្បាប់ស្តីពីការអប់រំ, ឆ្នាំ ២០០៧។ រាជធានីភ្នំពេញ, កម្ពុជា។
៣. ពុទ្ធសាសនបណ្ឌិត្យ(២០០៤), វចនានុក្រមខ្មែរភាគទី១, សម្តេចសង្ឃរាជ, ១៩៦៧, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី ៥។ រាជធានីភ្នំពេញ, កម្ពុជា។
៤. រាជរដ្ឋាភិបាលកម្ពុជា(២០០៨) លេខ១២៦អនក្រ.បក អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ខែកញ្ញា ឆ្នាំ ២០០៨។ រាជធានីភ្នំពេញ, កម្ពុជា។
៥. ក្រសួងអប់រំ យុវជន និងកីឡា(២០១៨)សៀវភៅណែនាំស្តីពីមគ្គុទ្ទេសន៍អាជីព និងការផ្តល់ប្រឹក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិ, នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។ រាជធានីភ្នំពេញ, កម្ពុជា។
៦. ក្រសួងអប់រំ យុវជន និងកីឡា (២០១០) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។ រាជធានីភ្នំពេញ, កម្ពុជា។
៧. រាជរដ្ឋាភិបាល(២០០៦) គោលនយោបាយជាតិ ស្តីពីការអប់រំពេញមួយជីវិត។ រាជធានីភ្នំពេញ, កម្ពុជា។
៨. រាជរដ្ឋាភិបាល, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(២០១៧), បានទទួលឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៧, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥។ រាជធានីភ្នំពេញ, កម្ពុជា។
៩. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ ២០៣០, គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ៤។ រាជធានីភ្នំពេញ, កម្ពុជា។
១០. ក្រសួងអប់រំ យុវជន និងកីឡា (២០២២)ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំ ២០២១-២០២២។ រាជធានីភ្នំពេញ, កម្ពុជា។
១១. ក្រសួងអប់រំ យុវជន និងកីឡា (២០០៣)គោលនយោបាយ ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០០៣-២០១៥។ រាជធានីភ្នំពេញ, កម្ពុជា។
១២. ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ បានទទួលការឯកភាពពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៦។ រាជធានីភ្នំពេញ, កម្ពុជា។
១៣. ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី។ រាជធានីភ្នំពេញ, កម្ពុជា។
១៤. ក្រសួងអប់រំ យុវជន និង កីឡា(២០០៦)គោលនយោបាយស្តីពីអប់រំបំណិនជីវិត។ រាជធានីភ្នំពេញ, កម្ពុជា។

១៥. ក្រសួងអប់រំ យុវជន និងកីឡា (២០១៤)គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា ២០៣០។ រាជធានីភ្នំពេញ, កម្ពុជា។
១៦. ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) គោលនយោបាយស្តីពី ការអប់រំបច្ចេកទេស បានទទួលការឯកភាពពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៣។ រាជធានីភ្នំពេញ, កម្ពុជា។
១៧. ក្រសួងអប់រំ យុវជន និងកីឡា(២០០៤) គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩, នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ។ រាជធានីភ្នំពេញ, កម្ពុជា។
១៨. ក្រសួងអប់រំ យុវជន និងកីឡា(២០២១)សេចក្តីណែនាំស្តីពី យុទ្ធសាស្ត្រសហគមន៍សាលារៀន។ រាជធានីភ្នំពេញ, កម្ពុជា។
១៩. ក្រសួងអប់រំ យុវជន និងកីឡា(២០១៨)សៀវភៅណែនាំប្រតិបត្តិស្តីពី ការគ្រប់គ្រងតាមសាលារៀន, គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា។ រាជធានីភ្នំពេញ, កម្ពុជា។
